# ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១

## សម្តេចក្រឡាហោម ៖ ការប្តេជ្ញាចិត្តរបស់កម្ពុជា ជាមួយរដ្ឋសមាជិកអាស៊ានទាំងអស់ ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ទម្រង់

https://cen.com.kh/ Posted ByPen Srey NeatSeptember 30, 2021

រាជធានីភ្នំពេញ ៖ ក្នុងនាមរដ្ឋមន្ត្រីទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនអាស៊ាន សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការចូលរួមចំណែកជាមួយរដ្ឋសមាជិកអាស៊ានទាំងអស់ ក្នុងភាពជាដៃគូដ៏ស្អិតរមួត ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ទម្រង់ ដោយប្រើប្រាស់គ្រប់លទ្ធភាព និងមធ្យោបាយ តាមរយៈការអនុវត្តយន្តការថ្នាក់ជាតិ យន្តការទ្វេភាគី ពហុភាគី និងថ្នាក់តំបន់ ដើម្បីកសាងបាននូវកម្លាំងរួមមួយដ៏មានសក្តានុពល ក្នុងការដោះស្រាយបញ្ហាប្រឈម និងការគំរាមកំហែងនានាពីឧក្រិដ្ឋកម្មឆ្លងដែន ។

ក្រសួងមហាផ្ទៃ ចេញសេចក្តីប្រកាសព័ត៌មាន ស្តីពីលទ្ធផលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៥ (15th AMMTC) ។ កាលពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំមន្ត្រីជាន់ខ្ពស់ ចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៥ ហៅកាត់ថា (AMMTC 15th) ប្រារព្ធឡើងតាមប្រព័ន្ធវីដេអូ។ កិច្ចប្រជុំនេះត្រូវដឹកនាំដោយប្រទេសប្រ៊ុយណេ ក្នុងឋានៈជាប្រធានកិច្ចប្រជុំនៅក្នុងឆ្នាំ២០២១ ចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្នុងនាមជារដ្ឋមន្ត្រី ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន បានអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ចូលរួមកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០២១ និងបានផ្លាស់ប្តូរយោបល់ជាមួយបណ្តារដ្ឋសមាជិកអាស៊ាន ដោយក្នុងនោះ បានកោតសរសើរចំពោះស្មារតីជួយគ្នាទៅវិញទៅមករវាងរដ្ឋសមាជិកអាស៊ាន ក្នុងគ្រាដ៏លំបាកបង្កឡើងដោយជំងឺកូវីដ-១៩ ដែលស្មារតីនេះដើរស្របទៅនឹងមូលបទរបស់អាស៊ានឆ្នាំ២០២១«យើងយកចិត្តទុកដាក់ យើងត្រៀមលក្ខណៈ យើងរីកចម្រើន» ។ សម្តេចក្រឡាហោម ស ខេង ក៏បានថ្លែងអំណរគុណ និងអបអរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសព្រុយណេ ដែលបានជំរុញយន្តការនានារបស់ AMMTC ជាពិសេសកិច្ចពិគ្រោះយោបល់ជាមួយប្រទេសដៃគូសន្ទនាឲ្យមានដំណើរការយ៉ាងរស់រវើក និងទទួលបានលទ្ធផលជាផ្លែផ្កា រួមចំណែកយ៉ាងសំខាន់ដល់ការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ក្នុងគោលដៅកសាងតំបន់អាស៊ាន ប្រកបដោយសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ ។ សម្តេចក្រឡាហោម ស ខេង ក៏បានចូលរួមផ្លាស់ប្តូរទស្សនៈ និងគាំទ្រចំពោះការវាយតម្លៃរបស់បណ្តារដ្ឋសមាជិកអាស៊ានអំពីស្ថានភាពនៃឧក្រិដ្ឋកម្មឆ្លងដែននៅក្នុងតំបន់ ជាពិសេសការសម្តែងនូវការព្រួយបារម្ភចំពោះការឆ្លៀតឱកាសកេងប្រយោជន៍ពីទំនើបកម្មនៃបច្ចេកវិទ្យា យកមកប្រើប្រាស់ជាមធ្យោបាយក្នុងការប្រព្រឹត្តអំពើខុសច្បាប់ ដែលនាំដល់ការកើនឡើងនូវបទល្មើសមួយចំនួននៃឧក្រិដ្ឋកម្មឆ្លងដែន ដូចជា អំពើហិង្សាជ្រុលនិយម អំពើភេរវកម្ម អំពើរត់ពន្ធមនុស្ស អំពើជួញដូរមនុស្ស បទល្មើសបច្ចេកវិទ្យា ការជួញដូរគ្រឿងញៀន និងការជួញដូរសត្វព្រៃ និងឈើខុសច្បាប់ជាដើម ។

ក្រៅពីការផ្លាស់ប្តូរទស្សនៈទៅវិញទៅមក លើសភាពការណ៍ឧក្រិដ្ឋកម្មឆ្លងដែន កិច្ចប្រជុំពេញអង្គថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ក៏បានអនុម័តឯកសារចំនួន០៣ រួមមាន ៖ ១.ឯកសារទស្សនទាន ស្តីពីផែនទីបង្ហាញផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការគ្រប់គ្រងព្រំដែនអាស៊ាន, ២.សេចក្តីប្រកាសអាស៊ាន ស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដំណាក់កាលក្រោយជំងឺកូវីដ-១៩, ៣.សេចក្តីថ្លែងការណ៍រួមរបស់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី

ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១៥។ បន្ទាប់មក នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ សម្តេចក្រឡាហោម ស ខេង ក៏បានអញ្ជើញជាតំណាងឲ្យកម្ពុជា ចូលរួមក្នុងពិធីប្រគល់-ទទួល តួនាទីជាប្រធានប្តូរវេនរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦ នៅឆ្នាំ២០២២ បន្តពីប្រទេសព្រុយណេ។ ក្នុងឱកាសទទួលតួនាទីដ៏ឧត្តុង្គឧត្តមនេះ សម្តេចក្រឡាហោម ស ខេង ក៏បានថ្លែងនូវការអបអរសាទរចំពោះប្រទេសព្រុយណេ ដែលបានបំពេញតួនាទីជាប្រធានកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែនលើកទី២១ (21st SOMTC) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៥ (15th MMTC) ប្រកបដោយជោគជ័យក្នុងឆ្នាំ២០២១នេះ។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃ និងក្នុងនាមជាប្រធានប្តូរវេននៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦ សម្តេចក្រឡាហោម ស ខេង បានសម្តែងនូវសេចក្តីសោមនស្សរីករាយចំពោះតួនាទីដ៏មានសារៈសំខាន់នេះ ដែលមិនត្រឹមតែជាមោទកភាពសម្រាប់ព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការឆ្លុះបញ្ចាំងឲ្យឃើញនូវការចូលរួមចំណែក និងការទទួលខុសត្រូវចំពោះអនាគតរបស់សហគមន៍ ក្នុងនាមកម្ពុជាជារដ្ឋសមាជិកអាស៊ាន។

សម្តេចក្រឡាហោម ស ខេង ក៏បានសង្កត់ធ្ងន់ អំពីភាពចាំបាច់ដែលអាស៊ានត្រូវបន្តពង្រឹងស្មារតី សាមគ្គីភាពរឹងមាំ និងការជួយគ្នាទៅវិញទៅមក ដើម្បីប្រយុទ្ធប្រឆាំង ទាំងបញ្ហាជំងឺកូវីដ-១៩ និងរួមគ្នាដោះស្រាយបញ្ហាជាច្រើនទៀត ក្នុងក្របខណ្ឌនៃឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសបទល្មើសមិនប្រពៃណី ដែលកំពុងមានការកើនឡើងឥតឈប់ឈរ និងបង្កការគំរាមកំហែងដល់សន្តិសុខផ្ទៃក្នុងប្រទេស និងតំបន់ ។ ក្នុងស្មារតីនេះ សម្តេចក្រឡាហោម ស ខេង បានបង្ហាញនូវការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការបន្តខិតខំពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ឲ្យកាន់តែសកម្ម និងស៊ីជម្រៅថែមទៀតជាមួយបណ្តារដ្ឋសមាជិកអាស៊ានលើការងារពង្រឹងការអនុវត្តច្បាប់ និងបានសម្តែងនូវក្តីសង្ឃឹមយ៉ាងមុតមាំចំពោះការបន្តគាំទ្រ និងការជួយជ្រោមជ្រែង ពីសំណាក់រដ្ឋមន្ត្រីទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន នៃរដ្ឋសមាជិកអាស៊ានទាំងអស់ និងលេខាធិការដ្ឋានអាស៊ាន ដើម្បីផ្តល់លទ្ធភាពដល់កម្ពុជាបំពេញតួនាទី ជាប្រធានកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី២២ (22nd SOMTC) និងកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៦ (16th AMMTC) នៅឆ្នាំ២០២២ ប្រកបដោយប្រសិទ្ធភាព និងសម្រេចបានសមិទ្ធផលថ្មីៗ បន្ថែមទៀតនៅក្រោម«សសរស្តម្ភសន្តិសុខនយោបាយ»ដើម្បីបម្រើដល់ឧត្តមប្រយោជន៍រួម និងបុព្វហេតុនៃសន្តិភាព វិបុលភាពសម្រាប់តំបន់អាស៊ាន ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ពលករខ្មែរ លួចឆ្លងដែនចូលទៅប្រទេសវៀតណាម ក្រោយបានចូល តែត្រូវសមត្ថកិច្ចឃាត់ខ្លួន ស្ថានអគ្គកុងស៊ុលកម្ពុជាជួយ

https://cen.com.kh/ Posted ByPen Srey NeatSeptember 30, 2021

ភ្នំពេញ ៖ ពលរដ្ឋខ្មែរ ១៨នាក់ ដែលឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើ និងប្រកបរបរចិញ្ចឹមជីវិត នៅទីក្រុងហូជីមិញនាពេលកន្លងមក ហើយត្រូវបានសមត្ថកិច្ចវៀតណាមឃាត់ខ្លួននោះ ពេលនេះត្រូវបានសម្របសម្រួលឲ្យវិលត្រឡប់មកកាន់ស្រុកកំណើតវិញ។ ការសម្របសម្រួលដល់ពលរដ្ឋខ្មែរ ១៨នាក់ ឆ្លងដែនខុសច្បាប់នេះ ធ្វើឡើងដោយស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងហូជីមិញ ប្រទេសវៀតណាមនាព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ជាមួយសមត្ថកិច្ចក្រុងហូជីមិញ ហើយក៏ទទួលបានការយោគយល់ និងអនុញ្ញាតតែម្តង។ ចំពោះការលួចឆ្លងដែនចូលទៅក្នុងទីក្រុងហូជីមីញទៀតសោត គឺដោយសារពួកគេជួបការលំបាកក្នុងបរិបទនៃជំងឺកូវីដ-១៩ និងមានជីវភាពខ្វះខាតខ្លាំង។ មន្ត្រីស្ថានអគ្គកុងស៊ុលកម្ពុជា បានរៀបចំរថយន្តដឹកជញ្ជូន និងបានជូនដំណើរពួកគេ ដល់ព្រំ

ដែនអន្តរជាតិបាវិត ខេត្តស្វាយរៀង និងបានរៀបចំទឹកបរិសុទ្ធ នំប៉ុងសាច់ ទុកសម្រាប់អាហារថ្ងៃត្រង់, លើសពីនេះ បានផ្ដល់មីក្នុងមួយគ្រួសារ ១កេស សម្រាប់ហូបក្នុងពេលចត្តាឡីស័កនៅកម្ពុជា។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បានឲ្យដឹងផងដែរថា ពលករខ្មែរ ១៨នាក់នេះ មុននឹងចេញដំណើរមកកម្ពុជា គឺបានធ្វើតេស្តរកកូវីដ-១៩រួចហើយ គឺលទ្ធផលអវិជ្ជមានទាំង ១៨នាក់៕ ពិសិដ្ឋ CEN

## កម្លាំងចម្រុះខេត្តបន្ទាយមានជ័យ ឃាត់ខ្លួនពលករខ្មែរ១៩នាក់ ដែលបម្រុងឆ្លងដែនទៅថៃខុសច្បាប់

http://freshnewsasia.com/ 2021-09-30 12:29pm

**(បន្ទាយមានជ័យ)៖** កម្លាំងចម្រុះខេត្តបន្ទាយមានជ័យ បានឃាត់ខ្លួនពលករខ្មែរចំនួន១៩នាក់ ដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ នៅ២ទីតាំងផ្សេងគ្នា ក្នុងស្រុកម៉ាឡៃ។ មន្ត្រីដែលចុះក្នុងប្រតិបត្តិការបង្ក្រាបករណីលួចឆ្លងដែននេះ បានបញ្ជាក់ថា ករណីទី១ កើតឡើងនៅយប់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១។ លោកវរសេនីយ៍ទោ យូ សុគន្ធភក្ដី មេបញ្ជាការវរសេនាតូចថ្មើរជើងលេខ៥១៣ បានដឹកនាំកម្លាំងនៅជួរមុខតាមខ្សែបន្ទាត់ព្រំដែនខ្មែរ-ថៃ នៅស្រុកម៉ាឡៃ បានសហការជាមួយកម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ និងកម្លាំងនៅតាមមូលដ្ឋាន ខណៈចេញល្បាតត្រួតពិនិត្យតាមព្រំដែនក្នុងភូមិសន្តិភាព ឃុំទួលពង្រ ដល់ភូមិចំបក់ ឃុំបឹងបេង ក៏បានប្រទះឃើញពលករខ្មែរបានចំនួន៨នាក់ ស្រីចំនួន ៣នាក់ ដែលបម្រុងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ នៅត្រង់ចំណុចភូមិបន្ទាយ២ ឃុំអូរសំព័រ រួចក៏ធ្វើការឃាត់ខ្លួនសាកសួរ និងចាត់ការតាមនីតិវិធី។

ករណីទី២ កើតឡើងនៅយប់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១។ លោកវរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការវរសេនាតូចថ្មើរជើងលេខ៥១៤ បានដឹកនាំកម្លាំងសហការជាមួយកម្លាំងចម្រុះ ដោយឃាត់ខ្លួនបានចំនួន១១នាក់ ក្នុងនោះស្រី៥នាក់ ជិះកង់៣ចំនួន១គ្រឿង នៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ លោកមេបញ្ជាការវរសេនាតូចថ្មើរជើងលេខ៥១៤ បានឱ្យដឹងថា កម្លាំងបានល្បាតជាប់ជាប្រចាំ២៤ម៉ោង លើ២៤ម៉ោង ដោយប្ដូរវេនគ្នាសហការជាមួយកម្លាំងចម្រុះដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ មិនឱ្យចូលទៅក្នុងសហគមន៍៕

## តុលាការឧទ្ធរណ៍ តម្កល់ទណ្ឌកម្ម ប្ដីប្រពន្ធជាប់ចោទ២នាក់ ដាក់គុក ក្នុងម្នាក់ៗ ៧ ឆ្នាំ ជាប់ពាក់ព័ន្ធ នឹងការបើកហាង លក់សាច់អាំង តែបង្កប់សេវាស៊ិច

https://dap-news.com/ ByPH104 Posted on September 30, 2021

**ភ្នំពេញ:** តុលាការឧទ្ធរណ៍ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី ៣០ ខែ កញ្ញ ឆ្នាំ២០២១ បានតម្កល់ទោស ជនជាប់ចោទ២នាក់ ជាងប្ដីប្រពន្ធ ដាក់ពន្ធនាគារ ក្នុងម្នាក់ៗ កំណត់ ៧ឆ្នាំ ជាប់ពាក់ព័ន្ធនឹងបទល្មើស សព្វារកម្ម មានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្ត កាលពីអំឡុងឆ្នាំ ២០២០ នៅក្នុងរាជធានីភ្នំពេញ ។

លោកស៊ិន វិសាល ជា ប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃ សាលាឧទ្ធរណ៍ រាជធានី ភ្នំពេញ បានថ្លែងអោយដឹង ក្នុងអង្គសវនាការថា ជនជាប់ចោទទាំង០២នាក់នេះ មានឈ្មោះ សឹក សុភាព ភេទប្រុស អាយុ ៤១ឆ្នាំ ត្រូវជាប្ដី និង ប្រពន្ធ ឈ្មោះ កប សុផាតអាយុ ៣៨ ឆ្នាំ។ លោកចៅក្រមបានបញ្ជាក់ថា ជនជាប់ចោទទាំង២ ត្រូវបានសមត្ថកិច្ចនគរបាលប្រឆាំង ការជួញដូរមនុស្សឃាត់ខ្លួនកាលពី ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២០ នៅត្រង់ក្នុងចំណុចហាងរបស់ពួកគេ ដែលមានទីតាំងស្ថិតក្នុង សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ពួកគេត្រូវបានតុលាការរាជធានីភ្នំពេញ កាលពីខែ សីហាឆ្នាំ ២០២០ កាត់ទោសដាក់ពន្ធនាគា ក្នុងម្នាក់ៗ កំណត់ ៧ ឆ្នាំ តែពួកគេបានប្ដឹងទាស់ មកកាន់សាលាឧទ្ធរណ៍ រាជធានីភ្នំពេញ ៕ ដោយ រស្មី អាកាស

## កម្លាំងចម្រុះឃាត់ខ្លួនជនជាតិថៃចំនួន ២៦នាក់បម្រុងឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 29/09/2021

ខេត្តបន្ទាយមានជ័យ៖ ជនជាតិថៃចំនួន ២៦នាក់ក្នុងនោះស្រីចំនួន ១២នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់មកកម្ពុជា ត្រូវកម្លាំងកងការពារព្រំដែនលេខ៥០៣ធ្វើការ សហការជាមួយកងពលតូចថ្មើរជើងលេខ៥១ និងនគរបាលព្រំដែនគោកលេខ៩១១ ឃាត់ខ្លួនបាននៅវេលាម៉ោង០១និង៤០នាទីរំលងអធ្រាត្រ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ស្ថិតនៅក្នុងភូមិសាស្រ្ត ភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ពេលដែលពួកគេ បម្រុងលួចឆ្លងដែនដោយខុសច្បាប់ ។

សមត្ថកិច្ចតាមបន្ទាត់ព្រំដែនប្រាប់ថា កងអនុសេនាធំល្បាតទី២ សហការជាមួយកម្លាំងចម្រុះធ្វើការ ឃាត់ខ្លួនបានជនជាតិថៃ ចំនួន ២៦នាក់ ស្រី ១២នាក់ ដែលបម្រុងឆ្លងដែនពីប្រទេសថៃ ចូលមកប្រទេសកម្ពុជានៅវេលាម៉ោង ០១:៤០នាទីរំលងអធ្រាត្រ ស្ថិតនៅក្នុងភូមិសាស្រ្ត ភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ អង្គភាពបានប្រគល់ឱ្យទៅក្រុមការងារចម្រុះនៅច្រកអូរបីជាន់។ ប្រភពថា ក្រុមការងារច្រកអូរបីជាន់បានបំពេញបែបបទនិងប្រគល់ជនជាតិថៃទាំងអស់វិលទៅកាន់ប្រទេសថៃវិញ នៅវេលាម៉ោង០៨និង៣០នាទីព្រឹក ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ទៅឱ្យ តម្រួត ត.ធ.ដ ថៃ កងរយលេខ១២៦ ប៉ុស្តិ៍៣៨ ស្ថិតក្នុងភូមិសាស្រ្ត ភូមិណងម៉ាក់មុន ឃុំគោកឃ្យូង ស្រុកគោកឃ្យូង ខេត្តស្រះកែវ។

គួររំលឹកថា នៅយប់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ឃើញថាកម្លាំងសមត្ថកិច្ចចម្រុះតាមបន្ទាត់ព្រំដែនកម្ពុជាថៃនៅគោលដៅខាងជើងផ្លូវជាតិលេខ៥ និងខាងត្បូងផ្លូវជាតិលេខ៥ បានសហការគ្នាឃាត់ខ្លួនពលករជិត៥០នាក់ក្នុងការរឹតបន្តឹងដើម្បីទប់ស្កាត់ការរីករាលដាលជម្ងឺcovid-19 ដែលកំពុងរាតត្បាត ៕

## កម្ពុជា-ចិន ឯកភាពបន្តកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើសឆ្លងដែន ការជួញដូរគ្រឿងញៀន

https://www.postkhmer.com/ រី សុចាន់ | Publication date 30 September 2021 | 10:36 ICT

**ភ្នំពេញៈ** ក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈចិន ឯកភាពគ្នាបន្តកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើសឆ្លងដែន ល្បែងស៊ីសងតាមអនឡាញខុសច្បាប់ និងការជួញដូរគ្រឿងញៀនខុសច្បាប់ បន្ទាប់ពីភាគីទាំង ២ បានកត់សម្គាល់សមិទ្ធផលសំខាន់ៗ ដែលកើតចេញពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងក្រសួងទាំង ២ រយៈពេលជាង ២ ឆ្នាំកន្លងមកនេះ។ ការឯកភាពគ្នានេះធ្វើឡើងក្នុងកិច្ចប្រជុំកាលពីថ្ងៃទី ២៨ ខែកញ្ញា ដែលលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា និងលោក ចាវ ឃើជឺ សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈចិនបានធ្វើជាសហប្រធានដឹកនាំ ហើយរដ្ឋមន្ត្រីទាំង ២ ក៏បានចុះហត្ថលេខាលើផែនការការងារស្តីពីការបន្តអនុវត្តច្បាប់នៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងក្រសួងទាំង ២។ កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងក្រសួងទាំង ២ ត្រូវបានអនុវត្តតាំងពីខែមីនា ឆ្នាំ ២០១៩ ក្រោមគំនិតផ្តួចផ្តើមរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃកម្ពុជា និងលោក ស៊ី ជីនភីង ប្រធានាធិបតីចិន។

សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងមហាផ្ទៃកម្ពុជាបានឱ្យដឹងកាលពីថ្ងៃទី២៩ ខែកញ្ញាថា៖ «ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ ភាគីទាំង ២ ក៏បានកត់សម្គាល់នូវលទ្ធផល និងសមិទ្ធផលសំខាន់ៗនារយៈពេល ជាង ២ ឆ្នាំកន្លងមក»។ សេចក្តីប្រកាសព័ត៌មានបន្តថា ដោយមើលឃើញនូវសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការការអនុវត្តច្បាប់រវាងប្រទេសទាំង ២ ភាគីទាំង ២ បានចុះហត្ថលេខាលើផែនការការងារនេះ ដើម្បីបន្តពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហការកាន់តែសកម្មក្នុងគោលដៅ ដើម្បីសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត បម្រើដល់ការអភិវឌ្ឍសង្គមជាតិ និងផលប្រយោជន៍ទៅវិញទៅមករបស់ប្រជាជននៃប្រទេសទាំង ២។ សេចក្តីប្រកាស

ព័ត៌មានបានបញ្ជាក់ថា៖ «ក្នុងនោះ [ភាគីទាំង ២] បានឯកភាពបន្តពង្រឹងកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេស ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ល្បែងស៊ីសងអនឡាញខុសច្បាប់។ អំពើឆបោកតាមប្រព័ន្ធទូរគមនាគមន៍ និងការជួញដូរគ្រឿងញៀនខុសច្បាប់»។

បើតាមប្រភពដដែល ភាគីទាំង ២ ក៏បានឯកភាពបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងគាំទ្រគ្នាទៅវិញទៅមក ដើម្បីបម្រើឱ្យការប្រារព្ធនូវព្រឹត្តិការណ៍ជាតិ និងអន្តរជាតិធំៗឱ្យប្រព្រឹត្តទៅដោយជោគជ័យតាមការគ្រោងទុក។ ក្នុងនោះរួមមានការទទួលតួនាទីជាប្រធានអាស៊ានឆ្នាំ ២០២២ ការប្រកួតកីឡារដូវរងាទីក្រុងប៉េកាំងឆ្នាំ ២០២២ និងការរៀបចំព្រឹត្តិការណ៍កីឡា SEA Games លើកទី៣២ ឆ្នាំ ២០២៣ ព្រមទាំងព្រឹត្តិការណ៍សំខាន់ៗដទៃទៀតដែលប្រារព្ធធ្វើនៅកម្ពុជា និងប្រទេសចិន។ សេចក្តីប្រកាសព័ត៌មានបញ្ជាក់ថា រដ្ឋមន្ត្រីទាំង ២ បានអបអរសាទរពីទំនាក់ទំនងដ៏ល្អរវាងថ្នាក់ដឹកនាំកំពូលនៃប្រទេសទាំង២ និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធលើគ្រប់វិស័យក្នុងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដែលបានរួមចំណែកនាំមកនូវវឌ្ឍនភាព និងការអភិវឌ្ឍសម្រាប់ប្រទេសទាំង ២។ រដ្ឋមន្ត្រីទាំង ២ បានថ្លែងកោតសរសើរទៅវិញទៅមកចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កងកម្លាំងអនុវត្តច្បាប់នៃភាគីទាំង ២ ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ទោះបីស្ថិតក្នុងស្ថានភាពប្រឈមដោយជំងឺកូវីដ ១៩ ក៏ដោយ។

លោក ផាត សុផានិត អ្នកនាំពាក្យក្រសួងមហាផ្ទៃបានប្រាប់ ភ្នំពេញ ប៉ុស្ដិ៍ នាថ្ងៃទី ២៩ កញ្ញាថា ផែនការការងារនេះ គឺបន្តអនុវត្តនូវអ្វីដែលបានចុះហត្ថលេខាម្តងរួចមកហើយកាលពីឆ្នាំ ២០១៩។ ភាគីទាំង ២ បន្តពង្រឹងកិច្ចសហប្រតិបត្តិការជារួមពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន។ ប៉ុន្តែគ្រាន់តែបន្ថែមការយកចិត្តទុកដាក់លើបទល្មើសមួយចំនួន ដូចជាការឆបោកតាមអនឡាញ ការរត់ពន្ធមនុស្សឆ្លងដែន ការជួញដូរមនុស្សជាដើម។ លោកថ្លែងថា៖ «មានសកម្មភាពសំខាន់ៗមួយចំនួននៅក្នុងផែនការការងារនេះដែលយើងខកខានមិនបានអនុវត្តកាលពីឆ្នាំ ២០១៩ និង ២០២០ កន្លងទៅ ដោយសារតែជំងឺកូវីដ ១៩ ដូចជា ការផ្លាស់ប្តូរគណៈប្រតិភូទៅវិញទៅមក ការបណ្តុះបណ្តាលកសាង សមត្ថភាពកងកម្លាំង និងការប្រារព្ធកម្មវិធីបង្កើនចំណងមិត្តភាពផ្សេងៗ (ប្រកួតកីឡា សិល្បៈ ជាដើម)។ ដូច្នេះហើយ ទើបយើងចុះហត្ថលេខា ដើម្បីបន្តអនុវត្តនូវអ្វីដែលខកខាន និងមិនទាន់សម្រេចបានកន្លងមក»៕

## ប្រទេសថៃជំរុញអោយចុះឈ្មោះជនចំណាកស្រុកមកពីកម្ពុជា

https://www.khmertimeskh.com/ Khmer Times September 30, 2021

ក្រសួងការងារថៃបានផ្តល់ពេលវេលាដល់និយោជក ក្នុងការចុះបញ្ជីពលករចំណាកស្រុកដែលគ្មានឯកសារត្រឹមត្រូវ បន្ទាប់មកនិងអនុញ្ញាតអោយពួកគេធ្វើការដោយស្របច្បាប់នៅក្នុងប្រទេសថៃ។ លោក Suchart Chomklin រដ្ឋមន្ត្រីក្រសួងការងារបានបង្ហាញនៅថ្ងៃអង្គារនេះថា បន្ទាប់ពីគណៈរដ្ឋមន្ត្រីបានយល់ព្រមតាមសំណើរបស់ក្រសួងសម្រាប់ការគ្រប់គ្រងការងាររបស់ជនជាតិមកពីប្រទេសចំនួនបីគឺកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ក្នុងគោលបំណងគ្រប់គ្រង និងការពារការរីករាលដាលនៃជំងឺកូវីដ-១៩។ លោក Suchart បាននិយាយថា នាយកដ្ឋានការងារត្រូវបានណែនាំអោយត្រួតពិនិត្យនៅកន្លែងសំណង់រោងចក្រ និងកន្លែងធ្វើការផ្សេងទៀតដើម្បីផ្តល់ការណែនាំសុខភាពដល់និយោជក និងពលករចំណាកស្រុករយៈពេល ៣០ ថ្ងៃ។ ក្នុងកំឡុងពេលនេះពលករចំណាកស្រុកខុសច្បាប់នឹងត្រូវបានចុះបញ្ជី ហើយនិយោជករបស់ពួកគេត្រូវដាក់ពាក្យសុំប័ណ្ណការងាររួមជាមួយឯកសារពាក់ព័ន្ធផ្សេងទៀតពីការិយាល័យការងារខេត្តឬការិយាល័យនៅបាងកក។ សំណុំបែបបទប័ណ្ណការងារនឹងត្រូវចំណាយអស់១០០បាត ហើយថ្លៃប័ណ្ណការងារនឹងត្រូវរក្សាទុកតាមបទប្បញ្ញត្តិពាក់ព័ន្ធ។

បន្ទាប់មក និយោជកនឹងទទួលបានឯកសារជំនួសអោយពលករចំណាកស្រុកដែលអាចប្រើបានរហូតដល់ពួកគេទទួលបានប័ណ្ណការងារដែលមានសុពលភាពរហូតដល់ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២៣ ។ លោកបាននិយាយថា គណៈរដ្ឋមន្ត្រីក៏បានពិចារណាពន្យារពេលសម្រាប់ពលករចំណាកស្រុកដែលកំពុងត្រូវបានសម្របសម្រួលតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីដែលមានរយៈពេលចាប់ពីថ្ងៃទី ២៩ ខែធ្នូដល់ថ្ងៃទី ៣១ ខែមីនាឆ្នាំក្រោយដោយសារតែសេវាកម្មមួយចំនួនត្រូវបានផ្អាកដោយសារជំងឺកូវីដ -១៩ ។ សេចក្តីសម្រេចនេះបានអនុញ្ញាតអោយនិយោជកដាក់ពាក្យសុំប័ណ្ណការងារជំនួសពលករចំណាកស្រុកតាមប្រព័ន្ធអនទ្បាញ។ ប្រសិនបើថ្លៃឈ្នួលត្រូវបានបង់មុនថ្ងៃទី ១៣ ខែកញ្ញា នាយកដ្ឋាននឹងចេញប័ណ្ណការងារដែលអាចប្រើបានរហូតដល់ថ្ងៃទី ១៣ ខែកុម្ភៈឆ្នាំ ២០២៣ ។

លោក Pairoj Chotikasathien អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ បាននិយាយថាពលករចំណាកស្រុកដែលទទួលបានប័ណ្ណការងារត្រូវចុះឈ្មោះសម្រាប់ការធានារ៉ាប់រងសុខភាពពីក្រសួងសុខាភិបាលសាធារណៈ ឬក្រុមហ៊ុនធានារ៉ាប់រង ខណៈពេលរង់ចាំអត្ថប្រយោជន៍សន្តិសុខសង្គម៕

# ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១

## ពលករ ១១នាក់ ប៉ុនប៉ងឆ្លងដែនចូលក្នុងប្រទេសថៃដោយខុសច្បាប់ ត្រូវសមត្ថកិច្ចឃាត់ខ្លួន

https://www.gntimes.com/ ថ្ងៃទី១ ខែតុលា ឆ្នាំ២០២១

ខេត្តបាត់ដំបង៖ សមត្ថកិច្ចការពារតំបន់ព្រំដែនបានធ្វើការឃាត់ខ្លួនពលករខ្មែរ ប្រុស-ស្រី ១១នាក់ ខណៈដែលពួកគេប៉ុនប៉ងលួចឆ្លងដែនដោយប្រថុយប្រថាន ទៅរកការងារធ្វើនៅប្រទេសថៃ ក្នុងវិបត្តិកូវីដ-១៩ ដោយគ្មានច្បាប់ទម្លាប់ ។ សមត្ថកិច្ចព្រំដែនបានឲ្យដឹងថា កាលពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២១ ម្សិលមិញនេះ កម្លាំងចម្រុះប្រចាំតំបន់ព្រំដែនបានចុះបង្ក្រាបទប់ស្កាត់ករណីប៉ុនប៉ងលួចឆ្លងដែនមួយករណី នៅក្នុងភូមិសាស្ត្រភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ដោយបានឃាត់ខ្លួនប្រជាពលរដ្ឋជាពលករខ្មែរសរុប ១១នាក់ ក្នុងនោះ បុរស ៥នាក់ និងស្ត្រី០៦នាក់។ក្រោយសមត្ថកិច្ចដេញដោលសួរនាំរកមេខ្យល់ដែលបាននាំចូលទៅប្រទេសថៃ ពួកគេឆ្លើយព្រមៗគ្នាថា ជាការប្រថុយប្រថានចូលដោយចិត្តរបស់ពួកគេ អត់មានមេខ្យល់នាំផ្លូវនោះទេ។ បន្ទាប់មកកម្លាំងចម្រុះបានអប់រំណែនាំរួចប្រគល់ទៅឲ្យអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដើម្បីអនុវត្តនីតិវិធីបន្ត៕ សួន សុខហៃ

## ឃាត់មេខ្យល់ លួចដឹកពលករ តាមម៉ូតូកង់បី បម្រុងឆ្លងដែនទៅថៃ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១ តុលា ២០២១ដោយ Dy Bunnara

ខេត្តបន្ទាយមានជ័យ៖ មេខ្យល់ម្នាក់លួចដឹកពលករ៥នាក់ តាមម៉ូតូកង់បីបំរុងលួចឆ្លងដែនទៅរកការងាធ្វើនៅស្រុកថៃ ដោយខុសច្បាប់ត្រូវនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំគោករមៀត ស្រុកថ្មពួក ធ្វើការឃាត់ខ្លួនពេលដែលនគរបាលប៉ុស្តិ៍ដើរល្បាតចម្ងាយ៣០០ម៉ែត្រ ខាងលិចរង្វង់មូលបឹងត្រកួន ត្រង់ចំណុចការ៉ាស់សាំង ក្នុងភូមិសាស្ត្រភូមិវល្លិ៍ប្រេង ឃុំគោករមៀត។ ជនសង្ស័យមានឈ្មោះ សៅ ធដា ភេទប្រុសអាយុ៣៣ឆ្នាំ មានទីលំនៅ ភូមិត្រពាំងសំរោង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យឃាត់ខ្លួនបាននៅវេលាម៉ោង៨និង៣០នាទីយប់ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១។

លោកវរសេនីយ៍ទោ ស៊ុន សារឿន នាយរងការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា កំលាំនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំគោករមៀតល្បាតខាងលិចរង្វង់មូលបឹងត្រកួន ប្រទះឃើញប្រជាពលរដ្ឋប្រុស-ស្រី ១ក្រុមមានគ្នាចំនួន៥នាក់ ក្នុងនោះក្មេង២នាក់ មានទីលំនៅភូមិប៉ែន ឃុំលៀច ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ និងមានអ្នកបើកម៉ូតូកង់បីមកដឹក ដោយមានការសង្ស័យក៏សួរនាំ ទើបដឹងថា ប្រជាពលរដ្ឋទាំង

នោះមានបំណងឆ្លងដែនទៅថៃដោយមានអ្នកបើកម៉ូតូកង់បីមកទទួលយក។ ក្រោយពីសួរនាំបានបញ្ជូនប្រជាពលរដ្ឋនិងអ្នកបើកម៉ូតូកង់បីទៅអធិការដ្ឋាននគរបាល ស្រុកថ្មពួក បន្តសួរនាំនិងមានវិធានការតាមនិតិវិធីបន្ត។ លោកវរសេនីយ៍ទោ ស៊ុន សារឿន ថាដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្ត នគរបាលស្រុកថ្មពួក បានធ្វើការឃាត់ខ្លួនជនសង្ស័យ ឈ្មោះ សៅ ធដា ហើយបញ្ជូនមកស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យដើម្បីចាត់ការបន្ត ។

នៅចំពោះមុខសមត្ថកិច្ចជនសង្ស័យបានសារភាពថា គេពិតជាមានបំណងដឹកពលករខ្មែរទាំង៥នាក់ ក្នុងនោះក្មេង២នាក់ ឆ្លងទៅប្រទេសថៃរកការងារធ្វើពិតប្រាកដមែន ដោយយកថ្លៃដឹកចំនួន៥០០បាត ក្នុង១នាក់ ដឹកឆ្លងទៅដល់ផ្លូវជាតិក្នុងដីថៃ។ ផ្អែកទៅលើចម្លើយសារភាពជនសង្ស័យ កំលាំជំនាញបានបញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ចាត់ការតាមនិតិវិធីនៅព្រឹក ថ្ងៃទី ១ ខែតុលា ឆ្នាំ ២០២១។ដោយឡែកពលករទាំង៥នាក់បានធ្វើការអប់រំណែនាំនិងធ្វើកិច្ចសន្យារួចឲ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញរៀងៗខ្លួន៕ អត្ថបទ៖ វ៉ាន់ ណាង

## កម្លាំងអន្តរាគមន៍នៅតាមបន្ទាត់ព្រំដែន បានឃាត់ខ្លួនពលករ ខុសច្បាប់១៥នាក់

https://cen.com.kh/ Posted ByPen Srey NeatOctober 1, 2021

បន្ទាយមានជ័យ ៖ នៅយប់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ កម្លាំងអន្តរាគមន៍នៅតាមបន្ទាត់ព្រំដែនសហការជាមួយប៉ូលីសមូលដ្ឋាន ចេញល្បាតត្រួតពិនិត្យតាមព្រំដែន ក៏បានប្រទះឃើញហើយ ធ្វើការឃាត់ខ្លួនពលករខ្មែរបានចំនួន ១៥នាក់ ស្រីចំនួន ៤នាក់ នៅត្រង់ចំណុចភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ និងទិសប៉ោយប៉ែតចំនួន ២នាក់ ដែលបម្រុងនិងឆ្លងអូរលួចចូលទៅប្រទេសថៃ ក៏ត្រូវបានកម្លាំងសហការ ធ្វើការឃាត់ខ្លួនរួចសាកសួរនាំ និងបានប្រគល់ជូនប៉ូលិសព្រំដែន៩១១ ដើម្បីអនុវត្តទៅតាមច្បាប់។

សូមបញ្ជាក់ថា ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការរីរាលដាលនៃជំងឺកូវីដ-១៩ កុំឲ្យឆ្លងចូលជាសហគមន៍ កម្លាំងចំណុះកងពលតូចថ្មើរជើងលេខ៥១ មានអង្គភាពវរសេនាតូចថ្មើរជើងលេខ ៥១១, ៥១៣, ៥១៤ និងកម្លាំចណុះទីបញ្ជាការ តែងតែយកចិត្តទុកដាក់អនុវត្តតាមបទបញ្ជាថ្នាក់លើទាំង ៣ទិស ក្នុងខេត្តបន្ទាយមានជ័យ ចាប់ពីទិសអូរនាង ប៉ោយប៉ែត និងទិសម៉ាឡៃ សហការជាមួយកម្លាំងនៅតាមមូលដ្ឋាន ចេញល្បាត ឆែកឆេរត្រួតពិនិត្យជាប្រចាំ ក្នុងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់៕ រក្សាសិទ្ធិដោយ ៖ បញ្ញាស័ក្តិ

## ស្ថានអគ្គកុងស៊ុលកម្ពុជាបានជួយសម្របសម្រួលជាមួយអាជ្ញាធរថៃបញ្ជូនពលករកម្ពុជាចំនួន ២១ នាក់ និងកុមារ ២ នាក់ ដែលជាប់គាំងក្នុងបរិបទកូវីដ ១៩ ឱ្យវិលត្រឡប់មកកម្ពុជាវិញ

https://www.postkhmer.com/ រី សុចាន់ | Publication date 01 October 2021 | 17:49 ICT

**ភ្នំពេញៈ** ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ប្រទេសថៃបានជួយសម្របសម្រួលជាមួយអាជ្ញាធរថៃបញ្ជូនពលករកម្ពុជាចំនួន ២១ នាក់ និងកុមារ ២ នាក់ ដែលជាប់គាំងក្នុងបរិបទកូវីដ ១៩ ឱ្យវិលត្រឡប់មកកម្ពុជាវិញនៅថ្ងៃទី ១ ខែតុលានេះ។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បានឱ្យដឹងនៅថ្ងៃទី ១ ខែតុលាថា៖ «ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ បានអន្តរាគមន៍សម្របសម្រួលបញ្ជូនពលករខ្មែរចំនួន ២១ នាក់ និងកុមារ ២ នាក់ ដែលមកពីតំបន់នានាក្នុងប្រទេសថៃ ឱ្យវិលត្រឡប់មកកម្ពុជាវិញ»។ លោកបញ្ជាក់ថា ពួកគេត្រូវបានបញ្ជូនតាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងបានប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល។

កាលពីថ្ងៃទី ២៩ ខែកញ្ញា ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងហូជីមិញ ប្រទេសវៀតណាម បានសម្របសម្រួលជាមួយអាជ្ញាធរក្រុងហូជីមិញរៀបចំឱ្យពលរដ្ឋកម្ពុជាចំនួន ៥ គ្រួសារ ដែលមានចំនួន ១៨ នាក់ ដែលឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅទីក្រុងហូជីមិញត្រឡប់មកកម្ពុជា ដោយសារជួបបញ្ហាលំបាកក្នុងបរិបទនៃជំងឺកូវីដ ១៩ និងមានជីវភាពខ្វះខាតខ្លាំង។ លោក កុយ គួង បញ្ជាក់ថា៖ «ស្ថានអគ្គកុងស៊ុលបានរៀបចំរថយន្តដឹកជញ្ជូន និងបានជូនដំណើរដល់ព្រំដែនអន្តរជាតិបាវិត ខេត្តស្វាយរៀង (បានធ្វើតេស្តទទួលលទ្ធផលអវិជ្ជមានកូវីដទាំង ១៨ នាក់ មុនចេញដំណើរ)»៕

## ឃាត់ខ្លួនពលរដ្ឋ ៨នាក់ដែលបម្រុងឆ្លងដែនចូលទឹកដីថៃ តាមច្រកស្រុកសំពៅលូន

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ២ តុលា ២០២១ដោយ sopheak khoun

កម្លាំងអធិការដ្ឋាន នគរបាលស្រុកសំពៅលូន នៅល្ងាចថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ បានសហការជាមួយកម្លាំង នគរបាលវរៈការពារព្រំដែនគោក ៨១៧ កម្លាំងផ្នែកសឹករងស្រុកសំពៅលូន និងកម្លាំងវរៈសេនាតូច ៥៣៣ ប្រចាំការតាមមាត់អូរព្រំដែនកម្ពុជា-ថៃ ធ្វើការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរ បម្រុងឆ្លងដែនចូលទៅក្នុងប្រទេសថៃខុសច្បាប់ចំនួន១លើក។ ការឃាត់ខ្លួននេះ បានធ្វើឡើងនៅចំណុចដីថៃ ជាប់មាត់អូរព្រំដែន ជាប់ភូមិសាស្រ្តភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ប្រជាពលរដ្ឋចំនួន ៨នាក់។ ពលករទាំងអស់នោះ បានធ្វើសកម្មភាពទាក់ទងមេខ្យល់ មិនស្គាល់អត្តសញ្ញាណ តាមរយៈលេខទូរស័ព្ទដោយឲ្យថ្លៃជូនក្នុងតម្លៃម្នាក់ ៧.០០០បាត ឆ្លងដែនចូលទៅក្នុងប្រទេសថៃ តែក៏ត្រូវកម្លាំងសមត្ថកិច្ចសហការ ធ្វើការឃាត់ខ្លួនតែម្តង។ ចំពោះអ្នកនាំផ្លូវចំនួន ២នាក់ភេទប្រុស មិនស្គាល់អត្តសញ្ញាណ បានរត់គេចខ្លួនបាត់។

បច្ចុប្បន្នប្រជាពលរដ្ឋទាំង ៨នាក់ ត្រូវបានកម្លាំងសមត្ថកិច្ច បាននាំទៅកាន់កន្លែងអធិការដ្ឋាន នគរបាលស្រុកសំពៅលូន ធ្វើការសាកសួរ ដើម្បីស្រាវជ្រាវរកមេខ្យល់ និងដោយមានការអនុញ្ញាតពីលោក កែវ សុជាតិ ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង បានសម្រេចឲ្យកម្លាំងសមត្ថកិច្ច ធ្វើការអប់រំចុះកិច្ចសន្យា និងបានឲ្យវិលត្រឡប់ទៅមូលដ្ឋានវិញហើយ៕ អត្ថបទ៖ សោ និយមវ័ត្ន

## រយៈពេលមួយសប្ដាហ៍មានពលករជាច្រើននាក់បម្រុងឆ្លងដែនខុសច្បាប់ត្រូវឃាត់ខ្លួន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០២ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ១៤:៣០

ខេត្តបន្ទាយមានជ័យ៖ ពលករជាច្រើននាក់ រួមទាំងជនបរទេសមួយចំនួន បម្រុងឆ្លងដែនទៅធ្វើការនៅប្រទេសថៃ ត្រូវបានឃាត់ខ្លួនដោយកម្លាំងតំបន់ប្រតិបត្តិការសឹករងខេត្ត ដែលឃាត់បានក្នុងភូមិសាស្រ្ត ស្រុកថ្មពួក និងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។នេះបើយោងតាមកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទបានផ្សាយ។

លោក ឧត្តមសេនីយ៍ ត្រី ជឹម ប៊ុនអាន មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ដល់កម្លាំងទាំងអស់ល្បាតជាប់ជាប្រចាំ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នាសហការល្អជាមួយកងកម្លាំងចំរុះ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍ ។ បើគិតក្នុងមួយសប្តាហ៍នេះ គឺកម្លាំងឃាត់ខ្លួនពលករចំនួន៤៩នាក់ ក្នុងនោះមានជនជាតិចិនចំនួន៤នាក់ផងដែលបម្រុងឆ្លងដែលទៅប្រទេសថៃ និងបានឃាត់ខ្លួន ដើម្បីសាកសួរនាំ និងបញ្ជូនបន្តទៅធ្វើចត្តាឡីស័ក ចំណែកអ្នកនាំផ្លូវត្រូវបញ្ជូនទៅមូលដ្ឋានរាជអាវុធហត្ថចាត់ការតាមនីតិវិធីច្បាប់ ។

ជាក់ស្តែង យប់ថ្ងៃទី១ ឈានចូល ថ្ងៃទី២ ខែតុលា ឆ្នាំ២០២១ លោកនាយចំណង់ ធប កុសល មេក្រុម គោលដៅដឹកនាំកម្លាំងដើរល្បាតដែលសហការជាមួយប៉ូលិសការពារព្រំដែនគោកលេខ៨១៥ ក៏ជួបពលករចំនួន ១៨នាក់ បំរុងឆ្លងដែនចេញទៅប្រទេសថៃត្រូវបានកម្លាំងល្បាតសហការណ៍ ឃាត់ខ្លួនបានតែម្តង ។

សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំងតំបន់ប្រតិបត្តិការសឹករងខេត្ត ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការ សហការជាមួយកម្លាំងចម្រុះ ទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ បាន ឃាត់ខ្លួនពលករឆ្លងដែនបញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួន បញ្ជូនទៅ សមត្ថកិច្ចជំនាញចាត់វិធានការតាមផ្លូវច្បាប់ ។ សូមបងប្អូនប្រជាពលរដ្ឋ កុំចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះ បញ្ចូល នាំពលករឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុខសុវត្ថិភាព និងខាតបង់ប្រាក់ជាបន្តបន្ទាប់ ជា ពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣ការពារ ៣កុំ អោយបានទាំងអស់គ្នា ដើម្បីគ្រួសារ និងសង្គមជាតិ៕

## ពលករ និងមេខ្យល់ សរុបចំនួន ៣៨នាក់ បម្រុងឆ្លងដែនខុសច្បាប់ ត្រូវឃាត់ខ្លួន ដោយកម្លាំងចម្រុះការពារព្រំដែន

https://cen.com.kh/ Posted ByPen Srey NeatOctober 2, 2021

បន្ទាយមានជ័យ ៖ ពលករ និងមេខ្យល់ ចំនួន ៣៨នាក់ និងជនជាតិថៃ ចំនួន ៤នាក់ ដែលបម្រុងលួចឆ្លង ដែនខុសច្បាប់ ត្រូវបានកម្លាំងកងការពារព្រំដែនលេខ៥០៣ សហការជាមួយកម្លាំងចម្រុះ ឃាត់ខ្លួនបាននៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ខណៈពេលដែលពួកគេ បម្រុងលួចឆ្លងដែនដោយខុសច្បាប់ កម្លាំងដើរល្បាតពួនស្ទាក់ចាប់ បានចំនួន ៣គោលដៅផ្សេងគ្នា សរុបចំនួន ៣៨នាក់ ស្រី ចំនួន ២៣នាក់ ក្មេង ចំនួន ៥នាក់ ស្រី ចំនួន ៣នាក់ មេ ខ្យល់ចំនួន ១នាក់ ម្ចាស់រថយន្តចំនួន ១នាក់ រថយន្តចំនួន ១គ្រឿង ក្នុងនោះជនជាតិថៃ ចំនួន ៤នាក់ ស្រី ចំនួន ៣នាក់។

នេះគឺបទបញ្ជាពីលោកឧត្តមសេនីយ៍ត្រី យួន ជឿន មេបញ្ជាការកងការពាព្រំដែនលេខ៥០៣ ដើម្បីពង្រឹង ការល្បាត តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងចម្រុះ ដើម្បី ទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍ និង តំបន់ផ្សេងទៀត។

សូមបញ្ជាក់ថា ខណៈកងកម្លាំងចម្រុះល្បាត ក៏បានជួបពលករបម្រុងលួចឆ្លងដែន ត្រូវបានកងកម្លាំងកង ការពារព្រំដែនលេខ៥០៣ ឃាត់ខ្លួនបានតែម្តង ក្រោយពីឃាត់ខ្លួន ក៏បានណែនាំដល់បងប្អូនប្រជាពលរដ្ឋ កុំឲ្យបន្ត ចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះបញ្ចូល នាំពលករឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុខសុវត្ថិភាព និងខាតបង់ប្រាក់ជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣ការពារ ៣កុំ ឲ្យបានទាំងអស់គ្នា ដើម្បី គ្រួសារ និងសង្គមជាតិ៕រក្សាសិទ្ធិដោយ ៖ បញ្ញាស័ក្តិ

## អាជ្ញាធរថៃឃាត់រថយន្តរត់ពន្ធពលករខ្មែរ

https://www.khmertimeskh.com/ October 3, 2021

**ពលករឆ្លងដែន២០នាក់ ត្រូវបានរកឃើញក្នុងរថយន្តពេលអាជ្ញាធរត្រួតពិនិត្យក្នុងខេត្ត នគរ រាជសីម៉ា** ជន ជាតិថៃពីរនាក់ ត្រូវបានចាប់ខ្លួននៅប៉ុស្តិ៍ត្រួតពិនិត្យមួយនៅក្នុងស្រុកស៊ីខៀវ ដោយចោទប្រកាន់ពីបទរត់ពន្ធពលករ ចំណាកស្រុកកម្ពុជាចំនួន ២០នាក់ លាក់ក្នុងរថយន្តដឹកអ្នកដំណើរកាលពីព្រឹកថ្ងៃសៅរ៍។ ប៉ូលីសត្រួតពិនិត្យនៅលើ ផ្លូវមិត្តភាព ក្នុងស្រុកស៊ីខៀវ បានផ្តល់សញ្ញាអោយរថយន្តឈប់ ប៉ុន្តែអ្នកបើកបរបានព្យាយាមបន្ថែមល្បឿន។ មន្ត្រី

ប៉ូលីស បានរារាំងរថយន្តហើយទីបំផុតបង្ខំឱ្យឈប់។ មន្ត្រីប៉ូលីសបានរកឃើញបុរស និងស្ត្រីខ្មែរចំនួន ២០នាក់ នៅក្នុងរថយន្តរួមជាមួយជនជាតិថៃពីរនាក់គឺអ្នកបើកបរឈ្មោះ ប៊ុនឈួយ តែធាណា អាយុ ៥៤ឆ្នាំ និងប្រាមុល កេតផាថុម អាយុ ៥៧ឆ្នាំ។

យោងតាមកំណត់ត្រាបទល្មើស បានបង្ហាញថាលោកស្រី ប្រាមុល ជាប្រជាពលរដ្ឋម្នាក់ រស់នៅស្រុកវ៉ាតថាណា នគរ ក្នុងខេត្តស្រះកែវ ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងការរត់ពន្ធកម្មករកាលពីដើមខែកញ្ញាហើយក្រោយមកត្រូវបានដោះលែងឱ្យនៅក្រៅឃុំ។ ក្នុងអំឡុងពេលសួរចម្លើយលោក ប៊ុនឈួយ បានប្រាប់ប៉ូលីសថាគាត់ត្រូវបានគេជួលក្នុងតម្លៃ ២ម៉ឺនបាត ដើម្បីទៅយកពលករចំណាកស្រុកមកពីស្រុកសឹងសាំង ក្នុងខេត្តនគររាជសីម៉ា ហើយនាំពួកគេទៅកាន់ផ្សារថៃ ក្នុងខេត្តប៉ាធុមថានី។ អ្នកបើកបរបានប្រាប់ថា៖ ជនជាតិខ្មែរបានចូលប្រទេសថៃ តាមច្រកព្រំដែនតាប្រាយ៉ា នៅខេត្តស្រះកែវ ហើយបានឡើងជិះរថយន្តឆ្ពោះទៅស្រុកសឹងសាំងដើម្បីរង់ចាំឡើងឡាន។

ប៉ូលីសបានចោទប្រកាន់ជនជាតិថៃទាំងពីរនាក់នេះពីបទរំលោភលើក្រឹត្យគ្រាអាសន្ន និងរត់ពន្ធជនជាតិបរទេសចូលក្នុងប្រទេស។ ពួកគេត្រូវបានប៉ូលីសឃុំខ្លួននៅប៉ុស្តិ៍ប៉ូលីស ស៊ីខៀវ រង់ចាំការចាត់វិធានការតាមផ្លូវច្បាប់បន្តទៀត។ជនចំណាកស្រុកខ្មែរទាំង២០នាក់នេះនឹងត្រូវប្រគល់ឱ្យនគរបាលអន្តោប្រវេសន៍មុនពេលត្រូវនិរទេសខ្លួន។

## ឃាត់ពលករខ្មែរ១៦នាក់ បម្រុងលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ នៅស្រុកអូរជ្រៅ

http://freshnewsasia.com/ 2021-10-03 12:58pm

**(បន្ទាយមានជ័យ)៖** កម្លាំងចម្រុះនៅតាមព្រំដែនកម្ពុជា នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២១នេះ បានឃាត់ខ្លួនពលករខ្មែរ ចំនួន១៦នាក់ ដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់ នៅចំណុចព្រំទល់ភូមិសិលាខ្មែរ និងភូមិទំនប់ដាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

បើតាមមន្ត្រីដែលចុះនៅក្នុងប្រតិបត្តិការនេះ បានឱ្យដឹងថា ដោយមានការយកចិត្តទុកដាក់ពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ និងអនុវត្តបទបញ្ជាយ៉ាងម៉ឺងម៉ាត់ពីលោកវរសេនីយ៍ឯក សូ ចាន់ណារី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៩១១ កម្លាំងប៉ុស្តិ៍ចំនួន០៨នាក់ដឹកនាំដោយលោកវរសេនីយ៍ត្រី ប៉ាក់ សារ៉ាត់ នាយប៉ុស្តិ៍សិលាខ្មែរ សហការជាមួយ កម្លាំងយោធា និងកម្លាំងប្រជាការពារភូមិសិលាខ្មែរ បានធ្វើការទប់ស្កាត់ ពលករខ្មែរ បម្រុងលួចឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ។ ក្រោយពីសួរនាំ និងទទួលបានបទបញ្ជាពីលោកមេបញ្ជាការ កម្លាំងប៉ុស្តិ៍បានបញ្ជូនពលករខ្មែរទាំង១៦នាក់ ទៅកន្លែងពិនិត្យសុខភាពច្រកអូរបីជាន់៕

## កម្លាំងនគរបាលការពារព្រំដែន ចុះសហការទប់ស្កាត់ពលរដ្ឋ ចំនួន៤នាក់ បម្រុងឆ្លងដែនចូលទឹកដីថៃខុសច្បាប់

https://cen.com.kh/ Posted ByPen Srey NeatOctober 3, 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ នៅថ្ងៃសៅរ៍ ទី០២ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៤និង០៧នាទីព្រឹក កម្លាំងប៉ុស្តិ៍ព្រំដែនគីឡូ១៣ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឺង ម៉េត នាយប៉ុស្តិ៍ រួមសហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន មេបញ្ជាការកងនុសេនាតូច, កម្លាំងយោធាវរសេនាតូច៥៣៣ ដឹកនាំដោយលោកអនុ

សេនីយ៍ឯក ទ្រី ងឿន មេបញ្ជាការរងវរសេនាតូចតូច៥៣៣ បានចុះធ្វើការទប់ស្កាត់ប្រជាពលរដ្ឋបម្រុងលួចឆ្លងដែនចូលទឹកដីថៃ ត្រង់ចំណុចនៃភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង បានចំនួន០៤នាក់ ស្រី០១នាក់ ។ បន្ទាប់ពីឃាត់ខ្លួន កម្លាំងបានធ្វើការសាកសួរ កត់ឈ្មោះ និងអប់រំណែនាំ រួចប្រគល់ពួកគាត់ឲ្យទៅកម្លាំង នៃអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដើម្បីដោះស្រាយតាមនីតិវិធី ៕រក្សាសិទ្ធិដោយ ៖ បញ្ញាស័ក្តិ

## កងកម្លាំងឈរជើងជួរមុខ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ ប្តេជ្ញារួមគ្នាបន្ត ទប់ស្កាត់បង្រ្កាបរាល់បទល្មើស ដែលលបលួចឆ្លងដែនខុសច្បាប់

https://cen.com.kh/ Posted ByPen Srey NeatOctober 3, 2021

ព្រះវិហារ៖ កងកម្លាំងប្រដាប់អាវុធកម្ពុជា និងកងកម្លាំងប្រដាប់អាវុធថៃ ឈរជើង នៅក្នុងទិសទី១ ប្រាសាទព្រះវិហារនៅតែប្តេជ្ញារួមគ្នាបន្តទប់ស្កាត់បង្រ្កាបរាល់បទល្មើសដែលលបលួចឆ្លងដែនខុសច្បាប់។ ការប្តេជ្ញារួមគ្នានេះ បានធ្វើឡើងនៅក្នុងកិច្ចប្រជុំមួយកាលពីព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០២១ ក្នុងភូមិសាស្ត្រជួរមុខទិសភ្នំទ្រព្យ, ទិសតាថាវ, និងទិសភ្នំ៣៣៣, នៅក្នុងភូមិសាស្ត្រទិសទី១ ប្រាសាទព្រះវិហារ ។ ភាគីទាំងពីរបានបើកកិច្ចប្រជុំដោយពិភាក្សាលើខ្លឹមសាររួមមាន៖ រួមគ្នាទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩តាមព្រំដែន ការរក្សាទំនាក់ទំនងល្អ រួមគ្នាទប់ស្កាត់ការលួចឆ្លងដែន ដោយខុសច្បាប់ របស់ពលរដ្ឋ នៃប្រទេសទាំងពីរ។

សូមបញ្ជាក់ថា គោលបំណងសំខាន់ក្នុងកិច្ចប្រជុំនេះ គឺបង្កើនកិច្ចសហប្រតិបត្តិការល្អ បន្ថែមទៀត រវាងកងកម្លាំងឈរជើងជួរមុខ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ នៅក្នុងទិសទី១ប្រាសាទព្រះវិហារ ដើម្បីរក្សាបានសុខសន្តិភាព និងការអភិវឌ្ឍន៍ ព្រមទាំងការរស់នៅប្រកបដោយភាពសុខសាន្ត របស់ប្រជាជននៃប្រទេសទាំងពីរ ឈរលើការណ៍ដោះស្រាយគ្នាដោយសន្តិវិធី ជៀសវាងការប្រឈមមុខដាក់គ្នាដោយកម្លាំងប្រដាប់អាវុធ៕ បញ្ញាស័ក្តិ

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ចុះសហការទទួលពលរដ្ឋខ្មែរត្រឡប់មកពីប្រទេសថៃ បញ្ជូនទៅមណ្ឌលចត្តាឡីស័ក

https://cen.com.kh/ Posted ByPen Srey NeatOctober 3, 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ នៅថ្ងៃសៅរ៍ ទី២ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៥និង៥៥នាទី កម្លាំងប៉ុស្តិ៍ព្រំដែនកូនភ្នំ (គោលដៅទី៣) ដឹកនាំដោយលោកអនុសេនីយ៍ទោ រឿន វ៉ាន់នី នាយរងប៉ុស្តិ៍ សហការជាមួយកម្លាំងផ្នែកស៊ើបការណ៍ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ សេង រ៉ុន (នាយផ្នែក) សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី១, វរសេនាតូចលេខ១ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ឡៃ លឿន មេបញ្ជាការកងអនុសេនាតូច, កម្លាំងយោធាកងអនុសេនាធំគាំទ្រ, វរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ឈឹម សុភាព មេបញ្ជាការកងអនុសេនាតូច បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញត្រង់ចំណុចនៃភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០២នាក់ស្រី០១នាក់ ។

បន្ទាប់ពីសាកសួរ, កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងបានប្រគល់បងប្អូនឲ្យទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣ ដើម្បីធ្វើចត្តាឡីស័ក ៕ រក្សាសិទ្ធិដោយ ៖ បញ្ញាស័ក្តិ

# ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បន្តនាំយគ្រឿងឧបភោគបរិភោគ ប្រគល់ជូនពលករខ្មែរដែលរងផលប៉ះពាល់ខ្លាំងដោយសារជំងឺកូវីដ-១៩

https://t.me/TVKlocal 03/10/2021

នៅព្រឹកថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២១ ឯកឧត្តម អ៊ុក សោភ័ណ ឯកអគ្គរាជ ទូត កម្ពុជាប្រចាំប្រទេសថៃ បានចាត់ លោក ធុច ដាលីន អគ្គទីប្រឹក្សា និង លោក ចិន សំណាង អនុព័ន្ធការងារប្រចាំស្ថានទូត នាំយក អង្ករ ត្រីខ បន្លែ ត្រី សាច់... ទៅ ប្រគល់ជូនតំណាងរបស់បងប្អូនពលករខ្មែរនៅផ្លូវផេតប៊ុរី១៧, សង្កាត់ផៈយ៉ាថៃ, ខ័ណ្ឌរ៉ាតធៈថេវី, រាជធានីបាងកក ដើម្បីនាំយក ទៅចែក ជូន បន្តដល់បងប្អូនពលករ សរុប ៩៣ គ្រួសារ ដែលរស់នៅ ខេត្តណៈខនប៉ះធុម ១៤ គ្រួសារ, សមុទ្រប្រាកាន ៣៨ គ្រួសារ, ឈុនប៊ុរី ៤ គ្រួសារ និងទីក្រុងបាងកក ៣៧ គ្រួសារ។ សូមបញ្ជាក់ថា បងប្អូនពលករខ្មែរទាំងនេះ សុទ្ធសឹងជាអ្នកដែលជួបការលំបាកខ្លាំង ខ្លះបាត់បង់ការងារ, ខ្លះមានឆ្លងជំងឺកូវីដ-១៩ និងមួយចំនួនទៀត ជាប់ធ្វើចត្តាឡីស័កមិនអាច ទៅធ្វើការបាន។

## បញ្ជូនមេខ្យល់២នាក់នាំពលករឆ្លងដែនខុសច្បាប់ទៅតុលាការ

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ៣ តុលា ២០២១ដោយ Sokhom Khon

មេខ្យល់២នាក់ នាំពលករ៦នាក់ទៅរកការងារធ្វើនៅស្រុកថៃដោយខុសច្បាប់ ត្រូវបានកម្លាំងការពារព្រំដែនលេខ៥០៣ ឃោធភូមិភាគទី៥ឃាត់ខ្លួនបាននៅវេលាម៉ោង៨យប់ ថ្ងៃទី២ ខែតុលា ឆ្នាំ២០២១។ តាមការបំភ្លឺរបស់ពលករចំនួន៦នាក់បានឲ្យដឹងថា នៅថ្ងៃទី២ ខែតុលានេះក្រុមខ្លួនបានសម្រេចចិត្តឆ្លងដែនទៅធ្វើការនៅប្រទេសថៃ ដោយបានទំនាក់ទំនងជាមួយមេខ្យល់តាមរយៈទូរស័ព្ទមេខ្យល់យកលុយក្នុង១នាក់៥០០០បាត ក្រុមខ្លួនបានរង់ចាំមេខ្យល់នៅមុខសួនស្នេហ៍ជនបទ ស្ថិតក្នុងក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ មួយសន្ទុះក្រោយមកមានរថយន្ត១គ្រឿងម៉ាកលុចស៊ីស ពណ៌ប្រផេះពាក់ផ្លាកលេខ ប.មានជ័យ 2B-1911 មកយកក្រុមខ្លួនហើយចេញដំណើរទៅពេលទៅដល់ចំណុចចម្ការកៅស៊ូមួយកន្លែង ស្រាប់តែមានមនុស្សប្រុសម្នាក់ទៀតឈ្មោះ យ៉ុង រីៈ ឡើងឡានទៅជាមួយពួកខ្លួនដែរ ដោយរូបគេប្រាប់ថា រូបគេជាអ្នកនាំពួកខ្លួនឆ្លងដែនទៅប្រទេសថៃ លុះជិះដល់ចំណុចប៉ុស្តិ៍ដើមព្រីងក៏ត្រូវបានកម្លាំងឃោធាឃាត់រថយន្តហើយធ្វើការសួរនាំ និងឃាត់ក្រុមខ្លួនបញ្ជូនមកបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តតែម្តង ។

លោកវរសេនីយ៍ត្រី ធឿង វាសនា បានបន្តទៀតថា ជនសង្ស័យជាម្ចាស់រថយន្តដឹកពលករមាន ឈ្មោះ វ៉ែន រឿន ភេទប្រុស អាយុ៥៦ឆ្នាំ រស់នៅភូមិសាមគ្គីមានជ័យ សង្កាត់ និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ចំណែកឈ្មោះ យ៉ុង រីៈ ភេទប្រុស អាយុ៣៥ឆ្នាំរស់នៅភូមិចម្ការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត ទទួលការងារស្រាវជ្រាវ និងបង្ក្រាបបទល្មើសបានឱ្យដឹងថា ដោយបានការអនុញ្ញាតពីលោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្ត មេខ្យល់ទាំង២នាក់នេះនៅព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០២១នេះបានបញ្ជូនទៅតុលាការដើម្បីដាក់ទោសទៅតាមច្បាប់។ ចំណែកពលករទាំង៦នាក់ត្រូវបានកម្លាំងធ្វើកិច្ចសន្យាអប់រំឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញហើយ ៕

អត្ថបទ៖ វ៉ាន់ ណាង

# ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១

## កម្លាំងអន្តរាគមន៍ ទប់ស្កាត់តាមបន្ទាត់ព្រំដែន ឃាត់ខ្លួនពលករលួចឆ្លងដែនខុសច្បាប់

https://cen.com.kh/ Posted ByPen Srey NeatOctober 3, 2021

បន្ទាយមានជ័យ ៖ នៅយប់ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២១ កម្លាំងអន្តរាគមន៍នៅតាមបន្ទាត់ព្រំដែនសហការជាមួយប៉ូលីសមូលដ្ឋាន ចេញល្បាតត្រួតពិនិត្យតាមព្រំដែន ក៏បានប្រទះឃើញពលករជាងសែសិបនាក់ លើគោលដៅពីផ្សេងគ្នា ដែលរត់គេចពី កងកម្លាំងល្បាតតាមព្រំដែន កម្លាំងចម្រុះបានសហការស្ទាក់ចាប់ពលករខ្មែរបានចំនួន២៨នាក់ ស្រីចំនួន ១០នាក់ ដែលស្ថិតនៅត្រង់ចំណុចភូមិសិលាខ្មែរ និងភូមសាស្ត្រស្រុកម៉ាឡៃ បម្រុងលួចឆ្លងដែនចូលទៅប្រទេសថៃ ក៏ត្រូវបានកម្លាំងធ្វើការឃាត់ខ្លួនរួចសាកសួរនាំ និង បានប្រគល់ជូននគរបាលព្រំដែនគោកដោយឡែកពលករដែលគេចខ្លួនកំពុងបន្តស្រាវជ្រាវឆែកឆេរុករក និងមេខ្យល់បន្តទៀត ដើម្បីអនុវត្តទៅតាមច្បាប់។

សូមបញ្ជាក់ថា ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ មិនឲ្យឆ្លងចូលជាសហគមន៍ កម្លាំងចំណុះកងពលតូចថ្មើរជើងលេខ៥១ មានអង្គភាពវរសេនាតូចថ្មើរជើងលេខ ៥១១, ៥១៣, ៥១៤ និងកម្លាំចណុះទីបញ្ជាការ តែងតែយកចិត្តទុកដាក់អនុវត្តតាមបទបញ្ជាថ្នាក់លើទាំង ៣ទិស ក្នុងខេត្តបន្ទាយមានជ័យ ចាប់ពីទិសអូរនាង ប៉ោយប៉ែត និងទិសម៉ាឡៃ សហការជាមួយកម្លាំងនៅតាមមូលដ្ឋាន ចេញល្បាត ឆែកឆេរត្រួតពិនិត្យជាប្រចាំក្នុងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់៕រក្សាសិទ្ធិដោយ ៖ បញ្ញាស័ក្តិ

## ចម្លើយសារភាព! នាំពលរដ្ឋជិត១00នាក់ឆ្លងដែន ដោយក្នុងម្នាក់យក៥000បាត

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៤ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ០៨:៥៨

ខេត្តបន្ទាយមានជ័យ ៖ ជនសង្ស័យចំនួន២នាក់ត្រូវបានកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស កងរាជអាវុធហត្ថខេត្ត រៀបចំសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២១ ដើម្បីចាត់ការតាមនីតិវិធី ។

លោកវរសេនីយ៍ត្រី ធឿង វាសនា ឲ្យដឹងថា ៖ ជនសង្ស័យជាម្ចាស់រថយន្តដឹកពលករនោះ ឈ្មោះ វ៉ែន រឿន ភេទប្រុស អាយុ៥៦ឆ្នាំ បច្ចុប្បន្នរស់នៅភូមិសាមគ្គីមានជ័យ សង្កាត់ និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និង ឈ្មោះ យ៉ុង វីរៈ ភេទប្រុស អាយុ៣៥ឆ្នាំ ជាអ្នកនាំផ្លូវ បច្ចុប្បន្នរស់នៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ នៅចំពោះមុខសមត្ថកិច្ច ជនសង្ស័យទាំ០២នាក់បានឆ្លើយសារភាពថា ពួកគេបានសហការគ្នាដើម្បីដឹកពលករ និងនាំឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់ពិតប្រាកដមែន ។ លោកវរសេនីយ៍ត្រី ធឿង វាសនា នាយការិយាល័យប្រឆាំងការជួញដូរមនុស្សបានឱ្យដឹងថា ជនសង្ស័យទាំង០២នាក់ខាងលើ ត្រូវបានកម្លាំង កងការពារព្រំដែនលេខ៥០៣ យោធភូមិភាគទី៥ បានឃាត់ខ្លួននៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ រួចក៏បញ្ជូនមក បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ដើម្បីចាត់វិធានការបន្ត ។

ហើយនៅចំពោះមុខសមត្ថកិច្ច ជនសង្ស័យទាំង០២នាក់ក៏បានសារភាពថា ពួកគេបាននាំមនុស្ស១ក្រុមចំនួន៩៦នាក់ឆ្លងដែនទៅធ្វើការនៅប្រទេសថៃ ដោយក្នុងម្នាក់យកតម្លៃ៥,០០០បាត ។ លោកនាយការិយាល័យបានបញ្ជាក់ទៀតថា ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្ត និងមានការសម្របសម្រួលពីឯកឧត្តម កើត សុវណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបន្ទាយមានជ័យ ជនសង្ស័យទាំង០២នាក់ រួមនឹងរថយន្ត ត្រូវបានកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស កងរាជអាវុធហត្ថខេត្ត រៀបចំសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្ត ដើម្បីចាត់ការតាមនីតិវិធី ៕

# ពលករចំនួន ២២នាក់ បម្រុងឆ្លងដែនខុសច្បាប់ ត្រូវបានឃាត់ខ្លួន ដោយកម្លាំងកងការពារព្រំដែន

https://cen.com.kh/ Posted ByPen Srey NeatOctober 4, 2021

បន្ទាយមានជ័យ ៖ ពលករចំនួន ២២នាក់ និងដែលបម្រុងលួចឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំងកងការពារព្រំដែនលេខ៥០៣ សហការជាមួយកងពលតូចថ្មើរជើងលេខ៥១ និងនគរបាលព្រំដែនគោកលេខ៩១១ ឃាត់ខ្លួនបាននៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០២១ ខណៈពេលដែលពួកគេ បម្រុងលួចឆ្លងដែនដោយខុសច្បាប់ កម្លាំងដើរល្បាតពួនស្ទាក់ចាប់បានចំនួន ៣គោលដៅផ្សេងគ្នា សរុបចំនួន ២២នាក់ ស្រី ចំនួន ៩នាក់។

គោលដៅទី១ កម្លាំងកងអនុសេនាធំល្បាតទី៣ ដឹកនាំដោយវរសេនីយ៍ត្រី កែវ សារី មេបញ្ជាការកងអនុសេនាធំល្បាតទី៣ សហការជាមួយកម្លាំងចម្រុះ ឃាត់ខ្លួនបានពលករ ចំនួន ១៦នាក់ ស្រី ៥នាក់ ដែលបម្រុងឆ្លងដែនចូលទៅប្រទេសថៃ នៅវេលាម៉ោង ០៣និង៣០នាទីជិតភ្លឺ ស្ថិតនៅក្នុងភូមិសាស្ត្រ ភូមិទំនប់ជាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ អង្គភាពបានប្រគល់អោយក្រុមការងារចម្រុះច្រកអូរបីជាន់ ដើម្បីបញ្ជូនទៅមណ្ឌលចត្តាឡីស័ក។

គោលដៅទី២ កម្លាំងកងអនុសេនាធំល្បាតទី៣ ដឹកនាំដោយវរសេនីយ៍ត្រី កែវ សារី មេបញ្ជាការកងអនុសេនាធំល្បាតទី៣ សហការជាមួយកម្លាំងចម្រុះ ឃាត់ខ្លួនបានពលករចំនួន ២នាក់ ស្រី ១នាក់ ដែលបម្រុងឆ្លងដែនចូលទៅប្រទេសថៃ នៅវេលាម៉ោង ០៩និង៣០នាទីព្រឹក ស្ថិតនៅក្នុងភូមិសាស្ត្រ ភូមិទំនប់ជាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ អង្គភាពបានប្រគល់អោយទៅក្រុមការងារចម្រុះច្រកអូរបីជាន់ដើម្បីបញ្ជូនទៅមណ្ឌលចត្តាឡីស័ក។

គោលដៅទី៣ កម្លាំងកងអនុសេនាធំល្បាតទី៣ ដឹកនាំដោយវរសេនីយ៍ត្រី កែវ សារី មេបញ្ជាការកងអនុសេនាធំល្បាតទី៣ សហការជាមួយកម្លាំងចម្រុះ ឃាត់ខ្លួនបានពលករចំនួន ៤នាក់ ស្រី ៣នាក់ ដែលបម្រុងឆ្លងដែនចូលទៅប្រទេសថៃ នៅវេលាម៉ោង ១៣:០០នាទី ស្ថិតនៅក្នុងភូមិសាស្ត្រ ភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ អង្គភាពបានប្រគល់អោយទៅក្រុមការងារចម្រុះច្រកអូរបីជាន់ដើម្បីបញ្ជូនទៅមណ្ឌលចត្តាឡីស័ក។

ដោយមានបទបញ្ជាពីលោកឧត្តមសេនីយ៍ត្រី យួន ជឿន មេបញ្ជាការកងការពារព្រំដែនលេខ៥០៣ ពង្រឹងការល្បាត តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងចម្រុះ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍ និងតំបន់ផ្សេងទៀត។

សូមបញ្ជាក់ថា ខណៈកងកម្លាំងចម្រុះល្បាត ក៏បានជួប ពលករបម្រុងលួចឆ្លងដែន ត្រូវបានកងកម្លាំង កងការពារព្រំដែនលេខ៥០៣ ឃាត់ខ្លួនបានតែម្តង ក្រោយពីឃាត់ខ្លួន ក៏បានណែនាំដល់បងប្អូនប្រជាពលរដ្ឋ កុំឲ្យបន្តចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះបញ្ចូល នាំពលករឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុខសុវត្ថិភាព និងខាតបង់ប្រាក់ជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣ការពារ ៣កុំ អោយបានទាំងអស់គ្នា ដើម្បីគ្រួសារ និងសង្គមជាតិ៕ រក្សាសិទ្ធិដោយ ៖ បញ្ញាស័ក្តិ

## មេខ្យល់ស្រីម្នាក់ ត្រូវឃាត់ខ្លួនតាមបទបញ្ជា ពីបទជូនមនុស្សទៅរកការងារធ្វើ នៅប្រទេសថៃ ដោយខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃចន្ទ ៤ តុលា ២០២១ដោយ Sorn Phanith

ស្ត្រីជាមេខ្យល់ម្នាក់ ត្រូវឃាត់ខ្លួនតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ពីបទជូនមនុស្សទៅរកការងារធ្វើនៅប្រទេសថៃ ដោយខុសច្បាប់នៅវេលាម៉ោង១២ព្រឹក ថ្ងៃទី៣ ខែតុលា ឆ្នាំ២០២១។

លោកវរសេនីយ៍ទោ ស៊ុន សារឿន នាយរងការិយាល័យ ប្រឆាំងការជួញដូរ និងមនុស្សការពារអនីតិជនបានឲ្យដឹងថា មេខ្យល់ដែលត្រូវឃាត់ខ្លួនមាន ឈ្មោះ វ៉ែន ឡឿង ភេទស្រី អាយុ៥៣ឆ្នាំ នៅភូមិក្ដិបថ្ម ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ លោកវរសេនីយ៍ទោ ស៊ុន សារឿន បានបញ្ជាក់ប្រាប់ឲ្យដឹងបន្តទៀតថា មុនឈានដល់ឃាត់ខ្លួនមេខ្យល់នោះ កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំគោករមៀតចុះល្បាតបានប្រទះឃើញពលករខ្មែរប្រុសស្រី ចំនួន៩នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃ ទៅរកការងារដោយខុសច្បាប់ កម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំគោករមៀត ឃាត់ខ្លួន ហើយនាំមកសាកសួរ នៅប៉ុស្តិ៍រដ្ឋបាលឃុំគោករមៀត។

នៅចំពោះមុខសមត្ថកិច្ចមេខ្យល់ឈ្មោះ វ៉ែន ឡឿង បានសារភាពថា ខ្លួនបានស៊ីឈ្នួលឲ្យថៅកែថៃ រកពលករទៅធ្វើការនៅប្រទេសថៃ ដោយក្នុងម្នាក់ថៅកែថៃឲ្យឈ្នួល៥០០បាត។ ដោយផ្អែកលើចម្លើយសារភាព និងការបំភ្លឺពីពលករខ្មែរទាំង៩នាក់។ ជនសង្ស័យត្រូវបានកម្លាំងនគរបាលការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រៀបចំសំណុំរឿងបញ្ជូនខ្លួនទៅស្នងការនគរបាលខេត្តបន្ទាយមានជ័យ ក្នុងនោះឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ បញ្ជាឲ្យបញ្ជូនមេខ្យល់ទៅសាលាដំបូងខេត្តនៅព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១ ដាក់ទោសទៅតាមច្បាប់ហើយ។ ចំណែកពលករខ្មែរទាំង៩នាក់ ក្រោយពីធ្វើកិច្ចសន្យាហើយសមត្ថកិច្ច បានឲ្យវិលត្រឡប់ទៅលំនៅឋានវិញផងដែរ៕ **អត្ថបទ៖ វ៉ាន់ ណាង**

## ឃុំខ្លួនមេខ្យល់០២នាក់ ពាក់ព័ន្ធការរត់ពន្ធមនុស្សជិត១០០នាក់ ទៅធ្វើការខុសច្បាប់នៅថៃ!!!!

https://cen.com.kh/ Posted ByPen Srey NeatOctober 4, 2021

ខេត្តបន្ទាយមានជ័យ ៖ ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែ តុលា ឆ្នាំ ២០២១ នេះ បានបង្គាប់ឲ្យឃុំខ្លួន បុរស០២ នាក់ ដែលសង្ស័យជាមេខ្យល់ជួញដូរមនុស្ស ជាប់ពាក់ព័ន្ធនឹងការនាំមនុស្សជិត១០០នាក់ លួចឆ្លងដែនទៅធ្វើការ ដោយខុសច្បាប់ នៅក្នុងប្រទេសថៃ ជាថ្នូរនឹងការទទួលប្រាក់ចំនួន៥,០០០បាត ក្នុងម្នាក់ៗ ពីពួកគេ។

មន្ត្រីនកងរាជអាវុធហត្ថ ប្រឆាំងការជួញដូរមនុស្សខេត្ត បានឲ្យដឹងថា ជនត្រូវចោទទាំង០២នាក់ ខាងលើនេះ មាន ទី ១-ឈ្មោះ វ៉ែន រឿន ភេទប្រុស អាយុ៥៦ឆ្នាំរស់នៅភូមិសាមគ្គីមានជ័យ សង្កាត់, ក្រុងប៉ោយប៉ែត, ខេត្តបន្ទាយមានជ័យ។ និង ទី ២ ឈ្មោះ យ៉ុង វិរៈ ភេទប្រុស អាយុ៣៥ឆ្នាំ ស់នៅភូមិចំការគរ, ឃុំស្វាយចេក ស្រុកស្វាយចេក, ខេត្តបន្ទាយមានជ័យ ។ ពួកគេត្រូវបានតំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ចោទប្រកាន់ពីបទៈ ការនាំចេញឆ្លងដែន ដោយមិនស្របច្បាប់ ដែលអាចប្រឈមនឹងការជាប់ពន្ធនាគារ ក្នុងម្នាក់ៗ ពី ០៥ ទៅ ០៧ ឆ្នាំ ប្រសិនបើ តុលាការរកឃើញ ពិរុទ្ធភាព។ ពួកគេត្រូវបាន ចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០២១ បន្ទាប់ពីបាននាំមនុស្ស ជិត១០០នាក់ តាមច្រករបៀង ទៅធ្វើការ ដោយខុសច្បាប់ នៅក្នុងប្រទេសថៃ៕ ចន្ទា ភា

## ជិត ២ ខែ មានពលករជិត ៩ ០០០ នាក់ បានវិលមកស្រុកកំណើតវិញតាមច្រកខេត្តឧត្តរមានជ័យ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 04 October 2021 | 12:46 ICT

**ឧត្តរមានជ័យៈ** ក្នុងរយៈពេលជិត ២ ខែ មានពលករខ្មែរជិត ៩ ពាន់នាក់ បានវិលត្រឡប់ចូលស្រុកកំណើតវិញតាមច្រកព្រំដែនខេត្តឧត្តរមានជ័យ បន្ទាប់ពីរាជរដ្ឋាភិបាលបានបើកច្រកព្រំដែនខេត្តឡើងវិញកាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០២១។

យោងតាមរបាយការណ៍ប្រចាំថ្ងៃ ស្តីពីចំនួនពលករចំណាកស្រុកមកពីប្រទេសថៃ តាមច្រកអន្តរជាតខេត្តឧត្តរមានជ័យបានឱ្យដឹងថា ក្នុងរយៈពេលជិត ២ ខែមកនេះ ដោយគិតចាប់ពីថ្ងៃទី ១៣ ខែសីហា ដល់ថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០២១ មានពលករខ្មែរសរុបចំនួន ៨ ៨១១ នាក់ បានត្រឡប់ចូលស្រុកកំណើតវិញ។ របាយការណ៍បន្តថា ក្នុងចំណោមពលករជិត ៩ ពាន់នាក់នោះ ក្នុងនោះមានវិជ្ជមានកូវីដ ១៩ សរុបចំនួន ៨៨៦នាក់។ ក្នុងរបាយការណ៍ដដែលបានបញ្ជាក់ថា ក្នុងរយៈពេលមួយខែចុងក្រោយនេះពោលក្នុងខែកញ្ញា ពលករដែលវិលចូលស្រុកកំណើតវិញមានការថយចុះ ដោយគិតជាមធ្យមក្នុង ១ ថ្ងៃ មានពលករចន្លោះពី ៥០ ទៅ ១០០នាក់ប៉ុណ្ណោះ។ ប៉ុន្តែក្នុងអំឡុងពេលបើកច្រកព្រំដែនឡើងវិញ នៅប៉ុន្មានថ្ងៃដំបូងក្នុងខែសីហា មានពលករវិលចូលស្រុកវិញប្រមាណ ២០០ ទៅ ៤០០ នាក់ឯណោះ។

អ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យលោក ផល លឹម បានឱ្យដឹងថា មូលហេតុដែលពលករនៅបន្តវិលចូលស្រុកវិញ គឺដោយសារស្ថានភាពកូវីដ ១៩ នៅប្រទេសថៃ មិនទាន់ធូរស្រាលនៅឡើយ ខណៈក្រុមហ៊ុន និងការដ្ឋានមួយចំនួននៅបន្តផ្អាកដំណើរការបណ្តោះអាសន្ន។ លោកបន្តទៀតថាមួយវិញទៀត ពលករទាំងនោះត្រឡប់ពីថៃចូលខ្មែរវិញ ក៏ដោយសារដើម្បីជួបជុំក្រុមគ្រួសារក្នុងអំឡុងពេលបុណ្យភ្ជុំបិណ្ឌផងដែរ៕

## ឃាត់ខ្លួនមេខ្យល់បញ្ជូនទៅតុលាការ ក្រោយគេចខ្លួនបានប៉ុន្មានថ្ងៃ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ៤ តុលា ២០២១ដោយ Sorn Phanith

នៅរយៈពេលប៉ុន្មានថ្ងៃមុននេះ កម្លាំងសមត្ថកិច្ច បានឃាត់ពលករចំនួន៨នាក់ នៅក្បែរមាត់អូរព្រំដែន ក្នុងស្រុកសំពៅលូន ខេត្តបាត់ដំបង ដែលបម្រុងឆ្លងដែនចូលទឹកដីថៃ ដោយគ្មានច្បាប់អនុញ្ញាត ព្រមទាំងបានអប់រំ និងធ្វើកិច្ចសន្យាឲ្យត្រឡប់ទៅផ្ទះវិញ ដោយឡែកមេខ្យល់បានរត់គេចខ្លួនបាត់ស្រមោល។

ក្រោមការដឹកនាំចង្អុលបង្ហាញពីលោក ឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការខេត្តបាត់ដំបង បានដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ រាល់ការទប់ស្កាត់បទល្មើសឆ្លងដែន ពិសេសមេខ្យល់នាំមនុស្សចេញចូលដោយខុសច្បាប់ ទើបលោកវរសេនីយ៍ទោ ទឹម រិធ័យ អធិការនគរបាលស្រុកសំពៅលូនបានដឹកនាំកម្លាំងជំនាញ ចុះធ្វើការស្រាវជ្រាវបង្ក្រាបមេខ្យល់នាំមនុស្សឆ្លងដែនចូលទៅប្រទេសថៃខុសច្បាប់ និងធ្វើការឃាត់បានខ្លួនជនសង្ស័យចំនួនម្នាក់។ សមត្ថកិច្ចបានឲ្យដឹងថា ជនសង្ស័យមាន ឈ្មោះ ហង្ស គឹមឈួន ភេទប្រុស អាយុ៣០ ឆ្នាំ មានទីលំនៅភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង សមត្ថកិច្ចបានបញ្ជាក់បន្ថែមថា ជនសង្ស័យខាងលើ បានធ្វើសកម្មភាពទាក់ទងពលករខ្មែរ ចំនួន០៨ នាក់ ស្រី ចំនួន០១ នាក់ (ក្នុងនោះក្មេង ចំនួន០២ នាក់ ) បម្រុងឆ្លងអូរព្រំដែនកម្ពុជា-ថៃ ចូលទៅក្នុងប្រទេសថៃ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៦:៣០នាទី ដោយទទួលបានកម្រៃម្នាក់ ៥០០ បាត។ បច្ចុប្បន្ន សមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនទៅការិយាល័យជំនាញដើម្បីចាត់ការតាមនីតិវិធីបន្ត៕ **អត្ថបទ៖ សោ និយមរ័ត្ន**

## ពលករខ្មែរ ១៧នាក់-កុមារម្នាក់ មកដល់កម្ពុជាក្រោយអន្តរាគមន៍

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១

(ភ្នំពេញ)៖ នៅថ្ងៃទី ៤ខែតុលា ឆ្នាំ ២០២១ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ បានអន្តរាគមន៍សម្របសម្រួលបញ្ជូនពលករខ្មែរចំនួន១៧នាក់ និងកុមារម្នាក់ ដែលមកពីតំបន់នានាក្នុងប្រទេសថៃឲ្យវិលត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើការតាមនីតិវិធីសុខាភិបាល។ នេះបើយោងតាមប្រភព ពីក្រសួងការបរទេសកម្ពុជា៕

## តុលាការខេត្តបន្ទាយមានជ័យសម្រេចឃុំខ្លួនស្ត្រីម្នាក់ ករណីនាំពលករខ្មែរឆ្លងដែនទៅប្រទេសថៃ

https://www.postkhmer.com/ គឹម សារុំ | Publication date 04 October 2021 | 16:34 ICT

តុលាការខេត្តបន្ទាយមានជ័យកាលពីថ្ងៃទី ៣ តុលា បានសម្រេចឃុំស្ត្រីម្នាក់នៅពន្ធនាគារខេត្ត ករណីនាំពលករប្រុសស្រី ៨ នាក់ បម្រុងឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់។

លោកស្រី ឌី សុជាតិ ស្នងការរងប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបានឱ្យដឹងនៅរសៀលថ្ងៃទី ៤ តុលានេះថា ស្ត្រីឈ្មោះ រ៉េន ឌឿន អាយុ ៥៣ ឆ្នាំ ត្រូវបានចៅក្រមស៊ើបសួរចេញដីកាឃុំខ្លួនបណ្ដោះអាសន្នក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ៣ តុលា។ លោកស្រីថា៖ «ករណីស្ត្រីម្នាក់នេះត្រូវតុលាការឃុំគាត់ពីម្សិលមិញ (ថ្ងៃទី ៣ តុលា)។ សមត្ថកិច្ចឃាត់គាត់នៅស្រុកថ្មពួក»។ លោកស្រី សុជាតិ រំឭកប្រាប់ថា កាលពីវេលាម៉ោងជាង ១១ ព្រឹក ថ្ងៃទី ២ តុលា កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំគោករមៀត ស្រុកថ្មពួក បានឃើញពលករខ្មែរប្រុសស្រីចំនួន ៨ នាក់ ជាមួយស្ត្រីត្រូវចោទបម្រុងនាំពលករលួចឆ្លងដែនទៅប្រទេសថៃ។ នៅពេលនោះសមត្ថកិច្ចបានឃាត់ពួកគេបញ្ជូនទៅអធិការដ្ឋាននគរបាលស្រុកថ្មពួកតែម្ដង។

លោកស្រីបន្តថា ចំពោះពលករប្រុសស្រីទាំង ៨ នាក់នោះ ត្រូវបាននគរបាលស្រុកថ្មពួកបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័កមុននឹងអនុញ្ញាតឱ្យពួកគេត្រឡប់ទៅលំនៅឋានវិញ។ រីឯស្ត្រីជាមេខ្យល់ខាងលើត្រូវបានឃាត់ខ្លួន។ ស្ត្រីជាមេខ្យល់ម្នាក់នេះបានសារភាពថា គាត់ត្រូវថៅកែថៃជួលគាត់ឱ្យរកពលករទៅធ្វើការនៅប្រទេសថៃ។ ដោយថៅកែនោះសន្យាឱ្យឈ្នួលក្នុងមនុស្សម្នាក់ ៥០០ បាត៕

## ២គោលដៅឃាត់ខ្លួនពលករបាន១២នាក់ បម្រុងលួចឆ្លងដែនខុសច្បាប់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៥ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ១៤:២១

បន្ទាយមានជ័យ ៖ ពលករចំនួន១២នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ត្រូវបានកម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៣, ៥១៤ សហការជាមួយកម្លាំងចម្រុះ ឃាត់ខ្លួនបាននៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១ ខណៈពេលដែលពួកគេបម្រុងលួចឆ្លងដែនដោយខុសច្បាប់ កម្លាំងដើរល្បាតពួនស្ទាក់ចាប់បានចំនួន២គោលដៅ សរុបចំនួន១២នាក់ ស្រីចំនួន៥នាក់។ នេះបើយោងតាមផេកកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទបានបង្ហោះ។

គោលដៅទី១ ពលករចំនួន៦នាក់ ស្រី២នាក់ ដែលបម្រុងឆ្លងដែនចូលទៅប្រទេសថៃ នៅវេលាម៉ោង០៣:៥០នាទីជិតភ្លឺ ពួកគាត់ក៏បានវង្វេងផ្លូវ រួចក៏បានចូលមកសារភាពជាមួយកម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៣ ដែលស្ថិតនៅក្នុងភូមិសាស្រ្ត ភូមិទំនប់ដាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ អង្គភាពបានប្រគល់អោយនគរបាលព្រំដែនគោក ដើម្បីបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ។

គោលដៅទី២ កម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៤ សហការជាមួយកម្លាំងចម្រុះឃាត់ខ្លួនបានពលករចំនួន៦នាក់ ស្រី៣នាក់ ដែលបម្រុងឆ្លងដែនចូលទៅប្រទេសថៃ នៅវេលាម៉ោង០៣:៣៥នាទីជិតភ្លឺ ស្ថិតនៅក្នុងភូមិ

សាស្ត្រ ភូមិទំនប់ដាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ (នៅលើផ្លូវជាតិលេខ៥៨) អង្គភាពបានប្រគល់អោយទៅក្រុមការងារចម្រុះច្រកអូរបីជាន់ ដើម្បីបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ។

ដោយមានបទបញ្ជាពីលោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ ពង្រឹងការល្បាត តាមបន្ទាត់ព្រំដែន កម្ពុជា-ថៃ ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងចម្រុះ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍ និងតំបន់ផ្សេងទៀត ។

សូមបញ្ជាក់ថា ខណៈកងកម្លាំងចម្រុះល្បាត ក៏បានជួប ពលករបម្រុងលួចឆ្លងដែន ត្រូវបានកងកម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៣ និង៥១៤ ឃាត់ខ្លួនបានតែម្តង ក្រោយពីឃាត់ខ្លួនក៏បានណែនាំដល់បងប្អូនប្រជាពលរដ្ឋកុំឲ្យបន្តចាញ់បោកមេខ្យល់ដែលតែងតែបញ្ឆុះបញ្ចូល នាំពលករឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុខសុវត្ថិភាព និងខាតបង់ប្រាក់ជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣ការពារ ៣កុំ អោយបានទាំងអស់គ្នា ដើម្បីគ្រួសារ និងសង្គមជាតិ៕

# ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១

## ត្រឹមតែមួយយប់ មានពលករបម្រុងឆ្លងដែនខុសច្បាប់ ចំនួន ១៩នាក់ ត្រូវបានឃាត់ខ្លួន ដោយកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ

https://cen.com.kh/ Posted ByPen Srey NeatOctober 8, 2021

បន្ទាយមានជ័យ ៖ ពលករ ចំនួន ១៩នាក់ បម្រុងឆ្លងដែនទៅធ្វើការនៅប្រទេសថៃត្រូវបានឃាត់ខ្លួន ដោយកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដែលឃាត់បានក្នុងភូមិសាស្ត្រ ភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

លោក ឧត្តមសេនីយ៍ ត្រី ជឹម ប៊ុនអាន មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ ដល់កម្លាំងទាំងអស់ ល្បាតជាប់ជាប្រចាំ ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការល្អជាមួយកងកម្លាំងចម្រុះ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩។ ជាក់ស្តែង យប់ថ្ងៃទី៧ ឈានចូលថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ ឧត្តមសេនីយ៍ត្រី រិទ្ធ រ៉ម មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងខេត្ត ទទួលទិសម៉ាឡៃ ដឹកនាំកម្លាំង ចំនួន ១៥នាក់ ល្បាតសហការជាមួយ នគរបាលវរសេនាតូចព្រំដែនលេខ៨១៥ ក៏ជួបពលករ ចំនួន ១៩នាក់ បម្រុងឆ្លងដែនចេញទៅប្រទេសថៃ ត្រូវបានកម្លាំងល្បាតសហការឃាត់ខ្លួនបានតែម្តង។ ក្រោយឃាត់ខ្លួនបាន ពលករទាំង ១៩នាក់ បានណែនាំ និងសាកសួរដើម្បីរកអោយឃើញនូវអ្នកនាំផ្លូវ និងបញ្ជូនពលករទាំងអស់ទៅធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័ក ស្រុកម៉ាឡៃ។

សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំង តំបន់ប្រតិបត្តិការសឹករងខេត្ត ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការសហការជាមួយកម្លាំងចម្រុះ ទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ បានឃាត់ខ្លួនពលករឆ្លងដែនបញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួន បញ្ជូនទៅសមត្ថកិច្ចជំនាញចាត់វិធានការតាមផ្លូវច្បាប់។ សូមបងប្អូនប្រជាពលរដ្ឋ កុំចាញ់បោកមេខ្យល់ ដែលតែងតែបញ្ឆុះបញ្ចូល នាំពលករឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុខសុវត្ថិភាព និងខាតបង់ថវិកាជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣ការពារ ៣កុំ អោយបានទាំងអស់គ្នា ដើម្បីគ្រួសារនិងសង្គមជាតិ៕ រក្សាសិទ្ធិដោយ ៖ កូលាប

## កម្លាំងទាហានឈុតខ្មៅថៃ ស្ទាក់ឃាត់ខ្លួនពលករខ្មែរចំនួន ១១ នាក់ និងជនជាតិថៃម្នាក់ បម្រុងឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 08/10/2021

ប្រទេសថៃ ៖ កម្លាំងទាហានឈុតខ្មៅថៃ ស្ទាក់ឃាត់ខ្លួនពលករខ្មែរចំនួន ១១ នាក់ និងជនជាតិថៃម្នាក់ទៀត តាមគោលដៅចំនួន៣ ក្នុងស្រុកតែមួយ និងក្នុងថ្ងៃតែមួយ ខណៈដែលពួកគេខ្លះបម្រុងរកច្រកចេញមកកម្ពុជាវិញ និងខ្លះទៀតកំពុងលបឆ្លងដែនទៅរកការងារធ្វើដោយខុសច្បាប់នៅប្រទេសថៃ។ ការឃាត់ខ្លួននេះបានធ្វើឡើងនាថ្ងៃទី ៧ ខែតុលា ឆ្នាំ២០២១ ដោយកម្លាំងកងវរយលេខ ១២ សហការជាមួយតម្រួតការពារព្រំដែនថៃ ដែលកំពុងធ្វើការល្បាតតាមខ្សែបន្ទាត់ព្រំដែន ដើម្បីទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទ នៅក្នុងរដូវកាល ការរាតត្បាតនៃជំងឺកូវីដ-១៩ ដ៏ខ្លាំងក្លា ។

តាមប្រភពបានឲ្យដឹងថា នៅគោលដៅទី១ បន្ទាប់ពីមានការសង្ស័យកម្លាំងការពារព្រំដែនថៃបានឃាត់រថយន្តមួយគ្រឿង ដែលកំពុងបើកបរលើកំណាត់ផ្លូវលេខ ៣០៨៥ ហើយត្រួតពិនិត្យឃើញថា អ្នកបើកបររថយន្តនេះគឺជាជនជាតិថៃ ឯអ្នកជិះខាងក្នុងចំនួន ៣ នាក់ (ស្រី១) គឺជាពលករខ្មែរ ដែលត្រឡប់មកពីទីក្រុងបាងកក និងបម្រុងរថយន្តដឹកទៅទម្លាក់នៅក្នុងភូមិសាស្រ្ត ណាងច័ន្ទ ។

ចំណែកគោលដៅទី២ គឺកម្លាំងយោធាថៃ បានឃាត់ខ្លួនពលករខ្មែរ ចំនួន ៤ នាក់ (ស្រី១) នៅចំណុចច្រកទ្វារទី១ មុខផ្សារ ហ្លួលជិនកេត ក្នុងឃុំអារញ្ញប្រាថេត ដែលកំពុងរង់ចាំរករថយន្តបន្តដំណើរចូលទៅរកការងារធ្វើដោយខុសច្បាប់ នាទីក្រុងបាងកក។

ដោយឡែកគោលដៅទី៣ ត្រូវបានឃាត់ខ្លួនពលករខ្មែរ បន្ថែម ៤ នាក់ទៀត (ស្រី២) នៅក្នុងចម្ការអំពៅក្នុងភូមិប៉ារ៉ៃម៉េ ឃុំប៉ារ៉ៃ ស្រុកអារញ្ញប្រាថេត ដែលបានលបឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ ។ ប្រភពដដែលបានឲ្យដឹងទៀតថា បច្ចុប្បន្នពលករខ្មែរទាំង ១១ នាក់ ត្រូវបានកម្លាំងយោធាថៃបញ្ជូនទៅកាន់អធិការដ្ឋានតម្រួតស្រុកអារញ្ញប្រាថេត ដើម្បីសាកសួរតាមនីតិវិធី ៕

## ឃាត់ខ្លួនពលករបម្រុងឆ្លងដែនខុសច្បាប់ជាបន្តបន្ទាប់ចំនួន២៩នាក់

https://gntimes.com/news/ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១

បន្ទាយមានជ័យ៖ ពលករប្រមាណ ២៩នាក់ ដែលបម្រុងឆ្លងដែនទៅធ្វើការនៅប្រទេសថៃ ត្រូវបានឃាត់ខ្លួនដោយកម្លាំងតំបន់ប្រតិបត្តិការសឹករងខេត្ត ដែលឃាត់បានក្នុងភូមិសាស្រ្ត ភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

លោកឧត្តមសេនីយ៍ត្រី ជឹម ប៊ុនអាន មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ដល់កម្លាំងទាំងអស់ល្បាតជាប់ជាប្រចាំ ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការល្អជាមួយកងកម្លាំងចម្រុះ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍ ។ ជាក់ស្តែង យប់ថ្ងៃទី៧ឈានចូលថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ ឧត្តមសេនីយ៍ត្រី រិទ្ធ រ៉ម មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងខេត្ត ទទួលទិសម៉ាឡៃ ដឹកនាំកម្លាំង ១៥នាក់ ល្បាតសហការជាមួយនគរបាលការពារព្រំដែនគោកលេខ ៨១៥ ក៏ឃើញពលករបម្រុងឆ្លងដែនចេញទៅប្រទេសថៃ ត្រូវបានកម្លាំងល្បាតសហការណ៍ ឃាត់ខ្លួនជាបន្តបន្ទាប់បានចំនួន ២៩នាក់ ដែកបម្រុងឆ្លងដែនចេញទៅប្រទេសថៃ ត្រូវបានកម្លាំងល្បាតសហការណ៍ ឃាត់ខ្លួនបានតែម្តង ។ ក្រោយឃាត់ខ្លួនបាន ពលករទាំង ២៩នាក់ បានណែនាំ និងសាកសួរនាំដើម្បីរកមុខមេខ្យល់ នឹងបានបញ្ជូនពលករទាំងអស់ទៅធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័ក ស្រុកម៉ាឡៃ ។

សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំងតំបន់ប្រតិបត្តិការសឹករងខេត្ត ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការសហការជាមួយកម្លាំងចម្រុះ ទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺ កូវីដ-១៩ បានឃាត់ខ្លួនពលករឆ្លងដែនបញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួន បញ្ជូនទៅសមត្ថកិច្ចជំនាញចាត់វិធានការតាមផ្លូវច្បាប់ ។

លោកឧត្តមសេនីយ៍ត្រី ជឹម ប៊ុនអាន មេបញ្ជាការសឹករងខេត្ត ក៏បានធ្វើការអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ កុំចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះបញ្ចូល នាំពលករឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុខសុវត្ថិភាព និងខាតបង់ប្រាក់ជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣ការពារ ៣កុំ ឲ្យបានទាំងអស់គ្នា ដើម្បីគ្រួសារ និងសង្គមជាតិ ពិសេសរួមគ្នាប្រយុទ្ធប្រឆាំងនឹងជំងឺ កូវីដ-១៩ និងវីរុសប្រភេទបំប្លែកថ្មី ដែលតា (Delta) ចូលក្នុងសហគមន៍ ៕ ដោយៈ ចន្ទ្រា

## ឃាត់ខ្លួនមុខសញ្ញាជាមេខ្យល់ចំនួន០២នាក់ នាំប្រជាពលរដ្ឋឆ្លងដែនដោយខុសច្បាប់ ចូលទៅប្រទេសថៃ

https://cen.com.kh/ Posted ByPen Srey NeatOctober 8, 2021

បាត់ដំបង ៖ អនុវត្តតាមយោបល់ដឹកនាំរបស់ លោកឧត្តមសេនីយ៍ទោ សាត គីមសាន ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង លោកវរសេនីយ៍ទោ ទឹម រិធ័យ អធិការនបាលស្រុកសំពៅលូន ដឹកនាំកម្លាំងសហការជាមួយ កម្លាំងនគរបាលវរៈសេនាតូចការពារព្រំដែនគោកលេខ៨១៧ កម្លាំងផ្នែកសឹករងស្រុកសំពៅលូន និងកម្លាំងវរៈសេនាតូច៥៣៣ ប្រចាំការតាមបណ្តោយមាត់អូរព្រំដែនកម្ពុជា-ថៃ បង្ក្រាបករណីនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន (ចូលទៅប្រទេសថៃ) ចំនួន០១ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២១។ ក្នុងកិច្ចប្រតិបត្តិការនេះ ជនសង្ស័យជាមេខ្យល់ក្នុងករណីនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន (ចូលទៅប្រ ទេ សថៃ) ១.ឈ្មោះ ចាម តឹក ភេទប្រុស អាយុ ៣៨ឆ្នាំ មានទីលំនៅភូមិស្រឡៅជ្រុំ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង និង២.ឈ្មោះ នី វណ្ណៈ ហៅ ណាក់ ភេទប្រុស អាយុ៥០ឆ្នាំ មានទីលំនៅភូមិស្រឡៅជ្រុំ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង។

សូមជម្រាបជូនថា ករណីឃាត់ខ្លួនមុខសញ្ញាជាមេខ្យល់ទាំងពីរនាក់នេះ គឺបន្ទាប់ពីពួកគេបានធ្វើសកម្មភាពនាំប្រជាពលរដ្ឋលួចឆ្លងដែនដោយខុសច្បាប់ចូលទៅក្នុងប្រទេសថៃ នាចំណុចមាត់អូរព្រំដែនកម្ពុជា-ថៃ ជាប់ភូមិសាស្រ្តភូមិស្រឡៅជ្រុំ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៨នាក់ កាលពីយប់ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១។ ឆ្លងតាមរយៈការស្រាវជ្រាវទើបសមត្ថកិច្ចកំណត់មុខសញ្ញាបាន និងឈានដល់ការឃាត់ខ្លួនតែម្តង។

តាមចម្លើយសារភាពរបស់ជនសង្ស័យខាងលើ សមត្ថកិច្ចកំណត់បានមុខសញ្ញាជាមេខ្យល់មួយចំនួនផ្សេងទៀត ដែលកំពុងគេចខ្លួន ហើយសមត្ថកិច្ចនឹងចាត់វិធានការតាមនីតិវិធីនៅពេលក្រោយ។ នៅពេលនេះ សមត្ថកិច្ចនគរបាលស្រុកសំពៅលូន បានរៀបចំសំណុំរឿងបញ្ជូនមកការិយាល័យជំនាញ ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់៕ រក្សាសិទ្ធិដោយ ៖ កូលាប

## យោធាថៃ ឃាត់ខ្លួនពលករខ្មែរ ៧នាក់ ដែលឆ្លងដែនខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ៩ តុលា ២០២១ដោយ sopheak khoun

ពលករខ្មែរចំនួន ៧នាក់ ដែលបានលួចឆ្លងដែនដោយខុសច្បាប់ ចូលទៅក្នុងទឹកដីថៃ ដើម្បីរកការងារធ្វើ ត្រូវបានកម្លាំងទាហានឈុតខ្មៅថៃឃាត់ខ្លួន ប្រគល់ឲ្យភាគីកម្ពុជាវិញ។ ការឃាត់ខ្លួន ដោយកម្លាំងទាហានកងរយ

លេខ ៥៤៦នេះ បានធ្វើឡើងនៅវេលាម៉ោង ៥ព្រឹក ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ ត្រង់ចំណុចព្រៃឫស្សី ក្បែរអូរព្រំដែនថៃ-កម្ពុជា ក្នុងភូមិសាស្រ្ត ស្រុកពោងណាំរ៉ន ខេត្តច័ន្ទបុរី។

យោងតាមការផ្សាយ របស់គេហទំព័រក្នុងស្រុកថៃ បានបញ្ជាក់ថា ពលករខ្មែរទាំង ៧នាក់ គឺមានស្រី ៣ នាក់ និងក្មេងតូចម្នាក់ផង ដែលពួកគេបានឆ្លងផុត ចូលទៅក្នុងទឹកដីថៃទៅហើយ ដើម្បីបន្តដំណើរទៅខេត្តផ្សេងៗទៀត ក្នុងទិសដៅរកការងារធ្វើ។ ក្រោយពេលឃាត់ខ្លួន យោធាថៃបានឲ្យមន្រ្តីសុខាភិបាល ស្រុកពោងណាំរ៉ន ចុះមកពិនិត្យសុខភាពពួកគេទាំងអស់គ្នាជាមុន ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវី-១៩ ចូលក្នុងសហគមន៍។ នៅថ្ងៃដដែលនោះដែរ ភាគីថៃបានទំនាក់ទំនងមកកាន់យោធាកម្ពុជា នៃការិយាល័យទំនាក់ទំនងព្រំដែនថៃ-កម្ពុជា និងកម្លាំងប៉ូលិសព្រំដែនកម្ពុជា ប្រចាំស្រុកកំរៀង ឲ្យចូលទៅទទួលយកពលករទាំងអស់ ត្រឡប់មកកម្ពុជាវិញ ដើម្បីអប់រំ ឬក៏ដើម្បីធ្វើចត្តាឡីស័កនៅទីនោះ៕ អត្ថបទ៖ សោ និយមវត្ថ

## នគរបាលការពារព្រំដែនគោក និងកម្លាំងយោធា បង្ក្រាបមុខសញ្ញា២នាក់ នាំមនុស្សឆ្លងដែន ចូលទឹកដីថៃ

https://cen.com.kh/ Posted ByPen Srey NeatOctober 9, 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលរដ្ឋចេញ-ចូលខុសច្បាប់ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់ លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ ថ្ងៃព្រហស្បតិ៍ ទី៧ ខែតុលា ឆ្នាំ២០២១ បានចាត់តាំងកម្លាំងប៉ុស្តិ៍ព្រំដែនគីឡូ៩ សហការបង្ក្រាបមុខសញ្ញានាំមនុស្សឆ្លងដែន ដឹកនាំដោយ លោកអនុសេនីយ៍ឯក ភុន -ហ៊ាង (នាយប៉ុស្តិ៍ ) រួមនិងកម្លាំងផ្នែកស៊ើបការណ៍ ដឹកនាំដោយ លោកអនុសេនីយ៍ទោ សេង វ៉ើន (នាយផ្នែក) សហការជាមួយកម្លាំងយោធាវរសេនាតូច លេខ៥៣៣ ដឹកនាំដោយ លោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ), កម្លាំងយោធាផ្នែកសឹករងសំពៅលូន ដឹកនាំដោយ លោកអនុសេនីយ៍ត្រី ឡាក់ ឌី (មេបញ្ជាការរង កងអនុសេធំ) បានធ្វើសកម្មភាពបង្ក្រាបមុខសញ្ញានាំមនុស្សឆ្លងដែនចូលទឹកដីថៃ ត្រង់ចំណុចនៃភូមិសាស្រ្តភូមិស្រឡៅជ្រុំ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង បានចំនួន ០១នាក់ ឈ្មោះ ចាប ទឹក ភេទប្រុស អាយុ៣៨ឆ្នាំ មានទីលំនៅភូមិស្រឡៅជ្រុំ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង និងបក្សពួកម្នាក់ទៀត (រត់គេចខ្លួនបាត់)។ បន្ទាប់ពីបង្ក្រាបបាន កម្លាំងជំនាញបានសាកសួរកត់ឈ្មោះ និងអប់រំណែនាំ រួចកម្លាំងបានប្រគល់ទៅឲ្យអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដើម្បីអនុវត្តតាមនីតិវិធីបន្ត៕ រក្សាសិទ្ធិដោយ ៖ កូលាប

## នគរបាលការពារព្រំដែនគោក ទប់ស្កាត់ប្រជាពលរដ្ឋលបលួចឆ្លងដែន ចូលទៅក្នុងប្រទេសថៃ ដោយខុសច្បាប់ចំនួន ៥៨ នាក់

https://cen.com.kh/ Posted ByPen Srey NeatOctober 9, 2021

បាត់ដំបង ៖ នៅព្រឹកថ្ងៃទី ៩ ខែតុលា ឆ្នាំ ២០២១ វេលា ម៉ោង០៤ និង០០នាទីទៀបភ្លឺ អនុវត្តតាមយោបល់ដឹកនាំជាប់ជាប្រចាំ របស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង លោកវរ សេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៩ បានដឹកនាំកម្លាំងសហការជាមួយ កងកម្លាំងកងពលពលតូចថ្មើរជើងលេខ ៥៣ ដែលឈរជើងនៅក្នុងភូមិសាស្រ្ត ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង រួមជាមួយសមត្ថកិច្ចនៃព្រះរាជាណាចក្រថៃ ដែលស្ថិតក្នុងភូមិសាស្រ្តជាប់ព្រំប្រទល់គ្នា

បានបង្ក្រាបទប់ស្កាត់បានទាន់ពេលប្រជាពលរដ្ឋដែលលបលួចឆ្លងដែន ពីប្រទេសកម្ពុជាចូលទៅក្នុង ប្រទេសថៃដោយខុសច្បាប់បានចំនួន ៥៨នាក់ ក្នុងនោះមានស្ត្រីចំនួន ៣៦នាក់និងកុមារចំនួន០៥នាក់ផងដែរ។ នៅពេលបង្ក្រាបទប់ស្កាត់បានភ្លាមៗសមត្ថកិច្ចថៃ បានបញ្ជូនពួកគាត់ទាំងចំនួន៥៨នាក់នេះ ប្រគល់មកឱ្យសមត្ថកិច្ចរបស់កម្ពុជាវិញ នៅវេលាព្រឹកនេះ។ នៅពេលបន្ទាប់នេះសមត្ថកិច្ចពាក់ព័ន្ធកំពុងធ្វើការសាកសួរស្រាវជ្រាវដើម្បីស្វែងរកប្រភពមេខ្យល់ដែលដឹកនាំពួកគាត់លបលួចឆ្លងដែនចូលទៅក្នុងប្រទេសថៃ ដោយខុសច្បាប់ ដើម្បីអនុវត្តតាមច្បាប់បន្តទៀត៕ រក្សាសិទ្ធិដោយ ៖ កូលាប

# ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១

## ពលករខ្មែរ លួចឆ្លងដែន10នាក់ ត្រូវឃាត់ខ្លួនដោយកងកម្លាំងតំបន់ ប្រតិបត្តិការសឹក រង បន្ទាយមានជ័យ

https://dap-news.com/ ByTR110 Posted on October 10, 2021

បន្ទាយមានជ័យ៖ លោកឧត្តមសេនីយ៍ត្រី ជឹម ប៊ុនអាន មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករង បន្ទាយមានជ័យ បាន ដាក់បទបញ្ជាយ៉ាងតឹងរឹង ការពារនៅតាមបន្ទាត់ព្រំដែន ក្នុងការរឹតបន្តឹងសន្តិសុខព្រំដែន ទប់ស្កាត់ពលករលួចឆ្លងដែនជាពិសេស បានចាត់តាំងកម្លាំងចុះស៊ើបអង្កេត ស្វែងរកមុខសញ្ញាមេខ្យល់ ចាប់ខ្លួនបញ្ជូនឲ្យសមត្ថកិច្ច ជំនាញចាត់ការតាមផ្លូវច្បាប់។ ជាក់ស្តែង នាយប់ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២១ នៅចំណុច ភូមិប្រសាទត្បែង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មានពលករខ្មែរ ចំនួន ១០នាក់ ស្រី ចំនួន ២នាក់ ដែលបម្រុងលួចឆ្លងដែនចូលប្រទេសថៃ ត្រូវបានឃាត់ខ្លួនដោយកម្លាំង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដែលដឹកនាំដោយ លោក អនុសេនីយ៍ឯក ហេង រ៉ា មេក្រុមគោលដៅ ខណៈលោកដឹកនាំល្បាតក៏បានជួបនឹងពលករ ក៏ឃាត់ខ្លួនបានតែម្តង។

សូមបញ្ជាក់ថា ក្រោយពីឃាត់ខ្លួន លោក មេក្រុមគោលដៅបានណែនាំដល់បងប្អូនប្រជាពលរដ្ឋ កុំបន្តចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះបញ្ចូលនាំពលករឆ្លងដែនខុសច្បាប់ ដោយមិនគិតពីសុវត្ថិភាព និងខាតបង់ប្រាក់កាសជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣កុំ ៣ការពារ អោយបានទាំងអស់គ្នា និងបាន ប្រគល់ពួកគាត់អោយទៅកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាល ឃុំបន្ទាយឆ្មារ ដើម្បីសាកសួរនិងបញ្ជូនទៅធ្វើចត្តាឡីស័ក។ សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំង តំបន់ប្រតិបត្តិការសឹករងខេត្ត ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការ សហការជាមួយកម្លាំងចម្រុះទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ បានឃាត់ខ្លួនពលករឆ្លងដែនបញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួន បញ្ជូនទៅសមត្ថកិច្ចជំនាញចាត់វិធានការតាមផ្លូវច្បាប់៕

## ពលករខ្មែរ ៤០ នាក់ត្រូវទាហានថៃចាប់ខ្លួនពីបទឆ្លងដែនខុសច្បាប់

https://www.khmertimeskh.com/ Khmer Times October 10, 2021

កម្លាំងសន្តិសុខព្រំដែនថៃ បានឃាត់ខ្លួនជនជាតិខ្មែរចំនួន ៤០នាក់ ដែលបានឆ្លងដែនចូលប្រទេសថៃដើម្បីស្វែងរកការងារធ្វើនៅយប់ថ្ងៃសុក្រទី៨ ខែតុលា។ ពលរដ្ឋខ្មែរទាំង ៤០នាក់ ត្រូវបានចាប់ខ្លួននៅតំបន់ផ្សេងៗគ្នា នៃស្រុកអារញ្ញ ខេត្តស្រះកែវ ដែលជាចំណុចឆ្លងកាត់សម្រាប់អ្នកឆ្លងដែនខុសច្បាប់ឆ្លងដែន និងច្រកឆ្លងកាត់ព្រំដែនរួមៗ ពួកគេទាំង ៤០នាក់ ត្រូវបានធ្វើតេស្តរកមេរោគកូវីដ-១៩ ហើយត្រូវបានបញ្ជូនត្រឡប់មកប្រទេសវិញនៅថ្ងៃសៅរ៍ទី៩ ខែតុលា។

ប្រជាជនកម្ពុជាកាន់តែច្រើនឡើងៗ កំពុងព្យាយាមលួចឆ្លងដែនចូលទៅក្នុងប្រទេសថៃ ដើម្បីស្វែងរកការងារធ្វើ ឬចូលធ្វើការវិញបន្ទាប់ពីវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងកំឡុងពេលវិបត្តិកូវីដ-១៩ នៅទីនោះ។

## ពលករខ្មែរចំនួន៨នាក់ បម្រុងឆ្លងដែនត្រូវកម្លាំងសមត្ថកិច្ចចម្រុះឃាត់ខ្លួន

http://nokorwatnews.com/ 10-10-2021

ខេត្តបន្ទាយមានជ័យ៖ នៅក្នុងខែតុលា ឆ្នាំ២០២១នេះ គេមើលឃើញថាកងកម្លាំងសមត្ថកិច្ចចម្រុះនៅបន្តឃាត់ពលករខ្មែរឆ្លងដែនជាបន្តបន្ទាប់ជាក់ ស្តែងពលករខ្មែរចំនួន ៨នាក់ ក្នុងនោះស្រីចំនួន ៤នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំងកងការពារព្រំដែនលេខ៥០៣ សហការជាមួយវរសេនាតូចថ្មើរជើងលេខ៥១៤ និងនគរបាលព្រំដែនគោកលេខ៩១១ នៅវេលាម៉ោង០៦និង១៥០០នាទីព្រឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ ស្ថិតនៅក្នុងភូមិសាស្ត្រ ភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ គ្រាដែលពួកគេបម្រុងដើរឆ្លងដែនក៏ត្រូវកម្លាំងចម្រុះឃាត់ខ្លួនតែងម្តង។ ការឃាត់ខ្លួនពលករខាងលើដឹកនាំកម្លាំងដោយលោកវរសេនីយ៍ត្រី យ៉ែម សំបូរ មេបញ្ជាការកងអនុសេនាធំល្បាតទី៥ សហការជាមួយកម្លាំងចម្រុះ ឃាត់ខ្លួនបានពលករ ចំនួន ៨នាក់ ស្រី ៤នាក់ ដែលបម្រុងឆ្លងដែនទៅប្រទេសថៃ ។

កម្លាំងសមត្ថកិច្ចចម្រុះពង្រឹងការល្បាត តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ ក្នុងដំណាក់កាលការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍ ។ ក្រោយពីឃាត់ខ្លួន ក៏បានណែនាំដល់បងប្អូនប្រជាពលរដ្ឋ កុំឲ្យបន្តចាញ់បោកមេខ្យល់ដែលតែងតែបញ្ចុះបញ្ចូល នាំពលករឆ្លងដែនដោយខុសច្បាប់ ដោយមិនគិតពីសុខសុវត្ថិភាព និងខាតបង់ប្រាក់ជាបន្តបន្ទាប់ និងសូមបន្តចូលរួមអនុវត្តវិធានការ ៣ការពារ ៣កុំ ឱ្យបានទាំងអស់គ្នា ដើម្បីគ្រួសារ និងសង្គមជាតិ៕

ពលករខាងលើបន្ទាប់ពីឃាត់ខ្លួន បានប្រគល់ឱ្យទៅក្រុមការងារចម្រុះនៅច្រកអូរបីជាន់ ដើម្បីបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ៕

## ពលករខ្មែរមកពីថៃ និងថៃចាប់បញ្ជូនតាមច្រកអូរបីជាន់និងបឹងត្រកួន១ថ្ងៃមាន៨៨នាក់ វិជ្ជមានកូវីដ ៥នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ១១ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ០៩:២៩

បន្ទាយមានជ័យ ៖ ពលករខ្មែរត្រឡប់ពីប្រទេសថៃ និងថៃចាប់បញ្ជូនតាមច្រកអូរបីជាន់ និងបឹងត្រកួន១ថ្ងៃមានចំនួន៨៨នាក់ វិជ្ជមានកូវីដ.១៩ ចំនួន៥នាក់ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ ភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ។

លោក វ៉ាន់ ដារ៉ាន់ ប្រធានច្រកតំបន់ព្រំដែនបឹងត្រកួនបានប្រាប់ថា ៖នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១នេះ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ និងភាគីថៃ ចាប់បញ្ជូនដែលក្រុមការងារទទួលមានចំនួន៣៥នាក់ ស្រី១៤នាក់ រកឃើញអ្នកវិជ្ជមានកូវីដ.១៩ ចំនួន៣នាក់ ស្រី២នាក់ និងអ្នកបើកបររថយន្តជាជនជាតិថៃចូលមកកម្ពុជាមានចំនួន៣៩នាក់ រកឃើញវិជ្ជមានកូវីដ.១៩ចំនួន១នាក់ ។

មន្ត្រីក្រុមការងារច្រកអូរបីជាន់ ស្រុកអូរជ្រៅ បានបញ្ជាក់ថា ៖ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១នេះ មានប្រជាពលរដ្ឋខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជា និងភាគីថៃចាប់បញ្ជូនដែលក្រុមការងារទទួលមានចំនួន៥៣នាក់ ស្រី២៣នាក់ កុមារ៥នាក់ ស្រី២នាក់ និងរកឃើញវិជ្ជមានកូវីដ.១៩មានចំនួន២នាក់ ។

គួរបញ្ជាក់ថា ៖ ភូមិសាស្ត្រខេត្តបន្ទាយមានជ័យមានច្រកចំនួន២កន្លែង ដែលទទួលពលករខ្មែរត្រឡប់ពីប្រទេសថៃមានច្រកអូរជាន់ស្រុកអូរជ្រៅ និងច្រកបឹងត្រកួនស្រុកថ្មពួក ដាក់ស្តែង១ថ្ងៃក្រុមការងារទទួលបានចំនួន

៨៨នាក់ ស្រី៣៧នាក់ និងរកឃើញអ្នកវិជ្ជមានកូវីដ.១៩ចំនួន៥នាក់ ចំពោះអ្នកដែលវិជ្ជមានកូវីដ.១៩ ត្រូវបានបញ្ជូនទៅព្យាបាលមណ្ឌលកងរ៉ាក្រុងសិរីសោភ័ណ និងអវិជ្ជមានកូវីដ.១៩ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក ៕

## ពលករចំនួន២០នាក់បម្រុងលួចឆ្លងដែនខុសច្បាប់ចូលទៅប្រទេសថៃត្រូវបានកម្លាំងសមត្ថកិច្ចចម្រុះឃាត់ខ្លួន

http://nokorwatnews.com/ 11-10-2021

ខេត្តបន្ទាយមានជ័យ ៖ ពលករចំនួន២០ នាក់បម្រុងលួចឆ្លងដែនដោយខុសច្បាប់ចូលទៅប្រទេសថៃ ត្រូវបានកម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៣ សហការជាមួយកម្លាំងចម្រុះធ្វើការឃាត់ខ្លួននៅយប់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ នៅចំណុចក្បាលទំនប់ ភូមិបន្ទាយពីរ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ យកមកសួរនាំ និងបានប្រគល់ជូនកម្លាំងជំនាញដើម្បីអនុវត្តទៅតាមច្បាប់។

សូមបញ្ជាក់ថា ដោយមានបទបញ្ជាពីលោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ ឱ្យពង្រឹងការល្បាតតាមបន្ទាត់ព្រំដែន កម្ពុជា-ថៃ ២៤ម៉ោងលើ២៤ម៉ោងដោយប្តូរវេនគ្នា សហការជាមួយកម្លាំងចម្រុះ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍ និងតំបន់ផ្សេងទៀត។ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ កុំឱ្យឆ្លងចូលទៅក្នុងសហគមន៍ កម្លាំងវរសេនាតូចថ្មើរជើងលេខ៥១១, ៥១៣ និង៥១៤ តែងតែយកចិត្តទុកដាក់អនុវត្តតាមបទបញ្ជាថ្នាក់លើទាំង៣ទិសក្នុងខេត្តបន្ទាយមានជ័យ ចាប់ពីទិសអូរនាង ប៉ោយប៉ែត និងទិសម៉ាឡៃ សហការជាមួយកម្លាំងនៅតាមមូលដ្ឋានចេញល្បាតឆែកឆេរត្រួតពិនិត្យជាប្រចាំក្នុងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់៕

## ឃាត់ខ្លួនជនជាតិថៃ ៧ នាក់ មកពីខេត្តមួយចំនួន ប្រុងឆ្លងដែនទៅធ្វើការនៅកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១១ តុលា ២០២១ដោយ Sorn Phanith

ជនជាតិថៃចំនួន ៧ នាក់ ដែលខំធ្វើដំណើរមកពីបណ្តាខេត្តមួយចំនួន ក្នុងប្រទេសថៃ ត្រូវកម្លាំងយោធាថៃក្នុងកងរយលេខ ១២ សហការជាមួយតម្រួតព្រំដែនលេខ ៤ ធ្វើការឃាត់ខ្លួន ខណៈដែលពួកគេកំពុងក្រាបក្នុងរថយន្ត ដើម្បីត្រៀមឆ្លងដែនចូលទៅធ្វើការនៅក្នុងប្រទេសកម្ពុជា។ ការឃាត់ខ្លួនជនជាតិថៃទាំង ៧ នាក់ នេះ គឺបានធ្វើឡើង នៅវេលាម៉ោង៣ និង ៣០ នាទី ទៀបភ្លឺ ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០២១ នៅពេលដែលកម្លាំងសមត្ថកិច្ចថៃកំពុងធ្វើការល្បាតតាមខ្សែបន្ទាត់ព្រំដែន ក៏បានប្រទះឃើញរថយន្តមួយគ្រឿង ម៉ាករ៉ូលេត ពណ៌ខ្មៅ ពាក់ស្លាកលេខបាងកក ៥៧១៨ ដែលបានចតស្ងៀម ត្រង់ចំណុចក្បែរបន្ទាត់ព្រំដែន ក្នុងឃុំគោកខ្សូង ស្រុកគោកខ្សូង ខេត្តស្រះកែវ (ដោយអ្នកបើកបររត់គេចខ្លួន)។

ក្រោយពីកម្លាំងចូលទៅពិនិត្យគឺឃើញមានជនជាតិថៃចំនួន ៧ នាក់ ស្រី៤នាក់ ដែលខ្លះអង្គុយក្នុងរថយន្ត និងខ្លះទៀតបានដេកក្រាបនៅក្នុងឃ្លុបខាងក្រោយរថយន្ត ។ ក្រោយពីកម្លាំងបានសាកសួររួចមក ជនជាតិថៃទាំងអស់ បានសារភាពថា ពួកគេទាំងអស់ គឺមកពីខេត្តស្រះកែវចំនួន ២ នាក់ ខេត្តណុនថៈបុរី ១ នាក់ ខេត្តខនកែន ១ នាក់ ខេត្តអ៊ូប៊ុនរ៉ាតថានី ១ នាក់ និងទីក្រុងបាងកក ចំនួន ២ នាក់ ដោយមានបំណងឆ្លងដែនទៅធ្វើការក្នុងកាស៊ីណូ អនឡាញ នាក្រុងប៉ោយប៉ែត ដោយនៅទីនោះឮថាបានប្រាក់ខែខ្ពស់ តែនៅពេលពួកគេមកដល់ក្បែរព្រំដែន តែក៏ត្រូវចាប់ខ្លួនតែម្តង ។

បច្ចុប្បន្នក្រោយពេលឃាត់ខ្លួន និងក្រោយពេលដែលក្រុមគ្រូពេទ្យបានពិនិត្យសុខភាពរួចមក ពួកគេទាំងអស់ ត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋានតម្រួត ស្រុកគោកខ្សូង ដើម្បីអនុវត្តតាមវិធានការច្បាប់៕ **សោ និយមរ័ត្ន**

# ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១

## សម្តេចក្រឡាហោម ស ខេង ណែនាំឱ្យអាជ្ញាធរខេត្តរតនគិរី បន្តប្រយុទ្ធប្រឆាំងបទល្មើសគ្រប់ប្រភេទ ជាពិសេស បទល្មើសរត់ពន្ធមនុស្ស និងគ្រឿងញៀន នៅតាមតំបន់ព្រំដែន

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១

(រតនគិរី)៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានមានប្រសាសន៍ណែនាំដល់អាជ្ញាធរខេត្តរតនគិរី ព្រមទាំងអ្នកពាក់ព័ន្ធ ត្រូវបន្តប្រយុទ្ធប្រឆាំងបទល្មើសរត់ពន្ធមនុស្ស គ្រឿងញៀន និងបទល្មើសផ្សេងៗទៀត ជាដើម នៅតាមតំបន់ព្រំដែន ឲ្យបានម៉ឺងម៉ាត់។ ពិសេស ត្រូវការពារឱ្យបានដាច់ខាតនូវបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយខេត្តជាប់ព្រំដែនដើម្បីជំរុញការអភិវឌ្ឍព្រំដែនឱ្យទៅជាព្រំដែនមានទាំងសន្តិភាព និងរីកចំរើនលើវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម។ ថ្លែងក្នុងឱកាសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីប្រកាសចូលកាន់មុខតំណែង អភិបាល នៃគណៈអភិបាលខេត្តរតនគិរី ថ្មី នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ នេះដែរ សម្តេចក្រឡាហោម ស ខេង ក៏បានកោតសរសើរចំពោះរដ្ឋបាលខេត្តរតនគិរីដែលរួមគ្នាខិតខំប្រឹងប្រែង ដើម្បីការពារសន្តិសុខ សន្តិភាព ស្ថេរភាពនយោបាយបានយ៉ាងល្អប្រសើរ។

សម្តេចក្រឡាហោម មានប្រសាសន៍ថា «បញ្ហាគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ព្រំដែន ជាកិច្ចជាប់ជាប្រចាំរបស់ខេត្តរតនគិរី ព្រោះជាប់ព្រំទល់ វៀតណាម និងឡាវ ហើយសំណូមពរសំខាន់បំផុត ត្រូវមានទំនាក់ទំនងជាមួយប្រទេសជិតខាង គឺការពារបូរណភាពទឹកដីឱ្យបាន និងការពារអធិបតេយ្យជាតិឱ្យបាន»។ សម្តេចក្រឡាហោម ក៏បានមានប្រសាសន៍បន្តទៀតថា ត្រូវអភិវឌ្ឍន៍ព្រំដែនដោយសន្តិភាព ដូចជា ៖ អភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ជាដើម ដើម្បីផលប្រយោជន៍ប្រទេសទាំងសង់ខាង ដូចជា ៖ កម្ពុជា-វៀតណាម-ឡាវ។ សម្តេច ក៏បានសង្កត់ធ្ងន់ផងដែរថា ជាពិសេស នោះ អាជ្ញាធរខេត្តរតនគិរី ក៏ត្រូវប្រឆាំងបទល្មើសផ្សេងៗទៀត ដូចជា ៖ រត់ពន្ធមនុស្ស គ្រឿងញៀន ជាដើម ដោយសហការជាមួយប្រទេសជិតខាង។

លើសពីនេះទៀត សម្តេចក្រឡាហោម បានបញ្ជាក់ថា ការគ្រប់គ្រងព្រំដែន និងការអភិវឌ្ឍន៍ព្រំដែន គឺត្រូវឈរលើគោលការណ៍សន្តិភាព ជាមួយការពង្រឹង និងពង្រីកក្នុងការសហប្រតិបត្តិការជាមួយប្រទេសជិតខាង។ ជាមួយគ្នានេះ សម្តេចក្រឡាហោម ក៏បានណែនាំដល់អាជ្ញាធរខេត្តរតនគិរី ត្រូវការពារធនធានធម្មជាតិឱ្យបានគង់វង្ស ដើម្បីទុកឱ្យកូនចៅជំនាន់ក្រោយ៕ ប្រភព៖ ក្រសួងមហាផ្ទៃ

## កម្លាំងប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ទទួលពលរដ្ឋ៣នាក់វិលត្រឡប់ពីប្រទេសថៃ

http://cambodiapolice.com/policekh/ 3:52 pm 11 តុលា 2021

ខេត្តបាត់ដំបង ៖ ប្រជាពលរដ្ឋខ្មែរ ចំនួន ០៣នាក់ ស្រី០១នាក់ ក្មេងស្រី០១នាក់ ដែលវិលត្រឡប់ មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រូវបានកម្លាំងកម្លាំងប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ទទួលនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ស្ថិតនៅត្រង់ចំណុចនៃភូមិគីឡូ១៣ ឃុំសន្តិភាព និងភូមិរស្មី ឃុំជ្រៃសីមា ក្នុងស្រុកសំពៅលូន ខេត្តបាត់ដំបង ។ ការទទួលពលរដ្ឋខ្មែរចំនួន៣នាក់នេះដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែន សហការ

ជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ មក ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០១នាក់ , ស្រី០នាក់ និងភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ បន្ទាប់ពីសាកសួរ,កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងបានប្រគល់បងប្អូនឲ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចិត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២៕

## ពលករខ្មែរ ជ្រៀតឆ្លងដែនខុសច្បាប់ ទៅថៃ ដើម្បីស្វែងរកការងារធ្វើ ត្រូវកងកម្លាំងកម្ពុជា និងថៃ ឃាត់ខ្លួន បន្តបន្ទាប់

https://www.rasmeinews.com/ OCT 11, 2021

**ដោយៈ ប,ជ័យ / ព្រំដែនកម្ពុជា-ថៃ:** *កងកម្លាំងកម្ពុជា និងថៃ បានស្ទាក់ឃាត់ខ្លួន បានជា បន្តបន្ទាប់ នូវពលករខ្មែរ ជ្រៀតឆ្លងដែនខុសច្បាប់ ទៅថៃ ដើម្បីស្វែងរកការងារធ្វើ ឡើងវិញ ក្នុងបំណងស្ដារជីវភាព ។*

លោកវរសេនីយ៍ទោ យូ សុគន្ធភក្តី មេបញ្ជាការ វរសេនាតូចថ្មើរជើង លេខ ៥១៣ នៃកងពលតូចថ្មើរជើងលេខ៥១ បានអោយដឹង កាលពីថ្ងៃទី១១ ខែតុលាថា: នៅយប់ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០២១ លោកបានចាត់តាំងកម្លាំង នៅជួរមុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា ថៃ នៅភូមិបន្ទាយពីរ ឃុំអូរសំព័រ ស្រុកម៉ាឡៃ សហការជាមួយកម្លាំងតំបន់ប្រតិបត្តិការសឹករង ខេត្តបន្ទាយមានជ័យ ចេញល្បាតត្រួតពិនិត្យ តាមបន្ទាត់ព្រំដែន ក៏បានប្រទះឃើញ ហើយឃាត់ខ្លួនពលករខ្មែរ បានចំនួន ២០នាក់ (ស្រីទាំងអស់) នៅត្រង់ចំណុចក្បាលទំនប់ ដែលបម្រុងនឹងលួចចូលទៅប្រទេសថៃ។ កម្លាំងសហការ បានឃាត់ខ្លួន រួចសាកសួរនាំ និងបានប្រគល់ជូនកម្លាំងជំនាញ ដើម្បីអនុវត្តទៅតាមច្បាប់។

ដោយឡែក នៅយប់ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២១ លោកអនុសេនីយ៍ឯក ហេង រ៉ា មេប្រចាំការគោលដៅសហការជាមួយ នគរបាលព្រំដែនជីគោក លេខ ៨០៧ថ្មពួក បានឃាត់ខ្លួន ប្រជាពលរដ្ឋ បម្រុងលួចឆ្លងដែនខុសច្បាប់ ទៅប្រទេសថៃ ចំនួន ១០ នាក់ (ស្រី២នាក់) ចេញតាមច្រកស្រែតាហម ស្ថិតក្នុងភូមិប្រាសាទត្បែង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ។

ករណីមួយទៀត តែទាក់ទិននឹងពលករខ្មែរដែរ កាលពីយប់ ថ្ងៃទី៨ ខែតុលា ទាហានឈុត ខ្មៅថៃ (ទាហានប្រាណកងតូច ទី១២ របស់ថៃ ប្រចាំស្រុកអារញ្ញប្រថេត បានចាប់ពលករ ខ្មែរ លួចឆ្លងដែនចូល- ចេញ ពីប្រទេសដោយខុសច្បាប់ នៅ ២ គោលដៅផ្សេងគ្នា បាន ៤០ នាក់ នៅព្រំដែនស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ។

សារព័ត៌មានថៃ រាយការណ៍ថា: នោះជាការរិតបន្តឹង បញ្ហាការលួចឆ្លងដែន ដោយខុសច្បាប់ នៅតាមបន្ទាត់ព្រំដែន កម្ពុជា-ថៃ ក្នុងអំឡុង នៃរាតត្បាតរបស់កូវីដ-១៩ ។ ក្នុងនោះដែរ កងកម្លាំងបូរផា (ឈុតប៉ារ៉ា) បានចេញល្បាត និងឃ្លាំមើល ក្នុងភូមិសាស្ត្រ ទទួលខុសត្រូវ បានប្រទះឃើញ និងចាប់ខ្លួនពលករខ្មែរ ២៨ នាក់ (ស្រី៩) និងក្មេង ២ នាក់ នៅពេលកំពុង លួចឆ្លងដែន ចូលប្រទេស ដោយខុសច្បាប់ ដើម្បីទៅធ្វើការ នៅប្រទេសថៃ នៅបរិវេណ ភូមិណូន ផាត់ថៈនា ឃុំផានសឹក ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ទើបឃុំខ្លួនយកទៅសាកសួរ និងចាត់ការតាមច្បាប់។

ជាមួយគ្នានេះដែរ កម្លាំងទាហានប្រាណទី១៣ ប្រចាំស្រុកខ្លងហាត ខេត្តស្រះកែវដែរ ក៏ចាប់ខ្លួនពលករខ្មែរ នៅពេលពួកគេ កំពុងលួចឆ្លងដែន តាមច្រករបៀង ដោយខុសច្បាប់ ដោយពួកគេសារភាព ជំហ៊ានដំបូងថា ត្រូវការធ្វើដំណើរត្រឡប់ ទៅប្រទេសកម្ពុជា ចំនួន ១២ នាក់ (ស្រី៣នាក់ និងក្មេងម្នាក់) បាននៅបរិវេណឃុំ ថាប់ព្រិក ស្រុកអារញ្ញ ខេត្តស្រះកែវ ទើបបញ្ជូនខ្លួន ទៅជំនាញ ស៊ើបសួរនៅស្រុកអារញ្ញ ដើម្បីចាត់ការ តាមច្បាប់បន្ត៕/V

# អាជ្ញាធរថៃចាប់បញ្ជូនពលករខ្មែរជិត៥០នាក់ត្រឡប់ទៅកម្ពុជាវិញ

https://www.rfa.org/khmer/news/ ដោយ ជាតិ ចំណាន2021-10-11

អាជ្ញាធរថៃបានចាប់បញ្ជូនពលករខ្មែរជិត ៥០នាក់ ត្រឡប់ទៅកម្ពុជាតាមច្រករបៀងព្រំដែនក្នុងខេត្តបន្ទាយមានជ័យនៅព្រឹកថ្ងៃទី១១ ខែតុលា។ ទន្ទឹមគ្នានេះមានពលករខ្មែរជាច្រើននាក់នៅតែបន្តឆ្លងដែនទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ដដែល។ មន្ត្រីសង្គមស៊ីវិល មើលឃើញថា ការឆ្លងដែនទៅប្រទេសថៃអំឡុងពេលនេះប្រឈមនឹងគ្រោះថ្នាក់ច្រើនជាងពេលមុនៗ។ អាជ្ញាធរថៃបានចាប់បញ្ជូនពលករខ្មែរចំនួន ៤៨នាក់ ប្រគល់ឱ្យអាជ្ញាធរកម្ពុជាតាមច្រករបៀងក្នុងខេត្តបន្ទាយមានជ័យនៅព្រឹកថ្ងៃទី១១ ខែតុលា។ ពលករទាំងនោះត្រូវបានអាជ្ញាធរខ្មែរបញ្ជូនទៅធ្វើចត្តាឡីស័កស្រុកអូរជ្រៅនិងទីរួមខេត្តអស់ហើយ ក្រោយពេលអាជ្ញាធរធ្វើតេស្តរកមេរោគជំងឺកូវីដ-១៩។

ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកការពារព្រំដែន លោក អ៊ុំ សុផល ប្រាប់វិទ្យុអាស៊ីសេរីថា ពលករខ្មែរដែលអាជ្ញាធរថៃបញ្ជូនមកកម្ពុជាទាំងនោះ គឺពួកគេឆ្លងដែនទៅធ្វើការងារនៅប្រទេសថៃដោយខុសច្បាប់។ ក្រៅអំពីពលករទាំងនេះ នៅមានពលរដ្ឋមួយចំនួនទៀត បន្តលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃជារៀងរាល់ថ្ងៃដដែល។ លោក អ៊ុំ សុផល បន្តថា ពលរដ្ឋទាំងនោះចាញ់បោកមេខ្យល់នាំឆ្លងដែនទៅប្រទេសថៃទាំងប្រថុយប្រថាន។ លោកបញ្ជាក់ថា មួយរយៈនេះយ៉ាងហោចណាស់មានពលរដ្ឋប្រមាណ១០នាក់ក្នុងមួយថ្ងៃ ត្រូវបានអាជ្ញាធរនៅតំបន់ព្រំដែនខេត្តបន្ទាយមានជ័យចាប់ខ្លួនក្នុងពេលពួកគេឆ្លងដែនចូលទៅប្រទេសថៃ៖ «រាល់ថ្ងៃថៃចាប់បញ្ជូនមកប្រហែលប៉ុណ្ណឹងឯង មួយថ្ងៃ៥០នាក់៦០នាក់។ គាត់លួចទៅថៃ ហើយអាជ្ញាធរតាមចាប់បានរហូតតែយើងបញ្ជូនទៅខេត្ត។អំឡុងពេលនេះប្រឈមជំងឺ កូវីដផង ហើយធ្វើដំណើរតាមផ្លូវវៃតឹងដែរមិនឱ្យចូលទេ»។ មេប៉ូលិសផ្កាយ១រូបនេះបន្ថែមទៀតថា អាជ្ញាធរខ្មែរនៅតែបន្តដាក់ពង្រាយកងកម្លាំងការពារតាមព្រំដែនទប់ស្កាត់ពលករឆ្លងដែនទៅប្រទេសថៃដដែល។

ជាមួយគ្នានេះ នៅរសៀលថ្ងៃទី១០ តុលា អាជ្ញាធរថៃបានចាប់ខ្លួនពលករខ្មែរចំនួន១៥នាក់ ក្នុងពេលដែលពួកគេលួចឆ្លងដែននៅស្រុកតាបផាក់យ៉ា(Taphaya) ខេត្តស្រះកែវ (Srakao) ជាប់ព្រំដែនខេត្តបន្ទាយមានជ័យ។ សារព័ត៌មានរបស់ថៃ ចុះផ្សាយនៅ១០តុលាឱ្យដឹងថា ពលករទាំងនោះមានទីលំនៅក្នុងខេត្តបន្ទាយមានជ័យទាំងអស់ ។ពួកគេបានឆ្លងដែនទៅប្រទេសថៃតាមរយៈមេខ្យល់ក្នុងតម្លៃពី៥ពាន់ទៅ៦ពាន់បាត ឬប្រមាណ១៩០ដុល្លារអាមេរិកក្នុងម្នាក់ ដើម្បីជាថ្នូរនាំទៅរកការងារធ្វើដោយខុសច្បាប់នៅខេត្តស្រះកែវ។ លោក អ៊ុំ សុផល ឱ្យដឹងថា ពលករទាំងនោះត្រូវបានអាជ្ញាធរថៃបញ្ជូនមកដល់កម្ពុជាវិញហើយ នៅថ្ងៃទី១១តុលា។

ទោះជាយ៉ាងណា មន្ត្រីអង្គការសង់ត្រាល់ ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា យល់ថា ពលករខ្មែរមិនគួរឆ្លងដែនទៅប្រទេសថៃអំឡុងពេលនេះនោះទេ ពីព្រោះការឆ្លងដែនបែបនេះប្រឈមនឹងអាជ្ញាធរថៃចាប់ខ្លួនដាក់ពន្ធនាគារ ឆ្លងជំងឺកូវីដ១៩ នឹងត្រូវទាហានថៃបាញ់បង្កគ្រោះថ្នាក់ដល់អាយុជីវិតជាដើម។ លោកបន្តថា មូលហេតុដែលពលរដ្ឋឆ្លងដែនទាំងប្រថុយប្រថានទៅប្រទេសថៃនេះ ដោយសារពួកគេមានជីវភាពក្រីក្រ ហើយជំពាក់បំណុលធនាគារ ស្របពេលដែលពួកគេអត់ការងារនៅក្នុងស្រុក៖ «ទី១គឺថៃមិនទាន់បើកច្រកឱ្យចេញចូលផ្លូវការបានទេ វាជាការល្មើសនូវបម្រាមរបស់ថៃ ដែលប្រឈមផ្នែកផ្លូវច្បាប់។ ទី២ពាក់ព័ន្ធឱកាសនៃការឆ្លងជំងឺកូវីដ១៩ ។ ទី៣ការចាញ់បោក ព្រោះការទៅធ្វើការនៅថៃនៅពេលនេះ គេមិនមែនទៅដល់ឱ្យយើងធ្វើភ្លាមទេ គេឱ្យយើងទៅធ្វើចត្តាឡីស័ក១៤ថ្ងៃអីណាណីអីចឹងទៀត ទម្រាំតែបានការងារធ្វើ។មែនៗទៅគឺប្រថុយខុសពីសព្វដងមានន័យថាប្រថុយខ្ពស់ខ្លាំងជាងមិនទាន់មានកើតជំងឺកូវីដ»។

របាយការណ៍អង្គការសង់ត្រាល់ ឲ្យដឹងថា ចាប់ពីខែមករា រហូតដល់ខែកក្កដា ឆ្នាំ២០២១ មានពលរដ្ឋខ្មែរជាង៧រយនាក់ (៧៤១) ត្រូវបានឃាត់ខ្លួន ពាក់ព័ន្ធនឹងការលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ

ក្នុងនោះមនុស្សជិត៨រយនាក់ (៧៦០) ត្រូវបានអាជ្ញាធរកម្ពុជានិងថៃចាប់ខ្លួន និងបញ្ជូនទៅចាត់ការតាមច្បាប់។ របាយការណ៍ដដែល រកឃើញថា មានពលរដ្ឋខ្មែររាប់ពាន់នាក់បានចាញ់បោកមេខ្យល់នាំឆ្លងដែនទៅធ្វើការនៅប្រទេសថៃ។ មន្ត្រីសង្គមស៊ីវិល លោក ឌី ថេហូយ៉ា ជឿថា ដើម្បីកុំឱ្យពលរដ្ឋឆ្លងខុសច្បាប់អំឡុងពេលនេះ គឺរដ្ឋាភិបាលគួរតែបង្កើតការងារក្នុងស្រុកឱ្យបានច្រើនសម្រាប់ឱ្យពលរដ្ឋ និងជួយរកទីផ្សារលក់កសិផលមានតម្លៃសមរម្យជូនដល់ពលរដ្ឋ ដើម្បីពួកគាត់អាចដាំដុះលក់រកប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារ។ លោកថា ប្រសិនបើរដ្ឋាភិបាលនៅតែមិនដោះស្រាយបញ្ហានេះទៀត នឹងធ្វើឱ្យពលរដ្ឋក្រីក្រធ្វើចំណាកស្រុកកាន់តែច្រើនជាមិនខាន៕

## ពលករខ្មែរ៨នាក់ ស្នើសុំឲ្យស្ថានអគ្គកុងស៊ុលជួយបញ្ជូនពួកគាត់ត្រឡប់មកកម្ពុជាវិញ

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១២ តុលា ២០២១ដោយ Sokhom Khon

នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ មានពលករខ្មែរចំនួន០៨នាក់ (ស្រី០១នាក់) ដែលធ្វើដំណើរមកពីតាមបណ្ដាខេត្តនានា នៃប្រទេសថៃ បានមកដល់ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តសាកែវ ដើម្បីស្នើសុំឲ្យស្ថានអគ្គកុងស៊ុលជួយបញ្ជូនពួកគាត់ត្រឡប់មកកម្ពុជាវិញ ដោយសារមិនមានការងារធ្វើ និងចង់វិលត្រឡប់ទៅស្រុកកំណើតវិញ។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានបានឲ្យដឹងនារសៀលនេះថា ក្រោយពីមកដល់ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលបានស្រង់ឈ្មោះ ហើយបានស្នើសុំកិច្ចអន្តរាគមន៍ទៅមន្ត្រីនគរបាលអន្តោប្រវេសន៍ខេត្តសាកែវ និងអាជ្ញាធរកម្ពុជាប្រចាំច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ដើម្បីសម្របសម្រួល និងបញ្ជូនពលករខ្មែរខាងលើឲ្យវិលត្រឡប់ទៅកម្ពុជាវិញ តាមច្រកព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត យកទៅប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល៕ អត្ថបទ៖ កោះកែវ

## ឃាត់ខ្លួនពលករខ្មែរ២០នាក់បម្រុងលួចឆ្លងដែនចូលប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១២ តុលា ២០២១ដោយ Sokhom Khon

ពលករខ្មែរប្រុសស្រីចំនួន២០នាក់ បម្រុងលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃត្រូវកម្លាំងចម្រុះឃាត់ខ្លួនបាននៅយប់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១។

វរសេនីយ៍ទោ យូ សុគន្ធភក្តី មេបញ្ជាការវរសេនាតូចថ្មើរជើងលេខ៥១៣បានប្រាប់ឲ្យដឹងថា ការឃាត់ខ្លួនពលករនេះ បានលោកបានដឹកនាំកម្លាំងនៅជួរមុខតាមខ្សែបន្ទាត់ព្រំដែនខ្មែរ-ថៃ នៅភូមិបន្ទាយពីរ ឃុំអូរសំព័រស្រុកម៉ាឡៃ ក្នុងនោះលោកបានសហការជាមួយកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ កម្លាំងចម្រុះចេញល្បាតត្រួតពិនិត្យតាមបន្ទាត់ព្រំដែនក៏បានប្រទះឃើញពលករខ្មែរស្រី ប្រុសចំនួន២០នាក់ នៅត្រង់ចំណុចក្បាលទំនប់ ដែលបម្រុងលួចឆ្លងដែនចូលទៅប្រទេសថៃ ក៏ត្រូវកម្លាំងចម្រុះធ្វើការឃាត់ខ្លួន រួចសួរនាំ និងបានប្រគលទៅឲ្យកម្លាំងជំនាញដើម្បីអនុវត្តទៅតាមច្បាប់បន្ត។

លោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ បានប្រាប់ឲ្យដឹងថា កម្លាំងចម្រុះធ្វើការល្បាតតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ២៤ម៉ោងលើ២៤ម៉ោង ដោយប្ដូរវេនគ្នាសហការជាមួយ កម្លាំងចម្រុះដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុង សហគមន៍ និងតំបន់ផ្សេងទៀត ។ លោកបានបញ្ជាក់ឲ្យដឹងទៀតថា ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ កុំឲ្យឆ្លងចូលជាសហគមន៍កម្លាំងវរសេនាតូចថ្មើរជើងលេខ៥១១និង៥១៣ និង៥១៤ តែងតែយកចិត្តទុកដាក់អនុវត្តតាមបទបញ្ជាថ្នាក់លើទាំង៣ទិសក្នុងខេត្តបន្ទាយមានជ័យ ចាប់ពីទិសអូរ

នាងប៉ោយប៉ែត និងទិសម៉ាឡៃ សហការជាមួយកម្លាំងនៅតាមមូលដ្ឋានចេញល្បាតឆែកឆេរត្រួតពិនិត្យ ជាប្រចាំក្នុងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ ។

លោកបានបញ្ជាក់ឲ្យដឹងបន្តទៀតថា ចំណែកពលករទាំង២០នាក់នោះត្រូវបានកម្លាំងចម្រុះប្រគល់ទៅឲ្យក្រុមគ្រូពេទ្យយកទៅធ្វើតេស្តរហ័ស និងបន្តយកទៅចត្តាឡីស័ក នៅមណ្ឌលព្យាបាលដើម្បីឲ្យបានគ្រប់ចំនួនដែលក្រុមគ្រូពេទ្យដាក់ឲ្យអនុវត្តទើបអាចឲ្យវិញត្រឡប់ទៅផ្ទះវិញបាន៕ អត្ថបទ៖ វ៉ាន់ ណាង

# ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១

## រាជរដ្ឋាភិបាល កំពុងប្រឹងប្រែងជួយសង្គ្រោះពលរដ្ឋ ២នាក់ ដែលចាញ់បោកមេខ្យល់នៅចិន មកកម្ពុជាវិញ

http://freshnewsasia.com/ 2021-10-13 01:46pm

**(ភ្នំពេញ)៖** រាជរដ្ឋាភិបាលកម្ពុជា កំពុងប្រឹងប្រែងជួយសង្គ្រោះប្រជាពលរដ្ឋ ២នាក់ ដែលពួកគាត់អះអាងថា ចាញ់បោកមេខ្យល់ទៅនៅប្រទេសចិន កាលពី ៥ឆ្នាំមុន ហើយត្រូវប្តីវាយធ្វើបាបយ៉ាងខ្លាំង។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស បានប្រាប់បណ្តាញព័ត៌មាន Fresh News នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ថា រាជរដ្ឋាភិបាលកម្ពុជា តែងតែគិតគូរជួយអន្តរាគមន៍គ្រប់បញ្ហាទាំងអស់ ឲ្យតែទទួលបានព័ត៌មាន។ លោកស្រីបានបញ្ជាក់យ៉ាងដូច្នេះថា៖ **«ក្នុងនាមជារាជរដ្ឋាភិបាល យើងពិតជានាំគ្នាដុតដៃដុតជើង ជួយពលរដ្ឋតែទន្ទឹមនឹងនោះ យើងចង់ការពារជនរងគ្រោះពិត ហើយក៏ត្រូវមានវិធានការដើម្បីទប់ស្កាត់ មិនឲ្យរងគ្រោះ ជាជាងការដែលចាំជួយនៅពេលរងគ្រោះរួចហើយ! យើងនឹងគិតទាំងអស់គ្នា។ ឥឡូវដោះស្រាយបញ្ហាចំពោះមុខសិន!»**។

ការដុតដៃដុតជើងអន្តរាគមន៍ពីរាជរដ្ឋាភិបាល បានធ្វើឡើងបន្ទាប់ពីស្រ្តី ២នាក់ ដែលអះអាងថា ខ្លួនជាជនរងគ្រោះផងនោះ អំពាវនាវទៅសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា តាមរយៈបណ្តាញសង្គម Tik Tok ជួយសង្គ្រោះនាងឱ្យបានមាតុភូមិនិវត្តន៍វិញ។ ក្នុងវីដេអូ ដែលបង្ហាញពីការទួញសោកលាយឡំនឹងទឹកភ្នែក ពួកគាត់អះអាងថា កំពុងស្ថិតនៅក្នុងគុក ហើយអត់មានអាហារហូបនោះទេ។

ជនរងគ្រោះទី១ មានឈ្មោះថា ឈឺន សុផៃ ទីកន្លែងកំណើតនៅភូមិកសិកម្ម ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ចំណែកឯជនរងគ្រោះទី២ មានឈ្មោះថា លីន សារ៉ែន ទីកន្លែងកំណើតភូមិម៉ាសែន ឃុំប៉ាហាល ស្រុកត្បែង ខេត្តព្រះវិហារ។ តាមរយៈបណ្តាញ Tik Tok ជនរងគ្រោះបានបញ្ជាក់យ៉ាងដូច្នេះថា៖ **«ជម្រាបសួរពុកម៉ែបងប្អូនទាំងអស់គ្នាខ្ញុំបានមកខ្លួននៅប្រទេសចិនអស់រយៈពេល ៥ ឆ្នាំហើយ។ ខ្ញុំបានចាញ់បោកមេខ្យល់ឡើងមក។ អញ្ចឹងខ្ញុំសុំឱ្យសម្តេច ប៊ុន រ៉ានី និងសម្តេច ហ៊ុន សែន ជួយយកខ្ញុំទៅខ្មែរផង។ នេះជាលេខទូរសព្ទខ្ញុំ 19979098645»**៕

## ប្រជាពលរដ្ឋដែលជាពលករខ្មែរជាង១០០នាក់មកពីបណ្តាខេត្តផ្សេងៗប្រុងឆ្លងដែនទៅប្រទេសថៃល្មើសច្បាប់ត្រូវសមត្ថកិច្ចឃាត់ខ្លួន

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១២ តុលា ២០២១ដោយ Kang Tola

បាត់ដំបង ៖ លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៩បានប្រាប់មុននេះបន្តិចថា ការឃាត់ខ្លួនពលកររហូតដល់១០០នាក់ខាងលើនេះ ដោយមានកិច្ចសហការគ្នាល្អរវាងកម្លាំងវរសេនាតូចការពារព្រំដែនគោកលេខ៨១៩ ជាមួយកម្លាំងនគរបាល នៃអធិការដ្ឋាននគរបាលស្រុកកំរៀង បានស្ទាក់

និងឃាត់ខ្លួនពលរដ្ឋជាពលករខ្មែរច្រើននាក់មិនធ្លាប់មានចាប់តាំងពីទៀបភ្លឺថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១មក។ ការឃាត់ខ្លួនពលករក្មេងចាស់ប្រុសស្រីទាំងអស់ សរុបចំនួន១៣០នាក់ ក្នុងនោះមានបុរសចំនួន៩៥នាក់ស្ត្រី ចំនួន៥២នាក់ និងកុមារតូចៗចំនួន១៣នាក់ផងដែរ។ ពួកគេទាំងអស់គ្នាបានលបលួចបម្រុងឆ្លងដែនចូលក្នុងទឹកដីថៃជាបន្តបន្ទាប់និងជាច្រើនគោលដៅនៅក្នុងភូមិសាស្ត្រភូមិអូរជាឃុំបឹងរាំងស្រុកកំរៀងខេត្តបាត់ដំបង។ លោកមេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៩បានបញ្ជាក់បន្តថា ពលករខ្មែរទាំង១៣០នាក់ ខាងលើ សុទ្ធសឹងជាប្រជាពលរដ្ឋដែលមកពីបណ្តាខេត្តនានាដូចជាខេត្តតាកែវខេត្តព្រៃវែងជាដើមក្នុងគោលបំណង ដើម្បីស្វែងរកការងារធ្វើទាំងប្រថុយប្រថានក្នុងពីស្ថានភាពប្រទេសជិតខាងកំពុងមានវិបត្តិកូវីដ-១៩។

បច្ចុប្បន្ននេះ នគរបាលការពារព្រំដែន៨១៩បានបញ្ជូនពលករទាំងអស់ប្រគល់ឲ្យកម្លាំងនគរបាលស្រុកកំរៀងដើម្បីសាកសួរបន្ថែមក៏ដូចជាបន្តស្វែងរកប្រភពមេខ្យល់ជាអ្នកដឹកនាំដើម្បីអនុវត្តតាមផ្លូវច្បាប់៕ *សៅ សារិទ្ធ*

## ពលករបេះផ្លែមៀននៅថៃត្រូវថៅកែបោះបង់ចោលក្រោយឆ្លងកូវីដ-១៩

https://www.rfa.org/khmer/news/ ដោយ មួង ណារ៉េត2021-10-12

ពលករខ្មែរបេះផ្លែមៀននៅប្រទេសថៃមានគ្នាជាង ៤០នាក់ ដែលបានឆ្លងជំងឺកូវីដ-១៩ ត្រូវបានថៅកែថៃដឹកមកទុកចោលនៅទីតាំងមួយកន្លែងដោយមិនបានផ្តល់ការព្យាបាលនោះទេ។ មន្ត្រីសង្គមស៊ីវិលជំរុញទៅស្ថានទូតខ្មែរប្រចាំប្រទេសថៃស្វែងរកពលករទាំងនេះដើម្បីជួយសម្របសម្រួលឲ្យបានព្យាបាលជំងឺ។ ពលករខ្មែរបេះផ្លែមៀននៅប្រទេសថៃ ដែលឆ្លងជំងឺកូវីដ-១៩ ត្អូញត្អែរថា ពួកគេត្រូវបានថៅកែយកទៅទុកចោលមិនផ្តល់ថ្នាំព្យាបាលអាហារហូបចុក និងកន្លែងរស់នៅសមរម្យនោះទេ។ ពលករបន្តថា ពួកគេមានគ្នាជិត ៥០នាក់ និងបានឆ្លងជំងឺកូវីដ-១៩ ជាបន្តបន្ទាប់ជាង ១០ថ្ងៃមកហើយ។

ពលករកំពុងឆ្លងជំងឺកូវីដ-១៩ ម្នាក់លោកស្រី ឈឿន ស្រី ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី១២ ខែតុលាថា លោកស្រីបានឆ្លងជំងឺកូវីដ-១៩ ពេលកំពុងបេះផ្លែមៀនក្នុងចម្ការមួយកន្លែងនៅខេត្តច័ន្ទបូរី (Chan Bori) ប្រទេសថៃ។ លោកស្រីបន្តថា ពេលថៅកែជនជាតិថៃដឹងថា ពលករឆ្លងជំងឺកូវីដ ថៅកែបានដឹកកម្មករទៅដាក់ចោលនៅលើដីមួយកន្លែង ហើយក៏មិនបានទាក់ទងមកក្រុមពលករនោះដែរ៖ «*អត់មានពេទ្យមានអីមកមើលផងបង គេ (ថៅកែ) យកមកថាមានពេទ្យមានថ្នាំដល់ពេលពួកខ្ញុំមកអត់មានឃើញពេទ្យមកផង*»។

ពលករម្នាក់ទៀតលោក នង ហេង ឲ្យដឹងដែរថា នៅកន្លែងនេះគ្មានទឹកភ្លើងប្រើប្រាស់គ្រប់គ្រាន់នោះទេ។ បន្ថែមពីនេះលោកថា ក្រុមពលករត្រូវរៃលុយគ្នាទិញបាយម្ហូបនិងទិញថ្នាំព្យាបាលដោយខ្លួនឯង៖ «*គេអត់មានផ្តល់ដំណឹងអីផង ដល់ឃើញមានជំងឺកូវីដ១៩ គេយកមកដាក់នៅហ្នឹងប៉ាដោយគេអត់មានផ្តល់ដំណឹងអីផង ទឹកចេញមកច្រូចៗពីរថ្ងៃហើយបានដូតទឹកម្តងហើយ ណាមួយអត់មានគ្រប់គ្រាន់ទឹកភ្លើងអត់មានគ្រប់គ្រាន់*»។

រីឯពលករឆ្លងជំងឺកូវីដ-១៩ ម្នាក់ទៀតលោកស្រី គន់ ហឿន ប្រាប់ថា គ្រួសារលោកស្រីឆ្លងជំងឺនេះទាំងប្តីនិងប្រពន្ធ។ លោកស្រីឲ្យដឹងទៀតថា ពេលនេះលោកស្រី កំពុងមានអាការៈធ្ងន់ធ្ងរដោយឡើងកម្តៅខ្លាំង ពិបាកដកដង្ហើម និងពិសារអាហារលែងបាន។ ពលការិនីរូបនេះ ស្នើទៅស្ថានទូតខ្មែរនៅប្រទេសថៃ និងរដ្ឋាភិបាលកម្ពុជាជួយអន្តរាគមន៍ដើម្បីឲ្យក្រុមពលករទាំងអស់ទទួលបានការព្យាបាលត្រឹមត្រូវពីក្រុមគ្រូពេទ្យ៖ «*ខ្ញុំធ្ងន់ជាងគេក្អកៗហើយហត់ក្តៅខ្លួនអត់ស្រួលជាងគេគេគ្រាន់តែផ្តាសាយ ខ្ញុំហូបអីអត់បានផងហ្នឹង*»។

ទាក់ទងបញ្ហានេះ វិទ្យុអាស៊ីសេរីបានព្យាយាមទាក់ទងសុំការបំភ្លឺពីមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកទទួលបន្ទុកពលករលោក គឹម ចំរើន និងអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ ប៉ុន្តែទូរស័ព្ទចូលគ្មានអ្នកទទួលនៅថ្ងៃទី១២ ខែតុលា។

ចំណែកអ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាលោក សុខ ឥសាន សុំមិនបកស្រាយបញ្ហានេះទេ លោកជំរុញឲ្យទៅសួរមន្ត្រីស្ថានទូតនិងក្រសួងពាក់ព័ន្ធ។ ទោះយ៉ាងណា អ្នកនាំពាក្យបក្សកាន់អំណាចរូបនេះយល់ថា ស្ថានទូតខ្មែរ គឺជាអ្នកទទួលបន្ទុកដោះស្រាយជូនពលករពេលដែលកើតមានបញ្ហាដូចនេះ៖ *«គេធ្វើតាមតួនាទីភារកិច្ចរបស់ស្ថានទូតតាមការណែនាំរបស់រដ្ឋាភិបាលក៏ដូចក្រសួងការបរទេសស្ថានទូតហ្នឹងជាតំណាងរាជរដ្ឋាភិបាលជួយគាំពារដល់ពលករខ្មែរយើងនៅក្រៅប្រទេស»។*

នេះមិនមែនជាលើកទី១ទេ ដែលពលករខ្មែរឆ្លងជំងឺកូវិដ១៩ មិនត្រូវបានថៅកែយកចិត្តទុកដាក់។ កន្លងទៅពលករខ្មែរជាច្រើននាក់ដែលឆ្លងជំងឺកូវីដ-១៩ ត្រូវរស់នៅវេទនាដោយគ្មានគ្រូពេទ្យព្យាបាលនិងស្នាក់នៅក្នុងតង់កៅស៊ូតាមយថាកម្ម។

ជុំវិញរឿងនេះមន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស(CENTRAL)លោក ឌីថេ ហូយ៉ា សង្កេតឃើញថា ចាប់តាំងពីមានការរាលត្បាតជំងឺកូវីដ-១៩ មកបញ្ហាបែបនេះកើតឡើងជាហូរហែ ដែលនេះជាការខ្វះការទទួលខុសត្រូវរបស់ភាគីថៅកែ។ លោកស្នើទៅភាគីថៅកែត្រូវមានការទទួលខុសត្រូវចំពោះករណីនេះ។ លោកជំរុញពលរដ្ឋត្រូវព្យាយាមទាក់ទងទៅស្ថានទូត ឬអ្នកពាក់ព័ន្ធដើម្បីជួយអន្តរាគមន៍៖ *«បញ្ហាកូវីដនេះជាបញ្ហាសកលអញ្ចឹងបើសិនគាត់(ពលករ)គាត់ធ្វើការនៅកន្លែងណា គ្រឹះស្ថានរោងចក្រសហគ្រាស គឺត្រូវទទួលខុសត្រូវក្នុងការព្យាបាល»។*

របាយការណ៍អង្គការសង់គ្រាល់ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរធ្វើការងារស្របច្បាប់ និងមិនស្របច្បាប់ជិត២លាននាក់(២.០០០.០០០) នៅប្រទេសថៃ។ ក្នុងចំណោមនោះគិតត្រឹមថ្ងៃទី៦ ខែកញ្ញា ក្រសួងសុខាភិបាលថៃបានរកឃើញពលករខ្មែរជាង ២ម៉ឺន៣ពាន់នាក់ (២៣.២១១) ឆ្លងជំងឺកូវីដ។ លោក ឌីថេ ហូយ៉ា ជំរុញទៅមន្ត្រីស្ថានទូតខ្មែរនៅប្រទេសថៃធ្វើការងាររបស់ខ្លួនឲ្យសកម្មថែមទៀតដើម្បីជួយសម្របសម្រួល ឬធ្វើអន្តរាគមន៍ជួយពលករដែលជួបទុក្ខលំបាកនេះ៕

## ឃាត់ខ្លួនថៃ ១៥ នាក់ និងស្ត្រីខ្មែរម្នាក់ ប្រុងលបឆ្លងដែនចូលមកធ្វើការនៅកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១២ តុលា ២០២១ដោយ Kang Tola

ប្រទេសថៃ ៖ ជនជាតិថៃចំនួន ១៥ នាក់ និងជនជាតិភូមា ១ នាក់ ដែលខំធ្វើដំណើរមកពីបណ្ដាខេត្តមួយចំនួន ត្រូវបានកម្លាំងយោធាថៃ ក្នុងកងវរសេនាធំ១២ សហការជាមួយតម្រួតព្រំដែនលេខ៤ ធ្វើការឃាត់ខ្លួនខណៈដែលពួកគេកំពុងឆ្លងដែនចូលមកធ្វើការនៅក្នុងប្រទេសកម្ពុជា។ ការឃាត់ខ្លួនជនជាតិថៃទាំង ១៥ នាក់ និងភូមាម្នាក់នេះ គឺបានធ្វើឡើង នៅចន្លោះម៉ោង ៣ ទៅម៉ោង ៤ ទៀបភ្លឺ ថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២១ ត្រង់ចំណុចក្បែរបន្ទាត់ព្រំដែន ត្រង់ចំណុចណងយ៉ាកែវ ក្នុង ស្រុកគោកខ្សូង ខេត្តស្រះកែវ។ ក្នុងកិច្ចប្រតិបត្តិការទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ក្នុងដំណាក់កាលនៃការរីករាលដាល នូវជំងឺកូវីដ-១៩ នេះ កម្លាំងបានឃាត់ខ្លួនជនជាតិថៃចំនួន ១៥ នាក់ ក្នុងនោះស្រី ៨ នាក់ និងស្ត្រីជនជាតិភូមា ម្នាក់ផងដែរ ដោយពួកគេមានបំណងឆ្លងដែនទៅធ្វើការក្នុងកាស៊ីណូ អនឡាញ ក្នុងប្រទេសកម្ពុជា ដោយនៅទីនោះបានប្រាក់ខែខ្ពស់ ហើយការចំណាយលើការស្នាក់នៅនិងការហូបចុក ត្រូវក្រុមហ៊ុនជាអ្នកចាយទាំងអស់ លុះពួកគេមកដល់ក្បែរព្រំដែន ក៏ត្រូវចាប់ខ្លួនតែម្តង។ បច្ចុប្បន្នក្រោយពេលឃាត់ខ្លួន និងក្រុមគ្រូពេទ្យបានពិនិត្យសុខភាពពួកគេទាំងអស់ ត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋានតម្រួត ស្រុកគោកខ្សូង ដើម្បីអនុវត្តន៍តាមវិធានការច្បាប់៕ *អត្ថបទ ៖ សោ និយមរ័ត្ន*

## កម្លាំងចម្រុះឃាត់ខ្លួនពលករខ្មែរប្រុសស្រី៤២នាក់លួចឆ្លងដែនទៅប្រទេសថៃខុសច្បាប់

http://nokorwatnews.com/ 12/10/2021

ក្រុងប៉ោយប៉ែត៖ កម្លាំងប៉ុស្តិ៍នគរបាលការពារព្រំដែនគោកលេខ៩១១សិលាខ្មែរ សហការជាមួយកម្លាំងយោធារួមគ្នាទប់ស្កាត់ពលករខ្មែរប្រុស ស្រីចំនួន៤២នាក់ ក្នុងនោះមានស្រី២១នាក់ និង កុមារីចំនួន០៣នាក់ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃនាវេលាម៉ោង១និង៣០នាទីរំលងអធ្រាត្រឈានចូលថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ នៅចំណុចខាងក្រោយប៉ុស្តិ៍ ស្ថិតនៅភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

ប្រភពពីមន្ត្រីនគរបាលការពារព្រំដែនបានឲ្យដឹងថា ដោយអនុវត្តបទបញ្ជាលោកមេបញ្ជាការរបស់ខ្លួន កម្លាំងប៉ុស្តិ៍ចំនួន០៨នាក់ ដឹកនាំដោយលោក ប៉ាក់ សារ៉ាត់ នាយប៉ុស្តិ៍ សហការជាមួយ កម្លាំងយោធា បានចេញទៅធ្វើការទប់ស្កាត់ ពលករខ្មែរ បម្រុងលួចឆ្លងដែនដោយខុសច្បាប់ ទៅរកការងារធ្វើ នៅក្រៅប្រទេស បានចំនួន៤២នាក់ ខាងលើនេះ។ ពលករទាំងអស់ ក្រោយពីសួរនាំតាមនីតិវិធីរួចរាល់ និងដោយទទួលបានបទបញ្ជាពីលោកមេបញ្ជាការ កម្លាំងប៉ុស្តិ៍ បានបញ្ជូនពួកគាត់ ទៅកន្លែងក្រុមការងារចម្រុះដើម្បីធ្វើតេស្តនិងពិនិត្យសុខភាពនៅច្រកអូរបីជាន់ឃុំអូរបីជាន់ស្រុកអូរជ្រៅ។ លោកមេបញ្ជាការក៏បានអំពាវនាវសូមបងប្អូនចូលរួមអនុវត្ត ៣កុំ ៣ការពារតាមវិធានការក្រសួងសុខាភិបាល។សូមឈប់លួចឆ្លងដែនខុសច្បាប់ដើម្បីជៀសវាងគ្រោះថ្នាក់ដល់អាយុជីវិត ព្រោះតំបន់មួយចំនួននៃព្រំដែននៅសេសសល់គ្រប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅឡើយ៕

## នគរបាលស្រុកកំរៀងឃាត់ខ្លួនមុខសញ្ញាជាមេខ្យល់ នាំប្រជាពលរដ្ឋឆ្លងដែនដោយខុសច្បាប់ ចូលទៅប្រទេសថៃ ចំនួន០២នាក់ អនុវត្តតាមផ្លូវច្បាប់

http://cambodiapolice.com/policekh/ 6:06 pm 13 តុលា 2021

ខេត្តបាត់ដំបង៖ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង២១ និង៣៧នាទី អនុវត្តតាមយោបល់ដឹកនាំរបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង លោកវរសេនីយ៍ទោ វេ គឹមចត់ អធិការនបាលស្រុកកំរៀង បានដឹកនាំកម្លាំងក្នុងអង្គភាពធ្វើការបង្ក្រាបករណីនាំមនុស្សចេញដោយមិនស្របច្បាប់ចូលទៅប្រទេសថៃចំនួន០១ករណី ត្រង់ចំណុចអូរព្រំដែនកម្ពុជាថៃ ក្រុមទី០១ ភូមិអូរក្រូច ឃុំបឹងរាំង ស្រុកកំរៀង ឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ និងពលករចំនួន ០២នាក់។

មន្ត្រីនគរបាលស្រុកកំរៀង មេខ្យល់បំរុងនាំពលករចេញទៅប្រទេសថៃដោយមិនស្របច្បាប់ទាំង២នាក់ រួមមាន ៖ ១.ឈ្មោះកាន់ អូន ហៅ មុំ ភេទស្រី អាយុ៥៤ឆ្នាំ និង២.ឈ្មោះ ពៅ ជុក ភេទប្រុស អាយុ ៥៧ឆ្នាំ អ្នកទាំងពីរស់នៅភូមិស្វាយ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។ ក្រោយឃាត់ខ្លួនសមត្ថកិច្ចបានធ្វើការសាកសួរលើជនសង្ស័យ អ្នកទាំងពីរបានឆ្លើយសារភាពថាពិតជាបាននាំពលករចំនួនពីរនាក់ដើម្បីលួចឆ្លងដែនចេញទៅប្រទេសថៃដោយស៊ីឈ្នួលឲ្យឈ្មោះ អូន ភេទស្រី រស់នៅក្នុងទឹកដីប្រទេសថៃបានថ្លៃឈ្នួលក្នុងម្នាក់ចំនួន ២,០០០បាត (ពីរពាន់បាត) ពិតប្រាកដមែន។ នៅពេលនេះ ប្រជាជនដែលត្រូវមេខ្យល់បំរុងឆ្លងដែនខុសច្បាប់ទាំងពីរនាក់ខាងលើសមត្ថកិច្ចបានធ្វើការណែនាំនិងធ្វើកិច្ចសន្យាអប់រំណែនាំរួចឱ្យវិលត្រឡប់ទៅសហគមន៍វិញ ចំនែកមេខ្យល់ទាំងពីរនគរបាលជំនាញបានរៀបចំសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្ត ដើម្បីចាត់ការបន្តតាមនិតិវិធី-ច្បាប់៕

## ពលករខ្មែរចំនួន ៣៧នាក់ បម្រុងនឹងលួចឆ្លងដែនខុសច្បាប់ ចូលទៅប្រទេសថៃ ត្រូវបានកម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៣ សហការជាមួយកម្លាំងចម្រុះធ្វើការឃាត់ខ្លួន

https://cen.com.kh/ Posted ByPen Srey NeatOctober 14, 2021

បន្ទាយមានជ័យ ៖ វរសេនីយ៍ទោ យូ សុគន្ធភក្តី មេបញ្ជាការ វរសេនាតូចថ្មើរជើងលេខ ៥១៣ នៅយប់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ បានចាត់តាំងកម្លាំងនៅជួរមុខតាមខ្សែបន្ទាត់ព្រំដែន ខ្មែរ-ថៃ នៅភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ សហការជាមួយកម្លាំងចម្រុះ ចេញល្បាតត្រួតពិនិត្យតាមបន្ទាត់ព្រំដែន ក៏បានប្រទះឃើញ ហើយធ្វើការឃាត់ខ្លួនពលករខ្មែរបាន ចំនួន ៣៧នាក់ ស្រី ១៨នាក់ នៅត្រង់ចំណុច (សិលាខ្មែរ) ដែលបម្រុងនិងលួចចូលទៅប្រទេសថៃ ក៏ត្រូវបានកម្លាំងសហការយើងធ្វើការឃាត់ខ្លួនរួចសាកសួរនាំ និងបានប្រគល់ជូនកម្លាំងជំនាញដើម្បីអនុវត្តទៅតាមច្បាប់។

សូមបញ្ជាក់ថា ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ កុំឲ្យឆ្លងចូលជាសហគមន៍ កម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៣ តែងតែយកចិត្តទុកដាក់អនុវត្តតាមបទបញ្ជាថ្នាក់លើ ទាំង៣ទិស ក្នុងខេត្តបន្ទាយមានជ័យ ចាប់ពីទិសអូរនាង ប៉ោយប៉ែត និងទិសម៉ាឡៃ សហការជាមួយកម្លាំង នៅតាមមូលដ្ឋាន ចេញល្បាតឆែកឆេរ ត្រួតពិនិត្យជាប្រចាំ ក្នុងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់៕ កូលាប

## ពលករខ្មែរចំនួន ៣៣នាក់ ត្រូវបានទាហានឈុតខ្មៅថៃ ឃាត់ខ្លួនក្បែរព្រំដែន

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៤ តុលា ២០២១ដោយ sopheak khoun

ពលករខ្មែរចំនួន ៣៣នាក់ ត្រូវបានក្រុមទាហានឈុតខ្មៅថៃ ក្នុងកងវរលេខ ១២ សហការជាមួយតម្រួតការពារព្រំដែនថៃឃាត់ខ្លួន ខណៈដែលពួកគេលបឆ្លងដែនដោយខុសច្បាប់ ដើម្បីចូលទឹកដីថៃរកការងារធ្វើ។ ការឃាត់ខ្លួននេះ បានធ្វើឡើងកាលពីវេលាម៉ោង ៣ និង៤៥នាទីទៀបភ្លឺថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២១ ត្រង់ចំណុចភូមិណងព្រី ក្នុងឃុំផានសឹក ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ប្រទេសថៃ។

នៅមុនពេលឃាត់ខ្លួន គឺមានពលករខ្មែរចំនួន ៣៣នាក់ បានលបឆ្លងព្រំដែនចូលទៅក្នុងទឹកដីថៃ ដោយនាំគ្នាដើរកាត់តាមព្រៃក្បែរខ្សែបន្ទាត់ព្រំដែន ស្របពេលដែលកម្លាំងទាហានឈុតខ្មៅថៃ កំពុងល្បាតក៏បានស្ទាក់ចាប់ ដែលក្នុងនោះមានប្រុស ១៦នាក់ និងស្រី ១៧នាក់។ ក្រោយការឃាត់ខ្លួន ពលករខ្មែរបានសារភាពថា ពួកគេទាំងអស់មានបំណងឆ្លង ចូលទៅរកការងារធ្វើនៅក្នុងប្រទេសថៃ តែក៏ត្រូវឃាត់ខ្លួនតែម្តង។ ក្រោយពេលឃាត់ខ្លួន ក្រុមយោធាថៃបានត្រួតពិនិត្យសុខភាពពួកគេទាំងអស់ ដើម្បីការពារនៅក្នុងដំណាក់កាលនៃជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាត និងបានបញ្ជូនទៅឲ្យអធិការដ្ឋានតម្រួត ស្រុកអារញ្ញប្រាថេត ដើម្បីអនុវត្តតាមនីតិវិធី៕ សោ និយមរ័ត្ន

# ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១

## ដេញចាប់ជនជាតិថៃ ៨នាក់ ប្រុងឆ្លងដែនទៅធ្វើការនៅកម្ពុជា ធ្វើឲ្យទាហានម្នាក់ រងរបួសបាក់ដៃ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៤ តុលា ២០២១ដោយ Sorn Phanith

ជនជាតិថៃ ៨នាក់ ដែលខំធ្វើដំណើរមកពីបណ្តាខេត្តមួយចំនួន ត្រូវបានកម្លាំងយោធាថៃ ក្នុងកងវរលេខ ១២ សហការជាមួយតម្រួតព្រំដែនលេខ ៤ ធ្វើការប្រដេញតាមរថយន្ត ដើម្បីឃាត់ខ្លួន រហូតប៉ះទង្គិចជាមួយរថយន្តបណ្តាលឲ្យរងរបួសបាក់ដៃឆ្វេងម្ខាង ខណៈដែលពួកគេកំពុងធ្វើដំណើរតាមរថយន្ត ដើម្បីត្រៀមឆ្លងដែនចូលទៅធ្វើការនៅក្នុងប្រទេសកម្ពុជា។ ការឃាត់ខ្លួនជនជាតិថៃទាំង ៨ នាក់ នេះ គឺបានធ្វើឡើង នៅវេលារំលងអធ្រាត្រ ឈានចូលយប់ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ នៅពេលដែលកម្លាំងសមត្ថកិច្ចថៃ កំពុងធ្វើការល្បាតតាមខ្សែបន្ទាត់ព្រំដែន

ក៏បានប្រទះឃើញរថយន្តមួយគ្រឿងម៉ាកអ៊ីស៊ុយស៊ុយ ឌុយមេក ពណ៌ខ្មៅ ពាក់ស្លាកលេខ ស្រះកែវ ដែលកំពុងធ្វើដំណើរត្រង់ចំណុចណាងយ៉ាកែវ ក្នុងឃុំគោកខ្សង ស្រុកគោកខ្សង ខេត្តស្រះកែវ នៅពេលមានការសង្ស័យទើបកម្លាំងចាប់ផ្តើមដេញរហូត ដោយរថយន្តបើកគេចទាល់តែធ្លាក់ផ្លូវ និងធ្វើឲ្យប៉ះទង្គិចដល់មន្ត្រីឃោជាម្នាក់ឲ្យរងរបួសធ្ងន់ផងដែរ (ដោយអ្នកបើកបរគេចខ្លួន)។

ក្រោយពីកម្លាំងចូលទៅពិនិត្យ គឺឃើញមានជនជាតិថៃចំនួន ៨ នាក់ ស្រី៤នាក់ ក្រោយពីកម្លាំងបានសាកសួររួចមក ជនជាតិថៃទាំងអស់ បានសារភាពថា ពួកគេទាំងអស់ គឺមកពីខេត្តស្រះកែវចំនួន ២ នាក់ ទីក្រុងបាងកក ចំនួន ១ នាក់ ខេត្តកិតប៊ូន ចំនួន ១ នាក់ ខេត្តកាំផែងភិត ចំនួន ២ នាក់ ខេត្តឡើយ ចំនួន ១ នាក់ និងខេត្ត ឈៀងរ៉ា ចំនួន ១ នាក់ ដោយមានបំណងឆ្លងដែនទៅធ្វើការក្នុងកាស៊ីណូអនឡាញ នាក្រុងប៉ោយប៉ែត ដោយនៅទីនោះឮថាបានប្រាក់ខែខ្ពស់ តែនៅពេលពួកគេមកដល់ក្បែរព្រំដែន តែក៏ត្រូវចាប់ខ្លួនតែម្តង ។ បច្ចុប្បន្នក្រោយពេលឃាត់ខ្លួន និងក្រោយពេលដែលក្រុមគ្រូពេទ្យបានពិនិត្យសុខភាពរួចមក ពួកគេទាំងអស់ត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋានតម្រួត ស្រុកគោកខ្សូង ដើម្បីអនុវត្តតាមវិធានការច្បាប់៕ **អត្ថបទ៖ សោ និយមវ័ន្ត**

## អ្នកនាំពាក្យក្រសួងការបរទេស៖ អគ្គកុងស៊ុលប្រចាំទីក្រុងក្វាងចូវ បានជួយដោះស្រាយបញ្ហាចំពោះមុខជូនស្ត្រី២នាក់ ដែលចង់វិលមកស្រុកវិញ, ពួកគេត្រូវផ្តាច់ចំណងអាពាហ៍ពិពាហ៍ជាមួយប្តីចិនសិន ទើបអាចមកស្រុកបាន

http://freshnewsasia.com/ 2021-10-14 01:15pm

**(ភ្នំពេញ)៖** លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បានប្រាប់បណ្តាញព័ត៌មាន Fresh News ថា សម្រាប់ស្ត្រីខ្មែរ២នាក់ ដែលចង់ស្វែងរកអន្តរាគមន៍ចង់វិលត្រឡប់មកស្រុកកំណើតវិញ ដោយមិនចង់បន្តរស់នៅជាមួយប្តីជនជាតិចិននោះ ត្រូវបានអគ្គកុងស៊ុលប្រចាំទីក្រុងក្វាងចូវ ប្រទេសចិន ជួបដោយផ្ទាល់ និងដោះស្រាយបញ្ហាចំពោះមុខ តាមរយៈការផ្តល់ថវិកាសម្រាប់ការស្នាក់នៅ និងការចាយវាយផងដែរ។ បើតាមលោក កុយ គួង សម្រាប់ស្ត្រីទាំង២នាក់នេះ ខាងអគ្គកុងស៊ុលរបស់កម្ពុជាប្រចាំនៅទីក្រុងក្វាងចូវ បានណែនាំឲ្យពួកគាត់ត្រឡប់ទៅដោះស្រាយដោយបញ្ចប់ចំណងអាពាហ៍ពិពាហ៍ជាមួយប្តីរបស់ខ្លួនជាមុនសិន ទើបអាចវិលត្រឡប់មកស្រុកកំណើតបាន ដោយសារច្បាប់ស្រុកចិនតម្រូវឲ្យធ្វើយ៉ាងដូច្នេះ។

លោក កុយ គួង បានបញ្ជាក់យ៉ាងដូច្នេះថា «**មកដល់ពេលនេះ ខាងអគ្គកុងស៊ុលរបស់យើង បានផ្តល់ថវិកាមួយចំនួនដើម្បីឲ្យពួកគាត់ស្នាក់នៅ ហូបចុកជាបណ្តោះអាសន្ន ពីព្រោះនគរបាលចិន គេនៅទាមទារឲ្យពួកគាត់ ទៅដោះស្រាយលែងលះលុបសៀវភៅអាពាហ៍ពិពាហ៍ឲ្យជ្រះស្រឡះសិន ទើបគាត់អាចត្រឡប់មកស្រុកកំណើតវិញបាន ពីព្រោះបើនៅជាប់ចំណងអាពាហ៍ពិពាហ៍មិនទាន់ស្អាតចឹង ច្បាប់ស្រុកគេតម្រូវឲ្យដោះស្រាយគ្នាសិន ដើម្បីឲ្យគេដឹងថាយើងពិតជាបានលែងលះជាមួយប្តីចិនពិតប្រាកដ ហើយពេលលុបបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវហើយ ទើបយើងមានសិទ្ធិមកប្រទេសខ្មែរសេរីបាន**»។ បើតាមអ្នកនាំពាក្យក្រសួងការបរទេសរូបនេះ សម្រាប់ពួកគាត់ទាំង២នាក់ដែលទៅដោះស្រាយបញ្ហាលែងលះឲ្យដាច់ជាមួយប្តីរបស់ខ្លួននោះ ក៏ប្តីមិនហ៊ានធ្វើបាបនោះដែរដោយសារនគរបាលចិនបានក្តាប់ និងទទួលបានករណីនេះរួចហើយ ដូច្នេះពួកគេមិនអាចធ្វើអ្វីខុសច្បាប់ទៅលើស្ត្រីទាំង២នាក់នេះបានទេ។

សូមបញ្ជាក់ថា ស្ត្រីខ្មែរ២នាក់ រួមមានទី១ មានឈ្មោះថា ឈីន សុផៃ ទីកន្លែងកំណើតនៅភូមិកសិកម្ម ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ចំណែកឯជនរងគ្រោះទី២ មានឈ្មោះថា លីន សារ៉ន ទីកន្លែងកំណើតភូមិម៉ាសែន ឃុំប៉ាហាល ស្រុកត្បែង ខេត្តព្រះវិហារ បានសុំអន្តរាគមន៍ដល់ថ្នាក់ដឹកនាំឲ្យជួយពួកគេត្រឡប់មកស្រុកកំណើតវិញ ដោយសារការធ្វើបាបពីសំណាក់ប្តីជនជាតិចិន។ តាមរយៈបណ្តាញ Tik Tok ជនរងគ្រោះបានបញ្ជាក់

យ៉ាងដូច្នេះថា៖ «ជម្រាបសួរពុកម៉ែបងប្អូនទាំងអស់គ្នាខ្ញុំបានមកខ្លួននៅប្រទេសចិនអស់រយៈពេល ៥ ឆ្នាំហើយ។ ខ្ញុំបានចាញ់បោកមេខ្យល់ឡើងមក។ អញ្ចឹងខ្ញុំសុំឱ្យសម្តេច ប៊ុន រ៉ានី និងសម្តេច ហ៊ុន សែន ជួយយកខ្ញុំទៅខ្មែរផង។ នេះជាលេខទូរសព្ទខ្ញុំ 19979098645»៕

## សមត្ថកិច្ចទប់ស្កាត់ពលរដ្ឋខ្មែរជិត២០០នាក់ បម្រុងលួចឆ្លងដែនទៅប្រទេសថៃ ខណៈមេខ្យល់ត្រូវបានឃាត់ខ្លួនជាបន្តបន្ទាប់

https://news.btv.com.kh/ 10/14/2021 03:10 PM

បាត់ដំបង ៖ កម្លាំងសមត្ថកិច្ចការពារព្រំដែនក្នុងភូមិសាស្ត្រខេត្តបាត់ដំបង បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរជិត២០០នាក់ បម្រុងលួចឆ្លងដែនខុសច្បាប់ ទៅរកការងារធ្វើនៅប្រទេសថៃ ខណៈមេខ្យល់ត្រូវបានកំណត់មុខសញ្ញា ឃាត់ខ្លួនបានជាបន្តបន្ទាប់ និងកសាងសំណុំរឿងតាមនីតិវិធីច្បាប់ផងដែរ។

លោក សុខ គឹមខុន អភិបាលស្រុកកំរៀង បានថ្លែងឲ្យដឹងថា ក្នុងរយៈពេល២ថ្ងៃ កងកម្លាំងវរៈនគរបាលការពារព្រំដែនគោកលេខ៨១៩ បានធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន១៨៨នាក់ ដែលត្រូវបានមេខ្យល់រៀបចំនាំចេញឆ្លងដែនទៅប្រទេសថៃដោយច្បាប់។ ជាក់ស្តែងកាលពីពេលថ្មីៗនេះ កម្លាំងវរសេនាតូចការពារព្រំដែនគោកលេខ ៨១៩ សហការជាមួយកងកម្លាំងកងពលពលតូចថ្មើជើងលេខ៥៣ និងកម្លាំងនគរបាលនៃអធិការដ្ឋាននគរបាលស្រុកកំរៀង បានស្ទាក់និងឃាត់ខ្លួនពលរដ្ឋខ្មែរជិត២០០នាក់ មានទាំងមនុស្សចាស់ ប្រុស ស្រី និងក្មេងតូចៗដែលត្រូវបានមេខ្យល់បម្រុងលួចនាំឆ្លងដែនទៅប្រទេសថៃ ហើយពួកគេភាគច្រើនជាប្រជាពលរដ្ឋដែលមកពីបណ្តាខេត្តតាកែវ និងខេត្តព្រៃវែង ក្នុងគោលបំណងលួចឆ្លងដែន ដើម្បីស្វែងរកការងារធ្វើទាំងមិនបានគិតពីស្ថានភាពប្រទេសជិតខាងកំពុងមានវិបត្តិកូវីដ១៩។ លោក បានបន្ថែមថា បន្ទាប់ពីទប់ស្កាត់ការលួចឆ្លងដែនរបស់ប្រជាពលរដ្ឋបានទាន់ពេលវេលា កម្លាំងសមត្ថកិច្ចក៏បានបន្តស៊ើបអង្កេត ស្វែងរក និងឃាត់ខ្លួនមេខ្យល់ ម្ចាស់សំណាក់ និងអ្នកផ្តល់ទីតាំងឲ្យពលរដ្ឋស្នាក់នៅមុនលួចឆ្លងដែន ដើម្បីកសាងសំណុំរឿងបញ្ជូនទៅកាន់តុលាការចាត់ការតាមនីតិវិធីច្បាប់។

ចំពោះប្រជាពលរដ្ឋខ្មែរទាំងអស់ដែលកម្លាំងសមត្ថកិច្ចការពារព្រំដែនបានឃាត់ខ្លួននោះ បន្ទាប់ពីសួរនាំអប់រំ និងធ្វើកិច្ចសន្យាបញ្ឈប់ការលួចឆ្លងដែនខុសច្បាប់ ពួកគេត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់ទៅកាន់ស្រុកកំណើតវិញរៀងៗខ្លួនអស់ហើយ។ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលឆ្លងជំងឺកូវីដ១៩ ជាពិសេសប្រភេទដែលតា (Delta)នៅកម្ពុជា កងកម្លាំងចម្រុះការពារព្រំដែនក្នុងភូមិសាស្ត្រខេត្តបាត់ដំបង បានធ្វើការទំនាក់ទំនង និងសហការយ៉ាងជិតស្និទជាមួយភាគីថៃ ដើម្បីទប់ស្កាត់មិនឲ្យប្រជាពលរដ្ឋខ្មែរលបលួចឆ្លងដែនចូលទៅក្នុងទឹកដីថៃដោយមិនស្របច្បាប់៕

## ឃាត់ខ្លួនមេខ្យល់ម្នាក់ ដែលកំពុងនាំពលករ ២ នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៤ តុលា ២០២១ដោយ Kang Tola

បាត់ដំបង ៖ មុខសញ្ញានាំមនុស្សឆ្លងដែន ១ នាក់ក្នុងចំណោមបក្ខពួក ៣ នាក់ ត្រូវបានកម្លាំងសមត្ថកិច្ចឃាត់ខ្លួន នៅក្បែព្រំដែនថៃ រួមជាមួយនឹងពលករចំនួន ២ នាក់ ផងដែរ ដែលពួកគេបម្រុងធ្វើសកម្មភាពឆ្លងដែនចូលទៅប្រទេសថៃ ដោយគ្មានច្បាប់អនុញ្ញាត។ ការឃាត់ខ្លួននេះបានធ្វើឡើង នាថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០២១ វេលាម៉ោង ៥ និង ១៥ នាទី ព្រឹក នៅចំណុចដីថៃ ជាប់មាត់អូរព្រំដែនកម្ពុជា-ថៃ ជាប់ភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ដោយកម្លាំងអធិការដ្ឋាននគរបាលស្រុកសំពៅលូន សហការជាមួយ

កម្លាំង វរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ កម្លាំងវរលេខ១ និង កម្លាំងវរសេនាតូចលេខ ៥៣៣ ប្រចាំការតាមមាត់អូរព្រំដែនត្រង់ចំណុចខាងលើ។

ក្រោយការសាកសួរ និងស្រាវជ្រាវ គឺករណីការនាំយកចេញដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែន (ចូលទៅក្នុងប្រទេសថៃ ) នេះ បង្កឡើងដោយជនសង្ស័យជាមេខ្យល់ចំនួន ៣ នាក់ ១.ឈ្មោះ អូន ចេវ ភេទប្រុស អាយុ ៤៥ ឆ្នាំ មានទីលំនៅ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន (ឃាត់ខ្លួនបាន) ២. ឈ្មោះ ញ៉ាញ់ ភេទប្រុស អាយុប្រហែល ៥៥ ឆ្នាំ មានទីលំនៅ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន (រត់គេចខ្លួន) និង ៣.ឈ្មោះ ពៅ ភេទស្រី អាយុប្រហែល ៣៥ ឆ្នាំ (ស្នាក់នៅធ្វើការក្នុងប្រទេសថៃ) បានធ្វើសកម្មភាព ទាក់ទងគ្នា លួចនាំពលករចំនួន ២ នាក់ រួមមាន ១.ឈ្មោះ សំ ចាន់រ៉ា ភេទប្រុស អាយុ ២៥ ឆ្នាំ មានទីលំនៅភូមិអន្លង់ចារ ឃុំព្រះស្តេច ស្រុកពាមជរ ខេត្តព្រៃវែង និង ២.ឈ្មោះ គឿក ពិសិដ្ឋ ភេទប្រុស អាយុ ២៤ ឆ្នាំ មានទីលំនៅ ភូមិជ្រួល ឃុំកន្សោមអកកំពង់ត្របែក ខេត្តព្រៃវែង ដោយយកប្រាក់ថ្លៃធ្វើដំណើរពីពលករ ក្នុងម្នាក់ ៦.០០០ បាត។

ក្នុងកិច្ចប្រតិបត្តិការនេះកម្លាំងសមត្ថកិច្ច បានធ្វើការឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ចំនួនម្នាក់ ខាងលើបញ្ជូនទៅអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ចំពោះពលករទាំង ២ នាក់ កម្លាំងសមត្ថកិច្ចបាន ធ្វើការអប់រំណែនាំ និង ចុះកិច្ចសន្យា ព្រមទាំងអោយវិលត្រឡប់ទៅមូលដ្ឋានវិញ៕ *សោ និយមវត្ថ័*

## ប.ស.ស. បើកសិក្ខាសាលាស្តីពី "ការគាំពារពលករទេសន្តរប្រវេសក៍ ក្នុងតំបន់អាស៊ីអាគ្នេយ៍" ដល់សមាជិកអង្គភាព សមាគមសន្តិសុខសង្គមអាស៊ាន ២២ស្ថាប័ន នៃអាស៊ានទាំង ១០

https://dap-news.com/national/ ByDR103 Posted on October 14, 2021

**ភ្នំពេញ៖ បន្ទាប់ពីបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) កម្ពុជា បានរៀបចំធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃសមាគមសន្តិសុខសង្គមអាស៊ាន លើកទី៣៧ ក្រោមប្រធានបទ "ការពង្រីកការគ្របដណ្តប់ របបសន្តិសុខសង្គម" កាលពីថ្ងៃទី០៩ ខែធ្នូឆ្នាំ២០២០ កន្លងទៅ នារសៀលថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ នេះ ប.ស.ស. កម្ពុជា បានបើកសិក្ខាសាលាដ៏សំខាន់មួយ ស្តីពី "ការគាំពារពលករទេសន្តរប្រវេសក៍ក្នុងតំបន់អាស៊ីអាគ្នេយ៍" តាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting) ជូនដល់តំណាងសមាជិក អង្គភាពសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) ចំនួន ១២០រូប មកពី ២២ស្ថាប័ន នៃអាស៊ានទាំង ១០ ប្រទេសផ្សេងគ្នា។**

ក្នុងឱកាសអញ្ជើញជាអធិបតីភាព ក្នុងសិក្ខាសាលានេះ លោក ហេង សុផាន់ណារិទ្ធ អគ្គនាយករង ប.ស.ស. និងជាប្រធានសមាគមសន្តិសុខសង្គមអាស៊ាន (ASEAN Social Security Association, ASSA) តំណាងដ៏ខ្ពង់ខ្ពស់ លោក អ៊ុក សមវិទ្យា ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក ប.ស.ស. បានថ្លែងឱ្យដឹងថា៖ សិក្ខាសាលាដ៏មានសារៈសំខាន់ខាងលើនេះ ត្រូវបានរៀបចំឡើងក្នុងន័យ (១) ចែករំលែកឧត្តមានុវត្តន៍ ចំណេះដឹង និងបទពិសោធន៍គ្នាទៅវិញទៅមក ក៏ដូចជាការលើកឡើង អំពីបញ្ហាប្រឈមដែលពាក់ព័ន្ធ ទៅនឹងពលករទេសន្តរប្រវេសក៍ និង (២). កំណត់តំបន់ និងចាត់វិធានការសំខាន់ៗ សម្រាប់ធ្វើឲ្យប្រសើរឡើងភ្លាមៗ និងរយៈពេលវែង នៃការការពារ និងការលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសក៍។ ក្នុងនាមលោកជាប្រធានសមាគម សន្តិសុខសង្គមអាស៊ាន លើកទី៣៧ (The 37th ASSA Chairman) លោកសង្ឃឹមយ៉ាងមុតមាំថា៖ សិក្ខាសាលារយៈពេលពេញ មួយរសៀលនេះ នឹងផ្តល់នូវចំណេះដឹង ព័ត៌មាន ឧត្តមានុវត្តន៍ និងបទពិសោធន៍ល្អៗរវាងគ្នាទៅវិញទៅមក នៃបណ្តាសមាជិកអង្គភាពសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) ទាំងមូល សម្រាប់ការការពារ និងការលើកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍របស់ពលករទេសន្តរប្រវេសក៍។ លើសពីនេះ ស្ថាប័នជាសមាជិក នៃសមាគម ASSA និងដៃគូពាក់ព័ន្ធ នឹងអាចកំណត់ចំណុច ចាត់វិធានការ និងកិច្ចសហការសំខាន់ៗ សម្រាប់ធ្វើឱ្យប្រសើរឡើង

ទាក់ទងនឹងការការពារសិទ្ធិ និងសុខុមាលភាពរបស់ពលករទេសន្តរប្រវេសក៍ ក្នុងឱកាសដែលកូវីដ-១៩ នៅតែបន្តរីករាលដាល និងបង្កជាផលប៉ះពាល់ ដល់ជីវភាពរស់នៅរបស់មនុស្សជាតិនៅក្នុងសកលលោក។

សូមបញ្ជាក់ថា៖ សមាគមសន្តិសុខសង្គមអាស៊ាន (ASSA) ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ដែលបានផ្តួចផ្តើមរួមគ្នាក្នុងចំណោមប្រទេសចំនួន៥ ដូចជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ។ បច្ចុប្បន្ន មានស្ថាប័នសន្តិសុខសង្គម នៅក្នុងបណ្តាប្រទេសអាស៊ានទាំងអស់ ចំនួន ២២ស្ថាប័ន បានចូលជាសមាជិក របស់សមាគម ASSA រួមទាំង បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃព្រះរាជាណាចក្រកម្ពុជាផងដែរ ដែលបានចូលជាសមាជិកនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃសមាគមសន្តិសុខសង្គមអាស៊ានលើកទី២៧ ដែលបានរៀបចំឡើងនៅប្រទេសសិង្ហបុរី។ ដោយគោរពតាមអនុស្សរណៈ នៃកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខា ដោយស្ថាប័នជាសមាជិក នៃសមាគម ASSA ដើម្បីអនុវត្តប្រព័ន្ធសន្តិសុខសង្គម ដែលត្រូវបានអភិវឌ្ឍ និងដាក់ឱ្យអនុវត្ត ស្របតាមស្តង់ដាអន្តរជាតិ និងក្របខ័ណ្ឌបទប្បញ្ញត្តិជាតិ ប្រព័ន្ធ និងបរិបទសម្រាប់ការផ្តល់ផលប្រយោជន៍ ជូនដល់កម្មករនិយោជិត។ ក្នុងកិច្ចព្រមព្រៀងនេះបានចែងថា សមាជិករបស់សមាគមសន្តិសុខសង្គមអាស៊ាន (ASSA) ត្រូវផ្លាស់វេនគ្នាធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍នេះរៀងរាល់ឆ្នាំ តាមអក្សរក្រម នៃឈ្មោះប្រទេសដែលជាសមាជិក។

គួររំលឹកថា៖ កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ កន្លងទៅ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) កម្ពុជា បានធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃសមាគមសន្តិសុខសង្គមអាស៊ាន លើកទី៣៧ (The 37th ASSA Chairman) ក្រោមប្រធានបទ"ការពង្រឹកការគ្របដណ្តប់របបសន្តិសុខសង្គម" ដោយទទួលបានលទ្ធផលគួជាទីគាប់ចិត្ត និងបានបញ្ចប់ដោយផ្លែផ្កា រហូតឈានដល់ការស្នើសុំឱ្យមានសិក្ខាសាលាដ៏សំខាន់ខាងលើនេះ៕

## ពលករខ្មែរ២២នាក់ ចាញ់បោកមេខ្យល់យកទៅប្លុងចោលនៅភូមិតេជោភ្នំធំត្រ ៣១៧

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៤ តុលា ២០២១ដោយ Kang Tola

បន្ទាយមានជ័យ ៖ រកឃើញពលករខ្មែរចំនួន ២២ នាក់ ត្រូវបានមេខ្យល់យកមកប្លុងចោលនៅផ្ទះមួយកន្លែងស្ថិតក្នុងភូមិតេជោ ភ្នំធំត្រ៣១៧ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីវេលាម៉ោង ៤ និង៣០នាទី រសៀលថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ។

លោកវរសេនីយ៍ឯក ជា ស្លួញ អធិការនគរបាលស្រុកស្វាយចេកបានឲ្យដឹងនៅថ្ងៃទី១៤ ខែតុលា២០២១ នេះថា កម្លាំងអធិការដ្ឋាននគរបាលស្រុកស្វាយចេកនិងលោកមេភូមិ តេជោភ្នំធំត្រ ៣១៧ និងអ្នកភូមិបានរកឃើញពលករទាំងនោះនៅចំណុចផ្ទះរបស់ឈ្មោះ សួន ម៉ាង ភេទប្រុសអាយុ ៣៩ឆ្នាំ នៅភូមិឃុំ ខាងលើ(ក្នុងមណ្ឌលអភិវឌ្ឍន៍យោធិនពិការ ៣១៧ តេជោភ្នំធំត្រ )។ ពលករទាំង ២២ នាក់ ក្នុងនោះមានមកពីខេត្តឧត្តរមានជ័យចំនួន ៦ នាក់ (ស្រី៣នាក់) មកពីខេត្តបាត់ដំបង១នាក់ (ប្រុស) មកពីខេត្តព្រះវិហារ ៦នាក់(ស្រី៣នាក់)មកពី ខេត្តបន្ទាយមានជ័យ ៩ នាក់(ស្រី២នាក់)។ ពលករបានប្រាប់សមត្ថកិច្ចថា ពួកគេមានបំណងទៅរកការងារធ្វើនៅប្រទេសថៃ ហើយមេខ្យល់នាំផ្លូវ និងដឹកជញ្ជូនតម្លៃ ៦.៥០០ បាតក្នុង១នាក់ៗ (ពេលទៅដល់ប្រទេសថៃ)។ ចំណែកអ្នករស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យចំនួន៧នាក់បាននិយាយថា ពួកគាត់ជិះឡានមកដល់ភូមិតេជោភ្នំធំត្រដោយថ្លៃឡាន១នាក់ៗ ចំនួន២០ម៉ឺនរៀល។

មុខសញ្ញាមេខ្យល់និងម្ចាស់រថយន្តបានរត់គេចខ្លួនតែបន្សល់ទុកតែរថយន្តម៉ាកនីសាន់ មួយបាំងកន្លះពណ៌ស ស៊េរីឆ្នាំ ១៩៩៥ ពាក់ស្លាកលេខសៀមរាប 2A 3605 ចង្កូតស្តាំ ចំនួន១ គ្រឿង។ នគរបាលបានយកមករក្សាទុកនៅកន្លែងអធិការដ្ឋាននគរបាលស្រុកស្វាយចេកហើយ។ ចំណែកពលករទាំង ២២ នាក់ ក្រោយធ្វើការសួរនាំរួច

នគរបាលបានបញ្ជូនឱ្យទៅធ្វើចត្តាឡីស័កនៅវិទ្យាល័យស្វាយចេកជាមុនសិន នៅមុនពេលអនុញ្ញាតឱ្យវិលទៅភូមិកំណើតវិញ៕ *ដោយ ៖ ណារី*

## ៤ ថ្ងៃ អាជ្ញាធរទប់ស្កាត់ការលបលួចឆ្លងដែនទៅប្រទេសថៃ បានជិត ២០០ នាក់

https://www.postkhmer.com/ នៅ ស៊ីវុត្ថា | Publication date 14 October 2021 | 17:58 ICT

**បាត់ដំបង:** គិតចាប់តាំងពីថ្ងៃទី ១០ ខែតុលា រហូតមដល់ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២១ នេះអាជ្ញាធរស្រុកកំរៀងខេត្តបាត់ដំបងបានឃាត់ខ្លួន និងទប់ស្កាត់ប្រជាពលរដ្ឋដែលលបលួចឆ្លងដែនចូលទៅក្នុងប្រទេសថៃ ដោយខុសច្បាប់មានចំនួនជិត ២០០ នាក់ ខណៈដែលមេខ្លោងចំនួន១១នាក់ត្រូវបានបញ្ជូនទៅតុលាការ ដើម្បីអនុវត្តទៅតាមនីតិវិធីច្បាប់។

លោកអភិបាលស្រុកកំរៀង លោក សុក គឹមខុន ប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២១ ថា ប្រជាពលរដ្ឋខ្មែរដែលមានបំណងឆ្លងចូលទៅប្រទេសថៃ ដោយខុសច្បាប់នេះ ព្រោះពួកគេបានឮតាមគ្នាថា ប្រទេសថៃ បើកច្រកវិញ ក៏បាននាំគ្នាសម្រុកមក ហើយមានចំនួនច្រើនក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ ។ លោកបានបន្តថា ពលរដ្ឋខ្មែរទាំងនេះ ក៏ធ្លាប់បម្រើការងារជាពលករនៅក្នុងប្រទេសថៃ កាលពីអំឡុងពេលដែលប្រទេសថៃរីករាលនៃជំងឺកូវីដ ១៩ ហើយពួកគេក៏ត្រឡប់មកកាន់កម្ពុជាវិញ។មកទល់ពេលនេះ ពួកគាត់មើលឃើញពីភាពស្ងប់ស្ងាត់ទាំងប្រទេសថៃ និងកម្ពុជា ពួកគាត់ក៏មានបំណងត្រឡប់ទៅវិញ ខណៈពេលដែលព្រំដែនមិនទាន់ត្រូវបានបើកច្រកជាផ្លូវការនៅឡើយ។ លោកបន្តទៀតថា មួយទៀត គឺបងប្អូនរបស់ពួកគាត់ដែលកំពុងរស់នៅក្នុងប្រទេសថៃ បានទូរស័ព្ទហៅឱ្យត្រឡប់ទៅវិញ ដើម្បីបានទៅបេះ ផ្លែមៀននៅក្នុងប្រទេសថៃ ព្រោះរដូវមៀនបានមកដល់ ហើយខ្វះកម្លាំងពលកម្ម។ ដូច្នេះពួកគាត់ចេះតែកៀរគេឱ្យត្រឡប់ទៅវិញ។ ជាមួយគ្នានេះ សមត្ថកិច្ចស្រុកក៏បានឃាត់ខ្លួន និងញូនមេខ្លោងជាច្រើនទៅតុលាការផងដែរ។

លោក សុក គឹមខុន បានបញ្ជាក់ថា៖ «យើងបានធ្វើការស្រាវជ្រាវ ពួកគាត់ដែលកំពុងស្នាក់នៅផ្ទះសំណាក់ រួចក៏ឃាត់ខ្លួនសួរនាំ ថ្ងៃខ្លះក៏មានចំនួនច្រើន ថ្ងៃខ្លះក៏មានចំនួនតិច ហើយបានអប់រំ និងបញ្ជូនគាត់ឱ្យត្រឡប់ទៅលំនៅឋានស្រុកកំណើតគាត់វិញអស់ហើយ ព្រោះគាត់មិនទាន់បានឆ្លងទៅថៃទេ»។ បើតាម លោក សុក គឹមខុន ប្រជាពលរដ្ឋដែលមានបំណងឆ្លងចូលទៅប្រទេសថៃ ដោយខុសច្បាប់នេះ បានស្នាក់នៅក្នុងមូលដ្ឋានស្រុកកំរៀង ក្នុងរយៈពេល ១ ឬ ២ ថ្ងៃ ហើយបន្តលួចទៅឆ្លងទៅតាមច្រករបៀង ឬច្រកផ្សេងៗ ប៉ុន្តែអាជ្ញាធរស្រុកពិនិត្យឃើញប្លែកមុខ ក៏បានសួរនាំ រួចក៏ដឹងពីមូលហេតុទើបបញ្ជូនឱ្យទៅកាន់ស្រុកកំណើតរៀងៗខ្លួន វិញ ។

លោក សួស សុកគ្រា ប្រធានមន្ទីរព័ត៌មាន និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបងប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ១៤ ខែតុលាថា ពាក់ព័ន្ធនឹងបញ្ហានេះ គណៈបញ្ជាឯកភាពខេត្តបានបើកកិច្ចប្រជុំនៅថ្ងៃទី ១៤ នេះ ដើម្បីរិះរកវិធីដើម្បីទប់ស្កាត់ពលរដ្ឋខ្មែរដែលមានបំណងលបលួចឆ្លងចូលទៅកាន់ប្រទេសថៃ ដោយខុសច្បាប់។ ទាក់ទងនឹងបញ្ហានេះដែរ កាលពីថ្ងៃទី ១២ ខែតុលា កម្លាំងនគរបាលនៃអធិការដ្ឋាននគរបាលស្រុកកំរៀងបានបង្ក្រាបទប់ស្កាត់បានទាន់ពេលវេលាប្រជាពលរដ្ឋដែលប៉ុនប៉ងលបលួចឆ្លងដែនពីប្រទេសកម្ពុជា ចូលទៅក្នុងប្រទេសថៃ ដោយខុសច្បាប់បានចំនួន ១៣០ នាក់ ដែលជាចំនួនច្រើនជាងគេ ក្នុងនោះមានស្ត្រីចំនួន ៥២ នាក់ និងកុមារចំនួន ១៣ នាក់ផង ស្ថិតនៅចំណុចភូមិអូរដាលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង៕

## ឃាត់រថយន្តសង្ស័យ ក្នុងស្រុកអារញ្ញ ឃើញពលករខ្មែរ ៧ នាក់ ដែលឆ្លងដែនខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១៥ តុលា ២០២១ដោយ Sorn Phanith

ជនជាតិថៃម្នាក់ ដែលជាអ្នកបើកបររថយន្ត ព្យាយាមបើករត់គេចពីកម្លាំងសមត្ថកិច្ច ត្រូវបានឃាត់ខ្លួន និងពលករខ្មែរចំនួន ៧ នាក់ ក៏ត្រូវបាននាំយកទៅសាកសួរដែរ ពាក់ព័ន្ធនឹងករណីលបឆ្លងដែនខុសច្បាប់ចូលទៅក្នុងប្រទេសថៃ ដើម្បីរកការងារធ្វើ។ ការឃាត់រថយន្តនេះគឺបានធ្វើឡើងនៅវេលាម៉ោង ៨ និង ៥០ នាទី ព្រឹក ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០២១ លើកំណាត់ផ្លូវជាតិលេខ ៣៤៨ ក្នុងឃុំណងស័ង្ខ ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ។ នៅមុនពេលប្រតិបត្តិការ គឺកម្លាំងតម្រួតនៃអធិការដ្ឋានស្រុកអារញ្ញ បានស្ទាក់ឃាត់រថយន្តមួយគ្រឿងបន្ទាប់ពីមានការសង្ស័យ ដោយរថយន្តនោះម៉ាក តូយូតា សូឡូណា ពណ៌មាស ពាក់ស្លាកលេខ បាងកក ៩០៣៩ ដែលកំពុងបោះពួយយ៉ាងលឿនក្នុងទិសដៅ ពីគោកខ្សូង ឆ្ពោះទៅអារញ្ញប្រាថេត។ នៅពេលឃើញសមត្ថកិច្ច ស្រាប់តែរថយន្តនោះបានបួងចង្កូតឆ្លងកាត់សួនពុះចែកទ្រូងផ្លូវបម្រុងត្រឡប់ក្រោយ បណ្ដាលឲ្យជាប់នៅទីនោះតែម្ដង។

ក្រោយពេលសមត្ថកិច្ចចូលពិនិត្យ គឺសង្កេតឃើញថា មានជនជាតិថៃម្នាក់ជាអ្នកបើកបរ ដោយឡែកនៅក្នុងរថយន្តមានពលករខ្មែរចំនួន ៧ នាក់ ក្នុងនោះស្រី ៣ នាក់ ដែលពួកគេបានជិះរថយន្តបម្រុងបន្តចូលទៅក្នុងទឹកដីថៃរកការងារធ្វើ។ បច្ចុប្បន្នអ្នកបើកបរដែលជាជនជាតិថៃ ត្រូវបានឃាត់ខ្លួនដើម្បីអនុវត្តតាមផ្លូវច្បាប់ ដោយឡែកពលករខ្មែរទាំង ៧ នាក់ កំពុងត្រូវបានបញ្ជូនទៅអធិការដ្ឋាន ស្រុកអារញ្ញប្រាថេតដើម្បីសាកសួរបន្ត៕**សោ និយមវត្ថ៍**

## ឃាត់ខ្លួនមេខ្យល់៣នាក់ និងពលករ៨នាក់ ដែលបម្រុងលួចឆ្លងដែនទៅថៃ

http://freshnewsasia.com/ 2021-10-15 03:37pm

**(បាត់ដំបង)៖** មេខ្យល់៣នាក់ និងពលករចំនួន៨នាក់ ដែលបម្រុងលួចឆ្លងដែនចូលទៅប្រទេសថៃដោយខុសច្បាប់ ត្រូវកម្លាំងសមត្ថចម្រុះឃាត់ខ្លួនបាន នៅវេលារំលងអាធ្រាត្រថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ស្ថិតនៅក្នុងភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។

សមត្ថកិច្ចបានបញ្ជាក់ថា ប្រតិបត្តិនេះអនុវត្តរួមគ្នារវាងកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ជាមួយកម្លាំងយោធាសឹករងស្រុកសំពៅលូន ព្រមទាំងកម្លាំងវរសេនាតូចលេខ៥៣៣។ សមត្ថកិច្ចបានឱ្យដឹងថា ក្រោយបង្ក្រាបជាក់ស្តែងរួមមានពលករខ្មែរសរុបចំនួន៨នាក់ ក្រោយមកបានបន្តនីតិវិធីសាកសួរ និងស្រាវជ្រាវទើបដឹងថា ក្នុងចំណោមពលករទាំង៨នាក់ខាងលើ មានបង្កប់នូវមេខ្យល់ចំនួន៣ផងដែរ ដែលបម្រុងនាំមនុស្សចំនួន៨នាក់ ទៅប្រទេសថៃ ដោយខុសច្បាប់។

មេខ្យល់ប្រុស ស្រីទាំង៣នាក់ខាងលើនេះ រួមមានឈ្មោះ ធូ ជា ភេទប្រុស អាយុ២៥ឆ្នាំ មានទីលំនៅក្នុងភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ចំណែក២នាក់មានឈ្មោះ បូ វន ភេទស្រី អាយុ៣៣ឆ្នាំ និងឈ្មោះ រឿន សុងវិ ភេទប្រុស អាយុ២០ឆ្នាំ អ្នកទាំង២នាក់ រស់នៅភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ ករណីប៉ុនប៉ងបម្រុងធ្វើសកម្មភាពល្មើសច្បាប់លួចឆ្លងដែននេះ កម្លាំងបង្ក្រាបដកហូតបានវត្ថុតាងបានមួយចំនួនរួមមាន៖ រថយន្ត ០១គ្រឿងម៉ាក Toyota Camry ពណ៌ខ្មៅ ផលិតឆ្នាំ១៩៩០ ពាក់ស្លាកលេខ ង-៥៨៦៩ ភព២ និងម៉ូតូចំនួន០២គ្រឿងទៀត ម៉ាកហុងឌ្រីម ពណ៌ខ្មៅ ផលិតឆ្នាំ២០១៧ និងម៉ាកវេវ ពណ៌ក្រហមលាយខ្មៅ ផលិតឆ្នាំ២០១៨។ បន្ទាប់ពីបញ្ចប់ការសាកសួរមេខ្យល់ទាំង៣នាក់ និងពលករខ្មែរទាំង៨នាក់ខាងលើនេះ រួមទាំងវត្ថុតាងត្រូវបានបញ្ជូនទៅឱ្យកម្លាំងអធិការដ្ឋានស្រុកសំពៅលូន ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់៕

# ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១

## ពលរដ្ឋខ្មែរ១៣នាក់ចាញ់បោកមេខ្យល់ដឹកទៅប្លង់ចោល យកថ្លៃឈ្នួលម្នាក់ ៦,០០០បាត ដើម្បីទៅថៃតែមិនបានសម្រេច

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ១៦ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ០៩:១៨

ខេត្តបន្ទាយមានជ័យ ៖ ប្រជាពលរដ្ឋខ្មែរ១៣នាក់ បានចាញ់បោកមេខ្យល់ដឹកទៅប្លង់ចោលក្នុងចំការដំឡូងមីមួយកន្លែង យកថ្លៃឈ្នួលទៅថៃម្នាក់៦,០០០បាត មិនបានសម្រេច ក៏ត្រូវកម្លាំងនគរបាលការពារព្រំដែនគោកលេខ៨០៧ ល្បាតប្រទះឃើញ និងធ្វើការឃាត់ខ្លួន នៅវេលាម៉ោង១១និង៣០នាទីយប់ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ នៅចំណុចខាងកើតផ្លូវលេខ៥៨ក្រវាត់ព្រំដែនប្រហែល៥០ម៉ែត្រ ក្នុងភូមិសាស្ត្រភូមិក្ដីបថ្ម ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ រួចបញ្ជូនឲ្យនគរបាលស្រុកថ្មពួក ដើម្បីមានវិធានការបន្ត ។

លោកវរសេនីយ៍ទោ ឈឿន គឹមឈុន អធិការនគរបាលស្រុកថ្មពួក បានឲ្យដឹងថា ពលករខ្មែរទាំង១៣នាក់ ក្នុងនោះមានស្រី០៥នាក់ និងកុមារ០១នាក់ រស់នៅភូមិខ្នារ ឃុំក្រសាំង ស្រុកចុងកាល ខេត្តឧត្តរមានជ័យ ។

បើយោងតាមការបំភ្លឺរបស់ពលរដ្ឋខ្មែរទាំង១៣នាក់ ប្រាប់ថា ពួកខ្លួនពិតជាមានបំណងចង់ឆ្លងដែនទៅធ្វើការនៅប្រទេសថៃមែន ហើយបានទាក់ទងបងប្អូនដែលធ្វើការនៅប្រទេសថៃ ដើម្បីទៅរកការងារធ្វើ បន្ទាប់មកពួកខ្លួនក៏បានទាក់ទងមេខ្យល់(មិនស្គាល់មុខ) ដោយគេយកថ្លៃឈ្នួលក្នុងម្នាក់៦,០០០បាត បន្ទាប់មកមេខ្យល់បានឲ្យរថយន្តម៉ាកតូរីសពណ៌ស១២កៅអីមិនចាំស្លាកលេខ ទៅយកពួកខ្លួននៅផ្ទះ ។ ពេលធ្វើដំណើរដល់ទីរួមស្រុកថ្មពួក ម្ចាស់រថយន្តនោះបានសុំលុយពួកខ្លួនម្នាក់១,៥០០បាត ប្រាប់ថាយកឲ្យថ្លៃអ្នកជូនផ្លូវឆ្លងដែន ។

ក្រោយយកលុយរួច ម្ចាស់រថយន្តបានឲ្យរថយន្តចំនួន០២គ្រឿងទៀតម៉ាកនីសាន់មួយគ្រឿង ពណ៌ត្រែអុី(ឡានទាហ៊ាន)០១គ្រឿង និង០១គ្រឿងទៀត ម៉ាកកាមរី ពុំចាំស្លាកលេខ មកសាងដឹកបន្តទៅច្រកបឹងត្រកួន ហើយបានដឹកទៅលាក់ទុកក្នុងចំការដំឡូងមីមួយកន្លែងឲ្យរង់ចាំមេខ្យល់មកទទួលយកទៅបន្ត ។ ដោយនៅចាំមេខ្យល់យូរពេក មិនឃើញមានអ្នកមកទទួល ម្យ៉ាងមេឃភ្លៀងផងនោះពួកខ្លួនក៏បាននាំគ្នាចេញមកលើផ្លូវក៏ត្រូវសមត្ថកិច្ចឃាមឃាត់សួរនាំតែម្ដង។

លោកអធិការបានបញ្ជាក់ថា បន្ទាប់ពីធ្វើការអប់រំ ណែនាំពួកគាត់កុំឲ្យចាញ់បោកមេខ្យល់ នាំឲ្យខាតបង់ប្រាក់កាស ព្រោះបច្ចុប្បន្នទាំងថៃនិងកម្ពុជា កំពុងតែប្រយុទ្ធប្រឆាំងការឆ្លងរាលដាលជំងឺកូវីដ-១៩ និងទប់ស្កាត់ឆ្លងដែនខុសច្បាប់ ។ ទន្ទឹមនោះ ពេលនេះបងប្អូនកំពុងចាញ់បោកមេខ្យល់ ធ្វើឲ្យខាតបង់ទាំងថវិកា និងពេលវេលាទៀត ។ ក្រោយពីបានធ្វើការអប់រំ និងកិច្ចសន្យារួច ពលរដ្ឋទាំងនោះត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កវិទ្យាល័យសម្ដេចឪ តាមបញ្ជារបស់លោក អែម សុខា អភិបាលស្រុកថ្មពួក ៕

## ឃាត់ខ្លួនជនជាតិថៃ ៧នាក់ ដែលមកពីខេត្តសមុទ្រប្រាកាន បម្រុងលបឆ្លងដែនមកធ្វើការនៅក្នុងប្រទេសកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១៥ តុលា ២០២១ដោយ Kang Tola

ប្រទេសថៃ ៖ ជនជាតិថៃចំនួន ៧ នាក់ ដែលក្នុងនោះមានប្រុស ៥ នាក់ និងស្រី ២ នាក់ ត្រូវបានតម្រួតការពារព្រំដែនថៃលេខ១២ ធ្វើការឃាត់ខ្លួននៅក្បែរខ្សែបន្ទាត់ព្រំដែន ខណៈដែលពួកគេបម្រុងលួចឆ្លងដែនចូលមកក្នុងប្រទេសកម្ពុជាដើម្បីរកការងារធ្វើ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីវេលាម៉ោង ៥ ព្រឹក ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ត្រង់ចំណុច ឃុំម៉ាកមុន ស្រុកគោកខ្សូង ខេត្តស្រះកែវ ប្រទេសថៃ បន្ទាប់ពីពួកគេកំពុងធ្វើដំណើរ ជិត

ដល់ព្រំដែនកម្ពុជា ក្នុងពេលដែលប្រទេសមានការរឹតបន្តឹង ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ កាន់តែមានសភាពធ្ងន់ធ្ងរ ពិសេសគឺមេរោគបម្លែងខ្លួន ដែលតា។

ពួកគេ បានអះអាងថា ពួកគេបានទាក់ទងការងារជាបុគ្គលិកកាស៊ីណូ អនឡាញ ក្នុងប្រទេសកម្ពុជា តាមរយៈផេកហ្វេសប៊ុក ទើបពួកគេនាំគ្នាជិះរថយន្តមកពីខេត្តសមុទ្រប្រាកាន មកចុះនៅស្រុកអារញ្ញប្រាថេត ហើយក៏មានរថយន្តតូរីស ពណ៌ស មកទទួល ដោយដឹកយកទៅទម្លាក់ត្រង់បរិវេណ ឃុំម៉ាកម៉ុន ដើម្បីដើរឆ្លងព្រំដែន។ ឯការលបឆ្លងដែននេះគឺ ដោយចូលទៅធ្វើការនៅក្នុងកាស៊ីណូអនឡាញដោយទៅដល់ទីនោះក្រុមហ៊ុននឹងជួយគ្រប់យ៉ាងទាំងការហូបចុក និងការស្នាក់នៅ ប៉ុន្តែមិនទាន់បានទៅដល់ផងត្រូវសមត្ថកិច្ចចាប់ខ្លួនទៅហើយ។ បច្ចុប្បន្នជនជាតិថៃទាំង ៧ នាក់ ត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋានតម្រួតស្រុកគោកខ្សូង ដើម្បីចាត់ការតាមនីតិវិធី ៕

*អត្ថបទ ៖ សោ និយមវ័ត្ថ*

## ស្ត្រីកម្ពុជាចំនួន ៤ នាក់ និងទារកម្នាក់ ដែលរស់នៅក្នុងប្រទេសចិនដោយខុសច្បាប់ត្រូវបានសង្គ្រោះឱ្យត្រឡប់មកប្រទេសកម្ពុជាវិញ

https://www.postkhmer.com/national/ រី សុចាន់ | Publication date 16 October 2021 | 16:09 ICT

**ភ្នំពេញៈ** អាជ្ញាធរកម្ពុជាប្រចាំប្រទេសចិន បានសហការជាមួយអាជ្ញាធរចិនជួយសង្គ្រោះស្ត្រីកម្ពុជាចំនួន ៤ នាក់ និងទារកម្នាក់ ដែលរស់នៅក្នុងប្រទេសចិន ដោយខុសច្បាប់ត្រឡប់មកប្រទេសកម្ពុជាវិញ។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសបញ្ជាក់នៅថ្ងៃទី ១៦ ខែតុលាថា៖ «ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងណាននីង ប្រទេសចិន បានសហការអន្តរាគមន៍ជាមួយអាជ្ញាធរចិន ជួយសង្គ្រោះស្ត្រីខ្មែរចំនួន៤ នាក់ និងទារកម្នាក់ ដែលមករស់នៅក្នុងប្រទេសចិន ដោយខុសច្បាប់ឱ្យវិលត្រឡប់មាតុប្រទេសវិញ»។ បើតាមលោក កុយ គួង ស្ត្រីកម្ពុជាទាំងនោះគ្រោងមកដល់ប្រទេសកម្ពុជា តាមជើងយន្តហោះ «CZ8313» នៅថ្ងៃទី ២៥ ខែតុលា នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ៕

## សមត្ថកិច្ច ឃាត់ខ្លួនពលករខ្មែរ ៥៧នាក់ ដែលមានបំណងលួចឆ្លងដែន ចូលប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ១៧ តុលា ២០២១ដោយ sopheak khoun

សមត្ថកិច្ចកម្ពុជា បានសហការជាមួយយោធាថៃ បង្ក្រាបមុខសញ្ញានាំពលករចេញ ដោយមិនស្របច្បាប់ ដើម្បីឆ្លងដែនចូលក្នុងប្រទេសថៃ ១ករណី។ កិច្ចប្រតិបត្តិការនេះ គឺបានធ្វើឡើងកាលពីព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០២១ ដឹកនាំដោយលោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរៈ៨១៩ និងលោកវរសេនីយ៍ត្រី លី ឡុងដែន មេបញ្ជាការរង ដឹកនាំកម្លាំងចំនួន ៩នាក់ រួមជាមួយកម្លាំងយោធា សហការជាមួយទាហានឈុតខ្មៅថៃកងរយលេខ ៥២៣ ធ្វើការទប់ស្កាត់ពលករលួចឆ្លងដែន ដោយមិនស្របច្បាប់ ចូលក្នុងប្រទេសថៃ នៅចំណុចចន្លោះបង្គោលសីមាលេខ ៥៣ និង៥៤ ក្នុងភូមិសាស្ត្រភូមិអូរក្រូច ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។

កម្លាំងចម្រុះ បានឃាត់ខ្លួនពលករចំនួន ៥៧នាក់ ដែលក្នុងនោះស្រី ២៣នាក់ និងក្មេង ៥នាក់ផងដែរ។ ក្រោយពីសួរនាំ គឺបានកំណត់មុខសញ្ញាជនសង្ស័យ ជាមេខ្យល់ម្នាក់ មានឈ្មោះ ឈន គ្រាន់ ភេទប្រុស អាយុ ៣៩ ឆ្នាំ រស់នៅ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។ ក្រោយសាកសួរ ក៏បានធ្វើកំណត់ហេតុប្រគល់ទៅឲ្យកម្លាំងអធិការដ្ឋាននគរបាលស្រុកកំរៀង អនុវត្តតាមនីតិវិធីច្បាប់៕ អត្ថបទ៖ សោ និយមវ័ត្ថ

# តម្លៃខ្លួនពលករខ្មែរឆ្លងដែនខុសច្បាប់ម្នាក់ៗហក់ឡើងដល់៩,០០០បាត

http://nokorwatnews.com/ 17/10/2021

ប្រទេសថៃ៖ សេចក្តីរាយការពីអ្នកសារព័ត៌មានថៃ កាលពីថ្ងៃទី១៦ តុលា ២០២១ ថាកម្លាំងអង្គភាពទាហានប្រាណទី១៣ កងកម្លាំងបូរផា និងកម្លាំងកងរយទាហានប្រាណទី១៣០២ ប្រចាំស្រុកខ្លងហាត បានចាត់កម្លាំងល្បាត និងឃ្លាំមើលក្នុងភូមិសាស្ត្រទទួលខុសត្រូវ ភូមិថាន់ ថៃ ឃុំថាប់ ព្រិក ស្រុកអារញ្ញ ខេត្តស្រះកែវ បានប្រទះឃើញឃាត់ខ្លួនពលករខ្មែរលួចឆ្លងដែនចូលមកប្រទេសថៃចំនួន២០នាក់ ក្នុងនោះប្រុស១៣និងស្រី៧នាក់។

សេចក្តីរាយការបញ្ជាក់ថា: ក្រោយពីសមត្ថកិច្ចថៃសួរនាំ ក្រុមពលករខ្មែរទាំងអស់ធ្វើដំណើរមកពីខេត្ត រួមមាន៖សៀមរាប,បន្ទាយមានជ័យ,បាត់ដំបង និងពោធិ៍សាត់ ត្រូវការឆ្លងចូលមកធ្វើការងារសំណង់ ក្នុងខេត្តឈុន បុរី ,ប៉ះធំ ថានី និងក្រុងបាងកក ដោយមុនលួចចូលមកប្រទេសថៃ ពលករខ្មែរទាំងអស់ខាងលើនិយាយថា មកប្រមូលផ្តុំគ្នានៅសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដោយចំណាយលុយឲ្យមេខ្យល់នាំពីប្រទេសខ្មែរ ទៅដល់កន្លែងធ្វើការក្នុងម្នាក់៩០០០បាត មុនចូលមកប្រទេសថៃបានចំណាយលុយមុនក្នុងម្នាក់ចំនួន៣០០០បាត ហើយ នៅសល់៦០០០បាតទៀត ហ្នឹងចំណាយនៅពេលទៅដល់គោលដៅ ដោយការចូលមកប្រទេសថៃ មានមេខ្យល់ជនជាតិខ្មែរជាអ្នកនាំផ្លូវឆ្លងអូរណាំសៃ ព្រំដែនកម្ពុជា-ថៃ ដើម្បីមករង់ចាំឡើងរថយន្តរបស់មេខ្យល់ជនជាតិថៃចូលទៅក្នុងប្រទេសថៃ ដូចដែលបានណាត់ទុក តែបែរជាត្រូវសមត្ថកិច្ចថៃចាប់ខ្លួនបានមុន ដោយពលករខ្មែរទាំង២០នាក់ខាងលើ មិនមានឯកសារឬលិខិតអនុញ្ញាតធ្វើដំណើរចូលប្រទេសថៃ និងលិខិតធ្វើការងារក្នុងប្រទេសថៃនោះឡើយ។យ៉ាងណាក៏ដោយ ក្រោយពីសមត្ថកិច្ចថៃអនុវត្តតាមវិធានរបស់សុខាភិបាល និងធ្វើកំណត់ហេតុចាប់ខ្លួនរួចរាល់ ក៏បញ្ជូនពលករខ្មែរទាំង២០នាក់នោះទៅឲ្យជំនាញ ដើម្បីចាត់ការតាមផ្លូវច្បាប់បន្ត៕

# ឃាត់ខ្លួននិងបញ្ជូនទីតុលាការ មេខ្យល់វ័យក្មេង២នាក់ពាក់ពន្ធ័នាំពលករទៅប្រទេសថៃ ដោយខុសច្បាប់

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 16/10/2021

ខេត្តបន្ទាយមានជ័យ៖ នៅល្ងាច ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០២១ មេខ្យល់ វ័យក្មេង២នាក់លួចនាំកលកររកការងារធ្វើនៅស្រុកថៃ ហើយបាននាំពលករមកពីប្រទេសថៃមកស្រុកខ្មែរវិញ តែត្រូវបានកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនឃាតខ្លួនបាន និងបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់វិធានការតាមច្បាប់ ។

លោកស្រី ឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង ទទួលផែនការងារ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា មេខ្យល់ទាំង២នាក់មានឈ្មោះ ម៉ា និត ភេទប្រុសអាយុ១៧ឆ្នាំ និងម្នាក់ទៀតឈ្មោះ ជឿន កុយ ភេទប្រុសអាយុ១៥ឆ្នាំ ទាំង២នាក់ នៅភូមិទំនប់ដាច់ ឃុំ អូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ លោកស្រី ឧត្តមសេនីយ៍ត្រី ឌី សុជាតិ បានបញ្ជាក់ឲ្យដឹងបន្តទៀតថា នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ កម្លាំងនគរបាលប៉ុស្តិ៍ ឃុំអូរបីជាន់ សហការជាមួយកម្លាំងយោធាឈរជើងនៅចំណុចភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ បានឃាត់ពលករ ចំនួន៤១ ក្នុងនោះ មានប្រុសមាន ស្រី បម្រុង ឆ្លងដែនទៅប្រទេសថៃ ក្នុងនោះក៏មានពលករខ្មែរចំនួន២នាក់មកពីប្រទេសថៃផងដែរ ។ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យបន្ទាប់មកកម្លាំងនគរបាលការិយាល័យ ជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការស្រាវជ្រាវឈានដល់ឃាត់ខ្លួនមេខ្យល់ចំនួន២នាក់ជាអ្នកនាំផ្លូវ មានឈ្មោះ ម៉ា និត និងឈ្មោះ ជឿន កុយ ។

លោកស្រី ឧត្តមសេនីយ៍ត្រី ឌី សុជាតិ បានបញ្ជាក់បន្ថែមថា តាមការសាកសួរនាំ ជនសង្ស័យឈ្មោះ ម៉ា និត និងឈ្មោះ ជឿន កុយ បានសារភាពថាគេទាំង២នាក់ ពិតជាអ្នកនាំផ្លូវពលករខ្មែរដែលមកពីថៃនិងពលករទៅធ្វើការនៅប្រទេសថៃពិតមែន ហើយសកម្មភាពនេះពួកគេបានជូនពលករ ទៅ មកបាន ចំនួន២លើក ឲ្យគេនាំផ្លូវមកខ្មែរវិញក្នុង១នាក់ពលករបង់ឲ្យតំលៃជូនតម្លៃ២,០០០បាត និងទី២ចំណែកពលករដែលឲ្យពួកគេនាំផ្លូវទៅថៃវិញក្នុង១នាក់ពលករឲ្យតំលៃជូនក៏២០០០បាតដែរ។

យោងតាមចម្លើយសារភាព ជនសង្ស័យទាំង២នាក់ កម្លាំងនគរបាលជំនាញការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅរសៀលថ្ងៃទី១៥ ខែតុលាឆ្នាំ២០២១ ចាត់តាមនិតិវីធីហើយដែរ៕

## ពលករខ្មែរ៣៧នាក់ត្រូវឃាត់ខ្លួន ខណៈបម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 15/10/2021

ខេត្តបន្ទាយមានជ័យ៖ ពលករខ្មែរ ប្រុស ស្រី ចំនួន ៣៧នាក់ បម្រុងលួចឆ្លងដែនទៅរកការងារធ្វើខុសច្បាប់ចូលទៅប្រទេសថៃ ត្រូវបានកំលាំងវរសេនាតូចថ្មើរជើងលេខ៥១៣ល្បាតនៅព្រំដែនឃាត់ខ្លួនបាន នៅយប់ចូល ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ នៅជួរមុខតាមខ្សែបន្ទាត់ព្រំដែន ខ្មែរ-ថៃ នៅភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

លោក វរសេនីយ៍ទោ យូ សុគន្ធភក្តី មេបញ្ជាការវរសេនាតូចថ្មើរជើងលេខ៥១៣ បានប្រាប់អ្នកយកព័ត៌មានឲ្យដឹងថា លោកបានដឹកនាំកម្លាំង១ក្រុម សហការជាមួយកម្លាំងចម្រុះចុះល្បាតនៅតាមខ្សែបន្ទាត់ព្រំដែន ខ្មែរ-ថៃ ត្រង់ចំណុច ភូមិសិលាខ្មែរ បានប្រទះឃើញពលករខ្មែរ ចំនួន ៣៧នាក់ ក្នុងនោះមានស្រី ១៨នាក់ ដែលបម្រុងលួចឆ្លងដែនចូលទៅបប្រទេសថៃ ក្រោយឃាត់ខ្លួនបានហើយប្រគល់ទៅឲ្យកម្លាំងជំនាញ ដើម្បីអនុវត្តទៅតាមច្បាប់។ លោក វរសេនីយ៍ទោ យូ សុគន្ធភក្តី បានប្រាប់ឲ្យដឹងបន្តថាពលករទាំង៣៧នាក់ នេះក្រោយពីសួនាំបាននិយាយថា ក្រុមខ្លួនបានលួចឆ្លងដែនដោយខុសច្បាប់ ចូលទៅក្នុងទឹកដីថៃ ដើម្បីស្វែងរកការងារធ្វើក្នុងខេត្តផ្សេងៗ ក្រោយពេលឃាត់ខ្លួនកំលាំងយោធាបានឲ្យក្រុមគ្រូពេទ្យជំនាញពិនិត្យសុខភាពពួកគេទាំងអស់គ្នាជាមុន ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវី-១៩ ចូលក្នុងសហគមន៍។ ក្រោយពីក្រុមគ្រូពេទ្យពិនិត្យហើយធ្វើការអប់រំនិងដើម្បីធ្វើចត្តាឡីស័កនៅទីនោះរួចរាល់ហើយឲ្យវិលត្រឡប់ទៅលំនៅដ្ឋានរៀងៗវិញ។

សូមបញ្ជាក់ថា ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ កុំឲ្យឆ្លងចូលសហគមន៍ កម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៣ បានយកចិត្តទុកដាក់អនុវត្តតាមបទបញ្ជាថ្នាក់លើទាំង ៣ទិស ក្នុងខេត្តបន្ទាយមានជ័យ ចាប់ពីទិសអូរនាង ប៉ោយប៉ែត និងទិសម៉ាឡៃ សហការជាមួយកម្លាំងនៅតាមមូលដ្ឋានចេញល្បាតឆែកឆេរត្រួតពិនិត្យជាប្រចាំក្នុងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ជាប្រចាំផងដែរ៕

## យោធាថៃបញ្ជូនពលករខ្មែរចំនួន២០នាក់លួចឆ្លងដែន ខុសច្បាប់ មកកម្ពុជាវិញ

http://nokorwatnews.com/ 18/10/2021

**ក្រុងប៉ោយប៉ែត ៖** ក្រោយពីពិធីបុណ្យភ្ជុំបិណ្ឌរួចសង្កេតឃើញមានប្រជាពលរដ្ឋខ្មែរបានសម្រុកឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ ហើយត្រូវបានសមត្ថកិច្ចថៃ ឃាត់ខ្លួនបញ្ជូនមកខ្មែរវិញជាបន្តបន្ទាប់ដែលទាំងនេះក៏ដោយសារតែគត្តាចាញ់បោកការឃោសនាអូសទាញរបស់មេខ្យល់ ។ មួយវិញទៀតខាងសមត្ថកិច្ចកម្ពុជាក៏មានវិធានការរឹតបន្តឹងក្នុងការទប់ស្កាត់ការលួចឆ្លងដែនដោយខុសច្បាប់របស់ប្រជាពលរដ្ឋ ទាំងនេះផងដែរ

តែទោះជាយ៉ាងណាក៏នៅមានការឆកល្វែងផងដែរ ។ ជាមួយគ្នានោះ សមត្ថកិច្ចកម្ពុជាក៏បានទប់ស្កាត់ប្រជាពលរដ្ឋខ្លួននិងបានធ្វើការអប់រំណែនាំរួចឲ្យគាត់វិលត្រឡប់ទៅលំនៅឋានជាបន្តបន្ទាប់។ ហើយទន្ទឹមនោះដែរគេក៏សង្កេតឃើញប្រជាជនថៃ ក៏មានបំណងលួចឆ្លងដែនមកធ្វើការនៅកម្ពុជា ហើយក៏ត្រូវសមត្ថកិច្ចថៃ ក៏ដូចជាសមត្ថកិច្ចកម្ពុជាបានទប់ស្កាត់ ការឆ្លងដែនខុសច្បាប់ នៅក្នុងដំណាក់កាលនៃប្រទេសទាំង០២កំពុងតែប្រយុទ្ធប្រឆាំងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩នេះ ។

បើតាមការឲ្យដឹងពីលោក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោក លេខ៨១៥ បានឲ្យដឹងនៅវេលាម៉ោង០៣ និង២៥នាទី ល្ងាចថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២១កន្លងទៅនេះថា មានប្រជាពលរដ្ឋខ្មែរលួច ឆ្លងដែនដោយខុសច្បាប់ ដែលសមត្ថកិច្ចថៃសហការជួយទប់ស្កាត់ នៅវេលាម៉ោង០៤ និង១០នាទី ល្ងាចនាថ្ងៃដដែលទាហានឈុតខ្មៅថៃ អនុសេនាធំលេខ១៣០២ បានទប់ស្កាត់ឃាត់បានប្រជាពលរដ្ឋខ្មែរប្រុស ស្រី ចំនួន២០នាក់នៅចំណុចភូមិប៉ាយខៀវ ឃុំផានស៊ឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ។ ត្រូវបានបញ្ជូនទៅឲ្យតម្រួតនៃអធិការដ្ឋានលួងណាំសែ ស្រុកអារញ្ញ ដើម្បីមានវិធានការបន្ត ។ លោក សួង សៅ បានបញ្ជាក់ថា៖ បើតាមការសាកសួរទៅសមត្ថកិច្ចថៃ ចំពោះប្រជាពលរដ្ឋខ្មែរទាំង២០នាក់នោះ ត្រូវបានបញ្ជូនមកកម្ពុជា តាមច្រកអូរបីជាន់ ស្រុកអូរជ្រៅវិញខេត្តបន្ទាយមានជ័យវិញហើយ៕

## អាមេរិកប្តេជ្ញាចិត្តបន្តជួយគាំទ្រការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជាឲ្យនៅកម្រិតទាបបំផុត

https://news.btv.com.kh/ 10/18/2021 07:10 PM

ភ្នំពេញៈ នៅក្នុងកិច្ចប្រជុំជាមួយកម្ពុជា ទាក់ទងនឹងការជួយជួរមនុស្ស នៅល្ងាចថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១នេះ ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា លោក W. Patrick Murphy ប្តេជ្ញាចិត្តក្នុងការបន្តជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់ការជួញដូរមនុស្សឲ្យនៅសល់កម្រិតទាបបំផុត ខណៈកម្ពុជាកំពុងធ្វើសេចក្តីព្រាងទាក់ទងនឹងការជួញដូរមនុស្សនេះក្នុងវិស័យអប់រំនោះ នេះបើតាមការបញ្ជាក់របស់លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។

ថ្លែងប្រាប់អ្នកសារព័ត៌មានក្រោយពីកិច្ចប្រជុំ ជាមួយភាគីអាមេរិកទាក់ទងនឹងការជួយជួរមនុស្ស ដែលបានធ្វើឡើងនៅក្នុងក្រសួងយុត្តិធម៌ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានឲ្យដឹងថា នៅក្នុងកិច្ចប្រជុំ ភាគីទាំងពីរ បានពិភាក្សាគ្នាជាច្រើនទាក់ទងនឹងការជួញដូរមនុស្ស ហើយនៅក្នុងកិច្ចប្រជុំនេះខាងទូតអាមេរិកប្រចាំនៅកម្ពុជា បានប្តេជ្ញាយ៉ាងម៉ឺតមាំថានឹងបន្តជួយកម្ពុជាជានិច្ច ជាពិសេសខិតខំធ្វើយ៉ាងណាជួយកម្ពុជាឲ្យរួចពីចំណាត់ថ្នាក់លេខពីរមកជាភាពល្អប្រសើរទាក់ទងនឹងការឃ្លាំមើលលើការជួញដូរមនុស្សនៅកម្ពុជាពីសំណាក់រដ្ឋាភិបាលអាមេរិកនោះ។ ជាមួយគ្នានោះដែរលោកជំទាវ ជូ ប៊ុនអេង ក៏បានបញ្ជាក់ជាថ្មីផងដែរថា នាពេលបច្ចុប្បន្ននេះ ក្រសួងពាក់ព័ន្ធ ជាពិសេសគឺក្រសួងមហាផ្ទៃ បានកំពុងរៀបចំតាក់តែងសេចក្តីព្រាងមួយចំនួនទាក់ទងនឹង ការជួញដូរមនុស្សនេះ ទៅក្នុងវិស័យអប់រំដើម្បីធ្វើយ៉ាងណាបញ្ច្រៀបអំពីបញ្ហាការជួញដូរមនុស្សដល់ការ បឋមសិក្សា និងមធ្យមសិក្សាផងដែរ។

សូមបញ្ជាក់ថា នៅក្នុងរយៈពេល៩ខែ ឆ្នាំ២០២១នេះ សមត្ថកិច្ចបានធ្វើការបង្ក្រាបករណីជួញដូរ មនុស្សបានជិតពីររយករណី ហើយបានជួយសង្គ្រោះជនរងគ្រោះឲ្យរួចផុតពីការជួញដូរមនុស្សនេះបាន ជាច្រើននាក់ផងដែរ ខណៈជនល្មើសបានចាត់វិធានការទៅតាមផ្លូវច្បាប់ជាធរមាននោះ៕ អត្ថបទ: បាន ចក់

# ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១

## ក្រុមការងារអន្តរក្រសួងស្ថាប័ន ជួបពិភាក្សា ជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ពាក់ព័ន្ធនឹងវឌ្ឍនភាព លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់កម្ពុជា

https://cen.com.kh/ Posted ByPen Srey NeatOctober 19, 2021

ភ្នំពេញ ៖ លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី អនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំក្រុមការងារអន្តរក្រសួងស្ថាប័នដើម្បីជួបពិភាក្សា ជាមួយ ឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅកម្ពុជា ពាក់ព័ន្ធនឹងវឌ្ឍនភាព លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់កម្ពុជា។ កិច្ចប្រជុំពិនិត្យនិងពិភាក្សាស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានការចូលរួមពីតំណាងពីក្រសួងយុត្តិធម៌ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងធនាគារជាតិនៃកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

កិច្ចប្រជុំបានពិភាក្សាលើបញ្ហា ពាក់ព័ន្ធនឹង ទី១.ការកាត់ទោសជនល្មើសជួញដូរមនុស្ស ទី២.ទិន្នន័យជាក់លាក់និងស៊ីជម្រៅ នៃការកាត់ទោសបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ទី៣.ការចុះធ្វើអធិការកិច្ចការងារលើកន្លែង ដែលមានហានិភ័យខ្ពស់ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដូចជាការដ្ឋានសំណង់ ឡូតដូ និងកន្លែងសេវាកម្សាន្តជាដើម ទី៤.ការធ្វើអធិការកិច្ចលើស្ថាប័ន ផ្តល់ប្រាក់កម្ចីនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងទី៥. វឌ្ឍនភាពលើការកំណត់អត្តសញ្ញាណជនរងគ្រោះ។

ទន្ទឹមនេះ ប្រតិភូសហរដ្ឋអាមេរិក ក៏មានបំណងឈ្វេងយល់បន្ថែមនូវការងាររបស់ក្រសួងអប់រំ យុវជននិងកីឡា ដែលបានបញ្ចូលមេរៀននៃការទប់ស្កាត់អំពើជួញដូរមនុស្ស ទៅក្នុងកម្មវិធីសិក្សាអប់រំផងដែរ។ គណៈប្រតិភូអាមេរិក ក៏បានសម្តែងនូវការកោតសរសើរ ដល់រាជរដ្ឋាភិបាល លើវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការបង្ក្រាបអំពើជួញដូរមនុស្ស ក៏ដូចជាការប្រមូលទិន្នន័យពាក់ព័ន្ធ នឹងអំពើជួញដូរមនុស្សនៅកម្ពុជា។

ក្រសួង ស្ថាប័នជំនាញ បានពន្យល់យ៉ាងក្បោះក្បាយនូវចំណុចទាំងនេះ ដូចជាតំណាងក្រសួងយុត្តិធម៌ បានពន្យល់ ក៏ដូចជាផ្តល់នូវឧទាហរណ៍ក្នុងការអនុវត្តច្បាប់ ដោយគ្មានការអត់ឱនរបស់កម្ពុជា ចំពោះអ្នកដែលប្រព្រឹត្តិនិងពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ហើយកំពុងរៀបចំប្រព័ន្ធកុំព្យូទ័រសម្រាប់ប្រមូលទិន្នន័យ ដើម្បីជានាបានភាពកាន់តែសុក្រិត្យនៃច្បាស់លាស់នៃទិន្នន័យ ផងដែរ។

ទន្ទឹមនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានលើកឡើងអំពីការធ្វើអធិការកិច្ចការងារ និងយន្តការដែលបានបង្កើត ដើម្បីធ្វើអធិការកិច្ចការងារក្នុងវិស័យសំណង់ កសិកម្ម កម្មន្តសាល និងឡូតដូ ដែលជាវិស័យមានហានិភ័យខ្ពស់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។ ចំណុចទី៤ ឆ្លើយតបដោយធនាគារជាតិនៃកម្ពុជា និងចំណុចទី៥ដោយ គ.ជ.ប.ជ ហើយក្នុងនោះក្រសួងអប់រំ យុវជន និងកីឡា ក៏បានបង្ហាញពីខ្លឹមសារនៃការដាក់បញ្ចូល ការទប់ស្កាត់អំពើជួញដូរមនុស្ស ទៅក្នុងកម្មវិធីសិក្សាថ្នាក់បឋមសិក្សា មធ្យមសិក្សា និងបង្កើតសម្ភារៈឧបទ្ទេសសម្រាប់គ្រូបង្រៀនផងដែរ។ ក្រសួងអប់រំនឹងផ្តល់ឯកសារមេរៀននេះដល់ភាគីអាមេរិកដើម្បីស្វែងយល់បន្ថែម។

កិច្ចប្រជុំបានបញ្ចប់ទៅដោយបរិយាកាសរីករាយ ស្និទ្ធស្នាល និងទទួលបានលទ្ធផលជាវិជ្ជមាន ហើយភាគីទាំង២ បានឯកភាពគ្នា ថានឹងបន្តកិច្ចសន្ទនាជាទៀងទាត់ ជាពិសេសបង្កើនកិច្ចសន្ទនាឱ្យបានញឹកញាប់រវាងមន្ត្រី

បច្ចេកទេសនៃភាគីទាំងពីរ ក្នុងគោលបំណងពង្រឹងកិច្ចសហការ ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស ដែលជាទាសភាពសម័យថ្មី។

ឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា បានលើកឡើងថា រដ្ឋាភិបាលរបស់លោកប្តេជ្ញាចិត្ត ក្នុងការបន្តជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់ការជួញដូរមនុស្សឲ្យនៅសល់កម្រិតទាបបំផុត ។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ បានបញ្ជាក់ថា ជាទូទៅសហរដ្ឋអាមេរិក គាត់មានការប្តេជ្ញាចិត្តថា ជួយប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សគ្រប់ប្រទេស។ ដោយឡែកកម្ពុជា គាត់ប្តេជ្ញាចិត្តថា នឹងបន្តគាំទ្រ ដើម្បីធ្វើយ៉ាងណាឲ្យសកម្មភាពជួញដូរមនុស្ស ត្រូវបានកាត់បន្ថយ៕ រក្សាសិទ្ធិដោយ ៖ កូលាប

## ឃាត់ខ្លួនមេខ្យល់ ៣នាក់ កំពុងនាំពលករខ្មែរ លួចឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ

https://kohsantepheapdaily.com.kh/ ១៥ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ១៧:៤៧

ខេត្តបាត់ដំបង ៖ នៅព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ កងកម្លាំងកងពលតូច ថ្មើរជើងលេខ៥៣ បានឃាត់ខ្លួន មេខ្យល់ចំនួន៣នាក់ កំពុងនាំពលករចំនួន៨នាក់ ក្នុងនោះស្រីចំនួន១នាក់ លួចឆ្លងដែនទៅប្រទេសថៃ ។

លោកអនុសេនីយ៍ឯក ទ្រី ងឿន មេបញ្ជាការរង វរសេនាតូចលេខ៥៣ បានឲ្យដឹងថា អនុវត្តតាមបទបញ្ជាមេបញ្ជាការ លោកបានបញ្ជាដឹកនាំកងកម្លាំងល្បាត តាមខ្សែព្រំដែនកម្ពុជា-ថៃ ដោយសហការជាមួយកម្លាំងប៉ូលីសការពារព្រំដែនគោក លេខ៨១៧ និងផ្នែកសឹករងស្រុកសំពៅលូន បានឃាត់ខ្លួនមេខ្យល់ចំនួន ៣នាក់ កំពុងនាំពលករឆ្លងដែនទៅកាន់ប្រទេសថៃ ស្ថិតនៅចំណុចភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

មេខ្យល់ ដែលត្រូវបានឃាត់ខ្លួនរួមមាន ៖ ទី១, ឈ្មោះ បូ វន ភេទស្រី អាយុ ៣៣ឆ្នាំ រស់នៅភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃខេត្តបន្ទាយមានជ័យ ។ ទី២. ឈ្មោះ រឿន សុងរី ភេទប្រុស អាយុ ២០ឆ្នាំ ភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ និងទី៣. ឈ្មោះ ថា ធូជារ ភេទប្រុស អាយុ២៥ ឆ្នាំ ភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបងដោយរួមមាន ម៉ូតូម៉ាកវ៉េវ ពណ៌ក្រហមខ្មៅ ចំនួន១គ្រឿង, ម៉ូតូម៉ាកហុងដាឌ្រីម ចំនួន១គ្រឿង និងឡានម៉ាកកាមារីកាត់គូទចំនួន១គ្រឿង ។

បច្ចុប្បន្នមេខ្យល់ទាំង៣នាក់នោះ ត្រូវបានបញ្ជូនទៅអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់ ៕

## ឃាត់ខ្លួនមេខ្យល់ ២នាក់ ដែលកំពុងនាំពលករ បម្រុងហែលឆ្លងទឹកអូរព្រំដែនចូលប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១៨ តុលា ២០២១ដោយ Sorn Phanith

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ១ រសៀល កម្លាំងចម្រុះ ដែលមានប៉ុស្តិ៍គីឡូ១៣ កម្លាំងវរៈ ៨១៧ កម្លាំងយោធាផ្នែកសឹករងស្រុក និងកម្លាំងវរ៥៣៣ បានធ្វើសកម្មភាពទប់ស្កាត់ប្រជាពលរដ្ឋ បម្រុងលួចឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ។ ការទប់ស្កាត់នេះ បានធ្វើឡើង នៅត្រង់ចំណុចភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ដោយបានឃាត់ខ្លួនមេខ្យល់ បានចំនួន ២ នាក់ និងពលករចំនួន ៥ នាក់ ក្នុងនោះស្រី៣នាក់ ខណៈដែលពួកគេត្រៀមឆ្លងទឹកអូរព្រំដែន ដែលកំពុងជន់ជោរ។ មេខ្យល់ទាំង២នាក់នោះគឺ ១.ឈ្មោះ ពិត ស្រស់ ភេទប្រុស អាយុ៣៧ឆ្នាំ និង ២.ឈ្មោះ មឿន រីត ភេទប្រុស អាយុ៣៧ឆ្នាំ ជនទាំងពីរមានទីលំនៅភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំណែកពលករទាំង៥នាក់ មានទីលំនៅភូមិអូរគគីរកណ្តាល ឃុំត្រាង

ស្រុកកំរៀង ខេត្តបាត់ដំបង ។ បន្ទាប់ពីទប់ស្កាត់បាន និងសាកសួរួចមក កម្លាំងចម្រុះ បានធ្វើកំណត់ហេតុរួចបាន ប្រគល់ពលករនិងមុខសញ្ញា(មេខ្យល់)ខាងលើទៅឲ្យខាងកម្លាំងអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដើម្បីចាត់ការបន្ត៕

## ពលករខ្មែរចំនួន០៧នាក់ បានស្នើសុំឲ្យស្ថានអគ្គកុងស៊ុលជួយបញ្ជូនពួកគាត់ត្រឡប់នៅកម្ពុជាវិញ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១៨ តុលា ២០២១ដោយ Kang Tola

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ មានពលករខ្មែរចំនួន០៧នាក់ (ស្រី០៤នាក់) និងកូនក្មេង០១នាក់) ដែលបានធ្វើដំណើរមកពីបណ្តាខេត្តនានា នៅក្នុងទឹកដីប្រទេសថៃ បានមកស្នើសុំឲ្យស្ថានអគ្គកុងស៊ុល ជួយបញ្ជូនពួកគាត់ត្រឡប់ទៅកម្ពុជាវិញ នេះបើតាមលោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា។ លោក កុយ គួង បានឲ្យដឹងនារសៀលថ្ងៃទី១៨ ខែតុលា នេះថា បន្ទាប់ពីសាកសួរ និងស្រង់ឈ្មោះរួច ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលប្រចាំខេត្តសាកែវ បានអន្តរាគមន៍ និងស្នើសុំទៅមន្ត្រីនគរបាលអន្តោប្រវេសន៍ខេត្តសាកែវ និងអាជ្ញាធរកម្ពុជាប្រចាំច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បញ្ជូនពលករខ្មែរខាងលើត្រឡប់ទៅកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ហើយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល៕ *ដោយ ៖ កោះកែវ*

## ពិតជាមិនធម្មតា!!ពលករខ្មែរចំនួន១០៤នាក់ត្រូវយោធាថៃឃាត់ខ្លួន

http://nokorwatnews.com/ 19/10/2021

ប្រទេសថៃ ៖ យោធាថៃបានធ្វើការឃាត់ខ្លួនពលករខ្មែរចំនួន១០៤ ដែលជឿជាក់មេខ្យល់ឆ្លងដែនខុសច្បាប់នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១នេះ។ សមត្ថកិច្ចតាមបន្ទាត់ព្រំដែនប្រាប់ថាៈ អាជ្ញាធរមានសម្ថកិច្ចថៃ បានចុះត្រួតពិនិត្យ នៅតាមច្រកព្រំដែនកម្ពុជា ថៃ បានឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរ លួចចូលក្នុងប្រទេសថៃ ដោយខុសច្បាប់ចំនួន ១០៤នាក់ នៅត្រង់បរិវេណ សួនប៉ាយូខាលីបតាន់ ខេត្តស្រះកែវ។ សមត្ថកិចបន្តថា ជនជាតិខ្មែរទាំងអស់ក៏បានសារភាពថា ពួកគាត់បានបង់ប្រាក់ទៅឱ្យមេខ្យល់ក្នុងម្នាក់ ចាប់ពី ៦,០០០បាត ទៅដល់ ៩,០០០បាត ដើម្បីឆ្លងដែនរកការងារធ្វើក្នុងប្រទេសថៃ។

ពលករខ្មែរទាំងអស់ក្រោយពីសមត្ថកិច្ចសួរនាំនៅល្ងាចថ្ងៃដដែលនេះ បានធ្វើការ ផាកពិន័យរួចរាល់ អាជ្ញាធរស្ថានីយ៍និងប៉ូលិសតាព្រះយ៉ា នឹងបញ្ជូនពួកគាត់ឱ្យត្រឡប់ចូលប្រទេសកម្ពុជាវិញតាមច្រកតំបន់ ឃុំគោកឃ្យូង ស្រុកតាព្រះយ៉ា ចូលមកកម្ពុជាក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ៕

## អ្នកនាំពាក្យ៖ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ អន្តរាគមន៍ដោះលែងពលរដ្ឋខ្មែរ១០៤នាក់

https://cen.com.kh/ Posted ByPen Srey NeatOctober 19, 2021

ភ្នំពេញ ៖ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ ប្រទេសថៃ បានអន្តរាគមន៍សហការជាមួយអាជ្ញាធរថៃ សម្របសម្រួលដោះលែងពលរដ្ឋខ្មែរចំនួន១០៤នាក់ (ប្រុស៦៥នាក់) ដែលត្រូវបានមេខ្យល់នាំចូលមកប្រទេសថៃដោយខុសច្បាប់តាមច្រករបៀង ហើយត្រូវបានសមត្ថកិច្ចថៃឃាត់ខ្លួនកាលពីព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១។ នេះបើតាមការបញ្ជាក់របស់លោកកុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា នៅព្រឹកថ្ងៃទី១៩ ខែតុលា។

អ្នកនាំពាក្យបានបន្តថា ក្រុមការងារស្ថានអគ្គកុងស៊ុលបានធ្វើការអប់រំអំពីហានិភ័យនៃការឆ្លងដែនខុសច្បាប់ និងហានិភ័យនៃការរីករាលដាលជម្ងឺកូវីដ១៩ និងបានសហការជាមួយអាជ្ញាធរថៃ និងអាជ្ញាធរកម្ពុជាបញ្ជូនពួកគាត់ទាំង១០៤នាក់ត្រឡប់មកកម្ពុជាវិញនៅល្ងាចថ្ងៃដដែល។

សូមជម្រាបថា ទាហានឈុតខ្មៅ តម្រួតការពារព្រំដែនថៃ បានចាប់ពលករខ្មែរចំនួនជាង ១០០នាក់ ដែលលួចឆ្លងដែនដោយខុសច្បាប់ចូលក្នុងទឹកដីថៃដើម្បីរកការងារធ្វើនៅរសៀលថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ក្នុងចម្ការដើមប្រេងខ្យល់ ក្នុងឃុំស៊ុំប៊ូន ស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ ប្រទេសថៃ ។ បន្ទាប់ពីចាប់ខ្លួនកក្រុមពលករខ្មែរបានសារភាពថា ពួកគេទាំងអស់មាន បំណងឆ្លងចូលទៅរកការងារធ្វើនៅក្នុងប្រទេសថៃ ដោយខំចំណាយអោយមេខ្យល់ក្នុងម្នាក់ៗ ចាប់ពី ៦.០០០ បាត ដល់ ៩.០០០ បាត ប៉ុន្តែក៏ត្រូវឃាត់ខ្លួនតែម្តង ក្រោយពេលឃាត់ខ្លួន ក្រុមយោធាថៃបានត្រួតពិនិត្យសុខភាពពួកគេទាំងអស់ ដើម្បីការពារនៅក្នុងដំណាក់កាល នៃជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាត និងត្រៀមបញ្ជូនទៅអោយភាគីកម្ពុជាវិញនៅល្ងាចនេះតាមច្រកអូរបីជាន់ ដើម្បីអនុវត្តតាមនីតិវិធី៕ រក្សាសិទ្ធិដោយ ៖ ចេស្តារ

## ពលករខ្មែរ ១០៤នាក់ ដែលចាញ់បោកមេខ្យល់ត្រូវសមត្ថកិច្ចថៃ បញ្ជូនមកកម្ពុជាវិញ

http://freshnewsasia.com/ 2021-10-19 10:16am

**(បន្ទាយមានជ័យ)៖** យ៉ាងហោចណាស់មានពលករខ្មែរចំនួន១០៤នាក់ ដែលចាញ់បោកមេខ្យល់ទៅរកការងារធ្វើនៅប្រទេសថៃ ត្រូវបានសមត្ថកិច្ចថៃ ដឹកបញ្ជូនមកកម្ពុជាវិញ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១នេះ តាមច្រកតំបន់ឃុំឃោគសូង ស្រុកតាប្រះយ៉ា ចេញតាមច្រករបៀងអូបីជាន់ ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ។

គួរជម្រាបថា អាជ្ញាធរមានសមត្ថកិច្ចថៃ បានចុះត្រួតពិនិត្យនៅតាមច្រកព្រំដែនថៃ-កម្ពុជា រហូតឈានទៅឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរដែលលួចឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ ចំនួន ១០៤នាក់ នៅត្រង់បរិវេនសួនប៉ាយូខាលីបតាន់ ខេត្តសាកែវ។ ក្រោយពីការសាកសួរពីសមត្ថកិច្ច ប្រជាពលរដ្ឋខ្មែរទាំងអស់ក៏បានសារភាពថា ពួកគាត់បានបង់ប្រាក់ទៅឱ្យមេខ្យល់ក្នុងម្នាក់ៗ ចាប់ពី៦,០០០បាត ទៅដល់៩,០០០បាត ដើម្បីបានចូលប្រទេសថៃ។ បន្ថែមពីនេះទៀត នៅល្ងាចថ្ងៃដដែលនេះបន្ទាប់ពីធ្វើការផ្តន្ទាទោស និងផាកពិន័យរួច អាជ្ញាធរសមត្ថកិច្ចថៃតាប្រះយ៉ានឹងបញ្ជូនពួកគាត់ឱ្យត្រឡប់ចូលប្រទេសកម្ពុជាវិញ តាមច្រកតំបន់ឃុំឃោគសូង ស្រុកតាប្រះយ៉ា ចេញតាមច្រករបៀងអូបីជាន់ ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ។

អាជ្ញាធរខេត្តបន្ទាយមានជ័យ សូមធ្វើការអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូប សូមមេត្តាកុំចាញ់បោកមេខ្យល់បន្តទៀត ដែលធ្វើឱ្យខាតបង់លុយកាក់ច្រើនណាស់ ដូច្នេះសូមប្រជាពលរដ្ឋ មេត្តារង់ចាំបន្តិចសិនចុះវាមិនទាន់ហួសពេលនោះទេ ពីព្រោះការឆ្លងដែនខុសច្បាប់ចូលក្នុងទឹកដីរបស់គេនោះមិនប្រាកដថាចូលបានស្រួលនោះទេ ព្រោះប្រទេសថៃ កំពុងរឹកបន្តឹងការទប់ស្កាត់ការីករាលដាលនូវជំងឺកូវីដ១៩ ដូចកម្ពុជាផងដែរ៕

## ពលករលួចឆ្លងដែនខុសច្បាប់ជាច្រើននាក់ ត្រូវបានឃាត់ខ្លួន ដោយកងកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ

https://cen.com.kh/ Posted ByPen Srey NeatOctober 19, 2021

បន្ទាយមានជ័យ ៖ មានពលករជាច្រើននាក់បម្រុងឆ្លងដែនទៅធ្វើការខុសច្បាប់នៅប្រទេសថៃ ត្រូវបានឃាត់ខ្លួនដោយកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ។ ដោយមានការដឹកនាំបញ្ជាផ្ទាល់ពី លោកឧត្តមសេនីយ៍ត្រី ជឹម ប៊ុនអាន មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដាក់បទបញ្ជាយ៉ាងតឹងរឹង ការពារ

នៅតាមបន្ទាត់ព្រំដែន ក្នុងការ រឹតបន្តឹងសន្តិសុខព្រំដែនទប់ស្កាត់ពលករលួចឆ្លងដែន ជាពិសេសបានចាត់តាំងកម្លាំងចុះស៊ើបអង្កេតស្វែងរកមុខសញ្ញាមេខ្យល់ ចាប់ខ្លួនបញ្ជូនឲ្យសមត្ថកិច្ចជំនាញចាត់ការតាមផ្លូវច្បាប់។

ជាក់ស្តែង រសៀលថ្ងៃទី១៨ ខែតុលា និងព្រលឹមថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១នេះ ឧត្តមសេនីយ៍ត្រី រិទ្ធ រ៉ម មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ប្រចាំការទិសម៉ាឡៃ ដឹកនាំកម្លាំងអន្តរាគមន៍ផ្នែកសឹករងស្រុក សហការជាមួយនគរបាលវរសេនាតូចព្រំដែនលេខ៨១៥ ល្បាតត្រួតពិនិត្យតាមបន្ទាត់អូរព្រំដែនកម្ពុជាថៃ បានជួបប្រទះប្រជាពលរដ្ឋខ្មែរ លួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ចំនួន ៣៤នាក់ ស្រី ១៥នាក់ ស្ថិតក្នុងភូមិសាស្ត្រអូរព្រំដែន ភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ក៏ឃាត់ខ្លួនបានតែម្តង។

សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំង តំបន់ប្រតិបត្តិការសឹករងខេត្ត ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការសហការជាមួយកម្លាំងចម្រុះ ទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ បានឃាត់ខ្លួនពលករឆ្លងដែនបញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួន បញ្ជូនទៅសមត្ថកិច្ចជំនាញចាត់វិធានការតាមផ្លូវច្បាប់។

ក្រោយពីឃាត់ខ្លួន លោកមេបញ្ជាការរង បានណែនាំដល់បងប្អូនប្រជាពលរដ្ឋ កុំបន្តចាញ់បោកមេខ្យល់ដែលតែងតែបញ្ចុះបញ្ចូល នាំពលករឆ្លងដែនខុសច្បាប់ ដោយមិនគិតពីសុវត្ថិភាព និងខាតបង់ប្រាក់កាសជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣កុំ ៣ការពារ អោយបានទាំងអស់គ្នា និងបានប្រគល់ពួកគាត់អោយទៅកងរាជអាវុធហត្ថ ស្រុកម៉ាឡៃ ដើម្បីសាកសួរនិងបញ្ជូនទៅធ្វើចត្តាឡីស័ក៕រក្សាសិទ្ធិដោយ ៖ កូលាប

# ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១

## មេខ្យល់ម្នាក់ នាំពលករខ្មែរ១៩នាក់មានកុមារ២នាក់ បម្រុងឆ្លងដែន ត្រូវនគរបាលការពារព្រំដែនគោកឃាត់ខ្លួន

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១៩ តុលា ២០២១ដោយ Kang Tola

បន្ទាយមានជ័យ ៖ នៅវេលាម៉ោង៥និង១០នាទីព្រឹក ថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០២១ នៅចំណុចមាត់អូរព្រំដែន ស្ថិតក្នុងភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ និងកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំបឹងបេង សហការជាមួយ កម្លាំងយោធាប្រតិបត្តិការសឹករងខេត្តបន្ទាយមានជ័យ បានធ្វើការឃាត់ខ្លួនពលករខ្មែរ ប្រុស ស្រី ចំនួន១៩នាក់ ក្នុងនោះមានកុមារចំនួន២នាក់ និងមេខ្យល់១នាក់ បម្រុងលួចឆ្លងដែនទៅប្រទេសថៃ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានប្រាប់អ្នកយកព័ត៌មានឲ្យដឹងថា ពលករខ្មែរទាំង១៩នាក់ ក្នុងនោះមានស្រីចំនួន៦នាក់ កុមារចំនួន២នាក់ មកពី៤ខេត្ត ក្នុងនោះ ១.មានខេត្តបន្ទាយមានជ័យចំនួន៣នាក់ ២.ខេត្តបាត់ដំបងចំនួន៩នាក់ ៣.ខេត្តត្បូងឃ្មុំចំនួន១នាក់ និង ៤.ខេត្តព្រៃវែងចំនួន៦នាក់។ លោកវរសេនីយ៍ឯក សួង សៅ បានបញ្ជាក់ឲ្យដឹងបន្តទៀតថា ក្នុងចំណោម ពលរទាំង១៩នាក់នោះ សមត្ថកិច្ចចម្រុះបានរកឃើញមេខ្យល់ម្នាក់បម្រុងជូនពលករទាំង១៩នាក់លួចឆ្លងដែនចូលទៅប្រទេសថៃរកការងារធ្វើមាន ឈ្មោះ យឹន សុឃី ភេទប្រុស អាយុ៣៤ឆ្នាំ រស់នៅភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ លោកវរសេនីយ៍ឯក សួង សៅ បានបញ្ជាក់បន្ថែមទៀតថា ចំពោះពលករទាំងអស់និងមេខ្យល់បន្ទាប់ពីធ្វើការណែនាំស្តីពីការឆ្លងរាលដាលរបស់ មេរោគកូវីដ-១៩ និងធ្វើកិច្ចសន្យារួច បានបញ្ជូនពួកគាត់ទៅមណ្ឌលចត្តាឡីស័កកម្រិត២ វិទ្យាល័យម៉ាឡៃដើម្បីយកសំណាកធ្វើតេស្តរកមេរោគកូវីដ-១៩មុននឹងប្រគល់ជូនផ្នែកជំនាញរបស់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃដើម្បីសួរនាំនិងចាត់វិធានការតាមនីតិវិធី ចំពោះអ្នកនាំផ្លូវផងដែរ៕ *ភ័ន ណាង*

# អភិបាលខេត្តបាត់ដំបង ឱ្យទប់ស្កាត់អ្នកឆ្លងដែនទៅថៃខុសច្បាប់

https://www.postkhmer.com/ នៅ ស៊ីវុត្ថា | Publication date 19 October 2021 | 10:44 ICT

**បាត់ដំបង:** អភិបាលខេត្តបាត់ដំបង ដែលទើបចូលកាន់តំណែងថ្មី លោក សុខ លូ បានណែនាំដល់សមត្ថកិច្ចនៅតាមបន្ទាត់ព្រំដែន និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវរួមគ្នាទប់ស្កាត់ពលរដ្ឋកុំឱ្យឆ្លងដែនខុសច្បាប់ទៅថៃ តាមរយៈការអូសទាញពីពួកមេខ្យល់។

លោក សួស សុភ័ក្រ្ត ប្រធានមន្ទីរព័ត៌មាន និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបង ប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី ១៨ តុលាថា ក្នុងកិច្ចប្រជុំគណៈបញ្ជាការរដ្ឋបាលខេត្តបាត់ដំបងពីថ្ងៃទី ១៤ តុលា លោក សុខ លូ លើកឡើងថា ពលរដ្ឋដែលបម្រុងឆ្លងដែនខុសច្បាប់ចូលទៅប្រទេសថៃ តែងតែកើតមានក្នុងភូមិសាស្ត្រខេត្តបាត់ដំបង ដូចជាស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន ជាដើម។ លោក សុខ លូ ក៏បានអំពាវនាវដល់អាជ្ញាធរនៃរដ្ឋបាលក្រុង ស្រុកពាក់ព័ន្ធក្នុងខេត្តទាំងអស់ ត្រូវមានវិធានការទប់ស្កាត់ឱ្យបាននូវលំហូរ នៃការលួចឆ្លងដែនខុសច្បាប់ទៅថៃ ជាពិសេសត្រូវរកមុខបក្ខពួកក្រុមមេខ្យល់ដែលតែងនាំពលករឆ្លងដែនខុសច្បាប់ឱ្យបាន ដើម្បីយកមកផ្តន្ទាទោសតាមច្បាប់។

លោក សួស សុភ័ក្រ្ត ថ្លែងថា៖ «ឯកឧត្តមអភិបាលខេត្តក៏បានដាស់តឿនដល់អាជ្ញាធរដែនដីតាមបណ្ដាស្រុកទាំងនេះឱ្យបន្តយកចិត្តទុកដាក់ចុះត្រួតពិនិត្យផ្នែករដ្ឋបាលលើទីតាំង ដែលសង្ស័យមានការប្រមូលផ្ដុំប្រជាពលរដ្ឋ ដែលបម្រុងឆ្លងដែន ដែលមេខ្យល់បានកំណត់ មុននាំឆ្លងដែនខុសច្បាប់ទៅថៃ និងត្រូវបង្កើនការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានខ្លួនកុំឱ្យចាញ់បោកមេខ្យល់ដែលនាំឆ្លងដែនខុសច្បាប់»។

លោក សុក គឹមខុន អភិបាលស្រុកកំរៀង ប្រាប់ភ្នំពេញ-ប៉ុស្តិ៍នៅថ្ងៃទី ១៨ តុលា ថា ពលរដ្ឋកម្ពុជានៅតែបន្តចាញ់បោកមេខ្យល់ និងមួយទៀតពួកគាត់បានឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ដើម្បីរកការងារធ្វើនៅតែមានជាបន្តបន្ទាប់។ សកម្មភាពនេះមិនមែនកើតឡើងតែនៅពេលបច្ចុប្បន្ននេះទេ គឺកើតឡើងតាំងពីអំឡុងពេលផ្ទុះជំងឺកូវីដ ១៩ ខ្លាំង ហើយភាគីថៃក៏បានបញ្ជូនពលករខ្មែរត្រឡប់មកវិញ និងអ្នកខ្លះទៀតក៏បានលបលួចត្រឡប់ទៅវិញដែរ។ លោកបានបន្តថា សម្រាប់ស្រុកកំរៀង សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីទប់ស្កាត់កុំឱ្យពលរដ្ឋលួចចូលទៅប្រទេសថៃដោយខុសច្បាប់។ ប៉ុន្តែករណីនេះក៏រមែងតែងតែមានការធ្វេសប្រហែសខ្លះ ព្រោះប្រជាពលរដ្ឋបានលួចចូលទៅមិនឱ្យសមត្ថកិច្ចដឹងជាមុន។ ទោះយ៉ាងណា សម្រាប់មេខ្យល់វិញនៅពេលដែលអាជ្ញាធរឃាត់ខ្លួនបានគឺមិនដែលលើកលែងនោះទេគឺត្រូវបញ្ជូនទៅតុលាការ ដើម្បីអនុវត្តតាមច្បាប់។

លោកបានបញ្ជាក់ថា៖ « កងកម្លាំងគ្មានបានទំនេរ បានសម្រាកបុណ្យទានអីទេ ហើយក៏មិនដែលបានដេកស្រួលដែរ ជាពិសេសកម្លាំងនៅតាមខ្សែបន្ទាត់ព្រំដែន។ និយាយរួមយើងបានដុតដៃដុតជើង ទាំងកម្លាំងខាងក្នុង និងខាងក្រៅដើម្បីទប់ស្កាត់កុំឱ្យពលរដ្ឋលួចឆ្លងដែន ចូលទៅប្រទេសថៃដោយខុសច្បាប់»។ បើតាមលោក គឹមខុន ប្រជាពលរដ្ឋដែលលួចឆ្លងដែនចូលទៅប្រទេសថៃមិនមែនអ្នករស់នៅក្នុងស្រុកកំរៀងទេ តែភាគច្រើនគឺមកពីតាមបណ្តាខេត្តនានាទូទាំងប្រទេសដោយមានមេខ្យល់ដឹកនាំ និងឮតាមគ្នាថាច្រកព្រំដែន ត្រូវបានបើកវិញ ខណៈដែលសាច់ញាតិនៅក្នុងប្រទេសថៃខ្លះបានទាក់ទងហៅត្រឡប់ទៅវិញ ដើម្បីបានបេះផ្លែឈើ ស្របពេលដែលប្រទេសថៃជួបវិបត្តិខ្វះកម្លាំងពលកម្ម។ លោក សុក គឹមខុន ថា អាជ្ញាធរស្រុកកំរៀងក៏ដូចជាស្រុកផ្សេងទៀតនៅជាប់ព្រំដែន មិនអាចទប់ស្កាត់មិនឱ្យលួចចូលទៅកាន់ប្រទេសថៃតែឯងបានទេ លុះត្រាតែមានការចូលរួមពីភាគីពាក់ព័ន្ធ ជាពិសេសខេត្តនានានៅទូទាំងប្រទេស ត្រូវណែនាំ និងផ្សព្វផ្សាយដល់ពលរដ្ឋនៅក្នុងភូមិស្រុករបស់ខ្លួនពីគ្រោះថ្នាក់ ទើបកិច្ចការនេះទទួលបានជោគជ័យ។

តាមរបាយការណ៍បូកសរុបរបស់គណៈបញ្ជាការដ្ឋានឯកភាពរដ្ឋបាលខេត្តបាត់ដំបង ប្រចាំខែកញ្ញា ឆ្នាំនេះ បង្ហាញថា តាមរយៈកិច្ចប្រតិបត្តិការរក្សាសន្តិសុខព្រំដែន សមត្ថកិច្ច បានទប់ស្កាត់ប្រជាពលរដ្ឋដែលបម្រុងឆ្លងដែនខុសច្បាប់បានចំនួន១៩លើក ដោយមានមនុស្សចំនួន១៩៨នាក់ (ស្រ្តី៦៥នាក់) ជាអនីតិជន២៨នាក់។ ជាមួយគ្នានេះ ខាងសមត្ថកិច្ចថៃក៏ធ្លាប់បានចាប់បញ្ជូនពលករខ្មែរដែលឆ្លងដែនខុសច្បាប់ឱ្យត្រឡប់មកវិញចំនួន ៧៨ លើក ដែលមានមនុស្សចំនួន ១ ២៤៥ នាក់ក្នុងនោះជាស្រ្តី ៤៧៧ នាក់ និងអនីតិជនចំនួន ២៤ នាក់ផងដែរ៕

## នគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាខេត្ត ឃាត់ខ្លួនពលករចំនួន ១២នាក់ និងអ្នកនាំផ្លូវ០២នាក់ បំរុងឆ្លងដែនទៅប្រទេសថៃ

http://cambodiapolice.com/policekh/ 9:41 am 19 តុលា 2021

ខេត្តបន្ទាយមានជ័យ ៖ នៅថ្ងៃទី១៨ ខែ តុលាឆ្នាំ២០២១ វេលាម៉ោង០៣ និង៣០នាទីល្ងាច ដល់ម៉ោង០៦ និង៥០នាទីយប់ កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោក លេខ៨១៥ សហការជាមួយកម្លាំងយោធាប្រតិបត្តិការសឹករងខេត្តបន្ទាយមានជ័យ បានធ្វើការឃាត់ប្រជាពលរដ្ឋប្រុស ស្រី ចំនួន១៤នាក់ ក្នុងនោះមានអ្នកនាំផ្លូវ០២នាក់ បំរុងលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ស្ថិតនៅចំណុចមាត់អូរព្រំដែន ក្នុងភូមិសាស្រ្តភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោលេខ៨១៥ បានឲ្យដឹងថា ៖ ប្រជាពលរដ្ឋដែលត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ការពារព្រំដែនចំបក់ សហការជាមួយកម្លាំងយោធាប្រតិបត្តិការសឹករងខេត្តបន្ទាយមានជ័យ ឃាត់ខ្លួនមានចំនួន ១២នាក់ មកពី០៤ខេត្ត មានខេត្តបន្ទាយមានជ័យ, តាកែវ, កំពង់ធំ និងខេត្តបាត់ដំបង ជាមួយគ្នានោះដែរបានស្រាវជ្រាវ និងរកឃើញអ្នកនាំផ្លូវចំនួន ០២នាក់ សរុបទាំងអស់១៤នាក់ ។ លោកវរសេនីយ៍ឯក បានបន្តឲ្យដឹងថា ៖ អ្នកនាំផ្លូវទាំង០២នាក់ ១-ឈ្មោះ សេន តុលា ភេទប្រុស អាយុ ៣៩ឆ្នាំ រស់នៅភូមិខ្ពស់ ឃុំប្រាំបីមុំ ស្រុកត្រាំង ខេត្តតាកែវ ។ ២-ឈ្មោះ អឿម អុល ភេទប្រុស អាយុ ៣២ឆ្នាំ រស់នៅភូមិស្ពានយោល ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ ប្រជាពលរដ្ឋទាំងនោះ បន្ទាប់ពីធ្វើការអប់រំ និងណែនាំអំពីផលប៉ះពាល់ នៃការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ ពិសេសមេរោគប្រភេទថ្មីដែលតារូច បានបញ្ជូនពួកគាត់ទៅមណ្ឌលចត្តាឡីស័កកម្រិត២ វិទ្យាល័យម៉ាឡៃ ដើម្បីយកសំណាកធ្វើតេស្តរកមេរោគកូវីដ-១៩ ។

ដោយឡែកចំពោះអ្នកនាំផ្លូវ០២នាក់ បានបញ្ជូនទៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ ដើម្បីចាត់ការបន្តតាមនីតិវិធី។ ជាមួយគ្នានោះដែរ លោកមេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ ក៏បានបន្ថែមថា ៖ នៅវេលាម៉ោង០៥ល្ងាច ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ នេះដែរ មានប្រជាពលរដ្ឋចំនួន ០៦នាក់ (ស្រី ០២នាក់ និងកុមារ ០១នាក់) បានវិលត្រឡប់មកពីប្រទេសថៃតាមភូមិសាស្រ្តប៉ុស្តិ៍ក្បាលទំនប់ ចំណុចក្បាលទំនប់ ក្នុងភូមិក្បាលទំនប់ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ប្រជាពលរដ្ឋទាំងនោះបានបញ្ជូនទៅមណ្ឌលចត្តាឡីស័កកំរិត២ វិទ្យាល័យម៉ាឡៃ ដើម្បីយកសំណាក ធ្វើតេស្តរកមេរោគកូវីដ-១៩ផងដែរ ៕

## នគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ទទួលពលរដ្ឋវិលត្រឡប់ពីប្រទេសថៃ ចំនួន ៨នាក់

http://cambodiapolice.com/policekh/ 10:24 am 19 តុលា 2021

**បាត់ដំបង** ៖ នៅវេលាម៉ោង០៤ និង១០នាទីទាបភ្លឺ ថ្ងៃអង្គារ ១៣កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និង

ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនកូនភ្នំ ចំនួន០៥នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ខៀវ រ៉ាត់ (នាយប៉ុស្តិ៍) រួមជាមួយកម្លាំងផ្នែកស៊ើបការណ៍ចំនួន០២នាក់ ដឹកដោយលោកអនុសេនីយ៍ទោ សេង វ៉ើន (នាយផ្នែក) សហការជាមួយកម្លាំងយោធាកងអនុសេនាធំគាំទ្រ, វរសេនាតូច៥៣៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ហែម សឿន (មេបញ្ជាការរងកងអនុសេនាធំ), កម្លាំងយោធាកងអនុសេនាធំទី១, វរសេនាតូចលេខ២១ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ ស៊ឹង ស៊ិត (មេបញ្ជាការរងកងអនុសេនាធំ) រួមជាមួយកម្លាំងអន្តរាគមន៍វរសេនាតូចលេខ២១ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី អ៊ុក វង្ស៊ុល (ជំនួយការហ្វឹកហ្វឺន) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជា វិញត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៨នាក់ ស្រី០៥នាក់ ក្មេង០៣នាក់ ក្មេងស្រី០២នាក់។ បន្ទាប់ពីទទួលបានកម្លាំងសមត្ថកិច្ចបានយកបងប្អូនប្រជាពលរដ្ឋមកកាន់គោលដៅប្រចាំការ ដើម្បីសាកសួរកត់ឈ្មោះ និងអប់រំណែនាំរួចប្រគល់ឲ្យទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិ គីឡូ១៣ ធ្វើការពិនិត្យសុខភាព៕

## ពលករចំណាកស្រុកបន្តលួចឆ្លងដែនទៅថៃទោះបីមានការរឹតត្បិត

https://www.khmertimeskh.com/ October 20, 2021 យឹម ស្រីលីន / ខ្មែរថាមស៍

ករណីឆ្លងដែនខុសច្បាប់ជាង ២០០ ករណី ត្រូវបានរាយការណ៍នៅចន្លោះខែសីហា និងខែតុលា ដោយមានមេខ្យល់រាប់សិបនាក់ ត្រូវបានចាប់ខ្លួននៅស្រុកកំរៀង ខេត្តបាត់ដំបង។ ចាប់ពីខែសីហា ដល់ពាក់កណ្តាលខែតុលា ពលករចំណាកស្រុកជាច្រើននាក់ ត្រូវបានគេរត់ពន្ធឆ្លងកាត់ព្រំដែនកម្ពុជា-ថៃនៅច្រកព្រំដែនក្នុងស្រុកកំរៀង ក្នុងគោលបំណងវិលត្រឡប់ទៅធ្វើការ ឬស្វែងរកការងារធ្វើនៅប្រទេសថៃវិញ ក្នុងនោះ ពួកគេខ្លះ ក៏ត្រូវបានមេខ្យល់បោកប្រាស់ផងដែរ។

លោកឧត្តមសេនីយ៍ទោសាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងបានប្រាប់កាសែតខ្មែរថាមស៍កាលពីពេលថ្មីៗនេះថា អាជ្ញាធរមានការព្រួយបារម្ភចំពោះពលករចំណាកស្រុក ដែលបានបង់ប្រាក់យ៉ាងច្រើនដល់មេខ្យល់ ហើយបន្ទាប់មកពួកគេត្រូវបានគេបោះបង់ចោលនៅលើភ្នំក្បែរព្រំដែន។ លោកបាននិយាយថា៖«ចាប់ពីថ្ងៃទី ១៥ ខែកញ្ញា រហូតដល់ថ្ងៃទី ១៥ ខែតុលា កម្លាំងនគរបាលបានស្ទាក់ចាប់ពលករចំណាកស្រុកចំនួន ១៧៦ នាក់ដែលប៉ុនប៉ងលួចឆ្លងដែន និងឃាត់ខ្លួនអ្នករត់ពន្ធចំនួន ២៦ នាក់»។ លោកបានបន្ថែមទៀតថា៖«ចាប់ពីថ្ងៃទី ១៥ ខែសីហា ដល់ថ្ងៃទី ១៥ ខែកញ្ញា អ្នករត់ពន្ធចំនួន ២៦ នាក់ ត្រូវបានចាប់ខ្លួន ហើយពលករចំណាកស្រុកចំនួន ១៥៣នាក់ ត្រូវបានឃាត់ខ្លួន»។ លោកបាននិយាយថា៖«យើងមិនដែលចាត់វិធានការតាមផ្លូវច្បាប់ណាមួយចំពោះពលករចំណាកស្រុកទាំងនោះដែលឆ្លងដែនដោយខុសច្បាប់នោះទេ ហើយអាជ្ញាធរគ្រាន់តែអប់រំពួកគេមិនឱ្យចាញ់បោកមេខ្យល់ និងឆ្លងដែនខុសច្បាប់ប៉ុណ្ណោះ ប៉ុន្តែ មេខ្យល់ត្រូវបានចាប់ខ្លួន និងផ្តន្ទាទោសតាមផ្លូវច្បាប់»៕

## ពលរដ្ឋចំណាកស្រុកនៅតែត្រូវមេខ្យល់នាំឆ្លងដែនទៅថៃ ខណៈសមត្ថកិច្ចព្រំដែនចាប់បានរាល់ថ្ងៃ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២០ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ១៤:១១

ខេត្តបាត់ដំបង ៖ បើទោះជាកម្លាំងប្រដាប់អាវុធការពារព្រំដែនប្រឹងប្រែងរឹតបន្តឹង និងឃាត់ខ្លួនពលរដ្ឋចំណាកស្រុកដែលត្រូវមេខ្យល់នាំឆ្លងដែនទៅប្រទេសថៃបានជាបន្តបន្ទាប់ស្ទើររាល់ថ្ងៃ តែពួកគេហាក់នៅតែត្រូវមេ

ខ្យល់ប្រើប្រាស់គ្រប់វិធី ដើម្បីនាំពលរដ្ឋចំណាកស្រុកឆ្លងដែនដោយខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ ដែលប្រឈមយ៉ាងខ្លាំងទៅនឹងការឆ្លងរាលដាលនៃជំងឺកូវីដ១៩។ ជាក់ស្តែង កាលពីរសៀលថ្ងៃទី១៩ តុលា កម្លាំងនគរបាលរការពារព្រំដែនលេខ៨១៧ សហការជាមួយកម្លាំងយោធាផ្នែកសឹករងស្រុកសំពៅលូនបានស្ទាក់ចាប់ខ្លួនក្រុមពលរដ្ឋចំណាកធ្វើស្រុកបានចំនួន០៧នាក់ ដែលមានស្ត្រីចំនួន០៣នាក់ ក្នុងនោះមានមេខ្យល់ចំនួន០២នាក់ ដែលបំរុងនាំជនចំណាកស្រុកទាំងនោះឆ្លងដែលចេញទៅប្រទេសថៃ ដោយគ្មានច្បាប់ ហើយត្រូវកម្លាំងការពារព្រំដែនខាងលើឃាត់នៅចំណុចភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ។

មន្ត្រីព្រំដែនបានឲ្យដឹងថា ក្នុងចំណោមក្រុមអ្នកបំពានច្បាប់ទាំង០៧នាក់នោះ មាន០៣នាក់ជាស្ត្រី និងមាន០២នាក់ជាមេខ្យល់ គឺ ម្នាក់ឈ្មោះ ពិត ស្រស់ ប្រុសអាយុ៣៧ឆ្នាំ នៅភូមិគីឡូ១៣ ឃុំសន្តិភាព និង ម្នាក់ទៀតឈ្មោះ មឿន រីត ប្រុសអាយុ៣៧ឆ្នាំ រស់នៅភូមិ ឃុំជាមួយគ្នា។ ជនទាំង០៧នាក់នេះ បំរុងនាំគ្នាឆ្លងអូរព្រំដែនចេញទៅប្រទេសថៃ តាមច្រករបៀងលួចលាក់ តែត្រូវកម្លាំងនគរបាលការពារព្រំដែន និង កម្លាំងយោធាស្រុក ទប់ស្កាត់ទាន់ពេលវេលា។ បើតាមមន្ត្រីព្រំដែនបានបញ្ជាក់ថា ពេលនេះជនទាំង០៧នាក់នេះ ត្រូវបានបញ្ជូនទៅប្រគល់ជូនខាងអធិការស្រុកសំពៅលូន ដើម្បីចាត់ការតាមនិតិវិធីហើយ។

សូមបញ្ជាក់ផងដែរថា បើតាមរបាយការណ៍របស់អាជ្ញាធរ និងកម្លាំងការពារព្រំដែនគោក ដែលឈរជើងតាមបន្ទាត់ព្រំដែន ខ្មែរ ថៃ ខេត្តបាត់ដំបង បានបង្ហាញសម្រាប់ប្រចាំខែកញ្ញា កន្លងទៅនេះ គឺកម្លាំងការពារព្រំដែនបានចាប់ខ្លួនមេខ្យល់សរុបបានចំនួន២២នាក់ ដោយមិនទាន់គិតដល់ខែតុលានេះទេ។ មេខ្យល់ទាំង២២នាក់នេះ ក៏ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅកាន់តុលាការជាបន្តបន្ទាប់ ដែលបច្ចុប្បន្នមេខ្យល់ទាំងនោះកំពុងជាប់គុកនៅឡើយ ៕

## តើពលករកម្ពុជាគួរត្រៀមខ្លួនយ៉ាងដូចម្តេច មុនសម្រេចចិត្តចេញទៅធ្វើការងារនៅក្រៅប្រទេស?

https://ams.com.kh/ 14/10/2021

**ភ្នំពេញ៖** របាយការណ៍របស់ក្រសួងការងារបានបង្ហាញថា បច្ចុប្បន្នមានពលករកម្ពុជាប្រមាណជាង ១លាននាក់កំពុងបម្រើការងារនៅក្រៅប្រទេស ក្នុងនោះ ជាង ៩០ភាគរយកំពុងធ្វើការនៅក្នុងប្រទេសថៃ និងប្រមាណ ៧ភាគរយកំពុងតែបម្រើការងារនៅប្រទេសម៉ាឡេស៊ី អារ៉ាប៊ីសាអូឌីត ជប៉ុន សិង្ហបុរី ហុងកុង និងសាធារណរដ្ឋកូរ៉េ ។

ជាមួយគ្នានេះរបាយការណ៍របស់អង្គការពលកម្មពិភពលោក (ILO) បានបង្ហាញថា មានពលករកម្ពុជាតិចតួចណាស់ដែលបានគេផ្តល់ការងារឱ្យធ្វើស្របនិង ជំនាញដែលពួកគេមាន ដោយជាទូទៅធ្វើការសម្រាប់តែប្រភេទការងារដែលមានប្រាក់កម្រៃទាបនៅក្នុងឧស្សាហកម្មដែលប្រើកម្លាំងកាយច្រើនជាងជំនាញ ។ របាយការណ៍បញ្ជាក់ថា ពលករទេសន្តប្រវេសន៍គេបាតុវាយតម្លៃថា មិនមានបទពិសោធន៍ ឬមិនមានការបណ្តុះបណ្តាលផ្លូវការដែលឆ្លើយតបទៅនឹងតម្រូវការជំនាញ។ ដូច្នេះ តើពលករកម្ពុជាគួរត្រៀមខ្លួនយ៉ាងដូចម្តេចមុននឹងសម្រេចចិត្តទៅធ្វើការងារនៅក្រៅប្រទេស ?

ឯកឧត្តម ថង សាម៉ុន អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ បានមានប្រសាសន៍ថា មុនចាកចេញទៅធ្វើការនៅក្រៅប្រទេស ពលករកម្ពុជាត្រូវគិតសិនថា តើជាការចាកចេញនោះរយៈពេលខ្លី ឬរយៈពេលវែង? បើតាមឯកឧត្តម ថង សាម៉ុន ចំណាកស្រុកដើម្បីធ្វើការងាររយៈពេលខ្លី អាចចាត់ទុកជាចំណាកស្រុកដោះទ័ល ប៉ុន្តែបើរយៈពេលវែងប្រជាពលរដ្ឋត្រូវរៀនជំនាញបច្ចេកទេសឱ្យបានច្បាស់លាស់ ។ ឯកឧត្តមលើកឧទាហរណ៍ថា ពលករកម្ពុជាដែលបម្រើការងារនៅប្រទេសថៃ ទទួលបានប្រាក់ខែ

តិចជាងពលករកម្ពុជាដែលទៅបម្រើការងារនៅប្រទេសកូរ៉េ ខណៈនៅប្រទេសកូរ៉េពលករបានបណ្តុះបណ្តាលជំនាញត្រឹមត្រូវ ។

សម្រាប់លោកបណ្ឌិត យង់ ពៅ អគ្គលេខាធិការរាជបណ្ឌិត្យសភាកម្ពុជា មានប្រសាសន៍ថា លោកមិនលើកទឹកចិត្តឱ្យពលករកម្ពុជាចេញទៅធ្វើការងារនៅក្រៅប្រទេសនោះទេ ប៉ុន្តែប្រសិនបើពួកគាត់ទៅ ត្រូវប្រាកដថា តើពួកគាត់ទៅធ្វើអ្វីនៅទីនោះ ហើយពួកគាត់គួរមានជំនាញប្រាកដមួយនៅក្នុងខ្លួន ។ "**នៅពេលដែលពលករមានជំនាញប្រាកដមួយនៅក្នុងខ្លួន ហើយទៅធ្វើការងារនៅប្រទេសដែលលូតលាស់ជាងយើង នោះមានន័យថា ពួកគាត់ទៅអភិវឌ្ឍន៍ជំនាញបន្ថែម លើសពីការគ្រាន់តែទៅរកលុយដើម្បីបំពេញសេដ្ឋកិច្ចខ្លួន ! ពលករកម្ពុជានឹងទទួលបានទាំងថវិកា ទាំងចំណេះ**ជំនាញ ហើយពេលពួកគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ ពួកគាត់អាចបង្កើតមុខរបរ ឬធ្វើការងារពាក់ព័ន្ធនឹងជំនាញរបស់គាត់បាន" លោកបណ្ឌិត យង់ ពៅ យ៉ាងណាក៏ដោយបើតាមលោកបណ្ឌិត យង់ ពៅ ល្គឹកណាពួកគាត់អាចធ្វើបែបនេះបាន លុះត្រាតែពលករកម្ពុជាមានជំនាញមូលដ្ឋានពីក្នុងស្រុកទៅ ដូច្នេះលោកលើកទឹកចិត្តដល់ពលករកម្ពុជា មុនធ្វើចំណាកស្រុកចេញទៅធ្វើការងារនៅក្រៅប្រទេស គួរតែមានជំនាញជាមុនសិន ដោយវានឹងផ្តល់ផលប្រយោជន៍ដល់យើងដូចជា ទី១ អាចរកលុយបានច្រើនជាងអ្នកអត់ជំនាញ និង ទី២ ពលករកម្ពុជាអាចចាប់ជំនាញថ្មីពីប្រទេសគេ មកអភិវឌ្ឍន៍ខ្លួនឯងបាន ៕

## បន្តឃាត់បានពលករខ្មែរ ៣៧នាក់ ដែលបម្រុងឆ្លងដែនខុសច្បាប់ចូលទៅប្រទេសថៃ

https://kohsantepheapdaily.com.kh/ ២០ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ១៨:២៦

ខេត្តបន្ទាយមានជ័យ ៖ លោកអនុសេនីយ៍ទោ ស រិទ្ធ មេគ្រប់គ្រងគោលដៅ ផ្នែកសឹករងម៉ាឡៃ ដឹកនាំកម្លាំងសហការជាមួយកងពលថ្មើរជើងលេខ៥១ និងនគរបាលការពារព្រំដែនគោកលេខ៨១៥ បានជួបពលករចំនួន ៣៧នាក់ ក្នុងនោះស្រី១៣នាក់ ក្មេង២នាក់ បម្រុងឆ្លងដែនចេញទៅប្រទេសថៃ ត្រូវបានកម្លាំងចម្រុះ ឃាត់ខ្លួនបានតែម្តង ។ ការឃាត់ពលករខ្មែរមួយក្រុមបម្រុងឆ្លងដែនដោយខុសច្បាប់ ចូលទៅប្រទេសថៃនេះ ធ្វើឡើងនាយប់ថ្ងៃទី ១៩ ឈានចូលថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១នេះ ត្រង់ភូមិសាស្ត្រ អូរព្រំដែន ភូមិក្បាលទំនប់ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ក្រោយពីឃាត់ខ្លួនបានកម្លាំងចម្រុះបានសាកសួរ និងបានអប់រំណែនាំ រួចក៏ប្រគល់អោយកម្លាំងអាវុធហត្ថស្រុក បន្តសាកសួរដើម្បីស្រាវជ្រាវរកមុខសញ្ញាមេខ្យល់ ដែលតែងតែញុះញុងអោយបងប្អូនឆ្លងដែនទៅធ្វើការដោយគ្រោះថ្នាក់ និងប្រថុយប្រថានបែបនេះ ។

សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំង តំបន់ប្រតិបត្តិការសឹករងខេត្ត ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការសហការជាមួយកម្លាំងចម្រុះ ទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ បានឃាត់ខ្លួនពលករឆ្លងដែនបញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួន បញ្ជូនទៅសមត្ថកិច្ចជំនាញចាត់វិធានការតាមនិតិវិធីច្បាប់ផងដែរ ៕

# ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១

## មេខ្យល់២នាក់ លួចជូនពលករទៅថៃត្រូវបានកម្លាំងអាវុធហត្ថ ឃាត់ខ្លួនបញ្ជូនទៅតុលាការ

https://www.kampucheathmey.com/ ថ្ងៃពុធ ២០ តុលា ២០២១ដោយ Kang Tola

បន្ទាយមានជ័យ ៖ មេខ្យល់២នាក់ លួចនាំពលករឆ្លងដែនទៅរកការងារធ្វើទៅប្រទេសថៃ ដោយខុសច្បាប់ ត្រូវបានកម្លាំងអាវុធហត្ថស្រុកម៉ាឡៃ សហការជាមួយកម្លាំងសឹករងស្រុកម៉ាឡៃ ធ្វើការឃាត់ខ្លួន បាននៅវេលាម៉ោង ៦ព្រឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១។

លោកវរសេនីយ៍ទោ ព្រហ្ម ថេង ប្រធានមន្ទីរស្រាវជ្រាវកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ បានប្រាប់អ្នកយកព័ត៌មានឲ្យដឹងថា ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ លើការទប់ស្កាត់បទល្មើសតាមព្រំដែនគ្រប់ប្រភេទ ជាពិសេសការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ ក្នុងសម័យកាលវិបត្តិកូវីដ១៩នេះ។ លុះនៅថ្ងៃ ទី២០ ខែតុលា ឆ្នាំ២០២១ កម្លាំងមូលដ្ឋានអាវុធហត្ថស្រុកម៉ាឡៃ បានសហការជាមួយកម្លាំងផ្នែកសឹករងម៉ាឡៃ វរៈ ៨១៩ ស្រាវជ្រាវស្ទាក់ចាប់បានពលករ ចំនួន ១៤នាក់ក្នុងនោះមាន ស្រី៧នាក់ ដែលកំពុងព្យាយាមលួចឆ្លងដែន ដោយខុសចូលទឹកដីថៃ ដើម្បីស្វែងរកការងារធ្វើ នៅចំណុចភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

ក្រោយពីឃាត់ខ្លួនពលករទាំង១៤នាក់ សួរនាំក្នុងនោះបានរកឃើញមានមេខ្យល់២នាក់ ១មានឈ្មោះ សេន តុលា ភេទប្រុស អាយុ៣៩ឆ្នាំ និង២មាន ឈ្មោះ អឿន អុល ភេទប្រុស អាយុ៣២ឆ្នាំ ទាំង២នាក់ មានរស់នៅភូមិស្ពានយោល ឃុំសីម៉ា ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ពលករខ្មែរចំនួន១២នាក់ ក្រោយពីធ្វើកំណត់ហេតុហើយបានបញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅវិទ្យាល័យម៉ាឡៃ ចំណែកជនសង្ស័យជាមេខ្យល់ ចំនួន២នាក់វិញ ត្រូវបានកម្លាំងជំនាញ កសាងសំណុំរឿងដោយចោទប្រកាន់ពីបទ នាំយកពលករឆ្លងដែនទៅប្រទេសថៃដោយមិនស្របច្បាប់ហើយកម្លាំងការិយាល័យជំនាញអាវុធហត្ថខេត្តបញ្ជូនទៅតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់។ *ភ័ន់ ណាង*

## តុលាការឃុំខ្លួនយុវជន ២ នាក់ ករណីនាំពលករឆ្លងដែនទៅថៃ

https://www.postkhmer.com/ គឹម សារុំ | Publication date 20 October 2021 | 14:44 ICT

**មានជ័យៈ** តុលាការខេត្តបន្ទាយមានជ័យសម្រេចឃុំខ្លួនយុវជនជាមេខ្យល់ ២ នាក់ ក្នុងពន្ធនាគារខេត្តពាក់ព័ន្ធនឹងករណីនាំពលករជាង ៤០ នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃ ហើយត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

លោកស្រី ឌី សុជាតិ ស្នងការរងប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបន្ទាយមានជ័យប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី ១៩ តុលាថា ជនត្រូវចោទ ២ រូបនេះមាន ឈ្មោះ ម៉ា និត ភេទប្រុស អាយុ ១៧ ឆ្នាំ និងឈ្មោះ ជឿន កុយ ភេទប្រុសអាយុ ១៥ ឆ្នាំ។ ពួកគេរស់នៅភូមិទំនប់ដាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ហើយត្រូវបានតំណាងអយ្យការចោទពីថ្ងៃទី ១៨ តុលា។ លោកស្រីបានបញ្ជាក់ថា៖ «ជនទាំង ២ នាក់ត្រូវបានតំណាងអយ្យការចោទពីការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន។ បទចោទនេះតាមមាត្រា ១១ នៃច្បាប់ការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ»។ ពាក់ព័ន្ធនឹងបទចោទនេះ បើតុលាការរកឃើញថា ពួកគេទាំង ២ នាក់ពិតជាបានប្រព្រឹត្តមែននោះ ត្រូវប្រឈមនឹងការផ្តន្ទាទោសជាប់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំ។

លោកស្រី ឌី សុជាតិ បានឱ្យដឹងថា ពួកគេទាំង ២ នាក់នោះត្រូវបាននគរបាលប៉ុស្តិ៍ អូរបីជាន់សហការជាមួយកម្លាំងយោធាឃាត់ខ្លួនកាលពីថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០២១ នៅភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខ

ណៈពួកគេកំពុងនាំពលករប្រុសស្រីចំនួន ៤១ នាក់ (មានក្មេងៗជាកូនពលករ ២ ទៅ ៣ នាក់ដែរ) បម្រុងឆ្លងដែនទៅប្រទេសថៃ។ លោកស្រីបានបន្តថា បើតាមចម្លើយរបស់ជនសង្ស័យទាំង ២ នាក់ថា ពួកគេធ្វើជាអ្នកនាំផ្លូវពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃ ដើម្បីធ្វើការនៅទីនេះបានចំនួន ២ លើកមកហើយ។ ប៉ុន្តែនៅលើកទី ៣ នេះក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង។ ចំពោះតម្លៃនាំពលករឆ្លងទៅប្រទេសថៃនេះដែរពួកគេយកគឺក្នុងមនុស្សម្នាក់ចំនួន ២ ពាន់បាត៕

## បញ្ជូនបុរស២នាក់ទៅតុលាការ ក្រោយនាំជនជាតិវៀតណាម១៦នាក់ចូលកម្ពុជា

https://kohsantepheapdaily.com.kh/ ភ្នំពេញ២១ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ០៨:៥៣

ខេត្តត្បូងឃ្មុំ ៖ បុរស២នាក់ ដែលជាមេខ្យល់នាំជនជាតិវៀតណាមប្រុសស្រីចំនួន១៦នាក់ ឆ្លងដែនដោយខុសច្បាប់ចូលមកកម្ពុជា បានត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១កន្លងទៅ នៅក្នុងទឹកដីស្រុកពញាក្រែក រួចបញ្ជូនបន្តទៅស្នងការដ្ឋាននគរបាលខេត្ត ។ ជនជាមេខ្យល់ទាំង២នាក់នេះ ម្នាក់ឈ្មោះ ទា ចឺផេង ភេទប្រុស អាយុ៣៦ឆ្នាំ រស់នៅភូមិត្រពាំងផ្លុង ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក និងម្នាក់ទៀតឈ្មោះ យុត រ៉ានី ភេទប្រុស អាយុ២២ឆ្នាំ រស់នៅភូមិស្ពឺ ឃុំក្រែក ស្រុកពញាក្រែក ។ ជនទាំង២នាក់នេះ ពាក់ព័ន្ធនឹងករណីនាំជនជាតិវៀតណាមចំនួន១៦នាក់(ស្រ្តី៤នាក់) ឆ្លងចូលមកកម្ពុជាដោយខុសច្បាប់តាមច្រករបៀងប៉ុស្តិ៍ការពារព្រំដែនកូនជ្រូក នៃវរៈការពារព្រំដែនលេខ៦១៥ កាលពីម៉ោងប្រហែល៤ រសៀល ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ។

ប៉ុន្តែពេលនោះក៏ត្រូវកងកម្លាំងល្បាតប្រទះឃើញនិងឃាត់ខ្លួន ហើយប្រសិនបើយឺតយ៉ាវតែកន្លះម៉ោង មេខ្យល់ទាំង២នាក់នេះនឹងនាំជនជាតិវៀតណាមទាំង១៦នាក់ ឡើងជិះរថយន្តចេញទៅបាត់ហើយ ។ ជាការអនុវត្តតាមនីតិវិធី ចំពោះជនជាតិវៀតណាមទាំង១៦នាក់បានឲ្យត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ចំពោះមេខ្យល់ជាជនជាតិខ្មែរទាំង២នាក់ ត្រូវបាននគរបាលស្រុកបញ្ជូនបន្តទៅស្នងការដ្ឋាននគរបាលខេត្ត ដើម្បីកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្ត ៕

## កុងស៊ុលកម្ពុជា ចែកស្បៀងអាហារ ជូនពលករខ្មែរនៅថៃជាង ១០០គ្រួសារ កំពុងជួបទុក្ខលំបាកដោយកូវីដ និងជំនន់ទឹកភ្លៀង

https://dap-news.com/ ByKD102Posted on October 21, 2021

**ភ្នំពេញ ៖ លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បានឲ្យដឹងថា នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ នេះ ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តសាកែវ បានសហការជាមួយអាជ្ញាធរថៃ នៃស្រុកគោកធ្លុង ខេត្តសាកែវ និងអង្គការការពារសិទ្ធិពលករ ចុះសួរសុខទុក្ខ និងយកស្បៀងអាហារ ជូនពលករខ្មែរចំនួន ១២៨គ្រួសារ នៅឃុំណុនម៉ាក់មុន ស្រុកគោកធ្លុង** ។ អំណោយឧបត្ថម្ភមានដូចជា អង្ករ មីកញ្ចប់ ទឹកសុទ្ធ ទឹកត្រី ទឹកស៊ីអ៊ីវ ត្រីខកំប៉ុង ទឹកដោះគោ និងសម្ភារៈមួយចំនួនទៀត ។ បន្ថែមពីនេះ ក្រុមការងារបានធ្វើការណែនាំអប់រំ និងក្រើនរំលឹកបន្ថែមដល់ ពលករខ្មែរទាំងអស់ ត្រូវថែទាំសុខភាពដើម្បី ចៀសវាងការឆ្លងជំងឺកូវីដ-១៩ ដោយត្រូវពាក់ម៉ាស់ជាប្រចាំ ពេលចេញធ្វើដំណើរទៅក្រៅ ឧស្សាហ៍លាងដៃនឹងសាប៊ូអាកុល ឬជែល មិនត្រូវទៅកន្លែងណា ដែលមានមនុស្សច្រើន ឬកន្លែងដែលមានខ្យល់ចេញចូលតិច និងអនុវត្តតាមវិធានការសុខាភិបាលថៃ ដែលអាជ្ញាធរថៃបានណែនាំ ព្រមទាំងហានិភ័យនៃ ការឆ្លងដែនចេញចូលកម្ពុជា-ថៃខុសច្បាស់ ៕

# បញ្ជូនជនជាតិចិន ២នាក់ ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ពីបទបង្ខាំងមនុស្សជំរិតទារប្រាក់ខុសច្បាប់ និងជួញដូរមនុស្ស

https://cen.com.kh/ Posted ByPen Srey NeatOctober 21, 2021

បន្ទាយមានជ័យ ៖ កម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ កសាងសំណុំរឿងបញ្ជូនខ្លួនជនសង្ស័យជនជាតិចិនចំនួន ២នាក់ ធ្វើសកម្មភាពបង្ខាំងមនុស្សជំរិតទារប្រាក់ខុសច្បាប់ និងជួញដូរមនុស្ស ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅរសៀលថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ដើម្បីចាត់ការតាមនីតិវិធី។

លោកវរសេនីយ៍ឯក សៅ សារឿន អធិការនគរបាលក្រុងប៉ោយប៉ែត បានឲ្យដឹងថា នៅវេលាម៉ោង៥និង៥០នាទីល្ងាច ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ លោកបានទទួលព័ត៌មានពីប្រជាពលរដ្ឋថា មានករណីបង្ខាំងមនុស្សប្រុសចំនួន២នាក់ នៅចំណុចអគារមួយកន្លែងបន្ទប់លេខ១១៤ ស្ថិតក្នុងភូមិគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ បន្ទាប់មកកម្លាំងនគរបាលក្រុងប៉ោយប៉ែត បានចុះទៅដល់កន្លែងកើតហេតុដោយមានការសហការពីម្ចាស់អគារ សមត្ថកិច្ចបានរំដោះជនរងគ្រោះជាបុគ្គលិកចំនួន២នាក់៖១-ឈ្មោះ ខឿន ឌាត ភេទប្រុស អាយុ ៣៣ឆ្នាំ ស្នាក់នៅបណ្តោះអាសន្នភូមិគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត, ២-ឈ្មោះ ជឹម ក្លឹប ភេទប្រុស អាយុ ៣៣ឆ្នាំ ស្នាក់នៅបណ្តោះអាសន្នភូមិគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ក្នុងនោះបានឃាត់ខ្លួនជនសង្ស័យជាមេការ ១នាក់ ឈ្មោះ ស៊ីន សៅស៊ុន ភេទប្រុសអាយុ ៣៦ឆ្នាំ ជាជនជាតិចិន ស្នាក់នៅភូមិគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត យកមកសួរនាំនៅអធិការដ្ឋាន នគរបាលក្រុងប៉ោយប៉ែត ។ បន្ទាប់មកនៅវេលាម៉ោង០៩ព្រឹក ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ កម្លាំងនគរបាលក្រុងបានឈានដល់ឃាត់ខ្លួនជនសង្ស័យម្នាក់ទៀតឈ្មោះ កៅ ឈុង ភេទប្រុស អាយុ៣៥ឆ្នាំ ជាជនជាតិចិន ស្នាក់នៅភូមិគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ទាំង២នាក់ ជាមេការក្រុមហ៊ុនអនឡាញមួយនៅក្រុងប៉ោយប៉ែត។

លោកអធិការបានបញ្ជាក់ថា៖ តាមបំភ្លឺរបស់ជនរងគ្រោះទាំង២នាក់ និយាយថា៖ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២១ ពួកគេបានសម្ភាសន៍ធ្វើការនៅក្រុមហ៊ុនអនឡាញនៅភ្នំពេញជាប់ចំនួន៦នាក់។ នៅយប់ថ្ងៃដដែលពួកគេទាំង៦នាក់ បានចេញពីភ្នំពេញមកប៉ោយប៉ែតដោយជិះរថយន្ត១គ្រឿង អ្នកបើកបរជាជនជាតិខ្មែរ និងអ្នកជិះក្នុងរថយន្តនោះមាន១នាក់ ជាជនជាតិចិន និង១នាក់ទៀត ជាជនជាតិបង់ក្លាដែស ហើយមកដល់ប៉ោយប៉ែតនៅវេលាម៉ោង៣ទាបភ្លឺ ដោយស្នាក់នៅអគារអនឡាញ។ លុះព្រឹកឡើងធ្វើសម្ភាសន៍ម្តងទៀតជាប់តែ ២នាក់ (ខឿន ឌាត និង ជឹម ក្លឹប)។ នៅថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០២១ ពួកចិននោះបានដាក់ខ្នោះខ្លួនទាំង២នាក់ និងគម្រាមឲ្យយកប្រាក់ឲ្យពួកគេវិញ ដោយប្រាប់ថាអ្នកនាំមកបានយកពួកគេទាំង២នាក់មកលក់ បើមិនបានប្រាក់ទេគេបង្ខាំងទុកក្នុងបន្ទប់នេះ៦ខែ ។ ជាមួយគ្នានោះ ពួកគេសុំទាមទារជម្ងឺចិត្តមកខ្លួនចំនួន៣ម៉ឺនដុល្លារ និងសុំឲ្យសមត្ថកិច្ចចាត់ការតាមនីតិវិធី។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា៖ តាមចម្លើយសារភាពរបស់ឈ្មោះ ស៊ី សៅស៊ុន មេការគ្រប់គ្រងអនឡាញ និយាយថា ខ្លួនបានស្គាល់អ្នកធ្វើការដូចគ្នាឲ្យជួយរកជនជាតិថៃ៦នាក់ មកធ្វើការពេលនោះសម្ភាសន៍ជាប់២នាក់ អាចធ្វើការបាន។ ដោយគិតថាអ្នកទាំង២នាក់ នោះជាជនជាតិថៃក៏បានឲ្យគាត់ទៅរៀនឲ្យចេះធ្វើការនៅក្នុងបុរីស៊ានហូរ ពេលទៅដល់កន្លែងរៀនគេប្រាប់ថាមិនមែនជាជនជាតិថៃ គឺជាជនជាតិខ្មែរក៏បញ្ជូនគាត់មកវិញ ដោយយល់ថាខ្លួនចាញ់បោកអ្នកដែលខ្លួនស្គាល់ ក៏ចាប់ជនរងគ្រោះទាំង២នាក់ដាក់ខ្នោះដៃរួចថតបង្ហោះឲ្យអ្នកនាំមកនោះឃើញ និងសងលុយខ្លួនវិញក្នុង១នាក់ចំនួន១,០០០ដុល្លារ និងសោហ៊ុយដឹកជញ្ជូនចំនួន២៥០ដុល្លា សរុបចំនួន២,៥០០ដុល្លារ ។ ចំណែក

ឈ្មោះ កៅ សុង វិញ បានសារភាពថា៖ ខ្លួនគេធ្វើការងារជាអ្នកគ្រប់គ្រងផ្នែកមើលការខូចខាតដូចជាទឹក ភ្លើង និងសម្ភារៈផ្សេងៗក្នុងអគារ។ ចំពោះការដាក់ខ្នោះជនជាតិខ្មែរ២នាក់នោះ ខ្លួនមិនបានពាក់ព័ន្ធឡើយ គឺឈ្មោះ ស៊ី សៅស៊ុន ជាអ្នកធ្វើទាំងអស់ ៕ រក្សាសិទ្ធិដោយ ៖ កូលាប

## លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ព្រមានមានវិធានការច្បាប់ ចំពោះមន្ត្រីនគរបាលណាពាក់ពន្ធ័បទល្មើស នាំមនុស្សឆ្លងដែន ខុសច្បាប់ និងបទល្មើស ជួញដូរថ្នាំញៀន

https://dap-news.com/ ByPH104Posted on October 21, 2021

បន្ទាយមានជ័យ ៖ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាល ខេត្តបន្ទាយមានជ័យ បានថ្លែងព្រមានចំៗ ចំពោះមន្ត្រីនគរបាល ដែលឈរជើង តាមបន្ទាត់ព្រំដែលកម្ពុជា-ថៃ ថាក្នុងនាមជានគរបាលជាតិ ដាច់ខាតមិនត្រូវពាក់ពន្ធ័ជាមួយឈ្មួញឬបទល្មើស ជួញដូរថ្នាំញៀន និងមេខ្យល់នាំមនុស្ស ឆ្លងដែនខុសច្បាប់ឡើយ បើរកឃើញបទល្មើស នៅគោលដៅណា លោកនឹងមានវិធានការ តាមច្បាប់និងបញ្ជូន ទៅតុលាការតែប៉ុណ្ណោះ។

ការថ្លែងនេះ ត្រូវបានធ្វើឡើង កាលពីព្រឹក ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១នេះ ក្នុងឱកាស ដែលលោកឧត្តមសេនីយ៍ស្នងការ អញ្ជើញចុះត្រួតពិនិត្យស្ថានភាព តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងបើកកិច្ចប្រជុំពង្រឹង ប្រសិទ្ធភាពការងារប្រចាំថ្ងៃ របស់នគរបាលការពារព្រំដែន នៅទីបញ្ជាការវរនគរបាលការពារព្រំដែនគោក៨០៧ ច្រកបឹងត្រកួន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី លោកលោកស្រី ឧត្តមសេនីយ៍ វរសេនីយ៍ និងមេបញ្ជាការវរការពារព្រំដែនគោកទាំង៤ផងដែរ ។ ទន្ទឹមគ្នានោះ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ក៏បានជម្រុញឲ្យគ្រប់មេបញ្ជាការវរៈ ត្រូវមានសាមគ្គីផ្ទៃក្នុង ពង្រឹងប្រសិទ្ធភាពកម្លាំង សហការជាមួយអាជ្ញាធរ ស្ថាប័នពាក់ពន្ធ័ និងភាគីថៃឲ្យបានល្អ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការធ្វើការងារ ។ កម្លាំងទាំងអស់ត្រូវរួមគ្នាទប់ស្កាត់រាល់បទល្មើសតាមព្រំដែន ពិសេសគឺបទល្មើស ១-ការជួញដូរមនុស្សឆ្លងដែនខុសច្បាប់(ពលករចំណាកស្រុក មេខ្យល់) ២-បទល្មើសសេដ្ឋកិច្ច (ទំនិញគេចពន្ធ និងរថយន្តចង្កូតស្តាំ) ៣-បទល្មើសជួញដូរគ្រឿងញៀន។

ក្រៅពីនេះលោកឧត្តមសេនីយ៍ស្នងការ ក៏បានដាក់ចេញនូវបទបញ្ជា ឲ្យកម្លាំងនគរបាលព្រំដែនទាំងអស់ត្រូវយកចិត្តទុកដាក់ ពង្រឹងប្រសិទ្ធភាពការងារ ត្រៀមកម្លាំងប្រចាំការ២៤ម៉ោង កសាងប៉ុស្តិ៍ ជំរក សម្ភារៈ បរិក្ខាទ័ព គ្រប់គ្រងគ្រាប់/អាវុធ បង្កបង្កើនការ ដាំដំណាំ ចិញ្ចឹមត្រី ចិញ្ចឹមសត្វ ដើម្បីទ្រទ្រង់ដល់ការហូបចុកប្រចាំថ្ងៃ ដើម្បីលើកស្ទួយជីវភាព នគរបាលតាមព្រំដែន ឲ្យកាន់តែមានភាពប្រសើរឡើង៕ ដោយ ប៊ុន សំណាង

# ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១

## លោកជំទាវ ជូ ប៊ុនអេង ៖ កូវីដជាឧបសគ្គ ហើយកូវីដក៏ជាឱកាស ក្នុងការរៀបចំគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ឡើងវិញ

https://cen.com.kh/ Posted ByPen Srey NeatOctober 22, 2021

កោះកុង ៖ លោកជំទាវ ជូ ប៊ុនអេង ថ្លែងថា "កូវីដជាឧបសគ្គ ហើយកូវីដក៏ជាឱកាសក្នុងការរៀបចំគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ឡើងវិញ ដើម្បីរៀបចំផែនការគោលនយោបាយគ្រប់គ្រង និងផ្តល់ការគាំទ្រទៅដល់ពួកគាត់ ឱ្យកាន់តែមានភាពល្អប្រសើរ នៅតាមច្រកព្រំដែនអន្តរជាតិ និងច្រកផ្សេងៗទៀត "។ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ថ្លែងយ៉ាងដូច្នេះក្នុងពិធីជួបសំណេះសំណាល និងពិនិត្យស្ថានភាព នៃលំហូររបស់ពលករឆ្លងកាត់ព្រំដែន ខេត្តកោះកុង ។ ព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ប្រតិភូអគ្គលេខាធិការដ្ឋាន គជបជ ដឹកនាំដោយលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និង

តំណាងពីក្រសួងសុខាភិបាល ទីប្រឹក្សាក្រសួង មន្ត្រីបច្ចេកទេស បានអញ្ជើញបន្តដំណើរទស្សនកិច្ចការងារ និងជួបពិភាក្សាការងារជាមួយមន្ត្រីមានសមត្ថកិច្ច នៅច្រកទ្វារអន្តរជាតិចាំយាម ខេត្តកោះកុង ។

មានការអញ្ជើញចូលរួមជាគណៈប្រតិភូ តំណាងក្រសួងសុខាភិបាល ទីប្រឹក្សាក្រសួង លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ អគ្គលេខាធិការរង អភិបាលរងខេត្ត ប្រធានច្រកព្រំដែនចាំយាម មន្ត្រីបច្ចេកទេសសុខាភិបាល និងអង្គការ IOM តំណាងធនាគារ ADB ។ គោលបំណងរបស់ប្រតិភូរាជរដ្ឋាភិបាលក្នុងដំណើរទស្សនកិច្ចនេះ គឺដើម្បីស្វែងរកជាតុចូលមួយចំនួន ដើម្បីគ្រប់គ្រងលំហូរចេញចូលតាមច្រកព្រំដែន និងអនុវត្តគោលនយោបាយគាំពារក្នុងវិស័យសុខាភិបាល របស់ពលករទេសន្តរប្រវេសន៍ ដើម្បីជាមូលដ្ឋានក្នុងការកសាងរៀបចំផែនការយុទ្ធសាស្ត្រជាតិ ក្នុងវិស័យសុខាភិបាល ៕ រក្សាសិទ្ធិដោយ ៖ កូលាប

## នគរបាលបញ្ជូនជនសង្ស័យ២នាក់ ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ពាក់ព័ន្ធករណីនាំមនុស្សឆ្លងដែនដោយមិនស្របច្បាប់

http://cambodiapolice.com/policekh/ 10:58 am 21 តុលា 2021

**បន្ទាយមានជ័យ** ៖ កម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានកសាងសំណុំរឿងបញ្ជូនជនសង្ស័យ២នាក់ ពាក់ព័ន្ធករណីនាំមនុស្សឆ្លងដែនដោយមិនស្របច្បាប់ ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅល្ងាចថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ដើម្បីចាត់តាមនិតិវិធី ។

លោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា៖ ជនសង្ស័យទាំង០២នាក់ ៖ ១-ឈ្មោះ យឹន សុឃី ភេទប្រុស អាយុ៣៤ឆ្នាំ នៅភូមិល្វា ឃុំ បឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ,២-ឈ្មោះ គីន រ៉េត ភេទប្រុស អាយុ ២២ឆ្នាំ នៅភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជាក់ឲ្យដឹងថា៖ នៅវេលាម៉ោង៥និង១០នាទី ព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ កម្លាំងនរបាលប៉ុស្តិ៍រដ្ឋបាលឃុំបឹងបេង និងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាប្រតិបត្តិការសិករងខេត្តបន្ទាយមានជ័យ បានទប់ស្កាត់ពលករបំរុងលួចឆ្លងដែន ដោយខុសច្បាប់ទៅប្រទេសថៃចំនួន១៨នាក់ ស្រី៦នាក់ និងកុមារ២នាក់ នៅចំណុចមាត់អូរព្រំដែន ក្នុងភូមិសាស្រ្ត ភូមិល្វា ឃុំបឹងបេង ក្នុងនោះចំណោមពលករទាំង១៨នាក់នោះ ក៏មានជនសង្ស័យចំនួន២នាក់ ជាអ្នកនាំផ្លូវផងដែរ គឺមានឈ្មោះ យឹន សុឃី និងឈ្មោះ គីន រ៉េត ។ លោកស្រីឧត្តមសេនីយ៍ស្នងការរង បានបញ្ជាក់ថា៖ តាមចម្លើយសារភាពរបស់ជនសង្ស័យទាំង២នាក់ ខ្លួនធ្លាប់នាំពលរឆ្លងដែនបានចំនួន២លើក ហើយរាល់ការនាំពលករលួចឆ្លងដែននេះ ក្នុង១នាក់គេយកតម្លៃ២០០បាត។ ផ្អែកតាមចម្លើយសារភាព និងការឃាត់ខ្លួនជាក់ស្តែង ជនសង្ស័យទាំង២នាក់ ត្រូវបានបញ្ជូនទៅសាលាដំបូងខេត្ត ចាត់ការតាមនិតិវិធីហើយដែរ៕

## ពលករខ្មែរត្រឡប់ពីថៃចូលកម្ពុជាក្នុង១ថ្ងៃជិត១០០នាក់ ហើយមានលួចឆ្លងដែនទៅថៃចាប់បញ្ជូនមកវិញទៀត

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២២ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ០៩:១៥

បន្ទាយមានជ័យ ៖ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ ក្នុង១ថ្ងៃជិត ១០០នាក់ ហើយមានលួចឆ្លងដែនទៅថៃចាប់បញ្ជូនមកវិញ រហូតដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ។

លោកវរៈសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ និងជាសមាជិកក្រុមការងារទទួលពលករខ្មែរច្រកអូរបីជាន់បានប្រាប់ថា ៖ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១នេះ នៅច្រកអូរបីជាន់ ស្រុកអូរជ្រៅ ក្រុមការងារបានទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ និងអាជ្ញាធរមានសមត្ថកិច្ចថៃចាប់តាមបន្ទាត់ព្រំដែននៅលួចឆ្លងទៅរកការងារធ្វើនៅប្រទេសថៃត្រូវបានបញ្ជូនមកវិញមានចំនួន៤០នាក់ ស្រី១៨នាក់ កុមារ៣នាក់ រកឃើញវិជ្ជមានកូវីដ១៩ ចំនួន១២នាក់ ស្រី៨នាក់ កុមារ៣នាក់ ។

លោក វ៉ាន់ ដារ៉ាន់ ប្រធានគណៈកម្មការច្រកតំបន់ព្រំដែនបឹងត្រកួន និងក្រុមការងារទទួលពលករត្រឡប់ពីប្រទេសថៃបានបញ្ជាក់ថា ៖ ច្រកបឹងត្រកួនស្រុកថ្មពួក នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១នេះមានពលករខ្មែរត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ ដែលត្រូវបានទទួលមានចំនួន២៦នាក់ ស្រី១២នាក់ក្នុននោះមានប្រជាពលរដ្ឋខ្មែរលួចឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់ត្រូវបានអាជ្ញាធរមានសមត្ថកិច្ចចាប់បញ្ជូនមកវិញ ។

គួរបញ្ជាក់ថា ៖ ចំពោះពលករខ្មែរដែលត្រឡប់មកផ្ទះវិញ និងអាជ្ញាធរថៃចាប់បញ្ជូនដែលក្រុមការងារទទួលរយៈពេល១ថ្ងៃ មានចំនួន៦៦នាក់ ស្រី៣០នាក់ កុមារ៣នាក់ និងរកឃើញអ្នកវិជ្ជមានកូវីដ១៩មានចំនួន១២នាក់ ស្រី៨នាក់ ចំពោះអ្នកវិជ្ជមានកូវីដ១៩ត្រូវបានបញ្ជូនទៅព្យាបាល និងអ្នកអវិជ្ជមានកូវីដ១៩ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលក្រុងសិរីសោភ័ណ ៕

## សមត្ថកិច្ចថៃ ឃាត់ខ្លួនមេខ្យល់ជាជនជាតិថៃ ៦នាក់ ដែលដឹកពលករខ្មែរឆ្លងដែនដោយខុសច្បាប់ នៅស្រុកអរញ្ញ ខេត្តស្រះកែវ

https://khmernote.com.kh/ October 22, 2021 srey nuch

ខេត្តបន្ទាយមានជ័យ៖ តាមការចុះផ្សាយរបស់ នាយកដ្ឋានផ្សព្វផ្សាយអប់រំ ដោយយោងតាមសេចក្តីរាយការណ៍ពីប្រទេសថៃបានឲ្យដឹងថា នៅវេលាម៉ោង១១និង១៥នាទី ព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១នេះ កម្លាំងស្រាវជ្រាវរបស់ស្នងការនគរបាលខេត្តស្រះកែវ សហការជាមួយកម្លាំងរបស់អធិការដ្ឋាននគរបាលស្រុកអារញ្ញ និងអង្គភាពពាក់ពន្ធ័ បានឃាត់ខ្លួនបណ្តាញលួចដឹកជញ្ជូនពលករខុសច្បាប់ជនជាតិខ្មែរ ដែលចូលមកក្នុងប្រទេសថៃសរុបចំនួន ៦០នាក់ រួមមាន៖

មេខ្យល់ជនជាតិថៃ ៦នាក់ ពលករខ្មែរ ៥៤នាក់ ក្នុងនោះប្រុស ២៩នាក់ ស្រី១៨នាក់ និងក្មេង៧នាក់ នៅលើថ្នល់បាយផាសអារញ្ញ ឆ្ពោះទៅទីរួមខេត្តស្រះកែវ ស្ថិតក្នុងឃុំបានដាន ស្រុកអារញ្ញ ខេត្តស្រះកែវ។ បញ្ជូនទៅសួរនាំបន្ថែម នៅអធិការដ្ឋាននគរបាលស្រុកអារញ្ញ។ សមត្ថកិច្ចថៃបានឲ្យដឹងថា ជំហ៊ានដំបូងសម្រាប់ពលករខ្មែរ បានប្រាប់សមត្ថកិច្ចថា ពួកគេបានចំណាយលុយឲ្យជនជាតិខ្មែរចាត់ការឲ្យក្នុងម្នាក់១,០០០បាត មិនរួមបញ្ចូលថ្លៃធ្វើដំណើរផ្សេងៗនៅខាងថៃទេ។ ក្នុងនោះបានបំបែកសំណុំរឿងទៅក្រុមមេខ្យល់នាំពលករខ្មែរ និងបានប្រកាសពីទោសទណ្ឌសម្រាប់ពលករខ្មែរ ដែលប្រព្រឹត្តបទល្មើសលួចឆ្លងចូលប្រទេសដោយខុសច្បាប់ផងដែរ។ បន្ទាប់ពីធ្វើ

ត្រួតពិនិត្យដោយអនុវត្តតាមវិធានរបស់ផ្នែកសុខាភិបាលនោះរួចមក ពលរដ្ឋទាំងនោះបានឲ្យត្រឡប់ទៅប្រទេសវិញ ដោយឲ្យខាងនគរបាលអន្តោប្រវេសន៍ខេត្តស្រះកែវ និងខាងទាហានជាអ្នកដំណើរការ។

ជាមួយគ្នានោះដែរពលករខ្មែរម្នាក់បានប្រាប់សមត្ថកិច្ចថៃថា ៖ ពួកគេប្រើវិធីដើរថ្មើជើងពីខាងកម្ពុជា តាំងពីម៉ោងប្រមាណ១១ យប់ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ ដើម្បីឆ្លងដែនតាមច្រករបៀងមកប្រទេសថៃ មករង់ចាំរថយន្តចូលមកទទួល និងដឹកទៅតែត្រូវសមត្ថកិច្ចចាប់បានមុន ដោយពួកគេមានបំណងទៅធ្វើការសំណង់នៅក្រុងបាងកក ហើយក្នុងនោះដែរពលករខ្មែរភាគច្រើនបានអះអាងថា ពួកគាត់បានចាក់វ៉ាក់សាំងការពារជម្ងឺកូវីដ-១៩ ហើយ ព្រមទាំងយកឯកសារចាក់វ៉ាក់សាំង និងលើកបង្ហាញសមត្ថកិច្ចថៃទៀតផងដែរ។ តែទោះជាយ៉ាងណាក៏ដោយ ក្រោយពីសមត្ថកិច្ចថៃសួរនាំ និងធ្វើកំណត់ហេតុរួចរាល់ក៏បានបញ្ជូនទៅឲ្យជំនាញស្រុកអារញ្ញ ដើម្បីចាត់វិធានការបន្ត ។ ចំណែកមេខ្យល់ជាជនជាតិថៃទាំង៦នាក់ សមត្ថកិច្ចនិងរៀបចំសំណុំរឿងតាមនិតិវិធី៕

## ចាប់ខ្លួនស្ត្រីជនជាតិចិន៣នាក់ បញ្ជូនទៅតុលាការពាក់ពន្ធករណីនាំទា.រកបម្រុងជិះយន្តហោះឆ្លងដែនខុសច្បាប់

https://kohsantepheapdaily.com.kh/ ភ្នំពេញ២៣ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ១៦:៣៩

រាជធានីភ្នំពេញ ៖ ស្ត្រីជនជាតិចិន៣នាក់ កាលពីរសៀលថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ នេះត្រូវបានកម្លាំងសមត្ថកិច្ចនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចាប់បញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ពាក់ពន្ធករណីនាំទា.រកឆ្លងដែនខុសច្បាប់ ។ ជនសង្ស័យជាជនជាតិចិន៣ នាក់នោះមាន១.ឈ្មោះ LI BINGRONG ភេទស្រី អាយុ៣៩ ឆ្នាំ ២.ឈ្មោះ WEI QIUCHAN ភេទស្រី អាយុ៥២ ឆ្នាំ និង៣.ឈ្មោះ ZHANG QIAN ភេទស្រី អាយុ២៥ ឆ្នាំ ។ ទាក់ទិននឹងការចាប់ខ្លួនស្ត្រីជនជាតិចិន៣ នាក់បញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញនោះ ប្រភពព័ត៌មានឲ្យដឹងថា កាលពីព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ កម្លាំងសមត្ថកិច្ចនគរបាលប្រចាំច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដោយមានការសង្ស័យបានធ្វើការឃាត់ខ្លួនស្ត្រីចិន៣ នាក់ ដូចមានឈ្មោះខាងលើ ក្នុងករណីកំពុងប្រព្រឹត្តបទល្មើសជាក់ស្តែង ដែលបីទា.រកអាយុមិនលើសពី១ឆ្នាំ ម្នាក់មួយៗ បម្រុងជិះយន្តហោះឆ្លងដែនទៅកាន់ប្រទេសចិន ។

ក្រោយឃាត់ខ្លួនស្ត្រីចិន៣ នាក់នោះ សមត្ថកិច្ចនគរបាលច្រកទ្វារព្រលានយន្តហោះអន្តរជាតិភ្នំពេញបានសហការ និងប្រគល់ជនសង្ស័យ៣នាក់ និងទា.រកទាំង៣ ឲ្យទៅសមត្ថកិច្ចជំនាញនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីបន្តនីតិវិធី ។ ដូច្នោះហើយទើបជនសង្ស័យត្រូវបានសមត្ថកិច្ចការិយាល័យប្រឆាំងការជួញដូរមនុស្សឆ្លងដែន កសាងសំណុំរឿងបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ។ ចំណែកទា.រកមានភេទប្រុស.ភេទស្រី អាយុមិនលើសពី១ឆ្នាំ ត្រូវបានសមត្ថកិច្ចនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានប្រគល់ឲ្យទៅក្រសួងសង្គមកិច្ចយកទៅចិញ្ចឹមបីបាច់ថែទាំជាបណ្ដោះអាសន្ន ។ សំណុំរឿងបានស្ថិតនៅដៃលោក សឿ ឡង់ឌី ព្រះរាជអាជ្ញារង(ប្រចាំការ)បើកការស៊ើបសួរ ដែលការសាកសួរនោះនៅមិនទាន់បានបញ្ចប់ទេ តំណាងអយ្យការបានផ្ញើជនសង្ស័យទៅសមត្ថកិច្ចគ្រប់គ្រងវិញ ស្នើឲ្យនាំមកបន្តនីតិវិធី ៕

## ពលករខ្មែរចំនួន៥១នាក់ដែលឆ្លងចូលដីថៃខុសច្បាប់ត្រូវបានយោធាថៃឃាត់ខ្លួន

https://www.facebook.com/neakmeasnews/ ដោយ ជីវ័ន្ត គេហទំព័រ នាគមាស 23/10/2021

(ប្រទេសថៃខេត្តស្រះកែវ)៖ ក្រុមទាហានឈុតខ្មៅថៃក្នុងកងវរសេនាធំទី១២ សហការជាមួយតម្រួតការពារព្រំដែនថៃលេខ៤ ចាប់ខ្លួនពលករខ្មែរចំនួន៥១នាក់ ខណៈដែលពួកគេលបឆ្លងដែនដោយខុសច្បាប់ដើម្បីចូលទឹកដីថៃរកការងារធ្វើ ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីល្ងាច ថ្ងៃទី ២២ ខែតុលា ឆ្នាំ២០២១ត្រង់ចំណុចណងម៉ាំងក្នុងភូមិ៥ឃុំណងវ៉េងស្រុកគោកខ្សូងខេត្តស្រះកែវប្រទេសថៃ ។នៅមុនពេលឃាត់ខ្លួនគឺមានពលករខ្មែរចំនួន ៥១ នាក់បានលបឆ្លងព្រំដែនចូលទៅក្នុងទឹកដីថៃ ដោយនាំគ្នាដើរកាត់តាមព្រៃក្បែរខ្សែបន្ទាត់ព្រំដែន ស្របពេលដែលកម្លាំងទាហានឈុតខ្មៅថៃ កំពុងល្បាតក៏បានស្ទាក់ចាប់ ដែលក្នុងនោះប្រុស ៣៣ នាក់និងស្រី១៨នាក់។

ក្រោយការចាប់ខ្លួនពលករខ្មែរ បានសារភាពថា ពួកគេទាំងអស់មានបំណងឆ្លងចូលទៅរកការងារធ្វើនៅក្នុងខេត្តឈុនបុរី ខេត្តណុនថៈបុរី និងទីក្រុងបាងកក ប្រទេសថៃ ដោយត្រូវចំណាយអោយមេខ្យល់ក្នុងម្នាក់ៗចាប់ពី ៤.០០០បាត ដល់ ៧.០០០បាត ហើយត្រូវប្រគល់លុយមុនក្និងម្នាក់៥០០បាតសិន ប៉ុន្តែក៏ត្រូវឃាត់ខ្លួនតែម្តង ។ ក្រោយពេលឃាត់ខ្លួន ក្រុមយោធាថៃបានត្រួតពិនិត្យសុខភាពពួកគេទាំងអស់ ដើម្បីការពារនៅក្នុងដំណាក់កាលនៃជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាតនិងបានបញ្ជូនទៅអោយអធិការដ្ឋានតម្រួតស្រុកគោកខ្សូងដើម្បីអនុវត្តតាមនីតិវិធី ៕

## បញ្ជូនជនជាតិបង់ក្លាដែស០២នាក់ ទៅតុលាការ ករណីចាប់ពង្រត់ ការបង្ខាំងមនុស្សខុសច្បាប់

https://cen.com.kh/ Posted ByPen Srey NeatOctober 24, 2021

បន្ទាយមានជ័យ ៖ នគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ បានបញ្ជូនជនសង្ស័យជនជាតិបង់ក្លែសចំនួន ០២នាក់ ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី ។

លោកស្រី ឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង ទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា ជនសង្ស័យជនជាតិបង់ក្លាដែសទាំង០២នាក់ មានឈ្មោះ មៀ ហាប៊ីប ភេទប្រុស អាយុ ២៧ ឆ្នាំ និងឈ្មោះ អ៊ីស្លាម អ៊ែលសារុល ភេទប្រុស អាយុ៣១ឆ្នាំ ទាំង០២នាក់ ស្នាក់នៅផ្ទះជួលលេខ៦E ផ្លូវ៣១២ ភូមិ៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ជនសង្ស័យទាំង០២នាក់នេះ ដោយទទួលបាននូវបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនរបាលខេត្តបន្ទាយមានជ័យ ដោយមានការអនុញ្ញាតពន្លាតដែនសមត្ថកិច្ច ពីឯកឧត្តម កើត សុវណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបន្ទាយមានជ័យ កម្លាំងនគរបាលការិយាល័យជំនាញ និងកម្លាំងអធិការដ្ឋាន សហការជាមួយកម្លាំងនគរបាលរាជធានីភ្នំពេញ បន្តស្រាវជ្រាវឈានដល់នាំខ្លួនជនសង្ស័យទាំង០២នាក់ មកសាកសួរនៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ និងធ្វើការឃាត់ខ្លួននៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១៦និង២៥នាទី ។

លោកស្រី ឧត្តមសេនីយ៍ស្នងការរង បញ្ជាក់ថា ជនសង្ស័យជនជាតិបង់ក្លាដែសទាំង០២នាក់នេះ ជាប់ពាក់ព័ន្ធករណីការចាប់ពង្រត់ ការឃុំឃាំងឬការបង្ខាំងមនុស្ស ជាមួយនឹងជនសង្ស័យជនជាតិចិន០២នាក់ ១/- ស៊ីន សៅស៊ុន ភេទប្រុសអាយុ៣៦ឆ្នាំ,២/-ឈ្មោះ កៅ ឈុង ភេទប្រុស អាយុ៣៥ឆ្នាំ ទៅលើជនរងគ្រោះជនជាតិខ្មែរ០២នាក់ ដោយដឹកពីភ្នំពេញមកក្រុងប៉ោយប៉ែត ហើយបង្ខាំងនៅចំណុចភូមិគីឡូលេខ៤ សង្កាត់ផ្សារ កណ្តាល ក្រុងប៉ោយប៉ែត កាលពីថ្ងៃទី០៨ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ដោយឲ្យជនរងគ្រោះទាំង០២នាក់ រកលុយម្នាក់

១,០០០ដុល្លារ មកសងខ្លួនវិញ ។ សូមបញ្ជាក់ថា ជនជាតិចិនទាំង០២នាក់ ត្រូវបានឃាត់ខ្លួនបញ្ជូនទៅសាលាដំបូងខេត្ត កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ៕ រក្សាសិទ្ធិដោយ ៖ កូលាប

# ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១

## កម្លាំងការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនិតិជន ឃាត់ខ្លួនមេខ្យល់៤នាក់ ករណីនាំមនុស្សឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

http://cambodiapolice.com/policekh/ 4:38 pm 24 តុលា 2021

បន្ទាយមានជ័យ ៖ មេខ្យល់ប្រុស-ស្រី៤នាក់ ត្រូវបានកម្លាំងនគរបាល ការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ សហការជាមួយកម្លាំងវរនគរបាលការពារព្រំដែនគោគ៨០៧ កម្លាំងនគរបាលអធិការដ្ឋាននគរបាលស្រុកស្វាយចេក ធ្វើការចាប់ឃាត់ខ្លួនខណៈកំពុងធ្វើសកម្មភាពនាំមនុស្សឆ្លងដែនទៅថៃខុសច្បាប់ ។

លោកឧត្តមសេនីយ៍ត្រី អ៊ុំ សុផល ស្នងការរង ទទួលផែនការងារព្រំដែន បានមានប្រសាសន៍ថា ក្រោមការដឹកនាំបញ្ជាផ្ទាល់ពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ឲ្យទប់ស្កាត់រាល់បទល្មើសតាមព្រំដែន ពិសេសបទល្មើសពលករឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ លោកបានដឹកនាំកម្លាំងចុះស្រាវជ្រាវនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ ក៏បានឃាត់ខ្លួនមេខ្យល់ប្រុស-ស្រីនាំមនុស្សឆ្លងដែនខុសច្បាប់ទៅថៃ ចំនួន៤នាក់ និងពលករចំនួន១៣នាក់ បញ្ជូនទៅឲ្យកម្លាំងអធិការដ្ឋាននគរបាលស្រុកស្វាយចេក អនុវត្តបន្តតាមនីតិវិធី ។

ពាក់ពន្ធ័ករណីខាងលើនេះ លោកស្រីឧត្តមសេនីយ៍ត្រី ឌី សជាតិ ស្នងការរង ទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងយេនឌ័រ បានមានប្រសាសន៍ថា ជនសង្ស័យឈ្មោះ សួន ម៉ាង ភេទប្រុស អាយុ៣៩ឆ្នាំ រស់នៅភូមិចំការគ ស្រុកស្វាយចេក ជាមេខ្យល់ពិតប្រាកដ ដោយរូបគេបានយកប្រាក់ពីពលករក្នុង១នាក់ ២៥០០បាត ជាថ្លៃរជូននាំផ្លូវ ។ ចំពោះឈ្មោះ ចំរើន ធារៈ ភេទប្រុស, ឈ្មោះ ចាន់ រស្មី ភេទស្រី និងឈ្មោះ ប្រម វិន័យ ភេទស្រី បានសារភាពថា ពួកគេបានដឹកជញ្ជូនពលករតាមរថយន្តនិងម៉ូតូ មកឲ្យមេខ្យល់ឈ្មោះ សួន ម៉ាន នៅច្រកបឹងព្រីង ក្នុងភូមិថ្មល់បំបបែក ឃុំគោករមៀត ស្រុកថ្មពួកពិតប្រាកដមែន ។ លោកស្រីស្នងការរងបានបញ្ជាក់ថា បច្ចុប្បន្នមេខ្យល់ប្រុស-ស្រីទាំង៤នាក់ ត្រូវបានឃាត់ខ្លួនបញ្ជូនទៅសាលាដំបូងខេត្តអនុវត្តតាមច្បាប់ និងបានតម្រូវឲ្យពួកគេប្រគល់ប្រាក់ជូនពលករទាំងអស់វិញ ។ ពលករទាំង១៣នាក់ ក្នុងនោះក្មេងម្នាក់ត្រូវបានសមត្ថកិច្ចបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលព្យាបាលកូវីដ-១៩ ក្នុងក្រុងសិរីសោភ័ណ ៕

## បញ្ជូនជនជាតិចិន២នាក់ បង់ក្លាដេស២នាក់ទីតុលាការ ពីបទចាប់ពង្រត់និងបង្ខាំងមនុស្សខុសច្បាប់នៅកាស៊ីណូមួយក្នុងបុរី សាន ហូ ក្រុងប៉ោយប៉ែត

https://cen.com.kh/ Posted ByPen Srey NeatOctober 25, 2021

បន្ទាយមានជ័យ ៖ ជនជាតិចិន២នាក់ បង់ក្លាដេស២នាក់ ត្រូវបានកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានសហការជាមួយកម្លាំងនគរបាល អធិការដ្ឋាននគរបាលក្រុងប៉ោយប៉ែត ឆ្មក់ចូលចាប់ខ្លួនពាក់ពន្ធ័ករណីពង្រត់និងបង្ខាំងមនុស្សខុសច្បាប់នៅក្នុងកាស៊ីណូមួយកន្លែងក្នុងបុរី សាន ហូ ក្រុងប៉ោយប៉ែត និងបានរំដោះជនរងគ្រោះជនជាតិថៃ៦នាក់ ជនជាតិខ្មែរ២នាក់ នៅភូមិគីឡូម៉ែត្រ៤ សង្កាត់/ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ យកមកសួរនាំកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១នេះ។

លោកវរសេនីយ៍ឯក សៅ សារឿន អធិការនគរបាលក្រុងប៉ោយប៉ែត បានឲ្យដឹងថា ក្រោមការដឹកនាំបញ្ជាផ្ទាល់ពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ និងមានការសម្របសម្រួលនីតិវិធីពីឯកឧត្តម កើត សុវណ្ណរ៉េត ព្រះរាជអាជ្ញារ អមសាលាដំបូងខេត្ត លោកបានដឹកនាំកម្លាំងសហការជាមួយ កម្លាំងការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនិជន ចុះស្រាវជ្រាវ និងឈានដល់ការធ្វក់ខ្លួនឃាត់ជមជាតិចិនបាន០២នាក់ ជនជាតិបង់ក្លាដេស២នាក់ ពាក់ពន្ធ័ករណីពង្រត់និងបង្ខាំងមនុស្សដោយខុសច្បាប់ ក្រៅពីនេះបានរំដោះជនជាតិថៃ០៦នាក់ ជនជាតិខ្មែរ០២នាក់ យកមកសួរនាំផងដែរ។

លោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនិតិជន បានឲ្យដឹងថា ការឃាត់ខ្លួនជនសង្ស័យទាំង៤នាក់ធ្វើឡើងបន្ទាប់ពីមានសាច់ញាតិជនរងគ្រោះបានមកប្តឹងសុំឲ្យសមត្ថកិច្ចជួយអន្តរាគមន៍ ខណៈបងប្អូនរបស់ខ្លួនបានទៅដាក់ពាក្យធ្វើការកាស៊ីណូអនឡាញ តែត្រូវមេការជនជាតិចិនចាប់បង្ខាំងទុក បង្អត់បាយ ចាប់ដាក់ខ្នោះថតរូបភាពបង្ហោះឲ្យសាច់សាច់យកលុយមកលោះ១នាក់ចំនួន១០០០ដុល្លា ទើបដោះលេងវិញ។ ក្រោយចុះស្រាវជ្រាវកម្លាំងសមត្ថកិច្ចយើងឃាត់បានជនសង្ស័យ ១-ឈ្មោះ ស៊ីនសៅស៊ុន ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិចិន ២-ឈ្មោះ កៅ ឈុង ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិចិន ៣-ឈ្មោះ អ៊ីស្លាម អ៊ែលសារុល ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិបង់ក្លាដេស និង៤-ឈ្មោះ មៀ ហាប៊ីប ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិបង់ក្លាដេស។

ពាក់ពន្ធ័ករណីនេះ លោកស្រី ឌី សជាតិ ស្នងការរង ទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងយ៉េនឌ័រ បានមានប្រសាសន៍ឲ្យដឹងថា យោងការបំភ្លឺរបស់ជនរងគ្រោះជនជាតិខ្មែរឈ្មោះ ឡឿម ឌាត ភេទប្រុស អាយុ៣៣ឆ្នាំ និងឈ្មោះ ជឹម ក្លឹប បានឲ្យដឹងថា ពួកខ្លួនបានទៅដាក់ពាក្យសម្ភាសន៍ចូលធ្វើការខាងកាស៊ីណូអនឡាញក្នុងក្រុមហ៊ុនមួយនៅភ្នំពេញ ហើយបានជាប់ជាមួយមនុស្ស០៦នាក់ផ្សេងទៀត កាលពីថ្ងៃទី០៨ តុលា ឆ្នាំ២០២១ យប់នេះពួកគេត្រូវបានជនជាតិចិនដឹកតាមរយន្តយកមកកាន់ក្រុងប៉ោយប៉ែត ម៉ោង៣ដល់គោលដៅ គេបានឲ្យស្នាក់នៅបន្ទប់លេខ១១៤ ក្នុងអាគារ១០០បន្ទប់ ព្រឹកបន្ទាប់ជនជាតិចិនបានយកទៅធ្វើការក្នុងកាស៊ីណូមួយនៅប៉ុរីសានហូ ក្រុងប៉ោយប៉ែត អ្នកអត់ចេះភាសារថៃត្រូវបានគេយកទៅភ្នំពេញវិញ ដោយឡែកពួកខ្លួនចេះថៃត្រូវបានគេទុកឲ្យនៅធ្វើការបន្ត បន្ទាប់មេការជនជាតិចិនបានសួររកអត្តសញ្ញាណប័ណ្ណជនជាតិថៃ ទម្រង់គ្រោះបានតបថាពួកខ្លួនក៏មានទេ ស្រាប់តែភ្លាមនោះត្រូវបានជនជាតិចិនយកទៅបន្ទប់លេខ ១១៤ និងបានចាក់បង្គខឹងកុំខឹងជាមួយនឹងខ្ញុំទៀតថៃចំនួន៦នាក់ ផ្សេងទៀត និងបានចាប់ដាក់ខ្នោះដៃ ឃុំឃាំងបង្អត់អាហារ ដោយប្រាប់ថា ពួកខ្លួនត្រូវបានគេលក់មកឲ្យខាងថៅកែកាស៊ីណូ បើចង់ចេញត្រូវបង់ប្រាក់ ១នាក់ ១០០០ដុល្លា បើគ្មានអ្នកមកលោះទេត្រូវឃុំទុកទីនេះរយៈពេល០៦ខែ។ចំណែកជនជាតិថៃ០៦នាក់ផ្សេងទៀត ក៏ត្រូវបានជនជាតិចិនខាងលើបង្ខាំងទុកផងដែរ ដោយខឹងជនជាតិថៃទាំងនោះមិនព្រមបង្កើតហ្វេសប៊ុក និងផេកក្លែងក្លាយ ដើម្បីបោកលុយជនជាតិថៃដូចគ្នា។

បច្ចុប្បន្នជនសង្ស័យទាំង៤នាក់ មានជនជាតិចិន២នាក់ ជនជាតិបង់ក្លាដេស២នាក់ ត្រូវបានការិយាល័យជំនាញកសាងសំណុំរឿង បញ្ជូនទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់៕ រក្សាសិទ្ធិដោយ ៖ កូលាប

## ត្រឹម១ថ្ងៃ! ពេលវេលាខុសគ្នា ទីតាំងផ្សេងគ្នា ឃាត់ខ្លួនពលរដ្ឋខ្មែរជិត៧០នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៥ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ១៣:៤៥

ខេត្តបន្ទាយមានជ័យ ៖ នៅយប់ថ្ងៃ២៤ ខែតុលា ឆ្នាំ២០២១នេះ កម្លាំងសមត្ថកិច្ចឈរជើងនៅតាមបន្ទាត់ព្រំដែនកម្ពុជា ក្នុងភូមិសាស្ត្រស្រុកស្វាយចេក បានធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរបំរុងលួចឆ្លងដែនចំនួន៣២នាក់ និងកម្លាំងសមត្ថកិច្ចថៃ ក៏បានធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរលួចឆ្លងដែនចូលក្នុងភូមិសាស្ត្រ ភូមិណងផៃ ឃុំតាប្រាយ៉ា

ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ បានជាបន្តបន្ទាប់ចំនួន៣២នាក់ផងដែរ សរុបចំនួន៦៤នាក់នៅទីតាំងផ្សេងគ្នា។

ករណីទី១- តាមការឲ្យដឹងពីកម្លាំងនគរបាលវរសេនាតូចការពារព្រំដែន៩១១ បានឱ្យដឹងថា៖ នៅម៉ោង០៤ និង៣០នាទីល្ងាច ថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០២១ កម្លាំងប៉ុស្តិ៍ការពារព្រំដែនចំការគ នៃវរសេនាតូចការពារព្រំដែនគោកលេខ៩១១ និងកម្លាំងយោធា បានស្ទាក់ឃាត់ខ្លួនពលរដ្ឋខ្មែរ៣២នាក់ (ក្នុងនោះស្រី១៧នាក់) ដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃ នៅត្រង់ចំណុចខាងជើងមណ្ឌលឃោធិនពិការតេជោភ្នំធំត្រ៣១៧ ស្ថិតក្នុងភូមិតេជោភ្នំធំត្រ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ បន្ទាប់មកពលរដ្ឋខ្មែរទាំងនោះ ត្រូវបានបញ្ជូនទៅឲ្យក្រុមការងារចម្រុះប្រចាំច្រកអូរបីជាន់។

ករណីទី២- បើតាមសេចក្តីរាយការណ៍ពីកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨០៧ បានឱ្យដែលថា ៖ នៅម៉ោង១០និង១០នាទីយប់ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២១នេះដែរ កម្លាំងនគរបាលស្រុកតាប្រាយ៉ា សហការជាមួយកម្លាំងទាហានបូព៌ា ធ.ក. តាប្រាយ៉ា ចាប់ឃាត់ខ្លួនពលករខ្មែរចំណាកស្រុកចូលទៅធ្វើការងារនៅប្រទេសថៃខុសច្បាប់បានចំនួន៣២នាក់ (ក្នុងនោះស្រី១៦នាក់) ស្ថិតនៅក្នុងភូមិសាស្រ្តភូមិណងផៃ ឃុំតាប្រាយ៉ា ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ ចម្ងាយ១៨គីឡូម៉ែត្រពីព្រំដែនភូមិសាស្រ្តឈមទល់មុខនឹងកម្ពុជា ស្ថិតក្នុងភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

ប្រភពដដែលបានបញ្ជាក់ថា ពលរដ្ឋខ្មែរដែលត្រូវបានសមត្ថកិច្ចថៃឃាត់ខ្លួននោះ ក្រុមការងារបានទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ប្រចាំការច្រកតំបន់បឹងត្រកួន ដើម្បីធ្វើការស្នើសុំសហការពីសមត្ថកិច្ចថៃ ឲ្យបញ្ជូនពលករទាំង៣២នាក់នោះត្រឡប់មកប្រទេសកម្ពុជាវិញ តែភាគីថៃមិនទាន់ឯកភាព និងបានបញ្ជូនពលរដ្ឋខ្មែរទាំង៣២នាក់នោះទៅធ្វើកំណត់ហេតុនៅអធិការដ្ឋានស្រុកតាប្រាយ៉ាតែម្តង៕

## ពលករខ្មែរ ៣៨ នាក់ ដែលតម្រួតថៃឃាត់ខ្លួន ត្រូវបានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ ជួយឱ្យត្រឡប់មកវិញ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 25 October 2021 | 18:03 ICT

**បន្ទាយមានជ័យ:** អគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ បានជួយអន្តរាគមន៍ភ្លាមៗ ដល់អាជ្ញាធរថៃ ឱ្យបញ្ជូនពលករខ្មែរ ៣៨ នាក់ ត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីត្រូវបានតម្រួតថៃចាប់ឃាត់ខ្លួន ខណៈពួកគេ កំពុងលួចឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ កាលពីយប់ថ្ងៃទី ២៤ ខែតុលា។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បានថ្លែងថា កាលពីរំលងអាធ្រាត្រឈានចូលថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០២១ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ បានអន្តរាគមន៍សហការជាមួយអាជ្ញាធរថៃ ជួយបញ្ជូនពលរដ្ឋខ្មែរចំនួន ៣៨ នាក់ (ប្រុស ២៩ នាក់) ដែលត្រូវបានមេខ្យល់នាំចូលទៅប្រទេសថៃ ដោយខុសច្បាប់តាមច្រករបៀង ឱ្យបានត្រឡប់មកកម្ពុជាវិញ នៅប៉ុន្មានម៉ោងក្រោយមកក្នុងថ្ងៃដដែលនោះ។

អ្នកនាំពាក្យសាលាខេត្តបន្ទាយមានជ័យលោក សេក សុខុម បានថ្លែងថា ចំពោះករណីពលករ ៣៨ នាក់ ដែលត្រឡប់ពីថៃនោះ លោកមិនទាន់ទទួលបានព័ត៌មានលំអិតនៅឡើយទេ។ ប៉ុន្តែលោកថា ជាទូទៅ ពលករខ្មែរខុសច្បាប់ ដែលអាជ្ញាធរនៅខេត្តស្រះកែវ បញ្ជូនត្រឡប់មកវិញភាគច្រើន មកតាមច្រកខេត្តបន្ទាយមានជ័យ។ លោកថា៖«ដូចករណីពលករខ្មែរ ១០៤ នាក់ កាលពីថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២១ ត្រូវបានអាជ្ញាធរខេត្តស្រះកែវ ប្រទេសថៃ បញ្ជូនមកកម្ពុជាវិញ តាមច្រកខេត្តបន្ទាយមានជ័យ ហើយបច្ចុប្បន្នពួកគាត់ក៏កំពុងដាក់ឱ្យធ្វើចត្តាឡីស័កដែរ»។ លោកនិយាយថា៖ «ចំពោះពលករខ្មែរដែលឃាត់ខ្លួន នៅលើទឹកដីថៃ ហើយត្រូវបញ្ជូនមកខ្មែរវិញ គឺសមត្ថកិច្ចជំនាញ គាត់តែងទៅជួបពលករ ដើម្បីស្រាវជ្រាវរកប្រភពថា តើគាត់ទៅតាមច្រកណា ហើយអ្នកណាជា

មេខ្យល់»។ បើតាមលោក សុខុម នៅក្នុងឆ្នាំ ២០២១ នេះ សមត្ថកិច្ចបានឃាត់ខ្លួនមេខ្យល់ និងបានបញ្ជូនទៅតុលាការជាបន្តបន្ទាប់។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័នភាពការងារ និងសិទ្ធិមនុស្ស (Central) បានថ្លែងថា ៖«នៅពេលថៃវីករាលដាលនៃជំងឺកូវីដ ១៩ ខ្លាំង គឺពលករសម្រុកមកខ្មែរវិញ ហើយក៏មានពលករខ្មែរខ្លះលួចចេញទៅថៃតាមច្រករបៀងដែរ »។ ដោយឡែកមូលហេតុដែលពលករខ្មែរ សម្រុកលួចទៅថៃមួយរយៈចុងក្រោយនេះ មានកត្តាពីរ គឺកត្តាជំរុញ និងកត្តាទាក់ទាញ។ លោកបញ្ជាក់ថា៖ «កត្តាជំរុញ គឺដោយសារគាត់អត់ទាន់មានមុខរបរច្បាស់លាស់នៅក្នុងស្រុក មានបំណុលជាប់ខ្លួន ជំពាក់ធនាគារជាដើម។ រីឯកត្តាទាក់ទាញ ដោយសារមេខ្យល់បានបញ្ចុះបញ្ចូល និងសន្យាជាមួយពលករថាបានការងារធ្វើនៅថៃ អីចឹងពលករចេះតែចាញ់បោកទៅ»។ លោក តុលា សង្កេតឃើញថា បច្ចុប្បន្ន រដ្ឋាភិបាលក៏បានខិតខំប្រឹងប្រែងធ្វើកំណែទម្រង់វិស័យកសិកម្ម ដែលជាផ្នែកមួយក្នុងការកាត់បន្ថយការធ្វើចំណាកស្រុកដែរ។ លោកបញ្ជាក់ថា៖«ខ្ញុំឃើញថា រដ្ឋាភិបាលគាត់ថា វិស័យកសិកម្ម មានសក្តានុពល ត្រូវតែអភិវឌ្ឍន៍ឡើងវិញដើម្បីទាក់ទាញកម្លាំងពលកម្ម។ ប៉ុន្តែល្បឿនក្នុងការកសាង ជួសជុល ធ្វើឱ្យប្រសើរឡើង ផ្នែកហេដ្ឋារចនាសម្ព័ន្ធវិស័យកសិកម្មនៅយឺតនៅឡើយ។ មួយវិញទៀត ការកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យកសិកម្មអត់ទាន់ឆ្លើយតបទេ ដោយសាររដ្ឋាភិបាលផ្តោតធ្ងន់ ទៅលើក្រុមហ៊ុនជាជាងកសិករលក្ខណៈគ្រួសារ»៕

# ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១

## អាជ្ញាធរថៃចាប់ខ្លួនពលករខ្មែរជិត២០នាក់ឆ្លងដែនទៅធ្វើការនៅប្រទេសថៃខុសច្បាប់

https://www.rfa.org/ ដោយ ជាតិ ចំណាន 2021-10-25

អាជ្ញាធរថៃចាប់ខ្លួនពលករខ្មែរជិត ២០ នាក់ក្នុងពេលដែលពួកគេលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់។ មន្ត្រីសង្គមស៊ីវិល សង្កេតឃើញថា ពលករឆ្លងដែនអំឡុងពេលនេះ ដោយសារពួកគេមានជីវភាពក្រីក្រ និងអត់ការងារធ្វើនៅក្នុងស្រុក។ ទាហានថៃបានចាប់ពលករខ្មែរចំនួន ១៧ នាក់ក្នុងពេលពួកគេធ្វើដំណើរនៅស្រុកតាផាក់យ៉ា (Taphaya) ខេត្តស្រះកែវ ជាប់ព្រំដែនស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នៅយប់ថ្ងៃទី២៣ ខែតុលា។ សារព័ត៌មានថៃចុះផ្សាយនៅថ្ងៃទី២៤ ខែតុលា ឱ្យដឹងថា ពលករទាំងនោះ ត្រូវបានមេខ្យល់ជនជាតិខ្មែរនាំទៅរកការងារធ្វើនៅខេត្តជាប់ទីក្រុងបាងកក(Bangkok)។

ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកការពារព្រំដែនលោក អ៊ុំ សុផល ប្រាប់វិទ្យុអាស៊ីសេរីថា អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរទាំង ១៧ នាក់នោះនិងមេខ្យល់ម្នាក់ប្រគល់ឱ្យអាជ្ញាធរកម្ពុជានៅព្រឹកថ្ងៃទី២៤ ខែតុលា។ លោកបញ្ជាក់ថា ក្រុមពលករត្រូវបានអាជ្ញាធរខ្មែរបញ្ជូនទៅធ្វើចត្តាឡីស័កនៅទីរួមខេត្តបន្ទាយមានជ័យភ្លាមៗក្រោយពេលអាជ្ញាធរបញ្ជូនមកដល់កម្ពុជា។ ចំពោះមេខ្យល់វិញលោកថា លោកបានបញ្ជូនទៅស្នងការដ្ឋាននគរបាលខេត្តដើម្បីចាត់ការតាមច្បាប់៖ «គេចាប់យប់មិញ ខ្ញុំសុំគាត់ឱ្យបញ្ជូនមកកម្ពុជា ដើម្បីយើងសួរនាំរកមេខ្យល់។ មេខ្យល់ចាប់បានហើយ តែសួរទៅជំនាញ ព្រោះខ្ញុំបានចាប់បញ្ជូនទៅជំនាញហើយ សួរលោកឧត្តមសេនីយ៍ស្នងការ។ គេបញ្ជូនមកដល់ខ្មែរអស់ហើយ ទាំងខាងម៉ាឡៃ១១នាក់ក៏បញ្ជូនមកអស់ហើយបញ្ជូនមកដល់មិញនេះ»។ មេប៉ូលិសផ្កាយមួយរូបនេះបន្តថា នៅថ្ងៃដដែលអាជ្ញាធរថៃបានចាប់បញ្ជូនពលករខ្មែរជាង ៤០ នាក់ត្រឡប់មកកម្ពុជាវិញតាមច្រករបៀងព្រំដែនក្នុងស្រុកម៉ាឡៃនិងស្រុកអូរជ្រៅខេត្តបន្ទាយមានជ័យ។ លោកថា ពលករភាគច្រើនត្រូវបានថៃចាប់ខ្លួននៅតំបន់ព្រំដែនជាប់កម្ពុជា ក្នុងពេលដែលពួកគេលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃខុសច្បាប់។ ចាប់តាំងពីចប់ពិធីបុណ្យភ្ជុំបិណ្ឌមកមានពលករខ្មែរជាច្រើននាក់បានឆ្លងដែនទៅប្រទេសថៃជាបន្តបន្ទាប់។

ក្នុងនោះយ៉ាងហោចណាស់មានពលករប្រមាណពី ១០ ទៅជាង ៥០ នាក់ ត្រូវបានអាជ្ញាធរខ្មែរចាប់ខ្លួនក្នុងពេលពួកគេបម្រុងឆ្លងដែនទៅប្រទេសថៃ។

ជុំវិញរឿងនេះ មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា សង្កេតឃើញថា មូលហេតុដែលប្រជាពលរដ្ឋឆ្លងដែង ដោយប្រថុយប្រថានអំឡុងពេលនេះ ដោយសារពួកគេមានជីវភាពក្រីក្រ និងគ្មានការងារធ្វើនៅក្នុងស្រុក។ លោកថា ពលករមិនគួរឆ្លងដែនទៅប្រទេសថៃអំឡុងពេលនេះទេ ពីព្រោះសកម្មភាពបែបនេះប្រឈមនឹងអាជ្ញាធរថៃចាប់ខ្លួន ឆ្លងជំងឺកូវីដ១៩ និងប្រឈមទាហានថៃបាញ់សម្លាប់ជាដើម៖ «ទៅតាមភូមិស្រុកនីមួយៗថា តើពួកគាត់ហ្នឹងមានការងារអីធ្វើឥឡូវហ្នឹង ហើយដំឡូងស្រូវភាគច្រើនលិចទឹកអស់។ អីចឹង ហើយមានតែបណ្តែតបណ្តោយខ្លួនទៅរកធ្វើជាកម្មករធ្វើជាពលករនៅប្រទេសថៃ ដើម្បីយកប្រាក់យកមក ដោះស្រាយជីវភាពផង សងធនាគារផង។ ព្រោះថា សព្វថ្ងៃហ្នឹងកូវីដៗហើយ ប៉ុន្តែធនាគារនៅតែដើរទារលុយធម្មតាហ្នឹង មិនមែនការរស់នៅសព្វថ្ងៃអ្នកជំពាក់លុយហ្នឹងធនាគារគេប្រាប់ថា អីចឹងឯងរកលុយអត់បានអីគេឈប់ទារឈប់អីអត់ទេនៅទាំងអស់»។

របាយការណ៍អង្គការសង់ត្រាល់ឲ្យដឹងថា ចាប់ពីខែមករា រហូតដល់ខែកក្កដា ឆ្នាំ២០២១ មានពលរដ្ឋខ្មែរជាង៧រយនាក់ (៧៤១) ត្រូវបានឃាត់ខ្លួន ពាក់ព័ន្ធនឹងការលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ ក្នុងនោះមនុស្សជិត៤រយនាក់ (៣៦០) ត្រូវបានអាជ្ញាធរកម្ពុជានិងថៃចាប់ខ្លួន និងបញ្ជូនទៅចាត់ការតាមច្បាប់។ របាយការណ៍ដដែលរកឃើញថា មានពលរដ្ឋខ្មែររាប់ពាន់នាក់បានចាញ់បោកមេខ្យល់នាំឆ្លងដែនទៅធ្វើការនៅប្រទេសថៃ អំឡុងពេលមានការរាតត្បាតជំងឺខ្លាំង។

មន្ត្រីសង្គមស៊ីវិលលោក ស៊ុំ ច័ន្ទគា យល់ថា ដើម្បីដោះស្រាយបញ្ហានេះរដ្ឋាភិបាលគួរតែបង្កើតការងារក្នុងស្រុកឱ្យបានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋធ្វើរកប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារ។ បន្ថែមពីនេះរដ្ឋាភិបាលត្រូវជួយរកទីផ្សារលក់កសិផលក្នុងតម្លៃសមរម្យជូនដល់កសិករ។ លោកជឿជាក់ថា ប្រសិនបើរដ្ឋាភិបាលនៅតែមិនដោះស្រាយបញ្ហានេះទេ នោះប្រជាពលរដ្ឋនឹងធ្វើចំណាកស្រុកកាន់តែច្រើន៕

## បញ្ជូនមេខ្យល់នាំមនុស្សឆ្លងដែនខុសច្បាប់៤នាក់ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ

http://nokorwatnews.com/ 26/1062021

ខេត្តបន្ទាយមានជ័យ ៖ នៅព្រឹកថ្ងៃទី២៥ខែ តុលានេះ កម្លាំងនគរបាលស្រុកស្វាយចេក បានបញ្ជូនជនសង្ស័យប្រុសស្រីជាមេខ្យល់ចំនួន០៤នាក់ ទៅសាលាដំបីងខេត្តបន្ទាយមានជ័យ ពាក់ព័ន្ធក្នុងករណីនាំមនុស្សឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ។ សមត្ថកិច្ចបានឲ្យដឹងថា ជនសង្ស័យទាំង៤នាក់ ត្រូវឃាត់ខ្លួននៅចំណុច០៣ គោលគោលដៅផ្សេងគ្នាជាច់ដោយឡែក ស្ថិតនៅក្នុងភូមិសាស្ត្រក្រុងប៉ោយប៉ែត និងស្រុកស្វាយចេក កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ ដោយមានមានការសម្របសម្រួលពីលោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា ជនសង្ស័យទាំង០៤នាក់ ខាងលើ មាន ១/- ឈ្មោះ សួន ម៉ាង ភេទប្រុស អាយុ៣៩ឆ្នាំ រស់នៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយ ចេក ខេត្តបន្ទាយមានជ័យ (ឃាត់ខ្លួននៅនឹងផ្ទះ) ស្ថិតក្នុងភូមិសាស្ត្រឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ, ២/- ឈ្មោះ ចំរើន ភារៈ ភេទប្រុស អាយុ៤១ឆ្នាំ រស់នៅភូមិសុខសាន្ត សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត, ៣/- ឈ្មោះ ចាន់ រស្មី ភេទស្រី អាយុ៣៩ឆ្នាំ នៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត (ទាំង០២នាក់នេះ ឃាត់ខ្លួននៅភោជនីយដ្ឋាន «ស្រស់ស្រាយ» ក្រុងប៉ោយប៉ែត ខេត្តបន្ទាយ

មានជ័យ), ៤/- ឈ្មោះ ប្រម វិន័យ ភេទស្រី អាយុ២៦ឆ្នាំ រស់នៅភូមិតៃ្បង ឃុំបុស្សរូ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ (ឃាត់ខ្លួនបាននៅខាងជើងភូមិតេជោភ្នំធំត្រ) ស្ថិតក្នុងភូមិសាស្ត្រឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។

ជនសង្ស័យទាំង០៤នាក់ខាងលើនេះ គឺជាមុខសញ្ញា យ៉ាងសកម្មក្នុងការនាំមនុស្សឆ្លងដែនដោយខុសច្បាប់ ដែលកម្លាំងនគរបាលរបស់លោកស្រីតាមប្រមាញ់ជាយូរមកហើយ។ នៅចំពោះមុខសមត្ថកិច្ចជនសង្ស័យបានសារភាពថា ពួកគេរកស៊ីទាក់ទងគ្នាក្នុងការនាំមនុស្សទៅប្រទេសថៃដោយយកថ្លៃចាប់ពី២០០បាតទៅ៣០០បាត ឬទៅដល់៥០០បាត ក្នុងពលករម្នាក់។ លុះមកដល់ព្រំដែន ពួកគេនាំឆ្លងដែនទៅថៃ គឺចាប់ពី៥,០០០បាតទៅដល់៦,០០០បាត ឬរហូតទៅដល់៧,០០០បាតទៀត ៕

## ស្ត្រីជនជាតិចិន៣នាក់ត្រូវបានតំណាងអយ្យការចោទប្រកាន់ហើយ ពីបទនាំយកទារកឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 26/1062021

ភ្នំពេញ ៖ លោក ប្លង់ សុផល ព្រះរាជអាជ្ញារង និង ជាអ្នកនាំពាក្យអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នារសៀលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ បានបញ្ជាក់ឲ្យដឹងថា ស្ត្រីជនជាតិចិន៣នាក់ដែលនាំទារកឆ្លងដែនខុសច្បាប់ ហើយត្រូវបានកម្លាំងសមត្ថកិច្ចឃាត់ខ្លួន និងបញ្ជូនមកសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ នាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

គួររំលឹកថា ស្ត្រីជនជាតិចិន៣ នាក់កាលពីរសៀលថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ នេះ ត្រូវបានកម្លាំងសមត្ថកិច្ចនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នឹងការពារអនីតិជន ចាប់បញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ពាក់ព័ន្ធករណីនាំទារកឆ្លងដែនខុសច្បាប់ ។ជនសង្ស័យជាជនជាតិចិន៣ នាក់នោះមាន១.ឈ្មោះ LI BINGRONG ភេទស្រី អាយុ៣៩ ឆ្នាំ ២.ឈ្មោះ WEI QIUCHAN ភេទស្រី អាយុ៥២ ឆ្នាំ និង៣.ឈ្មោះ ZHANG QIAN ភេទស្រី អាយុ២៥ ឆ្នាំ ។ ទាក់ទិននឹងការចាប់ខ្លួនស្ត្រីជនជាតិចិន៣ នាក់បញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញនោះ ប្រភពព័ត៌មានឲ្យដឹងថា កាលពីព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ កម្លាំងសមត្ថកិច្ចនគរបាលប្រចាំច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដោយមានការសង្ស័យ បានធ្វើការឃាត់ខ្លួនស្ត្រីចិន៣ នាក់ ដូចមានឈ្មោះខាងលើ ក្នុងករណីកំពុងប្រព្រឹត្តបទល្មើសដាក់ស្លែង បីទារកអាយុមិនលើសពី១ឆ្នាំ ម្នាក់មួយៗ បម្រុងជិះយន្តហោះឆ្លងដែនទៅកាន់ប្រទេសចិន ។

ក្រោយឃាត់ខ្លួនស្ត្រីចិន៣ នាក់នោះ សមត្ថកិច្ចនគរបាលច្រកទ្វារព្រលានយន្តហោះអន្តរជាតិភ្នំពេញ បានសហការ នឹងប្រគល់ជនសង្ស័យ៣ នាក់ នឹងទារកទាំង៣ ឲ្យទៅសមត្ថកិច្ចជំនាញ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នឹងការពារអនីតិជន ដើម្បីបន្តនីតិវិធី ។ ដូច្នោះហើយទើបជនសង្ស័យត្រូវបានសមត្ថកិច្ចការិយាល័យប្រឆាំងការជួញដូរមនុស្សឆ្លងដែន កសាងសំណុំរឿងបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ។ ចំណែកទារកមានភេទប្រុស.ភេទស្រី អាយុមិនលើសពី១ឆ្នាំ ត្រូវបានសមត្ថកិច្ចនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នឹងការពារអនីតិជន បានប្រគល់ឲ្យទៅក្រសួងសង្គមកិច្ច យកទៅចិញ្ចឹមបីបាច់ថែទាំជាបណ្ដោះអាសន្ន ។ បច្ចុប្បន្នជនត្រូវចោទទាំង៣នាក់កំពុងបញ្ជូនសុំណុំរឿងឡើងទៅកាន់ថៅក្រមស៊ើបសួរបន្ត៕

## ពលរដ្ឋខ្មែរ៣៨នាក់ ស្រី៩នាក់ លួចឆ្លងដែនចូលទៅថៃខុសច្បាប់ត្រូវបានសមត្ថកិច្ចថៃឃាត់ខ្លួន បញ្ជូនទៅប៉ុស្តិ៍នគរបាលចាត់ការបន្តតាមច្បាប់

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២៦ តុលា ២០២១ដោយ Kang Tola

បន្ទាយមានជ័យ ៖ តាមឲ្យដឹងពីសមត្ថកិច្ចខ្មែរ ដែលឈរជើងនៅតាមព្រំដែន កម្ពុជា .ថៃ បានប្រាប់អ្នកយកព័ត៌មានឲ្យដឹងថា តាមការឲ្យដឹងពីអាជ្ញាធរមានសមត្ថកិច្ចថៃ បានចាប់ឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរដែលលួចឆ្លងដែលខុសច្បាប់ចូលប្រទេសថៃតាមច្រកធម្មជាតិ ចំនួន ៣៨នាក់ ប្រុស២៩ ស្រី៩ នៅឃុំតាប្រាយ៉ា ស្រុកតាប្រាយ៉ា ខេត្តសាកែវ កាលពីយប់ ថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០២១។ ពលករទាំង៣៨នាក់ នេះក្រោយពីអាជ្ញាធរមានសមត្ថកិច្ចថៃបានចាប់ឃាត់ខ្លួនសួរនាំបាននិយាយថា ក្រុមខ្លួនបាញ់បោកមេខ្យល់ថានាំពួកខ្លួនយកទៅប្រទេសថៃរកការងារធ្វើល្អនៅខេត្តសាកែវ ក្នុង១នាក់ត្រូវបង់ថ្លៃឈ្នួលជូន១.០០០បាត ក្រោយមកយកទៅប្លុងចោលនៅកន្លែងតំបន់តាប្រាយ៉ាត្រូវសមត្ថកិច្ចដាំចាប់ខ្លួនតែម្តង។ ពលករទាំង៣៨នាក់ ក្រោយពេលឃាត់ខ្លួនកម្លាំងយោធាបានឲ្យក្រុមគ្រូពេទ្យជំនាញពិនិត្យសុខភាពពួកគេទាំងអស់គ្នាជាមុន ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ប្រទេសគេ។ ពលករទាំងអស់ក្រោយពីក្រុមគ្រូពេទ្យពិនិត្យហើយត្រូវបានសមត្ថកិច្ចថៃឃាត់ខ្លួន បញ្ជូនទៅប៉ុស្តិ៍នគរបាលចាត់ការបន្តតាមច្បាប់។

សមត្ថកិច្ចខ្មែរបាននិយាយថា ពលករខ្មែរទាំង៣៨នាក់ ត្រូវសមត្ថកិច្ចថៃចាប់នោះតើមកពីល្បិចមេខ្យល់ខ្លស់រឺយ៉ាងណារឺពលករខ្មែរទាំង៣៨នាក់ លួង់ទើបឲ្យមេខ្យល់ប្រើល្បិចបោកបានថាយកទៅរកការងារកន្លែងល្អៗធ្វើនៅស្រុកថៃទាំងប្រទេសគេបិទតាមព្រំដែនសូម្បីតែសត្វចូលមិនបានផងនោះដោយសារជំងឺកូវីដ១៩រីករាលដាលខ្លាំង។ សមត្ថកិច្ចបានបញ្ជាក់ឲ្យដឹងបន្តថា ក្នុងប្រទេសថៃរោងចក្រ កន្លែងផ្សេងៗទៀតក៏ត្រូវបិត ពលករខ្មែរខ្លះបង្ខំចិត្តចាកចេញពីស្រុក ថៃមកស្រុកកំណើតវិញអ្វីៗមិនទាន់ដំណើរការនៅឡើយដូច្នេះពលករខ្មែរទាំងអស់ចង់ទៅធ្វើការនៅថៃប្រយ័ត្នបាញ់បោកមេខ្យល់។ សព្វថ្ងៃនេះ សមត្ថកិច្ចថៃធ្វើការទប់ស្កាត់ពលករខ្មែរដែលលបលួចចូលឆ្លងដែនទៅ ធ្វើការក្នុងប្រទេសថៃខុសច្បាប់ខ្លាំងសំបើមណាស់ដើម្បីការពារទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩នេះ៕ *ភ័ន្ត ណាង*

## សមត្ថកិច្ចថៃចាប់បានពលករខ្មែរជាបន្តបន្ទាប់នៅតាមបន្ទាត់ព្រំដែន

https://go.kspg.co/ បន្ទាយមានជ័យ២៧ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ០៨:៥៣

ខេត្តបន្ទាយមានជ័យ ៖ សមត្ថកិច្ចថៃបានចាប់ពលករខ្មែររយៈពេល២ថ្ងៃ គឺមានចំនួន៥៨នាក់ ដែលតួលេខនេះ គិតត្រឹមនៅថ្ងៃទី២៥ ដល់២៦ ខែតុលា ឆ្នាំ២០២១ ស្ថិតនៅចំណុចក្នុងភូមិសាស្រ្ត ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ (តាមបន្ទាត់ព្រំដែន) ។

តាមមន្រ្តីយោធាទំនាក់ទនងព្រំដែនកម្ពុជា.ថៃ នៅច្រកតំបន់ព្រំដែនបឹងត្រកួន បានប្រាប់ឱ្យដឹងនៅថ្ងៃទី២៦ តុលា ថា លោកទទួលព័ត៌មានពីភាគថៃថា បានចាប់ពលករខ្មែរចំនួន៣៨នាក់ (ស្រីចំនួន៩នាក់) ដែលលួចឆ្លងទៅរកការងារធ្វើនៅប្រទេសថៃ ដោយខុសច្បាប់ ស្ថិតនៅតាមបន្ទាត់ព្រំដែនក្នុងភូមិ.ឃុំតាប្រាយ៉ា ស្រុកតាមប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ ។ ហើយនៅថ្ងៃទី២៦ តុលា ឆ្នាំ២០២១ កម្លាំងមានសមត្ថកិច្ចថៃក៏បានឃាត់ពលករខ្មែរចំនួន២០នាក់ (ស្រី៧នាក់) ទៀត បានលួចឆ្លងដែនចូលទៅដីថៃ ដើម្បីទៅរកការងារធ្វើដោយខុសច្បាប់ដូចគ្នា ។ មន្រ្តីយោធាទំនាក់ទំនងព្រំដែនកម្ពុជា.ថៃបានបញ្ជាក់ទៀតថា ក្រោយពេលអាជ្ញាធរថៃឃាត់ពលករខ្មែររយៈពេល២ថ្ងៃជាប់គ្នា សរុបមានចំនួន៥៨នាក់ (ស្រី១៦នាក់) ត្រូវលួចឆ្លងដែនតាមរយៈមេខ្យល់កម្ពុជា នាំឆ្លងដែនចូលក្នុងទឹកដីថៃ ។ ហើយមានមេខ្យល់ថៃមកចាំទទួលក្នុងទឹកដីថៃ ដែលជូនទៅរកការងារធ្វើដល់ក្រុងបាងកក ដោយយកប្រាក់

ក្នុងម្នាក់ចំនួន៦.០០០បាត តែពេលដែនជូនឆ្លងចូលទឹកដីថៃ ។ បច្ចុប្បន្ន ក្រោយពេលភាគីថៃឃាត់ពលករខ្មែរលួចឆ្លងដែនចូលក្នុងទឹកដីថៃ ត្រូវបានបញ្ជូនមកតាមច្រកអូរបីជាន់ស្រុកអូរជ្រៅ។

# ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១

## តុលាការឧទ្ធរណ៍ ជម្រះបណ្តឹងឧទ្ធរណ៍ស្ត្រីជាប់ចោទ២នាក់ ពាក់ព័ន្ធបទល្មើស នាំចេញមិនស្របច្បាប់ !!

https://cen.com.kh/ Posted ByPen Srey NeatOctober 28, 2021

ភ្នំពេញ ៖ តុលាការឧទ្ធរណ៍ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០២១ បានបើកសវនាការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ស្ត្រីជាប់ចោទ ២ នាក់ ដែលត្រូវបានតុលាការដំបូងខេត្តកំពង់ឆ្នាំង កាត់ទោសដាក់ពន្ធនាគារ កំណត់ ក្នុងម្នាក់ៗ កំណត់ ២ ឆ្នាំ ៦ ខែ ជាប់ពាក់ព័ន្ធនឹងការ នាំចេញមិនស្របច្បាប់ ប្រព្រឹត្តនៅក្នុង ខេត្តកំពង់ឆ្នាំង កាលពីអំឡុងឆ្នាំ ២០១៩ ។

លោក ងួន រតនា ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍រាជធានី ភ្នំពេញ បានថ្លែងឲ្យដឹងថា នៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌនេះ មានជនជាប់ចោទចំនួន ២នាក់ មានឈ្មោះ ទី១ ឈ្មោះ ប៊ុត ចាន់ដារី ភេទស្រី អាយុ ៤២ ឆ្នាំ រស់នៅស្រុក សាមគ្គីមានជ័យ ខេត្ត កំពង់ឆ្នាំង ។និង ទី២ ឈ្មោះ មុំ សេម ភេទ ស្រី អាយុ ៤០ ឆ្នាំ រស់នៅស្រុក សាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ ចំណែកឯ ជនរងគ្រោះ មានឈ្មោះ លង ស្រាល ភេទ ស្រី អាយុ ១៦ ឆ្នាំ រស់នៅ ស្រុក សាមគ្គីមានជ័យ ខេត្ត កំពង់ឆ្នាំង ។ (ត្រូវជាក្មួយស្រីរបស់ជនជាប់ចោទ) លោកចៅក្រមបានបញ្ជាក់ថា នៅក្នុងសំណុំរឿងក្តីនេះ ជនជាប់ចោទទាំង២នាក់ ត្រូវបាន សាលាខេត្តដំបូងខេត្តកំពង់ឆ្នាំង កាលថ្ងៃ ទី ៣០ ខែ មិថុនា ឆ្នាំ ២០២០ កាត់ទោស ដាក់ពន្ធនាគារ ក្នុងម្នាក់ៗ កំណត់ ២ ឆ្នាំ ៦ ខែ ពីបទ: នាំចេញមិនស្របច្បាប់។ តែឈ្មោះ ជនជាប់ចោទ ទាំង២នាក់ បានប្តឹងជំទាស់នឹងសាលក្រមរបស់សាលាដំបូងខេត្តកំពង់ឆ្នាំង មកកាន់សាលាឧទ្ធរណ៍។ ពួកគេត្រូវបានកម្លាំងអាវុធហត្ថ ខេត្ត កំពង់ឆ្នាំង ឃាត់ខ្លួន កាលពីថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៩ នៅស្រុក សាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។

នាពេលសវនាការ, ស្ត្រីជនជាប់ចោទ ២ នាក់ខាងលើ បានឆ្លើយបដិសេធចំពោះការចោទប្រកាន់ ពួកគេខាងលើ និង និយាយថា ពួកគេ មិនបានដឹង ឬ បានប្រព្រឹត្តអ្វី ដូចការចោទប្រកាន់ និង ផ្តន្ទាទោស អំពើសំណាក់តុលាការខេត្តកំពង់ឆ្នាំងនោះទេ។ ពួកគេ បានសំណូមពរដល់ក្រុមប្រឹក្សាចៅក្រមជំនុំជម្រះ សូមធ្វើការ បដិសេធសាលក្រមរបស់តុលាការ ខេត្តកំពង់ឆ្នាំង ទុកជាអាសារបង់ និង សម្រេចដោះលែងពួកគេអោយមានសេរីភាពវិញ។ សំណុំរឿងក្តីនេះ, សាលាឧទ្ធរណ៍ ភ្នំពេញនឹងប្រកាសសាលដីកា នៅព្រឹកថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ ២០២១៕រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## សេចក្តីជូនដំណឹង ស្តីពីការជ្រើសរើស ភ្នាក់ងារជ្រើសរើស ពលករចំណាកស្រុក

https://m.phnompenhpost.com/ 27/10/2021

ក្រុមហ៊ុន Charoen Pokphand Group បានប្រកាសអញ្ជើញភ្នាក់ងារជ្រើសរើសពលករ ដែលមានអាជ្ញាប័ណ្ណ និងបានចុះបញ្ជីមកពីព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសហភាពមីយ៉ានម៉ា ដើម្បីធ្វើការប្រកួតប្រជែងដោយបើកចំហក្នុងដំណើរការដេញថ្លៃប្រកបដោយតម្លាភាព និងយុត្តិធម៌ ដើម្បីផ្តល់សិទ្ធជូនក្រុមហ៊ុនដែលជាបុត្រសម្ពន្ធ័របស់ប្រទេសថៃ រួមជាមួយសេវាកម្មជ្រើសរើសពលករប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌តាមសេចក្តីប្រកាស លេខ No. 093/2020 ដែលទាក់ទងទៅនឹងគោលនយោបាយក្នុងការជ្រើសរើសពលករ និង សេចក្តីណែនាំរបស់ក្រុមហ៊ុន Charoen Pokphand Group ។ ក្រុមហ៊ុន CP Group តម្រូវឱ្យភ្នាក់ងារជ្រើសរើសពលករដែលចាប់អារម្មណ៍ទាំងអស់ ដែលទទួលបានអាជ្ញាប័ណ្ណនៅក្នុងប្រទេសទាំងពីរនេះដាក់ពាក្យស្នើសុំចូលទៅក្នុងដំណើរការដេញថ្លៃដោយបើកចំហ ដើម្បីធានាបាននូវតម្លាភាព និង យុត្តិធម៌នៅគ្រប់ដំណាក់កាលនៃដំណើរការជ្រើសរើសពលករ ។

ភ្នាក់ងារជ្រើសរើសពលករដែលមានចំណាប់អារម្មណ៍ត្រូវរក្សានូវការអនុវត្តឱ្យបានខ្ជាប់ខ្ជួន ដើម្បីការពារការកេងប្រវ័ញ្ច និង បង្ខិតបង្ខំកំលាំងពលកម្មដែលកើតឡើងក្នុងអំឡុងពេលដំណើរការជ្រើសរើសពលករ និងត្រូវគោរពតាមក្រមសីលធម៌អាជីវកម្មរបស់ក្រុមហ៊ុន CP Group គ្រប់ពេល ប្រសិនបើពួកគេត្រូវធ្វើការជាមួយក្រុមហ៊ុនក្នុងការផ្តល់សេវាកម្មជ្រើសរើសពលករ ។ * មានតែទីភ្នាក់ងារជ្រើសរើសពលករដែលទទួលបានអាជ្ញាប័ណ្ណនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ាប៉ុណ្ណោះ ដែលមានសិទ្ធិចុះឈ្មោះចូលរួមក្នុងវគ្គណែនាំតាមប្រព័ន្ធអ៊ីនធឺណិតនេះបាន ។ ** មានតែភ្នាក់ងារជ្រើសរើសពលករដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលចូលរួមក្នុងវគ្គណែនាំព័ត៌មានតាមអ៊ីនធឺណិតប៉ុណ្ណោះ ដែលមានសិទ្ធិចូលរួមប្រកួតប្រជែងក្នុងដំណើរការដេញថ្លៃបើកចំហនេះបាន៕

## កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី ការជ្រើសរើស ពលករប្រកបដោយយុត្តិធម៌និងក្រមសីលធម៌ រវាងច្រក ទេសន្តរប្រវេសន៍ការងារពីប្រទេសកម្ពុជាទៅប្រទេសថៃ

https://gdlf-kh.com/ Kim Sopha ភ្នំពេញ 28/10/2021

ភ្នំពេញ ៖ នាព្រឹកថ្ងៃព្រហស្បតិ៍ ៧រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ គណៈកម្មធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការគ្នាជាមួយអង្គការ IOM រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការជ្រើសរើសពលករប្រកបដោយយុត្តិធម៌និងក្រមសីលធម៌ រវាងច្រកទេសន្តរប្រវេសន៍ការងារពីប្រទេសកម្ពុជាទៅប្រទេសថៃ តាមប្រព័ន្ធអនឡាញ (ហ្សូម) ។ សមាសភាពបានចូលរួមនៅក្នុងសិក្ខាសាលានេះ មាន ឯកឧត្តម ហ៊ូ វុឌ្ឍី អនុរដ្ឋលេខាធិការក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងក្រសួងការបរទេស និងទំនាក់ទំនងអន្តរជាតិ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង លោកប្រធានលេខាធិការដ្ឋាន ប្រធាន អនុប្រធាននៃក្រុមការងារជំនាញទាំង៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងពីទីភ្នាក់ងារជាតិការងារ និងមុខរបរ របស់ក្រសួងការងារ តំណាងពីអង្គការដៃគូរអភិវឌ្ឍ អន្តរជាតិធ្វើការងារពាក់ព័ន្ធទេសន្តរប្រវេសន៍ តំណាងពីអង្គការសហប្រជាជាតិយូអិន UN តំណាងពីអង្គការពាក់ព័ន្ធនានាមួយចំនួនទៀតមាន អង្គការ (ILO) អង្គការវីនរ៉ក់អន្តរជាតិប្រចាំកម្ពុជា (Winrock ) អង្គការយុត្តិធម៌អន្តរជាតិ (IJM) អង្គការការពារផ្នែកច្បាប់ ស្ត្រី និងកុមារ

(LSCW) តំណាងពីសមាគមស្ត្រីមានវិបត្តិ (CWCC) តំណាងពីសម្ព័ន្ធចាប់ដៃ មជ្ឈមណ្ឌលការងារ និងមុខរបរ (Central) អង្គការសាម៉ារីតាន់ភើស (Samaritan's Purse) អង្គការរតនៈ (Rattanak) តំណាងពីសម្ព័ន្ធអ្នកវិនិយោគិន (NACC) សរុបប្រមាណ៥០រូប ។

ការពិគ្រោះយោបល់ថ្នាក់ជាតិនេះ ជាវេទិកាមួយសម្រាប់ តំណាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និយោជក អ្នកជ្រើសរើសការងារ និងសមាគមនរបស់ខ្លួន សង្គមស៊ីវិល និងអង្គការពាក់ព័ន្ធការងារពលករ និងកម្មករ ដើម្បីចូលរួមកិច្ចសន្ទនាស្តីពីការជំរុញការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងការប្តេជ្ញាចិត្តរបស់វិស័យឯកជន ទាក់ទងនឹងការជ្រើសរើស ពលករចំណាកស្រុកកម្ពុជា។ កម្មវិធីធ្វើឡើងនេះធ្វើឡើង ក្នុងគោលបំណង ៖

១. បង្កើនប្រសិទ្ធភាព ការវិភាគលើឯកសារគោល នយោបាយ របស់អង្គការ IOM លើការវិភាគ ប្រៀបធៀបនៃក្រប ខណ្ឌច្បាប់ជាតិ និងស្តង់ដារអន្តរជាតិនៅកម្ពុជាទៅកាន់ ច្រករបៀងចំណាកស្រុកប្រទេសថៃ។

២. ពិភាក្សាអំពីអនុសាសន៍ដើម្បីលើកកម្ពស់ ការជ្រើសរើស បុគ្គលិកដោយយុត្តិធម៌ និងសីលធម៌សម្រាប់ច្រករបៀង ចំណាកស្រុកពលករកម្ពុជាទៅប្រទេសថៃ។

៣. លើកសំណើរជាក់ស្តែង ដើម្បីលើកកម្ពស់ការជ្រើសរើសដោយយុត្តិធម៌ និងសីលធម៌សម្រាប់ច្រករបៀងចំណាកស្រុកពលករកម្ពុជាទៅប្រទេសថៃ។

៤.រៀបចំភាគីពាក់ព័ន្ធរបស់កម្ពុជា ដើម្បីចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីនាពេលខាងមុខ រវាងកម្ពុជា និងថៃ ស្តីពីការជំរុញកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីលើកកម្ពស់ការជ្រើសរើសបុគ្គលិកប្រកបដោយយុត្តិធម៌ និងសីលធម៌។

## លោកនាយករដ្ឋមន្ត្រី ស្នើអូស្ត្រាលីជួយបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដល់ស្ត្រី និងពលករចំណាកស្រុក

https://www.postkhmer.com/ រី សុចាន់ | Publication date 29 October 2021 | 09:17 ICT

**ភ្នំពេញៈ** លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើអូស្ត្រាលីជួយបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដល់ស្ត្រី និងពលករចំណាកស្រុក ដើម្បីមានសមត្ថភាពស្វែងរកការងារថ្មី និងជីវភាពល្អប្រសើរ ខណៈអូស្ត្រាលីប្រកាសផ្តល់ទឹកប្រាក់ចំនួន ១១៥ លានដុល្លារអាមេរិក សម្រាប់កិច្ចសហប្រតិបត្តិការជាមួយអាស៊ាន។ លោក ហ៊ុន សែន បានស្នើបែបនេះក្នុងកិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលី លើកទី១ កាលពីថ្ងៃទី ២៧ តុលា ឆ្នាំ ២០២១ តាមប្រព័ន្ធវីដេអូ។ លោកបញ្ជាក់ថា៖ «កម្ពុជាស្នើអូស្ត្រាលីបន្តជួយពង្រឹងវិស័យអាទិភាពមួយចំនួន ដូចជាវិស័យបច្ចេកវិទ្យាឌីជីថល ពាណិជ្ជកម្ម អេឡិចត្រូនិក សហគ្រាសធុនតូច និងមធ្យម វិស័យអប់រំ និងអភិវឌ្ឍន៍ធនធានមនុស្ស ជាពិសេសការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់ស្ត្រី និងពលករចំណាកស្រុក ដែលវិលត្រឡប់ពីក្រៅប្រទេស ដើម្បីឱ្យមានសមត្ថភាពស្វែងរកការងារថ្មី និងជីវភាពល្អប្រសើរ»។ លោកអំពាវនាវឱ្យមានការយកចិត្តទុកដាក់ និងពង្រឹងបន្ថែម ចំពោះកិច្ចសហប្រតិបត្តិការលើរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ព្រោះវាជាជំហានដ៏ប្រសើរមួយក្នុងការទទួលស្គាល់តួនាទីរបស់ស្ត្រីនៅក្នុងការជំរុញសុខុមាលភាពសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

លោកនាយករដ្ឋមន្ត្រីថ្លែងថា៖ «ក្នុងនាមជាប្រធានអាស៊ានឆ្នាំ ២០២២ កម្ពុជានឹងបន្តជំរុញនូវរបៀបវារៈនេះ និងស្នើសុំនូវកិច្ចសហប្រតិបត្តិការ និងការជួយគាំទ្រពីអូស្ត្រាលី»។ លោកលើកឡើងថា ការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលីប្រចាំឆ្នាំគឺជាសក្ខីភាពមួយដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរួមការសម្រេចបាននូវសមិទ្ធផលដ៏ធំធេងដែលអាចចាត់ទុកថាជាការបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយក្នុងទំនាក់ទំនងនៃដៃគូយុទ្ធសាស្ត្ររវាងភាគីទាំង២។ លោកថ្លែងថា ជាមួយនឹងទំនាក់ទំនង «ដ៏ល្អ» នេះកម្ពុជាគាំទ្រការលើកកម្ពស់ទំនាក់ទំនងអាស៊ាន-អូស្ត្រាលីឱ្យក្លាយទៅជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។ ទន្ទឹមនេះដែរ កម្ពុជាកោតសរសើរចំពោះគំនិតផ្តួចផ្តើមអូស្ត្រាលី

សម្រាប់អនាគតអាស៊ាន ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងសសរស្តម្ភទាំង ៣ របស់អាស៊ាន។ លោកនាយករដ្ឋមន្ត្រី ក៏បានកោតសរសើរចំពោះការចូលរួមចំណែក «ដ៏សកម្ម»របស់អូស្ត្រាលីក្នុងយុទ្ធនាការពហុភាគី ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ ១៩ និងការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចក្នុងតំបន់ជាពិសេសការដាក់ចេញនូវភាពជាដៃគូ សម្រាប់យុទ្ធសាស្ត្រនៃការស្តារឡើងវិញ និងកំណត់យកអាស៊ានជាដៃគូដ៏សំខាន់។ លោកបន្តថា ក្នុងបរិបទនៃការរស់នៅជាមួយកូវីដ ១៩ ការកសាងសហគមន៍អាស៊ានប្រកបដោយចីរភាព វិបុលភាព និងបរិយាប័ន្ន ពិតជាមានសារៈសំខាន់។ កម្ពុជាលើកទឹកចិត្តឱ្យអូស្ត្រាលីបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់អាស៊ានក្នុងសកម្មភាពជំរុញសមាហរណកម្មតំបន់ដូចជាផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ ២០២៥ និងផែនការសកម្មភាពនៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ានដំណាក់កាលទី ៤។ លោក ហ៊ុន សែន ស្នើឱ្យភាគីទាំង ២ អនុវត្តផែនការសកម្មភាពអាស៊ាន-អូស្ត្រាលីឆ្នាំ ២០២០-២០២៤ ឱ្យបានជោគជ័យ និងបន្តដោះស្រាយបញ្ហាប្រឈមដូចជាបញ្ហាសុខភាពសាធារណៈ ការជំរុញកំណើនសេដ្ឋកិច្ច និងការប្រែប្រួលអាកាសធាតុជាដើម។

នៅក្នុងកិច្ចប្រជុំនេះលោក ស្កុត ម៉ូរីសុន (Scott Morrison) នាយករដ្ឋមន្ត្រីអូស្ត្រាលីបានប្រកាសផ្តល់ទឹកប្រាក់ចំនួន ១៥៤ លានដុល្លារអូស្ត្រាលី (១១៥ លានដុល្លារអាមេរិក) សម្រាប់កិច្ចសហប្រតិបត្តិការជាមួយអាស៊ាន។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់នាយករដ្ឋមន្ត្រីអូស្ត្រាលីកាលពីថ្ងៃទី ២៧ តុលា។ ក្នុងចំណោមទឹកប្រាក់ចំនួន ១៥៤ លានដុល្លារអូស្ត្រាលីនេះ ទឹកប្រាក់ចំនួន ១២៤ លានដុល្លារអូស្ត្រាលី (៩៣លានដុល្លារអាមេរិក) គឺសម្រាប់គំនិតផ្តួចផ្តើមអនាគតអាស៊ាន ដើម្បីគាំទ្រគម្រោងដែលដោះស្រាយបញ្ហាប្រឈមដ៏ស្មុគស្មាញរួមមានសន្តិសុខ សុខភាព អំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន សន្តិសុខថាមពលការលើកកម្ពស់សេដ្ឋកិច្ចវិលជុំ និងមហាសមុទ្រដែលមានសុខភាពល្អ និងគាំទ្រការអនុវត្តទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក។ ចំណែកចំនួនទឹកប្រាក់ផ្សេងទៀតនឹងផ្តោតលើការផ្តល់អាហារូបករណ៍សម្រាប់អាស៊ាន ដើម្បីគាំទ្រអ្នកដឹកនាំអាស៊ាន ដែលកំពុងរះឡើងទៅសិក្សានៅប្រទេសអូស្ត្រាលី និងមួយទៀត សម្រាប់គំនិតផ្តួចផ្តើមអភិវឌ្ឍឌីជីថល និងជំនាញវិជ្ជាជីវៈសម្រាប់អនាគតរបស់អាស៊ាន ដើម្បីគាំទ្រការស្តារសេដ្ឋកិច្ចឡើងវិញរយៈពេលវែង។

សេចក្តីប្រកាសព័ត៌មានបញ្ជាក់ថា៖ «លោកនាយករដ្ឋមន្ត្រី (Scott Morrison) ក៏មានសេចក្តីសោមនស្សរីករាយក្នុងការគូសបញ្ជាក់ផងដែរពីការប្តេជ្ញាចិត្តរបស់អូស្ត្រាលីក្នុងការផ្តល់វ៉ាក់សាំងជំងឺកូវីដ ១៩ យ៉ាងតិច ៦០ លានដូសដល់តំបន់ឥណ្ឌូប៉ាស៊ីហ្វិកនៅត្រឹមចុងឆ្នាំ ២០២២។ ចាប់ពីចុងឆ្នាំ ២០២១ ដល់ពាក់កណ្តាលឆ្នាំ ២០២២ យើងនឹងចែករំលែកវ៉ាក់សាំងយ៉ាងហោចណាស់ ១០ លានដូសពីការផ្គត់ផ្គង់ក្នុងស្រុករបស់យើងជាមួយបណ្តាប្រទេសអាស៊ាន»។ លោក Scott Morrison ថ្លែងថា ខណៈការចាក់វ៉ាក់សាំងជំងឺកូវីដនៅក្នុងប្រទេសអូស្ត្រាលីបន្តកើនឡើង អូស្ត្រាលីនឹងបើកការមកកាន់ប្រទេសនេះឡើងវិញ ទៅកាន់ពិភពលោកនៅថ្ងៃខាងមុខ ហើយអូស្ត្រាលីកំពុងធ្វើការជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីរៀបចំការធ្វើដំណើរប្រកបដោយសុវត្ថិភាពក្នុងបរិបទ កូវីដ ១៩ តាមបែបគន្លងថ្មី។ លោកថ្លែងថា៖ «ដូច្នេះសហគមន៍របស់យើងអាចជួបជុំគ្នាដោយផ្ទាល់ឡើងវិញបាន»៕

## បន្ទាត់ព្រំដែនជាប់ប្រទេសថៃ ចរន្តពលករចេញចូលចាប់មិនអស់

https://kohsantepheapdaily.com.kh/ ភ្នំពេញ២៩ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ១៦:៥៩

ខេត្តបន្ទាយមានជ័យ ៖ ក្រុមការងារទទួលពលករខ្មែរមកពីប្រទេសថៃបានឱ្យដឹងថា គ្រាន់តែរយៈពេល១ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ បានទទួលពលករខ្មែរជិត១០០នាក់ ដែលភាគច្រើនត្រូវអាជ្ញាធរថៃ ចាប់បញ្ជូនមកវិញតាមច្រកចំនួន២ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ។

វរសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ និងជាសមាជិកទទួលពលករខ្មែរនៅច្រកអូរបីជាន់ ថ្លែងថា នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១នោះ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ និងអាជ្ញាធរថៃចាប់បញ្ជូនមកវិញតាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ មានចំនួន៧០នាក់ ក្នុងនោះស្រី៣៥នាក់ និងកុមារ៦នាក់ ហើយតាមរយៈការធ្វើតេស្តរហ័ស បានរកឃើញអ្នកវិជ្ជមានកូវីដ-១៩ចំនួន៥នាក់(ស្រី៣នាក់) ។

លោក វ៉ាន់ ដារ៉ាន់ ប្រធានគណៈកម្មាធិការច្រកតំបន់ព្រំដែនបឹងត្រកួន ស្រុកថ្មពួក ថ្លែងថា នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១នោះដែរ ក្រុមការងារបានទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ តាមច្រកតំបន់បឹងត្រកួន មានចំនួន២១នាក់(ស្រី១៣នាក់) ។

ហេតុការណ៍ដាច់ដោយឡែកមួយទៀតបានឲ្យដឹងថា អនុវត្តតាមបទបញ្ជារបស់ឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្ត ក្នុងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ និងស្រាវជ្រាវមុខសញ្ញាមេខ្យល់នាំឆ្លងដែនទៅប្រទេសថៃខុសច្បាប់នោះ កាលពីវេលាម៉ោងប្រមាណ៩និង២០នាទីយប់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ កម្លាំងនគរបាលនគរបាលស្រុកថ្មពួកសហការជាមួយនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ បានឃាត់ខ្លួនពលករប្រុសស្រីចំនួន១៣នាក់ដែលបម្រុងលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ។ ជាមួយនេះ បានឃាត់ខ្លួនម្ចាស់គោយន្តកន្ត្រៃម្នាក់ ដែលដឹកពលករទាំងនោះនៅចំណុចខ្ទមចម្ការជំឡូងខាងជើងភូមិតាឡីចម្ងាយប្រមាណ១គីឡូម៉ែត្រ ក្នុងភូមិតាឡី ឃុំគោករមៀត ស្រុកថ្មពួក ។

វរសេនីយ៍ទោ ឈឿន គឹមឈុន អធិការនគរបាលស្រុកថ្មពួក បានឲ្យដឹងថា ពលករទាំង១៣នាក់នេះមានស្រី៣នាក់ មកពីខេត្តស្ទឹងត្រែង២នាក់ ខេត្តសៀមរាប២នាក់ ខេត្តកំពង់ស្ពឺ១នាក់ ខេត្តពោធិ៍សាត់២នាក់ ខេត្តព្រៃវែង១នាក់ និងខេត្តស្វាយរៀង៥នាក់ ។ ចំណែកម្ចាស់គោយន្តកន្ត្រៃឈ្មោះ នួន ស្រោច ភេទប្រុស អាយុ៣៨ឆ្នាំ រស់នៅភូមិព្រៃវែង ឃុំគំរូ ស្រុកថ្មពួក ។ លោកអធិការបញ្ជាក់ថា តាមការសួរនាំពលករទាំង១៣នាក់ប្រាប់ថា ពួកគាត់មានបំណងទៅរកការងារធ្វើនៅប្រទេសថៃ ដោយបានទាក់ទងជាមួយថៅកែថៃដើម្បីធ្វើការ ដោយថៅកែថៃជាអ្នករកមេខ្យល់ឲ្យគេយកថ្លៃក្នុងម្នាក់៧.០០០បាត ។ រីឯម្ចាស់គោយន្តនិយាយថា ខ្លួនដឹកពលករពីទីរួមស្រុកថ្មពួកដោយមានមនុស្សម្នាក់មិនស្គាល់ឈ្មោះទាក់ទងខ្លួនតាមទូរស័ព្ទឲ្យដឹកពលករទាំងនោះ ទៅទុកនៅចំណុចខាងលើ ដោយបានថ្លៃឈ្នួលក្នុងម្នាក់ចំនួន២០០បាត និងបានប្រាក់ខ្លះនិងនៅមិនទាន់បានខ្លះ ។ ក្រោយពីសួរនាំរួច ពលករទាំង១៣នាក់ ត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅស្រុកអូរជ្រៅ ចំណែកម្ចាស់គោយន្តកន្ត្រៃ ស្នើសុំយោបល់ពីថ្នាក់ដឹកនាំដើម្បីឃាត់ខ្លួនផងដែរ ៕